**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal University of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# អភិបាលកិច្ចល្អនៃរដ្ឋបាលស្រុកល្វាឯម

ស្រាវជ្រាវពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ក. គា សេងហ៊ាន់**

**ក. ជន ពេជចិន្តា**

សាស្ត្រាចារ្យណែនាំ

**លោក យូ តូនី**


ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**

ជំនាន់ទី១៣

ឆ្នាំចូលរៀន ២០១៦

ឆ្នាំសរសេរសារណា ២០២០

# លិខិតថ្លែងអំណរគុណ

នាងខ្ញុំទាំងពីរឈ្មោះ **ភា សេងហ៊ាន់** និង **ផន ពេជចិន្តា** ជានិស្សិតថ្នាក់បរិញ្ញាបត្រជំនាញរដ្ឋបាល-សាធារណៈ ឆ្នាំទី៤ ជំនាន់ទី១៣ ក្រុម P4A2 នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចឆ្នាំសិក្សា ២០១៩-២០២០។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះលោកឪពុក **ធូ សាមន** និងអ្នកម្តាយ**ទូច ថុល** និងលោកឪពុក **កាន ភា** និងអ្នកម្តាយ **ហម ឈាន់** ជាទីគោរពនិងជាមានគុណដ៏ខ្ពង់ខ្ពស់មិនអាចកាត់ថ្លៃបាន ដែលបានចិញ្ចឹមបីបាច់ថែរក្សារូបកូនតាំងពីតូចរហូតដល់ធំ ដោយមិនគិតពីការនឿយហត់ដើម្បីផ្គត់ផ្គង់កូនអោយបានចូលរៀនទោះជាលោកទាំងពីរហូរញើស និងជួបនូវការលំបាករាល់ថ្ងៃយ៉ាងណាក៏ដោយលោកទាំងពីរតែងតែផ្តល់កម្លាំងចិត្តដល់កូនៗគ្រប់ពេលវេលា សម្រាប់បញ្ចប់ការសិក្សាពីកម្រិតមួយទៅកម្រិតមួយទៀត។

ជាបន្ទាប់យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **ឯកឧត្តមបណ្ឌិត លុយ ចណ្ណា** សាកល-វិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចដែលកន្លងមកលោកបានខិតខំដឹកនាំ និងគ្រប់គ្រងអោយដំណើរការប្រព័ន្ធអប់រំនៅទីនេះមានភាពប្រសើរ និងប្រព្រឹត្តទៅដោយរលូនរួមទាំងផ្តល់ការអនុញ្ញាតអោយពួកយើងខ្ញុំបានចូលសិក្សាថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈ នៅសាកលវិទ្យាល័យនេះផងដែរ និងបង្កភាពងាយស្រួលដល់ការសិក្សារបស់ពួកខ្ញុំកន្លងមក ក្នុងគោលបំណងសម្រេចបាននូវធនធានមនុស្សសម្រាប់សង្គមជាតិក្នុងគោលដៅអភិវឌ្ឍប្រទេសជាតិប្រកបទៅដោយចីរភាព និងនិរន្តរភាព។

**លោកគ្រូ អ្នកគ្រូ លោក/លោកស្រីសាស្រ្តាចារ្យ** ដែលបានបង្រៀនអប់រំរូបយើងខ្ញុំទាំងពីរតាំងពីកម្រិតមធ្យមសិក្សារហូតដល់កម្រិតឧត្តមសិក្សាពួកលោកទាំងអស់បានជួយបង្រៀនដល់សិស្សនិស្សិតទាំងអស់ ដោយមិនគិតពីសេចក្តីលំបាកអ្វីឡើយក្នុងការផ្ទេរចំណេះដឹងមកអោយសិស្សនិស្សិតគ្រប់ជំនាន់។

លើសពីនេះនាងខ្ញុំទាំងពីរនាក់សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនដល់ លោកសាស្រ្តាចារ្យ **យូ តូនី** ដែលបានឆ្លៀតពេលវេលាដ៏មានតម្លៃ និងមមាញឹកពីការបង្រៀនដើម្បីធ្វើការដឹកនាំយើងខ្ញុំសរសេរសារណា បញ្ចប់ការសិក្សាដោយមិនខ្លាចនឿយហត់ក្នុងការផ្តល់គោលគំនិតមតិយោបល់ បែបបទ និងយុទ្ធ-សាស្រ្តសំខាន់ៗតាំងពីចាប់ផ្តើមរហូតដល់សារណានេះត្រូវបានបញ្ចប់ដោយជោគជ័យ។

ហើយឆ្លៀតក្នុងឱកាសនេះដែរយើងខ្ញុំសូមថ្លែងអំណរគុណ ចំពោះលោកអភិបាល នៃគណៈអភិបាលស្រុកល្វាឯមលោក **ភឹម ភីរ៉ា** លោកនាយករដ្ឋបាល **ញឹក សាត** និងមន្ត្រីរាជការទាំងអស់នៅក្នុងស្រុកល្វាឯ-មដែល បានផ្តល់ឯកសារ ផ្តល់យោបល់ផ្សេងៗ តាមសេចក្តីត្រូវការរបស់យើងខ្ញុំ។

ជាចុងក្រោយនេះរូបនាងខ្ញុំទាំងពីរនាក់  សូមប្រសិទ្ធពរជ័យជូនទៅដល់អ្នកមានគុណទាំងអស់អោយជួបតែក្តីសុខនៅក្នុងក្រុមគ្រួសារជាពិសេសអោយជួបតែពុទ្ធិពរទាំងបួនប្រការគឺ **អាយុ**: **វណ្ណ**: **សុខ**: **ពល**: កុំបីឃ្លៀងឃ្លាតឡើយ

# អារម្ភកថា

៚📖៚

ការគ្រប់គ្រងរដ្ឋបាលនៅ ព្រះរាជាណាចក្រកម្ពុជា កាន់តែមានភាពប្រសើរឡើងក្រោមរបបដឹកនាំតាមបែបលទ្ធិប្រជាធិតេយ្យនៅក្នុងប្រទេសកម្ពុជា។ ហើយអ្វីដែលគួរអោយកត់សម្គាល់នោះគឺការគ្រប់គ្រងរដ្ឋបាលដែលមានភិបាលកិច្ចល្អជាស្នូលដែលនាំអោយមានការអភិវឌ្ឍ និងរីកចម្រើនយ៉ាងខ្លាំងក្លានៃរដ្ឋបាលថ្នាក់ស្រុកជាពិសេសបម្រើសេវាសាធារណៈ ជូនចំពោះប្រជាពលរដ្ឋមានការឆាប់រហ័សដូចជាការធ្វើ អត្រានុកូលដ្ឋាន សៀវភៅគ្រួសារ និងការចុះសំបុត្រអាពាហ៍ពិពាហ៍។ ក្រោយពីការសង្កេតឃើញថាមានការរីកចម្រើននេះហើយដែលបានធ្វើអោយ នាងខ្ញុំទាំងពីរនាក់មានបំណងចងក្រងនូវ សារណា នេះឡើងដើម្បីបង្ហាញអោយឃើញពីកំណែទម្រង់រដ្ឋបាលស៊ីជម្រៅដោយប្តូរពីឥរិយាបថអ្នកគ្រប់គ្រងមកជាឥរិយាបថអ្នកផ្តល់សេវាវិញ។ ជាជាងការសិក្សាតែទ្រឹស្តីនាងខ្ញុំទាំង ពីរនាក់បានសម្រេចជ្រើសយកប្រធានបទ **“អភិបាលកិច្ចល្អនៃរដ្ឋបាលស្រុកល្វាឯម”** មកធ្វើការសិក្សាស្រាវជ្រាវ។

សារណាដែលកំពុងស្ថិតនៅក្នុងដៃមិត្តអ្នកអាននេះ ទោះជាបានចេញជារូបរាងពិតមែនតែកំហុសដែលបានកើតឡើងដោយអចេតនាដូចជា៖ ការប្រើពាក្យពេចន៍ ការប្រើភាសា អក្ខរាវិរុទ្ធ ការប្រើប្រាស់វេយ្យាករណ៍ ការប្រើប្រាស់ភាសាបរទេសនៅមានការឆ្គាំឆ្គងខ្លះដោយចៀសមិនរួច។ លើសពីនេះទៅទៀតកម្រិតនៃការយល់ដឹង ពេលវេលា ឯកសារ កិច្ចសហការពីមន្ត្រីមូលដ្ឋានញ៉ាំងអោយកិច្ចការនេះមិនទាន់មានលក្ខណៈទូលំទូលាយនៅឡើយទេ។

ជាចុងក្រោយនេះយើងខ្ញុំសង្ឃឹមថា សារណា នេះពិតជាជំនួយក្នុងការផ្តល់គន្លឹះខ្លះៗសម្រាប់មិត្តអ្នកអានណាដែល ចង់ចេះ ចង់ដឹង ចង់ស្រាវជ្រាវ ចង់ស្វែងយល់ពីគ្រប់មជ្ឈដ្ឋានទាំងអស់។ ម្យ៉ាងទៀតនាងខ្ញុំទាំងពីរនាក់ពិតជាមានសេចក្តីរីករាយ និងរង់ចាំទទួលយកគ្រប់យ៉ាងនូវមតិរិះគន់ដើម្បីស្ថាបនាពីសំណាក់មិត្តអ្នកអានដើម្បីនាង ខ្ញុំទាំងពីរនាក់បន្តពង្រឹងស្ថាបនាឯកសារស្រាវជ្រាវនេះអោយកាន់តែមានគុណភាព និងក្លាយជានិក្ខេបបទបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររបស់នាងខ្ញុំទាំងពីរ ។

# មាតិកា

Contents **ទំព័រ**


**សេចក្តីផ្តើម** ........ ១

**ជំពូកទី ១**

**ទិដ្ឋភាពទូទៅនៃរដ្ឋបាលស្រុកល្វាឯមលើអភិបាលកិច្ចល្អ**

**១.១ ទិដ្ឋភាពទូទៅ** ........ ៣

១.១.១ ប្រវត្តិសង្ខេបរបស់ស្រុកល្វាឯម ........ ៣

១.១.២ ស្ថានភាពភូមិសាស្ត្ររបស់ស្រុក ........ ៣

១.១.៣ ស្ថានភាពប្រជាពលរដ្ឋ និង ដង់ស៊ីតេ ........ ៤

**១.២ អភិបាលកិច្ចល្អ** ........ ៤

១.២.១ និយមន័យ និងគោលការណ៍អភិបាលកិច្ចល្អទាំង៩ ........ ៤

១.២.២ គោលបំណងនៃការអនុវត្តអភិបាលកិច្ចល្អ ........ ៨

១.២.៣ អភិបាលកិច្ចល្អនៃការគ្រប់គ្រងរដ្ឋបាលស្រុកល្វាឯម ........ ៨

**ជំពូកទី២**

**ការប្រព្រឹត្តទៅនៃការអនុវត្តរដ្ឋបាលស្រុកល្វាឯម**

**២.១ តួអង្គសំខាន់ៗ** ........ ១០

២.១.១ ក្រុមប្រឹក្សាស្រុកល្វាឯម ........ ១០

២.១.២ គណៈអភិបាលស្រុកល្វាឯម ........ ១៤

២.១.៣ នាយករដ្ឋបាលស្រុកល្វាឯម ........ ១៩

២.១.៤ គណៈកម្មាធិកាផ្សេងៗរបស់ក្រុមប្រឹក្សាស្រុកល្វាឯម ........ ២១

**២.២ យន្តការផ្ទៃក្នុងស្រុកល្វាឯម** ........ ២៣

២.២.១ ការិយាល័យចំណុះសាលាស្រុក ........ ២៣

២.២.២ ការិយាល័យស្រុកប្រតិបត្តិ ........ ២៧

២.២.៣ មន្ទីរពេទ្យបង្អែកស្រុក ........ ២៧

**២.៣ ការទំនាក់ទំនងជាមួយស្ថាប័នផ្សេងៗ** ........ ២៧
២.៣.១ ការទំនាក់ទំនងពីថ្នាក់ស្រុកទៅខេត្ត ........ ២៧
២.៣.២ ការទំនាក់ទំនងពីថ្នាក់ស្រុកទៅ ឃុំ សង្កាត់ ........ ២៩
២.៣.៣ ការទំនាក់ទំនងពីថ្នាក់ស្រុកទៅក្រសួង និងស្ថាប័ន ........ ៣២
២.៣.៤ ការទំនាក់ទំនងជាមួយកងកម្លាំងប្រដាប់អាវុធ ........ ៣៣

## ជំពូកទី៣

## សមិទ្ធផលដែលសម្រេចបាន និងចក្ខុវិស័យនៅក្នុងស្រុកល្វាឯម

**៣.១ សមិទ្ធផលដែលទទួលបាន** ........ ៣៥
៣.១.១ វិស័យសេដ្ឋកិច្ច ........ ៣៥
៣.១.២ វិស័យសង្គមកិច្ច ........ ៣៦
៣.១.៣ វិស័យដីធ្លី និងធនធានធម្មជាតិ និងបរិស្ថាន ........ ៣៨
៣.១.៤ វិស័យក្នុងការគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់ ........ ៣៩
៣.១.៥ ផលលំបាកដែលមាន ........ ៤១
**៣.២ ចក្ខុវិស័យនាពេលអនាគតនៅក្នុងស្រុកល្វាឯម** ........ ៤២
៣.២.១ ការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិល ........ ៤២
៣.២.២ ការពង្រឹងនៃការអនុវត្ត ភូមិ ឃុំ មានសុវត្ថិភាព ........ ៤២
៣.២.៣ ការប្រឡងប្រណាំងលើ ភូមិ ឃុំ គំរូនៅក្នុងស្រុកល្វាឯម ........ ៤៣
**សេចក្តីសន្និដ្ឋាន** ........ ៤៤
**ការផ្តល់អនុសាសន៍** ........ ៤៦

# សេចក្តីផ្តើម

អភិបាលកិច្ចល្អ គឺជាការប្រើប្រាស់នូវអំណាចខាងនយោបាយសេដ្ឋកិច្ច និងរដ្ឋបាលដើម្បីគ្រប់គ្រងប្រទេស និងជាវិធីសាស្ត្រដែលរដ្ឋស្ថាប័នអង្គភាពប្រើប្រាស់គ្រប់គ្រងសេដ្ឋកិច្ចសង្គមកិច្ចជាមួយសន្តិសុខដើម្បីបម្រើផលប្រយោជន៍រួមដល់ប្រជាពលរដ្ឋ។ អភិបាលកិច្ចល្អគឺជាគោលការណ៍គ្រឹះនៃរដ្ឋបាលក្នុងប្រទេសប្រកាន់នូវលទ្ធិប្រជាធិបតេយ្យសេរី។

ប្រទេសកម្ពុជាយើងវិញបានជ្រើសរើសយករបបប្រជាធិបតេយ្យ បន្ទាប់ពីប្រទេសយើងបានរៀបចំការបោះឆ្នោតនៅក្នុងឆ្នាំ ១៩៩៣ រៀបចំឡើងដោយអាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិនៅកម្ពុជាដើម្បីបង្កើតរដ្ឋាភិបាលស្របច្បាប់នៅកម្ពុជា។ ពលរដ្ឋខ្មែរកាន់តែយល់ដឹងអំពីលទ្ធិប្រជាធិបតេយ្យស្របពេលជាមួយគ្នានេះដែលរដ្ឋាភិបាលកម្ពុជាក៏បានរៀបចំក្នុងការធ្វើកំណែទម្រង់រដ្ឋបាលសាធារណៈ ស៊ីជម្រៅដោយបានបែងចែករដ្ឋបាលជាពីរថ្នាក់គឺ រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្រោយពីមានការធ្វើកំណែទម្រង់រដ្ឋ-បាលនេះយើងមើលឃើញថាទឹកដីនៃព្រះរាជាណាចក្រកម្ពុជាបានបែងចែកជា រាជធានី ខេត្ត ក្រុង ស្រុកខណ្ឌ ឃុំ សង្កាត់។ ជាមួយនិងការអនុវត្តកម្មវិធីរបស់រាជរដ្ឋាភិបាល និងផ្អែកតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១ និងដំណាក់កាលទី២រាជរដ្ឋាភិបាលបានអនុម័តនូវក្របខណ្ឌយុទ្ធសាស្ត្រកំណែ-ទម្រង់វិមជ្ឈការនិងវិសហមជ្ឈការកាលពី ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៥។ ស្របតាមក្របខណ្ឌយុទ្ធសាស្ត្រនេះច្បាប់ពីរត្រូវបានអនុម័តបង្កើតឡើង គឺច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា រាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ កាលពីឆ្នាំ២០០៨ និងអនុវត្ត២០០៩។

ការរៀបចំប្រព័ន្ធអភិបាលកិច្ចល្អនេះ គឺត្រូវប្រតិបត្តិប្រកបដោយតម្លាភាព គណនេយ្យភាព និងបានជម្រុញ អោយមានកិច្ចការអភិវឌ្ឍន៍តាមមូលដ្ឋាន និងការផ្តល់សេវាសាធារណៈដែលអាចឆ្លើយតបតាមតម្រូវការរបស់ប្រជាពលរដ្ឋដើម្បីចូលរួមកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។ អភិបាលកិច្ចល្អប្រកបដោយសុក្រឹតនិច្ច័-យចាត់ចែង និងការគ្រប់គ្រងបញ្ហាជាមួយធនធានសាធារណៈ អោយមានប្រសិទ្ធភាពហើយបានឆ្លើយតបទៅតាមតម្រូវការ និងផលប្រយោជន៍របស់សង្គមជាតិទាំងមូលនេះអាចបញ្ជាក់អោយឃើញពីការរីកចម្រើននៅតាមមូលដ្ឋាននានា។ ដោយមើលឃើញពីសារៈសំខាន់នៃអភិបាលកិច្ចល្អ នៃរដ្ឋាភិបាលកម្ពុជាបានប្រកាសថា **“អភិបាលកិច្ចល្អ គឺជាបុរេលក្ខខណ្ឌសំខាន់បំផុតមួយដើម្បីធានាអោយមានការអភិវឌ្ឍន៍សង្គម សេដ្ឋកិច្ចប្រកបដោយចីរភាព សមធ៌ម និង យុត្តិធម៌នៅក្នុងសង្គម ”**។ នៅពេលនោះផងដែររាជរដ្ឋាភិបាលបាននិងកំពុងបន្តអនុវត្តផែនការសកម្មភាពអភិបាលកិច្ចល្អ អោយបានទូទាំងប្រទេស និងបានកំណត់នៅក្នុងយុទ្ធសាស្ត្រចតុ-កោណរបស់រដ្ឋាភិបាលកម្ពុជាជាមួយនិងការបញ្ចូលគោលការណ៍នៃ អភិបាលកិច្ចល្អ នៅក្នុងក្របខណ្ឌ

គោលនយោបាយ និងយុទ្ធសាស្ត្រនានារបស់រាជរដ្ឋាភិបាលដោយគោរពតាមច្បាប់ស្ដីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីឆ្ពោះទៅកាន់ការអភិវឌ្ឍ ប្រទេសជាតិប្រកបដោយភាពជោគជ័យ។ ការអនុវត្តគោលការណ៍អភិបាលកិច្ចល្អ នៅក្នុងស្រុកល្វាឯមខេត្តកណ្ដាលបានធ្វើការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលក្នុងនោះរួមមានគោលការណ៍ភូមិ ឃុំ មានសុវត្ថិភាពកម្មវិធីវិនិយោគបីឆ្នាំរំកិល និងអភិបាលកិច្ចល្អនៅក្នុងមូលដ្ឋានជាមួយ និងការអភិវឌ្ឍតាមបែបវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ។

តើអភិបាលកិច្ចល្អ នៅក្នុងស្រុកល្វាឯមមានលក្ខណៈយ៉ាងដូចម្ដេច?

តើចក្ខុវិស័យស្រុកល្វាឯម ដើម្បីជម្រុញអភិបាលកិច្ចល្អ កាន់តែប្រសើរមានអ្វីខ្លះ?

ដើម្បីជ្រួតជ្រាបចំពោះប្រធាននៃសារណានេះក៏ដូចជាឆ្លើយសំណួរ គតិយុត្តិខាងលើយើងខ្ញុំនិងធ្វើការបក ស្រាយបង្ហាញនៅក្នុងប្លង់ គោលជា៣ជំពូកដូចខាងក្រោមនេះ៖

ជំពូកទី១៖ ទិដ្ឋភាពទូទៅនៃរដ្ឋបាលស្រុកល្វាឯម លើអភិបាលកិច្ចល្អ

ជំពូកទី២៖ ការប្រព្រឹត្តទៅនៃការអនុវត្តរដ្ឋបាលស្រុកល្វាឯម

ជំពុកទី៣៖ សមិទ្ធផលដែលសម្រេចបាននិងចក្ខុវិស័យនៅក្នុងស្រុកល្វាឯម

# ជំពូកទី ១
# ទិដ្ឋភាពទូទៅនៃរដ្ឋបាលស្រុកល្វាឯមលើអភិបាលកិច្ចល្អ

## ១.១ ទិដ្ឋភាពទូទៅ

### ១.១.១ ប្រវត្តិសង្ខេបរបស់ស្រុកល្វាឯម

ល្វាឯម គឺជាស្រុកមួយក្នុងចំណោមស្រុកទាំង ១១ របស់ខេត្តកណ្តាល ដែលមាន ១៥ឃុំ និង៤៣ ភូមិហើយមានផ្ទៃដីសរុប ២៦០.៩២ គីឡូម៉ែតការ៉េដែលមានប្រជាជនសរុប ៨០៨១៥នាក់ ស្រី ៤០៩៦២នាក់។[1]

### ១.១.២ ស្ថានភាពភូមិសាស្ត្ររបស់ស្រុក

ស្រុកល្វាឯម គឺជាស្រុកមួយដែលស្ថិតនៅភាគខាងកើតនៃ ខេត្តកណ្តាល តាមបណ្តោយទន្លេមេ-គង្គក្រោមដងទន្លេតូចចម្ងាយ ៤០គ.ម ពីសាលាខេត្តកណ្តាល មានព្រំប្រទល់រដ្ឋបាល ខាងលិចជាប់ស្រុកខ្សាច់កណ្តាល និងខណ្ឌចំការមន នៃរាជធានីភ្នំពេញ ខាងកើតជាប់ស្រុកកំពង់លាវ និងស្រុកពាមរក៍ខេត្តព្រៃវែង ខាងជើងជាប់ស្រុកពារាំងខេត្តព្រៃវែង និងខាងត្បូងជាប់ស្រុកកៀនស្វាយ។ ចំពោះភូមិសាស្ត្រជាតំបន់វាលទំនាប ដែលសម្បូរទៅដោយ បឹងបួរ ព្រៃក ជាច្រើនស្ថានភាពបែបនេះធ្វើអោយសម្បូរធនធានធម្មជាតិ ដីមានជីជាតិសម្រាប់ដាំដំណាំកសិកម្ម។ ស្រុកល្វាឯមស្ថិតនៅជាប់រាជធានីភ្នំពេញខណ្ឌដោយទន្លេចតុមុខដែលបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋធ្វើដំណើរនិងដឹកកសិផលទៅលក់នៅរាជធានីភ្នំពេញ។

ម្យ៉ាងវិញទៀតដោយសារតែស្រុកនេះខណ្ឌដោយទន្លេ ទើបធ្វើអោយប្រជាកសិករជួបឧបសគ្គជាច្រើន នៅរដូវវស្សាផ្លូវលំជាច្រើនត្រូវបានខូចខាតទឹកហូរកាត់ផ្តាច់ផ្លូវមានការលំបាកក្នុងការធ្វើដំណើរ និងដឹកកសិផលទៅឯរាជធានីភ្នំពេញព្រមទាំងត្រូវចំណាយថវិកាច្រើនក្នុងការឆ្លង ទូកដ ថែមទៀតផង។

**ចំពោះផ្ទៃដីវិញ**

នៅក្នុងស្រុកល្វាឯម មានផ្ទៃដីសរុប ២៦.០៩២ ហិកតា និងមាន ១៥ ឃុំ ៤៣ភូមិ ក្នុងនោះមានឃុំអរិយក្សត្រ ឃុំបារុង ឃុំបឹងគ្រុំ ឃុំកោះកែវ ឃុំកោះរះ ឃុំល្វាសរ ឃុំពាមឧកញ៉ាអុង ឃុំភូមិធំ ឃុំព្រែកក្មេង ឃុំព្រែករៃ ឃុំព្រែកឫស្សី ឃុំសំបួរ ឃុំសារិកាកែវ ឃុំថ្មគរ ឃុំទឹកឃ្លាំង។ ស្រុកល្វាឯមមានផ្ទៃដីកសិកម្មសម្រាប់ផលិតស្រូវវស្សាចំនួន ៨៥៥ហិចតា និងស្រូវប្រាំង ៧០១៤ហិចតា និងដំណាំរួមផ្សំដូចជាពោតក្រហម ១៣៩៩ ហិចតា សណ្តែក ២៦ហិច-តាបន្លែចម្រុះ ១១៦ហិចតា ម្ទេស ៨ហិចតា ស្លឹកគ្រៃ ២៥០ហិចតា ចេក ៤៥ហិចតា ល្ហុង ៧៣ហិចតា ឈូក ៧៦៨ហិចតាដំណាំស្វាយកែវរមៀត ៧៧៤ហិចតាដូង ២៣ហិចតា ល្មុត ០៤ហិចតា និងដំណាំរួមផ្សំផ្សេងៗ ២៣ហិចតា។

[1] នៅក្នុងរបាយការណ៍ប្រចាំឆ្នាំ ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលស្រុកល្វាឯម ឆ្នាំ២០១៩

### ១.១.៣ ស្ថានភាពប្រជាពលរដ្ឋ និង ដង់ស៊ីតេ

ចំពោះប្រជាជនវិញមានសរុប៨៦.៩១៩គ្រួសារក្នុងនោះមានស្រ្តីចំនួន ៤៣.៤៥៦គ្រួសារកំនើនប្រជាជន ៣,៨% អត្រាមេគ្រួសារស្រ្តី ១៣% អត្រាមុខរបរកសិកម្ម ៦៧,៣% អត្រាកុមារអាយុ ៦-១៤ ឆ្នាំមិនបានចូលរៀន ១០,៨៦%អត្រាអ្នកមិនចេះអក្សរពីអាយុ១៥-៤៥ឆ្នាំមានចំនួន២,២៥% ចំពោះស្រ្តីមិនចេះអក្សរ 0%ការបង្ក កំណើតអត្រាស្រ្តីសំរាលកូនសរុបមានចំនួន៧៤,៥% ស្រ្តីសំរាលកូនដោយពេទ្យឆ្មបមានចំនួន ១.៦០៣នាក់។ ក្នុងនោះអត្រាមរណៈភាពមាតានិងទារកចាប់ពីក្រោយសំរាលកូនពី 0-១ខែ មានចំនួន 0%គ្រួសារប្រើប្រាស់ទឹក ម៉ាស៊ីនមានចំនួន ៦៤,៥% អត្រាប្រជាជនប្រើប្រាស់ទឹកអណ្តូងមានចំនួន ៧,៨៤%សមាមាត្រគ្រួសារដែលមាន បង្គន់អនាម័យប្រើប្រាស់មានចំនួន ៧៩,៤% ដង់ស៊ីតេប្រជាជនស្មើ ១គម$^2$/១នាក់ មានចំនួន ៤នាក់/១គម$^២$ មុខរបរកសិកម្មដំណាំស្រូវជាចំបងមានចំនួន ១៣.៦២២នាក់ មុខរបរបន្ទាប់បន្សំ ចិញ្ចឹមជ្រូកមាន់ ទា គោ ក្របី ១៥៦គ្រួសារ។[2]

## ១.២ អភិបាលកិច្ចល្អ

### ១.២.១ និយមន័យ និងគោលការណ៍អភិបាលកិច្ចល្អទាំង៩

- **និយមន័យ**

យោងតាមការពន្យល់ក្នុងវចនានុក្រមសម្តេចសង្ឃ **ជួន ណាត** ពាក្យអភិបាល **គឺមានន័យថាជាការគ្រប់គ្រងបីបាច់ការថែរក្សាហេតុនេះអភិបាលកិច្ចល្អ គឺមានន័យថាជាការគ្រប់គ្រងល្អ**។ បើយើងនិយាយជាន័យរួមវិញ ពាក្យថាអភិបាលកិច្ចល្អ គឺវាសម្តៅទៅលើវិធាន ឬបែបផែននៃការគ្រប់គ្រងដែលមានភាពល្អត្រឹមត្រូវ ច្បាស់លាស់ ដែលមានអង្គការបណ្តាញចាត់តាំងត្រឹមត្រូវមានទំនាក់ទំនងល្អរវាងថ្នាក់លើ និងថ្នាក់ក្រោមមាន ប្រសិទ្ធភាពនៃការងារខ្ពស់ដែលស្ថិតក្រោមវិធានមួយបិតប្រាកដតឹងរឹងទន់ភ្លន់ និងច្បាស់លាស់។

យោងតាមសៀវភៅរបស់ក្រសួងមហាផ្ទៃដែលចេញក្នុង ខែមិថុនា ឆ្នាំ២០១០ បានអោយនិយមន័យ ចំពោះអភិបាលកិច្ចល្អមានន័យថា **គឺជាវិធីសាស្ត្រដែលរដ្ឋ ស្ថាប័ន អង្គភាព ប្រើប្រាស់ក្នុងការគ្រប់គ្រងសេដ្ឋកិច្ច និងសន្តិសុខដើម្បីបម្រើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋ ។**

ស្រដៀងនេះដែរកម្មវិធីអភិវឌ្ឍសហប្រជាជាតិ (UNDP1997) បានអោយនិយមន័យលើពាក្យអភិ-បាលកិច្ចល្អមានន័យថា **ជាការប្រើប្រាស់អំណាចខាងនយោបាយសេដ្ឋកិច្ច និងរដ្ឋបាលដើម្បីគ្រប់គ្រងកិច្ចការរបស់ប្រទេស ។**

- **គោលការណ៍អភិបាលកិច្ចល្អទាំង៩**

[2] នៅក្នុងរបាយការណ៍ប្រចាំឆ្នាំ ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលស្រុកល្វាឯម ឆ្នាំ២០១៩

ជាមួយគ្នានេះដែរការអនុវត្តនូវអភិបាលកិច្ចល្អ ជាមួយការគ្រប់គ្រងលើប្រព័ន្ធរដ្ឋបាល គឺត្រូវមានការអនុវត្តលើគោលការណ៍៩ ចំណុចសម្រាប់យកមកផ្តល់អោយប្រជាជនក្នុងការអភិវឌ្ឍសង្គមជាតិអោយមានការរីកចម្រើនគ្រប់វិស័យជាពិសេសសណ្តាប់ធ្នាប់សង្គម និងអំពើពុករលួយដែលរួមមានដូចខាងក្រោម៖

**១.ការចូលរួម៖** គឺបានស្ថិតនៅក្នុងបរិបទនៃអភិបាលកិច្ចល្អដែលសម្តៅទៅលើការចូលរួមរបស់ប្រជាពលរដ្ឋទាំងបុរស និង ស្ត្រីដែលមានអាជ្ញាធរប្រជាពលរដ្ឋអង្គការមិនមែនរដ្ឋាភិបាលនានា និងអ្នកពាក់ព័ន្ធផ្សេងៗទៀតក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត និងការអនុវត្តធ្វើសេចក្តីសម្រេចចិត្តនោះដែលមានសារៈសំខាន់នៃការចូលរួមគឺ ដើម្បីធានាថាព័ត៌មានទាំងឡាយស្តីពីបញ្ហាតម្រូវការ និងបំណងប្រាថ្នារបស់ប្រជាពលរដ្ឋគ្រប់រូបត្រូវបានប្រមូលនិង វិភាគបានគ្រប់ជ្រុងជ្រោយមុន និងធ្វើការសម្រេចចិត្តធ្វើអ្វីមួយ។

ជាទូទៅការចូលរួមនេះគឺត្រូវបានចែកចេញជា ២ ធំៗ គឺ៖

- ការចូលរួមដោយផ្ទាល់ គឺជាការចូលរួមរបស់អ្នកពាក់ព័ន្ធគ្រប់រូបដោយខ្លួនឯងផ្ទាល់នៅក្នុងដំណើរការនៃការសម្រេចចិត្តនិងការអនុវត្តសេចក្តីសម្រេចចិត្តនោះ។

- ការចូលរួមតាមរយៈអ្នកតំណាង គឺអ្នកតំណាងប្រជាពលរដ្ឋចូលរួមក្នុងដំណើរការនៃការសម្រេចចិត្ត និងអនុវត្តសេចក្តីសម្រេចនោះតាមឆន្ទៈ និងផលប្រយោជន៍របស់ប្រជាពលរដ្ឋ ដែលបានអោយខ្លួនតំណាងអោយនៅក្នុងតំបន់នោះ។

**២. នីតិរដ្ឋ៖** គឺជាការទាមទារអោយមានឯកសារក្របខ័ណ្ឌច្បាប់គ្រប់គ្រាន់ដើម្បីបម្រើ និងការពារផលប្រយោជន៍សាធារណៈការពារសិទ្ធិមនុស្សជាពិសេសក្រុមងាយរងគ្រោះ ឬក្រុមភាគតិចហើយច្បាប់ទាំងនោះត្រូវបានអនុវត្តដោយមិនលំអៀងលើសពីនេះទៅទៀតត្រូវមានប្រព័ន្ធទទួលខុសត្រូវមាន ប្រព័ន្ធតុលាការឯករាជ្យ និងយុត្តិធម៌ និងពង្រឹងការអនុវត្តច្បាប់ដោយមិនលំអៀង និងមិនពុករលួយដែលផ្តោតលើចំណុចសំខាន់ ៥យ៉ាងគឺ៖

- ឯកសារក្របខ័ណ្ឌច្បាប់ គឺជាលិខិតបទដ្ឋានគតិយុទ្ធដែលរួមមានច្បាប់ព្រះរាជក្រឹត្យអនុក្រឹត្យប្រកាស សេចក្តីសម្រេចសេចក្តីណែនាំដីកា និងលិខិតបទដ្ឋានគតិយុទ្ធនានា។ ដែលមានឯកសារសំខាន់ៗបី គឺគោលការណ៍គឺតាមការវិវត្តរបស់សង្គម និងតាមតម្រូវការនៃការគ្រប់គ្រងរដ្ឋហើយចំពោះច្បាប់ផ្ទៃក្នុងគឺចាច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស សម្រាប់ធ្វើការដាក់ចេញនូវបទបញ្ជាផ្សេងពីរដ្ឋាភិបាលចំណែកច្បាប់អន្តរជាតិគឺជាសន្ធិសញ្ញា អនុសញ្ញា កតិសញ្ញា ពិធីសារ ក្នុងការចុះកិច្ចសន្យាជាមួយប្រទេសផ្សេង និងជាការចូលរួមទៅលើគោលការណ៍ណាមួយដែលអន្តរជាតិយកមកអនុវត្តទូទាំងពិភពលោក។

- ការពារសិទ្ធិ សិទ្ធិមនុស្ស គឺជាសេចក្តីត្រូវការចាំបាច់របស់មនុស្សគ្រប់ៗរូបដែលមានតាំងពីកំណើតដើម្បីទាមទារនូវអ្វីៗដែលធ្វើអោយមនុស្សរស់នៅប្រកបដោយវិចារណញ្ញាណ និងសេចក្តីថ្លៃថ្នូរ។ក្នុងនោះសិទ្ធិជាមូល-

ដ្ឋានធំបំផុតសម្រាប់មនុស្សគ្រប់រូប គឺជីវិតសេរីភាពនិងការស្វះស្វែងរកសុភមង្គលដែលមិនអាចលក់ប្តូរបានឬដកហូតបានពីសេរីភាពយុត្តិធម៌ និងសន្តិភាព។

- ប្រព័ន្ធទទួលខុសត្រូវ គឺត្រូវបានបេងចែកដាច់ដោយឡែកពីគ្នាក្នុងការទទួលខុសត្រូវក្នុងនោះខាងអំណាចនយោបាយត្រូវទទួលខុសត្រូវលើការបង្កើតសភា អោយលេចចេញជារដ្ឋាភិបាល និងត្រូវធ្វើជាប្រមុខរដ្ឋក្នុងការគ្រប់គ្រងប្រទេសចំណែកខាងអំណាចនីតិបញ្ញត្តិជាសភា សម្រាប់ទទួលខុសត្រូវក្នុងការតាក់តែងនូវច្បាប់ផ្សេងៗ រីឯខាងអំណាចនីតិប្រតិបត្តិជាអ្នកអនុវត្តនូវការគ្រប់គ្រងរដ្ឋបាលទូទាំងប្រទេស ហើយជាអ្នករៀបចំបង្កើតនូវអាជ្ញាធរដែនដីសម្រាប់រៀបចំសណ្តាប់ធ្នាប់សង្គមអោយមានសន្តិសុខល្អ និងជាអ្នករៀបចំនូវមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ចាប់ពីថ្នាក់ជាតិមកដល់ថ្នាក់ក្រោមជាតិ។ ចំណែកខាងអំណាចតុលាការគឺជាអ្នក ធ្វើអោយមានការគោរពច្បាប់ទូទាំងប្រទេសអោយមានការគោរច្បាប់ និងដាក់ទោសចំពោះជនណាដែលមិនគោរពច្បាប់។

- ប្រព័ន្ធយុត្តិធម៌គឺត្រូវធ្វើអោយមានភាពឯករាជ្យយុត្តិធម៌ និងតម្លាភាព ចំពោះពលរដ្ឋគ្រប់រូបជាពិសេសតុលាការដែលមានតួនាទីកាត់ក្តី និងជម្លោះនានាដោយយុត្តិធម៌ និងមិនលំអៀងដែលជំរុញអោយមានយុត្តិធម៌ ហើយជាយន្តការដើម្បីអោយមានការគោរពច្បាប់ និងអនុវត្តច្បាប់ជាពិសេសត្រូវលុបបំបាត់អោយបាននូវអំពើពុករលួយចំពោះតុលាការ។

- សមត្ថកិច្ចពង្រឹងការអនុវត្តច្បាប់មិនលម្អៀងនិងមិនពុករលួយដែលត្រូវអនុវត្តទៅតាមឯកសារច្បាប់ទាំងនោះគឺត្រូវធ្វើយ៉ាងពេញលេញត្រឹមត្រូវយុត្តិធម៌ និងមិនលម្អៀងដែលសមត្ថកិច្ចទទួលខុសត្រូវ គឺត្រូវអនុវត្តតាមច្បាប់ដោយមិនលម្អៀង និងមិនពុករលួយដែលជាការរួមចំណែកយ៉ាងខ្លាំងក្នុងអភិបាលកិច្ចល្អនៅក្នុងសង្គម។

**៣. តម្លាភាព៖** គឺរាល់ការសម្រេចចិត្ត និងការអនុវត្តសេចក្តីសម្រេចនោះត្រូវធ្វើឡើងដោយមានការអនុលោមទៅតាមច្បាប់ និងបទដ្ឋាននានាហើយព័ត៌មានពាក់ព័ន្ធ និងការសម្រេចចិត្ត និងការអនុវត្តសេចក្តីសម្រេចចិត្ត ត្រូវផ្សព្វផ្សាយជាចំហតាមរយៈប្រព័ន្ធសមស្រប និងអាចស្វែងរកបានជាពិសេសចំពោះអ្នកដែលទទួលរងនូវផលប៉ះពាល់ពីការសម្រេចចិត្ត និងការអនុវត្តសេចក្តីសម្រេចចិត្តទាំងនោះ និងព័ត៌មានទាំងនោះត្រូវមានលក្ខណៈគ្រប់គ្រាន់ និងងាយយល់ចំពោះប្រជាពលរដ្ឋ។

**៤. ការព្រមព្រៀងឯកភាពគ្នា៖** គឺជាការពិចារណាទូលំទូលាយ និងវែងឆ្ងាយលើផលប្រយោជន៍និងតម្រូវការរបស់អ្នកពាក់ព័ន្ធផ្សេងៗគ្នានៅក្នុងសង្គម ហើយឈានទៅរកការសម្រេចចិត្តដោយមានការព្រមព្រៀងឯក-ភាពគ្នាលើជម្រើសនិងវិធីសាស្ត្រល្អណាមួយដែលបម្រើផលប្រយោជន៍ទូទៅ។

**៥. សមធម៌៖** គឺជាក្រុម ឬជនគ្រប់រូបទាំងអស់ជាពិសេសក្រុមភាគតិចនិងក្រុមដែលងាយរងគ្រោះមានឱកាសគ្រប់គ្រាន់នៅក្នុងការចូលរួមបញ្ចេញយោបល់លើកឡើងនូវតម្រូវការពិតប្រាកដ ដើម្បីអនុវត្តសកម្មភាព

និងផលប្រយោជន៍សមស្របដើម្បីកែលម្អ និងថែរក្សាសុខុមាលភាពរបស់ពួកគេ។ ជាមួយគ្នានេះដែរចំពោះសុខ-ភាពរបស់ពលរដ្ឋទាំងអស់នៅក្នុងសង្គមគឺត្រូវតែមានការការពារ និងថែរក្សាពីរាជរដ្ឋាភិបាលដែលជាដំណើរការនៃការសម្រេចចិត្ត និងការអនុវត្តសេចក្តីសម្រេចចិត្ត ប្រកបដោយសមធម៌ និងធ្វើអោយគ្រប់ពលរដ្ឋទាំងអស់នៅក្នុងសង្គមមានអារម្មណ៍ថាពួកគាត់ម្នាក់ៗ គឺជាសមាជិកពិតប្រាកដរបស់សង្គម និងបានចូលរួមចំណែកនៅក្នុងដំណើរការអភិវឌ្ឍសង្គមនោះ។ សុខុមាលភាពដែលពលរដ្ឋចង់បាន គឺភាពសប្បាយភាពសុខស្រួលសុវត្ថភាពសន្តិភាពសុខភាព ល្អនិងភាពគ្រប់គ្រាន់ចំពោះការគិតទៅដល់លើ ជំនឿ សាសនា ស្មារតី ផ្លូវចិត្ត អារម្មណ៍ព្រមទាំងជីវភាពរស់នៅរបស់ពលរដ្ឋម្នាក់ៗសម្រាប់រស់នៅប្រចាំថ្ងៃផងដែរ។

**៦. ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ៖** គឺជាដំណើរការ និងរចនាសម្ព័ន្ធគ្រប់គ្រងក្នុងការប្រើប្រាស់ធនធានអោយអស់លទ្ធភាព និងសន្សំសំចៃខ្ពស់ដើម្បីបង្កើតលទ្ធផល ដែលមានគុណភាពខ្ពស់បរិមាណច្រើនអាចបម្រើផលប្រយោជន៍ជាអតិបរិមា និងបានឆ្លើយតបទៅតម្រូវការពិតរបស់សង្គម។ ម្យ៉ាងទៀតត្រូវបានរួមបញ្ចូលចំពោះការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព និងការការពារបរិស្ថានហើយដើម្បីអោយមានប្រសិទ្ធភាពនិងភាពស័ក្តិសិទ្ធិក្នុងការអនុវត្តនោះ គឺត្រូវមានការពិចារណាលើចំណុចផ្សេងៗមួយចំនួនគឺការប្រើប្រាស់ធនធានអោយបានត្រឹមត្រូវការអនុវត្តសកម្មភាពដែលជាអាទិភាពខ្ពស់ជៀសវាងអនុវត្តនូវ ការិយាធិបតេយ្យការគិតគូររយៈពេលវែងលើការប្រើប្រាស់ធនធានធម្មជាតិគ្មានអំពើពុករលួយ និងមានការសម្រេចចិត្តតាមចូលរួមជាដើម។

**៧.គណនេយ្យភាព៖** គឺជាការអនុវត្តតួនាទី និងភារកិច្ចនៅក្នុងដំណើរការនិងក្នុងការអនុវត្តសេចក្តីសម្រេចចិត្តទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួនដោយរាយការណ៍ព្រមទាំងបញ្ជាក់ពីមូលហេតុអ្វី ដែលខ្លួនបានសម្រេច និងអនុវត្ត។ គណនេយ្យភាព គឺមិនត្រឹមតែជាការទទួលខុសត្រូវចំពោះមុខអ្នកណាម្នាក់ដែលបានស្នើសុំអោយធ្វើអ្វីមួយនោះទេប៉ុន្តែជាការទទួលខុសត្រូវនូវសកម្មភាព ដែលបានអនុវត្តចំពោះមុខអ្នកពាក់ពន្ធ័ទាំងអស់ហើយគណនេយ្យភាពរួមមានគណនេយ្យភាពចំពោះថ្នាក់ដឹកនា និងគណនេយ្យភាពចំពោះមុខសាធារណៈជន

**៨.ការឆ្លើយតប៖** គឺជាការខិតខំប្រឹងប្រែងរបស់អង្គភាព ស្ថាប័នដើម្បីបម្រើដល់ប្រជាពលរដ្ឋ និងអ្នកដែលពាក់ពន្ធ័ទាំងអស់ដោយស្មើភាពគ្នា និងមិនរើសអើងនៅក្នុងក្របខណ្ឌពេលវេលាដ៏សមហេតុផល។ ជាមួយគ្នានេះដែលការឆ្លើយតបត្រូវតែមានការបំពេញសេវាកម្មជូនប្រជាពលរដ្ឋ តាមការស្នើសុំត្រូវមានដំណោះស្រាយដែលស្តែង ឡើងជាសកម្មភាពដើម្បីដោះស្រាយបញ្ហាឫការលំបាកនានាការឆ្លើយបំភ្លឺអំពីមូលហេតុដែលមិនអាចឈានដល់ការធ្វើសកម្មភាពដោះស្រាយបញ្ហាឫការលំបាកទាំងនោះបាននិងសំណើសុំអន្តរាគមន៍ពីស្ថាប័នអង្គភាពមាន សមត្ថកិច្ចដើម្បីជួយដោះស្រាយបញ្ហា ឫការលំបាកទាំងនោះព្រមទាំងជំរាបអំពីសំណើសុំអន្តរា-ន៍នេះដល់ប្រជាពលរដ្ឋដែលពាក់ព័ន្ធ នឹងបញ្ហាឫការលំបាកទាំងនោះ។

**៩.ចក្ខុវិស័យជាយុទ្ធសាស្ត្រ៖** គឺសម្រាប់អ្នកដឹកនាំទាំងអស់ និងស្ថាប័នសាធារណៈនានាត្រូវមានទស្សនៈទូលំទូលាយ និងសម្រាប់រយៈពេលវែងអំពីអភិបាលកិច្ចល្អ និងការអភិវឌ្ឍធនធានមនុស្សដោយយកចិត្តទុកដាក់អំពីតម្រូវការចាំបាច់នានាដែលត្រូវអភិវឌ្ឍលើការងារនេះ។ ជាងនេះទៅទៀតមេដឹកនាំទាំងអស់ត្រូវមានការយល់អោយច្បាស់អំពីទិដ្ឋភាពនានាលើចំណុចមួយចំនួនលើផ្នែក ប្រវត្តិសាស្ត្រ វប្បធម៌ និងសង្គមដែលមានការពាក់ពន្ធ័ទៅនិងអភិបាលកិច្ចល្អ។

### ១.២.២ គោលបំណងនៃការអនុវត្តអភិបាលកិច្ចល្អ

ដើម្បីធ្វើអោយការមានការគ្រប់គ្រងលើផ្នែក សេដ្ឋកិច្ច សង្គមកិច្ចនិងវិបត្តិទាំងឡាយតាមមធ្យោបាយមួយដែលបានផ្តល់នូវ[3]ផលប្រយោជន៍យ៉ាងច្រើនបំផុតដល់ប្រជាពលរដ្ឋក្នុងការជំរុញ និងការគាំទ្រដំណើរការនៃការគ្រប់គ្រងរបស់សាលាស្រុកព្រៃល្វាឯម នឹងការអភិវឌ្ឍមួយប្រកបដោយនិរន្តរភាព។ អភិបាលល្អ គឺជាការដឹកនាំប្រកបដោយទៅដោយសុភវិនិច្ឆ័យដោយចេះចាត់ចែង និងការគ្រប់គ្រងបញ្ហា និងធនធានសាធារណៈប្រកបដោយប្រសិទ្ធភាព ហើយមានការឆ្លើយតបទៅនិងតម្រូវការ និងផលប្រយោជន៍សង្គមជាតិទាំងមូល។ ក្នុងនោះគោលបំណង សម្រេចបាននូវអភិបាលកិច្ចល្អ គឺត្រូវទាមទានូវការអភិវឌ្ឍធនធានមនុស្សប្រកបដោយនិរន្តរភាពចំពោះពលរដ្ឋ គឺត្រូវមានសេវាថែទាំសុខភាពមាំមួន និងមានអាយុវែងសម្រាប់រស់នៅដើម្បីអោយប្រជា-ពលរដ្ឋទាំងអស់ចូលរួមយ៉ាងពេញលេញនៅក្នុងសកម្មភាពសេដ្ឋកិច្ច និងសង្គមកិច្ចហើយត្រូវមានសេវាអប់រំល្អសមស្របដែលគ្រប់គ្រានសម្រាប់ពលរដ្ឋទូទៅ ដើម្បីអោយប្រជាជនមានចំណេះដឹងគ្រប់គ្រាន់ជាមួយជំនាញពេញលេញក្នុងការបង្កើនឪកាសអោយបានច្រើន និងត្រូវបង្កើនឪកាសសម្រាប់ប្រជាពលរដ្ឋទូទៅដើម្បីទទួលបាននូវផលប្រយោជន៍ពីសកម្មភាពសេដ្ឋកិច្ច និងមានការងារធ្វើដើម្បីរកប្រាក់ចំណូលគ្រប់គ្រាន់សម្រាប់បំពេញតម្រូវការមូលដ្ឋានលើស្បៀងអាហារ សម្លៀកបំពាក់ទីជម្រកជាដើមចំពោះពលរដ្ឋទាំងអស់នៅក្នុងសង្គមដើម្បីអោយមានការរីកចម្រើន។

### ១.២.៣ អភិបាលកិច្ចល្អនៃការគ្រប់គ្រងរដ្ឋបាលស្រុកល្វាឯម

នៅក្នុងស្រុកល្វាឯម មានការអនុវត្តការគ្រប់គ្រងរដ្ឋបាលតាមគោលការណ៍នៃរដ្ឋបាលដែលឯកភាពដើម្បីបង្កើតជំរុញ និងធ្វើអោយមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមរយៈគោលនយោបាយ វិមជ្ឈការ និងសហវិមជ្ឈការដោយផ្អែកតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ ដោយស្រុកល្វាឯមមានការបែងចែកនូវភារកិច្ចបានយ៉ាងត្រឹមត្រូវទៅតាមផ្លូវច្បាប់ និងមុខងារដោយមិនមានការរំលោភបំពានចំពោះគ្នា និងមានការគោរពសិទ្ធិទៅតាមតួនាទីនៃសមាជិក ក្នុងនោះក្រុមប្រឹក្សាស្រុកមានសិទ្ធិទៅ

[3] នៅក្នុងសៀវភៅក្រសួងមហាផ្ទៃទំព័រ៣ បោះពុម្ភ ខែមិថុនា ឆ្នាំ២០១០

លើគណៈអភិបាលស្រុករាល់ពេលមានភាពមិនសមហេតុផលក្នុងការសម្រេចមិនបានល្អ។ ក្នុងនោះគណៈ-អភិបាលស្រុកល្វាឯមបានអនុវត្តនូវសកម្មភាពនៃការបម្រើសេវាសាធារណៈ ជូនពលរដ្ឋបានល្អប្រសើរព្រមទាំងមានកម្មវិធីបណ្តុះបណ្តាលនៅតាមឃុំនីមួយៗដើម្បីពួកគាត់ទទួលបាននូវការបម្រើសេវាសាធារណៈប្រកបដោយតម្លាភាព។ ជាមួយគ្នានេះដែលការអភិវឌ្ឍរបស់ស្រុក គឺតាមបែបប្រជាធិបតេយ្យ ចំពោះពលរដ្ឋដែលមានលក្ខណៈជាភាពជាតំណាងសាធារណៈស្វ័យភាពរបស់មូលដ្ឋានការពិគ្រោះយោបល់ និងការចូលរួមឆ្លើយតប និងគណនេយ្យភាពការលើកកំពស់គុណភាពជីវភាពរបស់ប្រជាពលរដ្ឋ ក្នុងមូលដ្ឋានការលើកស្ទួយដល់មូល-ដ្ឋានតម្លាភាព និងសុចរិតភាព និងវិធានការប្រឆាំងអំពើពុករលួយ និងការរំលោភអំណាចជាដើមសម្រាប់លើកស្ទួយដល់ស្រុកល្វាឯមមានការជឿនលឿនកាន់តែប្រសើរឡើង ជាពិសេសអាចជាប់ជាស្រុកគំរូផងដែរនាពេល-អនាគត។ ជាពិសេសការរៀបចំសណ្តាប់ធ្នាប់សាធារ-ណៈទៅលើសន្តិសុខបង្ក្រាបលើក្មេងទំនើង ចោរកម្ម ការជួញដូរស្ត្រី និងកុមារការចែកចាយគ្រឿងញៀនអំពើពុករលួយនិងគ្រោះថ្នាក់ចរាចរណ៍ គឺត្រូវបានលុបបំបាត់ស្ទើរតែ ១០០% ហើយនៅក្នុងស្រុកសព្វថ្ងៃមានការខិតខំអនុវត្តបន្តនូវការអភិវឌ្ឍតាមលក្ខណៈ អភិបាលកិច្ចល្អអោយកាន់តែប្រសើរឡើងជារៀងរាល់ឆ្នាំដោយមានគោរពតាម គោលការណ៍របស់រាជរដ្ឋាភិបាលនៃព្រះរាជណា-ចក្រកម្ពុជា។

# ជំពូកទី២
# ការប្រព្រឹត្តទៅនៃការអនុវត្តរដ្ឋបាលស្រុកល្វាឯម

## ២.១ តួអង្គសំខាន់ៗ

### ២.១.១ ក្រុមប្រឹក្សាស្រុកល្វាឯម

ស្រុកល្វាឯមបានធ្វើការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាស្រុក ដែលស្របតាមច្បាប់ស្តីពីការជ្រើសរើសក្រុមប្រឹក្សាស្រុកដែលជាអ្នកតំណាងសាធារណៈជាអ្នកការពារ និងជាអ្នកបម្រើផលប្រយោជន៍ជូនប្រជាពលរដ្ឋទាំងអស់នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា។ សព្វថ្ងៃនេះប្រធានក្រុមប្រឹក្សាស្រុកល្វាឯម គឺជាមនុស្សប្រុសដែលបានជាប់ឆ្នោតជាប្រធានក្រុមប្រឹក្សាគឺលោក **សែម សោត្ថិ** និងមានសមាជិក ១៩នាក់ហើយក្រុមប្រឹក្សាស្រុកមានការផ្តល់នូវ តួនាទី និងសិទ្ធអំណាចក្នុងការអនុវត្តបម្រើអោយប្រជាពលរដ្ឋមានសិទ្ធិប្រឆាំងនូវរាល់សេចក្តីសម្រេចខុសពីច្បាប់រួមមានសិទ្ធិអំណាចធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ និងសិទ្ធិអំណាចធ្វើសេចក្តីសម្រេចខាងប្រតិបត្តិដោយក្រុមប្រឹក្សាស្រុកត្រូវប្រើប្រាស់អំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិរបស់ខ្លួនដោយផ្អែកតាមគោលការណ៍បែបបទ និងនីតិវិធីដែលកំណត់ក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា។

ប្រធានក្រុមប្រឹក្សាស្រុកដែលគ្រប់គ្រងដោយលោក **សែម សោត្ថិ** នៅក្នុងនាមគាត់ជាប្រធានក្រុមប្រឹក្សា-ស្រុកល្វាឯមគាត់មានសិទ្ធិចុះហត្ថលេខា និងប្រថាប់ត្រារដ្ឋបាលស្រុកលើករណីមួយចំនួនៈ

- ដីកា ឬសេចក្តីសម្រេចដែលក្រុមប្រឹក្សាស្រុកបានអនុម័តរួចរាល់
- សេចក្តីសម្រេចបង្កើតគណៈកម្មាធិការឬអនុគណៈកម្មាធិការឬក្រុមការងារតាមការសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សាស្រុកល្វាឯម
- កំណត់ហេតុប្រជុំដែលអង្គប្រជុំក្រុមប្រឹក្សាស្រុកអនុម័តរួច
- សំណើដកហូតអភិបាលស្រុក ឬ អភិបាលរងស្រុកចេញពីមុខតំណែងតាមការសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សាស្រុក[4]
- លិខិតអញ្ជើញរបស់ក្រុមប្រឹក្សាស្រុកល្វាឯម
- ប្រតិទិនប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាស្រុកល្វាឯមសម្រាប់រយៈពេល១ខែ
- សំណើសុំផ្លាស់ប្តូរសមាជិក ក្រុមប្រឹក្សាស្រុកល្វាឯមកិច្ចការដទៃទៀតតម្រូវដោយ និងលិខិតបទ-ដ្ឋានគតិយុត្តនានា។ ចំពោះការអនុវត្តសិទ្ធិអំណាចរបស់ខ្លួន ក្រុមប្រឹក្សាស្រុកត្រូវបានត្រួតពិនិត្យពិចារណាដែលមានចំណុចសំខាន់ៗមួយចំនួនដែលពាក់ព័ន្ធ និងរបៀបរបបអនុវត្តការងារដូចខាងក្រោមៈ

[4] មាត្រា១៣១ អនុក្រឹត្យលេខៈ២១៦. អនក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង ក្រុមប្រឹក្សា គណៈអភិបាលស្រុក

-ក្រុមប្រឹក្សាស្រុកល្វាឯម ត្រូវបំពេញមុខងារនិងភារកិច្ចរបស់ខ្លួនដោយធ្វើសេចក្តីសម្រេចខាងបញ្ញត្តិតាមរយៈដីកា និងសេចក្តីសម្រេចខាងប្រតិបត្តិ។ រាល់សេចក្តីសម្រេចខាងបញ្ញត្តិ និងសេចក្តីសម្រេចខាងប្រតិបត្តិត្រូវធ្វើឡើងនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាស្រុកល្វាឯម និងត្រូវធានាថាសេចក្តីសម្រេចទាំងនោះត្រូវបានអនុវត្តដោយមានការតាមដាននិងវាយតម្លៃជាប្រចាំ។

-ក្រុមប្រឹក្សាស្រុកល្វាឯមអាចចាត់អោយគណៈកម្មាធិការណាមួយ ឬមួយចំនួនដែលត្រូវអោយបង្កើតឡើងដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬអាចបង្កើតគណៈកម្មាធិការ ឬអនុ-គណៈកម្មាធិការ ឬក្រុមការងារនានាដើម្បីស្រាវជ្រាវរៀបចំសេចក្តីព្រាងដីកា ឬសេចក្តីព្រាងសេចក្តីសម្រតាមការចាំបាច់។ គណៈអភិបាលស្រុកល្វាឯមត្រូវបានដឹកនាំដោយនាយករដ្ឋបាលសាលាស្រុក និងការិយាល័យពាក់ព័ន្ធនៃសាលាស្រុកល្វាឯមដើម្បីផ្តល់ការគាំទ្រផ្នែកច្បាប់បច្ចេកទេស និងការគាំទ្រដទៃទៀតដល់គណៈកម្មាធិការ ឬអនុគណៈកម្មាធិការឬក្រុមការងារខាងលើ ព្រមទាំងធ្វើការសម្របសម្រួលណែនាំដល់ការិយាល័យនានានៃសាលាស្រុកល្វាឯម ក្នុងការរៀបចំសេចក្តីព្រាងដីកា ឬសេចក្តីព្រាងសេចក្តីសម្រេចដើម្បីដាក់ជូនក្រុមប្រឹក្សាស្រុកពិនិត្យពិភាក្សានិងអនុម័ត។ លើសពីនេះទៅទៀតអភិបាលស្រុកល្វាឯម ត្រូវបានណែនាំនាយករដ្ឋបាលសាលា-ស្រុកអោយរៀបចំដីកាឬ សេចក្តីសម្រេចដែលក្រុមប្រឹក្សាស្រុកល្វាឯមបានអនុម័តរួចអោយស្របតាមទម្រង់ដែលបានកំណត់ដើម្បីដាក់ជូនប្រធានក្រុមប្រឹក្សាស្រុកល្វាឯមត្រូវបានចុះហត្ថលេខា នៅក្នុងនាមក្រុមប្រឹក្សាស្រុករបស់ខ្លួននិងត្រូវប្រថាប់ត្រារដ្ឋបាលស្រុកល្វាឯម។ ក្រុមប្រឹក្សាស្រុកល្វាឯមត្រូវចាត់អោយអភិបាលស្រុកល្វាឯមចាត់ចែងផ្សព្វផ្សាយជាសាធារណៈជាបន្ទាន់នូវ ដីកា ឬសេចក្តីសម្រេចដែលក្រុមប្រឹក្សាស្រុកល្វាឯមបានអនុម័តរួចលើកលែងតែមានការកំណត់ផ្សេងពីនេះព្រមទាំងចាត់ចែងអោយអនុវត្ត អោយមានប្រសិទ្ធភាពនៅក្នុងស្រុកផងដែរ។

-ក្នុងករណីកិច្ចការណាមួយដែលជាតម្រូវការចាំបាច់នៃមូលដ្ឋានរបស់ខ្លួន ហើយដែលកិច្ចការនោះច្បាប់ឬលិខិតបតដ្ឋានគតិយុត្តមិនបានចែងអំពីបែបបទ និងនីតិវិធីនៅក្នុងការប្រើប្រាស់អំណាចបញ្ញត្តិ ឬអំណាច-ប្រតិបត្តិរបស់ខ្លួនក្រុមប្រឹក្សាស្រុកល្វាឯមត្រូវចាត់អោយគណៈអភិបាលស្រុកល្វាឯមធ្វើការសិក្សាស្រាវជ្រាវរៀបចំបែបបទ និងនីតិវិធិសមស្របដោយឈរលើគោលការណ៍ តម្លាភាពគណនេយ្យភាព និងប្រសិទ្ធភាពដាក់ជូនក្រុមប្រឹក្សាស្រុកពិនិត្យនិងអនុម័ត ដើម្បីដោះស្រាយកិច្ចការទាំងនោះ ឬអាចស្នើយោបល់ពីរដ្ឋមន្ត្រីក្រសួង-មហាផ្ទៃឬរដ្ឋមន្ត្រី ឬប្រធានស្ថាប័នពាក់ព័ន្ធនានា ធ្វើការបញ្ជាក់នូវបែបបទនីតិវិធីដើម្បីដោះស្រាយកិច្ចការទាំងនោះ។ក្នុងករណីកិច្ចការណាមួយដែលច្បាប់ និងលិខិតបទដ្ឋានគតិយុត្តបានកំណត់អំពីបែបបទនិងនីតិវិធីដែរក៏ប៉ុន្តែបែបបទនិងនីតិវិធីនោះចែងមិនច្បាស់លាស់ ឬមិនសមស្របនិងស្ថានភាពជាក់ស្តែងនៃមូលដ្ឋានរបស់ស្រុកហើយដែលក្រុមប្រឹក្សាស្រុកល្វាឯមមិនអាចអនុវត្តបានក្រុមប្រឹក្សាស្រុកត្រូវចាត់អោយគណៈអភិបាលស្រុក

ល្វាឯមធ្វើសំណើមករដ្ឋមន្ត្រីមកក្រសួងមហាផ្ទៃជាបន្ទាន់។ ដោយផ្អែកតាមយន្តការ គ.ជ.អ.ប រដ្ឋមន្ត្រីក្រសួងមហាផ្ទៃធ្វើការសម្របសម្រួលជាមួយរដ្ឋមន្ត្រី ឬប្រធានស្ថាប័នពាក់ព័ន្ធដើម្បីពិនិត្យ និងដោះស្រាយករណីនេះ។

ដើម្បីលើកកម្ពស់គណនេយ្យភាពរបស់ ក្រុមប្រឹក្សាស្រុកល្វាឯម ចំពោះប្រជាពលរដ្ឋរបស់ស្រុកនៅក្នុងការប្រើប្រាស់អំណាចប្រតិបត្តិ និងអំណាចបញ្ញត្តិរបស់ខ្លួនក្រុមប្រឹក្សាស្រុកល្វាឯម ត្រូវរៀបចំអោយមានយន្តការពិគ្រោះពិភាក្សាជាមួយសមាជិកក្រុមប្រឹក្សាឃុំក្នុងស្រុកល្វាឯម ដែលសម្តៅធានាអោយបានថាជម្រើសសេចក្តីសម្រេច និងសកម្មភាពរបស់ក្រុមប្រឹក្សាស្រុកល្វាឯម មានការឆ្លើយតបចំពោះតម្រូវការជាអាទិភាពរបស់ក្រុមប្រឹក្សាឃុំ និងប្រជាពលរដ្ឋទាំងអស់នៅក្នុងស្រុកល្វាឯម។ កិច្ចប្រជុំរបស់ក្រុមប្រឹក្សាស្រុកល្វាឯមត្រូវបានចែកជាពីរធំៗ គឺកិច្ចប្រជុំជាសាមញ្ញដែលក្រុមប្រឹក្សាត្រូវប្រជុំយ៉ាងហោចណាស់ចំនួន ១២ដង ក្នុងមួយឆ្នាំ និងកិច្ចប្រជុំវិសាមញ្ញ នៅក្នុងដែនសមត្ថកិច្ចរបស់ស្រុកបានតាមការចាំបាច់ ដើម្បីឆាប់ដោះស្រាយបញ្ហាជាបន្ទាន់ ឬជាពិសេសណាមួយ។[5] កិច្ចប្រជុំសាមញ្ញ និងវិសាមញ្ញអាចយកជាការបានលុះត្រាតែកិច្ចប្រជុំទាំងនេះប្រព្រឹត្តទៅត្រឹមត្រូវតាមបទបញ្ជាផ្ទៃក្នុងរបស់ ក្រុមប្រឹក្សាស្រុកល្វាឯម ហើយរាល់សេចក្តីសម្រេចទាំងឡាយណាដែលធ្វើឡើងមិនសមស្រប និងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាស្រុកល្វាឯម ឬរដ្ឋធម្មនុញ្ញឬច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តនានាសេចក្តីសម្រេចនោះពុំមានសុពលភាពឡើយ។រាល់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាស្រុកល្វាឯមត្រូវធ្វើសេចក្តីសម្រេចខាងបញ្ញត្តិឬធ្វើសេចក្តីសម្រេចខាង ប្រតិបត្តិដែលជាគោលការណ៍គោលនយោបាយរបស់រដ្ឋបាលស្រុកល្វាឯម និងជាវិធានការបែបបទនីតិវិធី ចែកការងារតាមការចាំបាច់នៅក្នុងស្រុកល្វាឯមដែល ទាក់ទងទៅនិងៈ

- ការរៀបចំដើម្បីទទួលមុខងារភារកិច្ច និងវិធានថ្មីដែលស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។
- ការអនុវត្តមុខងារជាជម្រើសរបស់ក្រុមប្រឹក្សាស្រុកល្វាឯម
- ការរៀបចំផែនការអភិវឌ្ឍរយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំ រួមទាំងសមាសភាពនៃផែនការដែលស្ថិតក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យរបស់ក្រុមប្រឹក្សាស្រុករួមគ្នាប្រភេទក្រុមប្រឹក្សាផ្សេងៗ ក្រសួង ស្ថាប័ន ឬមន្ទីរអង្គភាពនានារបស់រាជរដ្ឋាភិបាល និងដៃគូរពាក់ព័ន្ធនានា។
- ថវិកាប្រចាំឆ្នាំនិងក្របខណ្ឌចំណាយរយៈពេលមធ្យមរបស់រដ្ឋបាលស្រុកល្វាឯម
- បញ្ហាហិរញ្ញវត្ថុផ្សេងទៀតរបស់ក្រុមប្រឹក្សាស្រុកល្វាឯមក
- ការរៀបចំរចនាសម្ព័ន្ធប្រព័ន្ធ និងធនធានរួមទាំងការរៀបចំគណៈកម្មាធិការការិយាល័យ និងបុគ្គលិករបស់ ក្រុមប្រឹក្សាស្រុកល្វាឯម។

---

[5] មាត្រា១៣២ អនុក្រឹត្យលេខៈ២១៦.អនក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង ក្រុមប្រឹក្សា គណៈអភិបាលស្រុក

- ការបែងចែកភារកិច្ចដល់សមាជិកក្រុមប្រឹក្សាស្រុកល្វាឯម ដើម្បីជួយប្រាស្រ័យទាក់ទងជាមួយប្រជា- ពលរដ្ឋនិងទទួលតាមដានការងារនានាតាមតម្រូវការរបស់ក្រុមប្រឹក្សាស្រុកល្វាឯម។
- ការគ្រប់គ្រង និងការប្រើប្រាស់ទ្រព្យសម្បត្តិរបស់រដ្ឋបាលស្រុកល្វាឯម
- ដំណើរការពិគ្រោះយោបល់ជាមួយសាធារណៈជនរួមទាំងការ ពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សា ឃុំ សង្កាត់ក្នុងស្រុកល្វាឯម និងការផ្សព្វផ្សាយព័ត៍មាននានា ជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាស្រុកល្វាឯម។
- សមិទ្ធផលនិងបញ្ហាប្រឈមនៃកិច្ចការនានាដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាស្រុកល្វាឯម
- កិច្ចការផ្សេងៗទៀតដែលកំណត់ដោយច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តនានា។

ម្យ៉ាងទៀតក្រៅពីកិច្ចការដែលក្រុមប្រឹក្សាស្រុកល្វាឯម ត្រូវធ្វើការសម្រេចដូចរៀបរាប់ខាងលើក្រុមប្រឹក្សាស្រុកល្វាឯមអាចធ្វើការសម្រេចក្នុងកិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញរបស់ខ្លួននូវកិច្ចការផ្សេងៗទៀតរួមមាន៖

- ការកោះអញ្ជើញអភិបាលស្រុកល្វាឯម ឬអភិបាលរងស្រុក ឬគណៈអភិបាលស្រុកល្វាឯមទាំងមូលឬបុគ្គលិកដែលពាក់ព័ន្ធមកសាកសួរអំពីការអនុវត្តសេចក្តីសម្រេចរបស់ ក្រុមប្រឹក្សាស្រុកល្វាឯម ឬហេតុការណ៍ណាមួយដែលកើតមានក្នុងស្រុកល្វាឯម ឬការដោះស្រាយបញ្ហាបន្ទាន់ និងជាពិសេសណាមួយទាំងកិច្ចការផ្សេងៗទៀតដែលពាក់ព័ន្ធដល់រដ្ឋបាលស្រុកល្វាឯម។
- ការសម្រេចអោយមានការសិក្សាស្រាវជ្រាវ ឬការស៊ើបអង្កេតលើករណីទាំងឡាយណាដែលក្រុមប្រឹក្សា- ស្រុកល្វាឯម យល់ឃើញថាមានសារៈសំខាន់ដល់ពលរដ្ឋដែលខ្លួនជាតំណាង និងសម្រេចអោយធ្វើការផ្សព្វផ្សាយលទ្ធផលនៃការសិក្សាស្រាវជ្រាវ ឬការធ្វើអង្កេតនេះព្រមទាំងណែនាំដល់គណៈអភិបាលស្រុកល្វាឯមអំពីវិធានការដោះស្រាយតាមលទ្ធផលនៃការធ្វើអង្កេតនេះ។
- ការវាយតម្លៃអំពីសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ ឬក្រុមប្រឹក្សាសង្កាត់ និងតម្រូវការចាំបាច់ក្នុងការគាំទ្រឃុំក្នុងស្រុកល្វាឯម។
- ការពិនិត្យស្រាវជ្រាវ និងការសេចក្តីរាយការណ៍ទៅក្រសួងមហាផ្ទៃ ក្នុងករណីមានការរំលោភអំណាចកើតមានឡើងក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។
- ការពិនិត្យដោះស្រាយ ចំពោះទង្វើមិនស្របច្បាប់ដែលប្រព្រឹត្តដោយក្រុមប្រឹក្សាស្រុកល្វាឯម ឬសមាជិកក្រុមប្រឹក្សាស្រុកល្វាឯម ឬគណៈអភិបាលស្រុកល្វាឯម ឬអភិបាលស្រុកល្វាឯម ឬអភិបាលរងស្រុក ឬដោយបុគ្គលិករបស់ក្រុមប្រឹក្សាស្រុកល្វាឯម។
- ការពិនិត្យ និងចាត់វិធានការដោះស្រាយវិវាទនៅមូលដ្ឋានស្របទៅតាមច្បាប់ និងនីតិវិធីជាធរមាន
- ការពិនិត្យ និងដោះស្រាយអោយបានសមស្រប អំពីសំណូមពរឬការតវ៉ានានារបស់ប្រជាពលរដ្ឋក្នុង

ដែនសមត្ថកិច្ចរបស់ខ្លួន។

- ការពិនិត្យ និងអនុម័តរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំដែលរៀបចំដោយគណៈអភិបាលស្រុកល្វាឯម។
- បញ្ហាផ្សេងៗទៀត ដែលតម្រូវដោយច្បាប់លិខិតបទដ្ឋានគតិយុត្ត ព្រមទាំងបញ្ហានានាដែលក្រុមប្រឹក្សាស្រុកល្វាឯម និងគណៈអភិបាលស្រុកល្វាឯម និងគណៈអភិបាលស្រុកល្វាឯមយល់ឃើញថាមានការចាំបាច់។

### ២.១.២ គណៈអភិបាលស្រុកល្វាឯម

នៅក្នុងស្រុកល្វាឯមមានអភិបាល មួយរូប ដែលត្រូវបានតែងតាំងដោយ រដ្ឋាភិបាលកម្ពុជាតាមអនុក្រឹត្យលេខ អនក្រ.តក ចំពោះលោក **ភឹម ភីរ៉ា** ឋាននន្តរសិក្ខិវរមន្ត្រី ថ្នាក់លេខ៣ ជាអភិបាលស្រុកល្វាឯម និងអភិបាលរងបីនាក់ទៀតគឺលោក **យី យ៉េន** លោក **ចេង ឌីណា** លោក **កន សុខកាយ** អ្នកទាំងនេះគឺត្រូវបានតែងតាំងឡើងស្របតាមលក្ខខណ្ឌនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ នៅក្នុងនោះគណៈអភិបាលស្រុកល្វាឯមគាត់មានតួនាទី និងភារកិច្ចលើះ

- គណៈអភិបាលស្រុកល្វាឯម[6] ត្រូវធ្វើការសិក្សាស្រាវជ្រាវដើម្បីផ្តល់យោបល់ជូន ក្រុមប្រឹក្សាស្រុកល្វា-ឯមអំពីកិច្ចការនានាដែលពាក់ព័ន្ធ និងអំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិរបស់ក្រុមប្រឹក្សាស្រុកល្វាឯមដើម្បីអោយក្រុមប្រឹក្សាស្រុកធ្វើការពិចារណាអនុម័តទៅក្នុង កិច្ចប្រជុំសាមញ្ញ ឫវិសាមញ្ញទាក់ទងទៅនិងះ

- ការពិនិត្យមុខងារភារកិច្ច និងធនធានទាំងអស់ដែលបានប្រគល់ ឫបានផ្ទេរមកអោយក្រុមប្រឹក្សាស្រុកល្វាឯមនិងរបៀបរបបបែបបទនីតិវិធីនៃការអនុវត្តមុខងារភារកិច្ច និងការចាត់ចែងធនធានទាំងនោះអោយបានល្អ
- រៀបចំយុទ្ធសាស្ត្រ និងរៀបចំរចនាសម្ពន្ធ័ប្រព័ន្ធ និងធនធានដើម្បីទទួលយកមុខងារភារកិច្ច និងធនធានដែលបានប្រគល់ ឫបានផ្ទេរស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ផែនការអភិឌ្ឍរយៈពេលប្រាំឆ្នាំ និងកម្មវិធីបីឆ្នាំរំកិលប្រចាំឆ្នាំ
- ក្របខណ្ឌចំណាយរយៈពេលមធ្យម និងការធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ
- គម្រោងថវិកាប្រចាំឆ្នាំ
- ការងារហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ស្រុកល្វាឯម
- ការបង្កើត ការកែសម្រួល ឫការរំសាយការិយាល័យនានា
- ការរៀបចំតួនាទី ភារកិច្ច និងលក្ខខណ្ឌការងាររបស់បុគ្គលិក

[6] មាត្រា១៣៣ អនុក្រឹត្យលេខៈ២១៦.អនក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង ក្រុមប្រឹក្សា គណៈអភិបាលស្រុក

- ការកំណត់យុទ្ធសាស្ត្រដើម្បីអភិវឌ្ឍសមត្ថភាពដល់ ក្រុមប្រឹក្សាស្រុកល្វាឯមគណៈអភិបាលស្រុកល្វាឯ-ម និងបុគ្គលិករបស់ក្រុមប្រឹក្សាស្រុកល្វាឯម
- ការរៀបចំរបាយការណ៍ប្រចាំឆ្នាំដាក់ជូនក្រុមប្រឹក្សាស្រុកល្វាឯមពិនិត្យ និងអនុម័តមិនអោយលើសពី ៤៥ ថ្ងៃបន្ទាប់ពីដំណាច់ឆ្នាំនីមួយៗដែលពាក់ពន្ធ័និងៈ
  - ➢ ដីកា និងសេចក្តីសម្រេចនានាដែលបានដាក់ចេញដោយក្រុមប្រឹក្សាស្រុកល្វាឯម និងសកម្មភាពលទ្ធ-ផលនៃការអនុវត្ត
  - ➢ វាយតម្លៃអំពីការបំពេញការងាររបស់គណៈអភិបាលស្រុកល្វាឯម និងបុគ្គលិករបស់ក្រុមប្រឹក្សាស្រុកល្វាឯម
  - ➢ របាយការណ៍ហិរញ្ញវត្ថុ
  - ➢ វិធានការចាំបាច់ដើម្បីលើកកម្ពស់សមភាពយេនឌ័រ
  - ➢ កិច្ចការផ្សេងៗទៀតដែលក្រុមប្រឹក្សាស្រុកល្វាឯម យល់ឃើញថាចាំបាច់ត្រូវដាក់បញ្ចូលក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ស្រុកល្វាឯមរបាយការណ៍ប្រចាំខែ ត្រីមាស និង ឆមាសរបស់ស្រុកល្វាឯមការវាយតម្លៃរបស់ក្រុមប្រឹក្សាឃុំនៅក្នុងស្រុកល្វាឯម និងតម្រូវការគាំទ្រចំពោះឃុំ នៅក្នុងស្រុកល្វាឯម
- ការបង្កើតគណៈកម្មាធិការ ឫអនុគណៈកម្មាធិការ ឫក្រុមការងារនានាតាមការចាំបាច់ដើម្បីជួយដល់ការអនុវត្តរបស់ក្រុមប្រឹក្សាស្រុកល្វាឯម[7]
- ការរៀបចំយុទ្ធសាស្ត្រផ្សព្វផ្សាយព័ត៌មានដល់សាធារណៈជនដូចជាការរៀបចំក្តាប់ព័ត៌មានការបិទផ្សព្វផ្សព្វផ្សាយព័ត៌មានលើក្តារព័ត៌មាន និងការស្វះស្វែងរកមធ្យោបាយផ្សព្វផ្សាយព័ត៌មាននានាជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់សាលាស្រុកល្វាឯម
- កិច្ចសហការ និងការគាំទ្រដល់ ក្រុមប្រឹក្សាឃុំ នៅក្នុងស្រុកល្វាឯមជារបស់ស្រុក
- ការដោះស្រាយសំណើសំណូមពរ និងបញ្ហាប្រឈមនានារបស់ឃុំ
- កិច្ចការផ្សេងៗទៀត ដែលកំណត់ដោយច្បាប់លិខិតបទដ្ឋានគតិយុត្តនានា និងដែលតម្រូវដោយក្រុមប្រឹក្សាស្រុកល្វាឯម។

- នៅពេលទទួលបានរបាយការណ៍ ឫព័ត៌មានអំពីការរំលោភអំណាចគណៈអភិបាលស្រុកល្វាឯមត្រូវធ្វើការស៊ើបអង្កេតជាបន្ទាន់។ ប្រសិនបើរកឃើញថាមានការរំលោភអំណាចពិតប្រាកដមែន គណៈអភិបាលស្រុក

[7] មាត្រា១៤៧ អនុក្រឹត្យលេខៈ២១៦.អនក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងរបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង ក្រុមប្រឹក្សា គណៈអភិបាលស្រុក

ល្វាឯមត្រូវធ្វើសេចក្តីរាយការណ៍ទៅក្រុមប្រឹក្សាស្រុកល្វាឯម និងសេចក្តីរាយការណ៍ជូនអភិបាលខេត្តកណ្តាល ដើម្បីអោយរដ្ឋបាលខេត្តធ្វើសេចក្តីរាយការណ៍ជូនរដ្ឋមន្ត្រីនៃក្រសួងមហាផ្ទៃ។

អភិបាលស្រុកល្វាឯម គឺមានតួនាទីជាតំណាងក្រសួងស្ថាប័ននានារបស់រាជរដ្ឋាភិបាលនៅក្នុងរដ្ឋបាលស្រុកល្វាឯមរបស់ខ្លួន។ នៅក្នុងតួនាទីជាតំណាងក្រសួងស្ថាប័ននានារបស់រាជរដ្ឋាភិបាលនេះ អភិបាលស្រុកល្វាឯមត្រូវធ្វើដូចជា៖

- ថែរក្សាសន្តិសុខសណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈ លើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋក្នុងស្រុកល្វាឯមអំពីច្បាប់ និងធានាអោយមានការអនុវត្តច្បាប់ព្រមទាំងធានាអោយមានការការពារ និងគោរពសិទ្ធិមនុស្សចំពោះប្រជាពលរដ្ឋទាំងអស់នៅក្នុងស្រុកល្វាឯម។
- ធ្វើជាប្រធានគណៈបញ្ជាការឯកភាពស្រុកក្នុងការ ដឹកនាំសម្របសម្រួលការិយាល័យអង្គភាពពាក់ព័ន្ធនានា និងសង្កាត់នៅក្នុងស្រុកល្វាឯមដើម្បីធានារក្សាសន្តិសុខសណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈនៅក្នុងស្រុកល្វាឯម[8]។
- ណែនាំដល់ការិយាល័យអង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួងស្ថាប័នដែលប្រចាំនៅស្រុកល្វាឯមអោយអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួនបានត្រឹមត្រូវស្របតាមច្បាប់គោលនយោបាយជាតិ និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនិងការិយាល័យអង្គភាព និងទីភ្នាក់ងារនិមួយៗនោះ។
- សម្របសម្រួលតម្រង់ទិសដល់ការិយាល័យអង្គភាព និងទីភ្នាក់ងារនានាក្រសួង ស្ថាប័នដែលប្រចាំនៅស្រុកល្វាឯមក្នុងការឆ្លើយតបតម្រូវការជាអាទិភាពនៅមូលដ្ឋាន។ នៅក្នុងករណីកិច្ចកិច្ចការទាំងឡាយណាដែលមានការពាក់ព័ន្ធច្រើនវិស័យអភិបាលស្រុកល្វាឯម ត្រូវការសម្របសម្រួលការិយាល័យអង្គភាពទីភ្នាក់ងារពាក់ព័ន្ធដើម្បីសហការគ្នាអនុវត្តកិច្ចការនោះដោយផ្អែកទៅតាមគោលនយោបាយរបស់ រាជរដ្ឋាភិបាលច្បាប់លិខិតបទដ្ឋានគតិយុត្តនានា និងតម្រូវការអាទិភាពរបស់មូលដ្ឋាន។ តាមរយៈគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាស្រុក-ល្វាឯមត្រូវសម្របសម្រួលតម្រង់ទិស ការិយាល័យអង្គភាព ទីភ្នាក់ងារនានារបស់ក្រសួងស្ថាប័នដែលប្រចាំនៅស្រុកល្វាឯមក្នុងការធ្វើសមាហរណកម្មផែនការនិងថវិការបស់ស្រុកទៅក្នុងផែនការនិងថវិការបស់ក្រុមប្រឹក្សាស្រុកល្វាឯម
- ពិនិត្យវាយតម្លៃផ្តល់មូលវិចារណ៍ និងដាក់ពិន្ទុប្រធានការិយាល័យអង្គភាព នៃក្រសួងស្ថាប័ននានាដែលប្រចាំស្រុកល្វាឯម។

ពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាស្រុកល្វាឯមជាមុន នៅក្នុងការផ្តល់យោបល់ លើបេក្ខភាពដែលស្នើតែងតាំង

[8] មាត្រា១៥៤ អនុក្រឹត្យលេខៈ២១៦.អនក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង ក្រុមប្រឹក្សា គណៈអភិបាលស្រុក

ជាប្រធានការិយាល័យ និងអង្គភាពនៃក្រសួង ស្ថាប័ននានាប្រចាំនៅស្រុកល្វាឯម។ នៅក្នុងករណីមិនគាំទ្រចំពោះបេក្ខភាពដែលស្នើតែងតាំងខាងលើនេះ អភិបាលស្រុកល្វាឯម ត្រូវធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរដោយបញ្ជាក់អំពីហេតុផល នៃការមិនគាំទ្រនេះជូនអភិបាលខេត្តកណ្តាលដើម្បីអោយអភិបាលខេត្ត ធ្វើការសម្របសម្រួលជាមួយប្រធានមន្ទីរអង្គភាពសាមីជាមុនសិន និងធ្វើសេចក្តីរាយការណ៍ជូនមន្ត្រី ឬប្រធានស្ថាប័នសាមី។

- រាយការណ៍ជាលាយលក្ខណ៍អក្សរ និងជាបន្ទាន់ទៅអភិបាលខេត្តកណ្តាលក្នុងករណីពិនិត្យឃើញមានភាពមិនប្រក្រតីដែលកើតមានក្នុងការិយាល័យអង្គភាព និងទីភ្នាក់ងារណាមួយរបស់ក្រសួង ស្ថាប័នដែលប្រចាំនៅក្នុងស្រុកល្វាឯម ឬក្នុងករណីប្រធានការិយាល័យប្រធានអង្គភាព និងអ្នកទទួលខុសត្រូវនៃការិយាល័យអង្គភាពបានប្រព្រឹត្តខុសឆ្គងពីតួនាទី និងភារកិច្ចរបស់ខ្លួន។ អភិបាលខេត្តកណ្តាលត្រូវណែនាំដល់មន្ទីរអង្គ-ភាពខ្សែបណ្តោយសាមីប្រចាំខេត្តកណ្តាលដើម្បីស្រាវជ្រាវអំពីបញ្ហានេះ ឬអាចចាត់តាំងគណៈកម្មាធិការឬក្រុមការងារដែលមានការចូលរួមពីរដ្ឋបាលស្រុកល្វាឯម ពាក់ព័ន្ធអោយធ្វើការស៊ើបអង្កេតលើករណីនេះ ជាបន្ទាន់ដើម្បីធ្វើសេចក្តីរាយការណ៍ជូនមន្ត្រី ឬប្រធានស្ថាប័នសាមីដោះស្រាយស្របតាមនីតិវិធី។
- មានសិទ្ធិស្នើជាលាយលក្ខណ៍អក្សរទៅ អភិបាលខេត្តកណ្តាល ដើម្បីចាត់វិធានការផ្លាស់ប្តូរ ឬដកហូតពីមុខតំណែងនូវប្រានការិយាល័យ ឬប្រធានអង្គភាព ឬអ្នកទទួលខុសត្រូវនៃទីភ្នាក់ងារណាមួយរបស់ក្រសួងស្ថាប័នដែលប្រព្រឹត្តខុសច្បាប់ហើយដែលមិនអាចធ្វើយុត្តិកម្មបាន។[9]

សេចក្តីរាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំរបស់ការិយាល័យទាំង១២ និងទីភ្នាក់ងារនានា របស់ក្រសួងស្ថាប័នដែលប្រចាំនៅក្នុងស្រុកល្វាឯមត្រូវដាក់ជូន អភិបាលស្រុកល្វាឯមដើម្បីពិនិត្យនិងផ្តល់យោបល់ប្រសិនបើអភិបាលស្រុកល្វាឯមឯកភាព អភិបាលស្រុកល្វាឯមត្រូវចុះហត្ថលេខាលើរបាយការណ៍នោះរួមជាមួយ និងប្រធានការិយាល័យអង្គភាព និងអ្នកទទួលខុសត្រូវនៃទីភ្នាក់ងារនោះ។[10] ចំពោះសេចក្តីរាយការណ៍ក្រៅពីនោះ ការិយាល័យអង្គភាព និងភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅស្រុកល្វាឯមត្រូវចម្លងជូនសាលាស្រុកល្វាឯមទុកមួយច្បាប់។

នៅក្នុងការអនុវត្តតួនាទីភារកិច្ចរបស់លោក **ភឹម ភីរ៉ា** គណៈអភិបាលស្រុកល្វាឯម អភិបាលស្រុកល្វា-ឯម អភិបាលរងស្រុកល្វាឯមទាំង៣នាក់ ត្រូវពិនិត្យពិចារណាលើចំណុចសំខាន់ៗ មួយចំនួនដែលពាក់ព័ន្ធ

[9] មាត្រា១៥៦ អនុក្រឹត្យលេខ:២១៦.អនក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង ក្រុមប្រឹក្សា គណៈអភិបាលស្រុក

[10] មាត្រា១៤៩ អនុក្រឹត្យលេខ:២១៦.អនក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង ក្រុមប្រឹក្សា គណៈអភិបាលស្រុក

និងរបៀបរបបអនុវត្តការងារដូចខាងក្រោម៖[11]

- ការអនុវត្ត តួនាទី ភារកិច្ច របស់ខ្លួនអភិបាលស្រុកល្វាឯមត្រូវគោរពតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលច្បាប់លិខិតបទដ្ឋានគតិយុត្តនានា និងការណែនាំរបស់រាជរដ្ឋាភិបាលក្រសួង ស្ថាប័ននានានិងត្រូវមានគណនេយ្យភាពចំពោះរដ្ឋាភិបាលក្រសួងមហាផ្ទៃ និងក្រសួង ស្ថាប័ននានាស្របទៅតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា។
- ក្នុងការអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួន និងការងារដទៃទៀតដែលខ្លួនយល់ឃើញថាចាំបាច់អភិបាលស្រុកល្វាឯម ត្រូវយកការងារទាំងនោះមកពិគ្រោះពិភាក្សានៅក្នុង គណៈអភិបាលស្រុកល្វាឯមរបស់ខ្លួនដោយឈរលើគោលការណ៍ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ព្រមទាំងការសម្រេចនិងគោលការណ៍ណែនាំពីក្រុមប្រឹក្សាស្រុកល្វាឯមរបស់ខ្លួន។
- អភិបាលស្រុកល្វាឯម ត្រូវទទួលខុសត្រូវនៅចំពោះមុខក្រុមប្រឹក្សាស្រុកល្វាឯម អំពីសកម្មភាពការងារទាំងអស់របស់គណៈអភិបាលស្រុកល្វាឯម។
- អភិបាលស្រុកល្វាឯម ត្រូវចុះហត្ថលេខាលើលិខិតស្នាមរដ្ឋបាលនានា សម្រាប់ចាត់ចែងការងារប្រចាំថ្ងៃដើម្បីអនុវត្តសេចក្ដីសម្រេច នៃក្រុមប្រឹក្សាស្រុកល្វាឯមរបស់ខ្លួនលើកលែងតែលិខិតបទដ្ឋាន ដែលតម្រូវអោយប្រធានក្រុមប្រឹក្សាស្រុក ចុះហត្ថលេខា ក្នុងនាមក្រុមប្រឹក្សាស្រុកល្វាឯមរបស់ខ្លួន។ អភិបាលស្រុកល្វាឯមអាចប្រគល់សិទ្ធិដល់អភិបាលរងស្រុក ក្នុងការចុះហត្ថលេខាលើ ឯកសារ លិខិតស្នាមរដ្ឋបាលចាំបាច់មួយចំនួនក្នុងក្របខ័ណ្ឌនៃភារកិច្ចដែលបានបែងចែកជូនអភិបាលរងស្រុកល្វាឯមនីមួយៗ។ ក៏ប៉ុន្តែ អភិបាលស្រុកល្វាឯម ត្រូវទទួលខុសត្រូវអំពីភាពត្រឹមត្រូវតាមច្បាប់ និងបែបបទនីតិវិធីចំពោះ ឯកសារ លិខិតស្នាមដែលបានប្រគល់សិទ្ធិចុះហត្ថលេខាដល់អភិបាលរងស្រុកល្វាឯម។ អភិបាលស្រុកល្វាឯម មានសិទ្ធិដកហូតមកវិញនូវសិទ្ធិចុះហត្ថលេខាពីអភិបាលស្រុករងណាម្នាក់ដែលប្រើប្រាស់ អំណាចនេះមិនសមស្របច្បាប់ និងមិនស្របតាមបែបបទនីតិវិធី។ ការប្រគល់និងការដកហូតមកវិញនូវសិទ្ធិក្នុងការចុះហត្ថលេខានេះអភិបាលស្រុកល្វាឯម ត្រូវរាយការណ៍ជូនក្រុមប្រឹក្សាស្រុកល្វាឯមរបស់ខ្លួន។ ក្នុងករណីអភិបាលស្រុកល្វាឯម អវត្តមានអភិបាលស្រុកល្វាឯម ត្រូវផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរជូន អភិបាលរងស្រុកមួយរូបណាឱ្យទទួលជាអភិបាលស្រុកស្ដីទី។ ប្រសិនបើអភិបាលស្រុកល្វាឯម អវត្តមានដោយពុំមានការផ្ទេរសិទ្ធិអភិបាលរងស្រុកដែលស្ថិតនៅលំដាប់លេខរៀងលើគេនៃប្រកាសតែងតាំងអភិបាលរង ន ស គណៈអភិបាលស្រុកល្វាឯមត្រូវធ្វើជាអភិបាលស្រុកស្ដីទី។ នៅក្នុងករណីអភិបាលស្រុកល្វាឯមស្ដីទីអវត្តមានអភិបាលខេត្តកណ្ដាលត្រូវចេញដីកាដើម្បីប្រគល់កិច្ចការដល់អភិបាលរង

[11] វាក្យខណ្ឌ២ ៣ និង៤ មាត្រា១៤៩ អនុក្រឹត្យលេខៈ២១៦.អនក្រ.បក ស្ដីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង ក្រុមប្រឹក្សា គណៈអភិបាលស្រុក

ស្រុក មួយរូប អោយទទួលជាអភិបាលស្រុកស្តីទី និងធ្វើសេចក្តីរាយការណ៍ជូនរដ្ឋបាលខេត្តកណ្តាលដើម្បីអោយរដ្ឋបាលខេត្ត ធ្វើសេចក្តីរាយការណ៍មករដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ អភិបាលស្រុកល្វាឯម ស្តីទីត្រូវរាយការណ៍រាល់កិច្ចការដែលបានអនុវត្តជូនអភិបាលស្រុកល្វាឯមនៅពេលដែលអភិបាលស្រុកល្វាឯមមានវត្តមានវិញ។

- គណៈអភិបាលស្រុកល្វាឯម ត្រូវជួបប្រជុំពិភាក្សា ដើម្បីបែងចែកភារកិច្ចដល់អភិបាលស្រុកល្វាឯម និងអភិបាលរងស្រុកល្វាឯម ហើយសុំការសម្រេចពីក្រុមប្រឹក្សាស្រុកល្វាឯមរបស់ខ្លួន។ អភិបាលរងស្រុកដែលបានទទួលការបែងចែកភារកិច្ចនេះ ត្រូវទទួលខុសត្រូវអំពីសកម្មភាពរបស់ខ្លួនចំពោះមុខអភិបាលស្រុកល្វាឯម។
- គណៈអភិបាលស្រុកល្វាឯម ឬអភិបាលស្រុកល្វាឯម ឬអភិបាលរងស្រុកដែលបានសម្រេច និងដែលបានអនុវត្តកិច្ចការណាមួយផ្ទុយ និងច្បាប់លិខិតបទដ្ឋានគតិយុត្តនានា ឬកិច្ចការណាមួយដែលស្ថិតក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាស្រុកល្វាឯម ហើយពុំបានទទួលការសម្រេចពីក្រុមប្រឹក្សាស្រុកល្វាឯមធ្វើការសម្រេច ឬការសកម្មភាពនោះពុំមានសុពលភាពឡើយ។ ដូច្នេះគណៈអភិបាលស្រុកល្វាឯមទាំងមូល ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់អំពីការសម្រេច ឬសកម្មភាពទាំងនេះ។
- អភិបាលរងស្រុកល្វាឯម ត្រូវទទួលខុសត្រូវចំពោះមុខអភិបាលស្រុកល្វាឯម លើភារកិច្ចនានាដែលបានប្រគល់ជូនហើយត្រូវចូលរួមជាមួយ អភិបាលស្រុកល្វាឯមទទួលខុសត្រូវអំពីការសម្រេច និងសកម្មភាពក្នុងគណៈអភិបាលស្រុកល្វាឯមរបស់ខ្លួនដើម្បីធានាអោយបាននូវគោលការណ៍ នៃការអនុវត្តការងារនេះគណៈអភិបាលស្រុកល្វាឯមត្រូវប្រជុំប្រចាំ **អឌ្ឍមាស**។ ការប្រជុំអឌ្ឍមាសទី២ នៃខែនីមួយៗជាការប្រជុំប្រចាំខែ។
- ចំពោះក្រៅពីការ ប្រជុំប្រចាំអឌ្ឍមាស និងការប្រជុំប្រចាំខែនេះគណៈអភិបាលស្រុកល្វាឯមអាចកោះប្រជុំតាមការចាំបាច់ជាបន្ទាន់របស់ស្រុកបើមានសភាពការមិនល្អ។

### ២.១.៣ នាយករដ្ឋបាលស្រុកល្វាឯម

ក្រុមប្រឹក្សាស្រុកល្វាឯម និងគណៈអភិបាលស្រុកល្វាឯមត្រូវមាននាយករដ្ឋបាល មួយរូបហៅថានាយករដ្ឋបាលសាលាស្រុកល្វាឯម។ នាយករដ្ឋបាលនៅស្រុកល្វាឯម មានមួយរូបដែលមានឈ្មោះ លោក **ញឹក សាត** ជានាយករដ្ឋបាល និងជានាយករដ្ឋបាលរងប្រចាំនៅសាលាស្រុកសព្វថ្ងៃ។ នាយករដ្ឋបាលសាលាស្រុកល្វាឯមមានតួនាទី និងភារកិច្ចសម្រាប់៖

- ជាជំនួយការដល់ក្រុមប្រឹក្សាស្រុកល្វាឯម គណៈអភិបាលស្រុកល្វាឯម និងអភិបាលស្រុកល្វាឯមនូវការចាត់ចែងកិច្ចការរដ្ឋបាល និងធានានិរន្តរភាពកិច្ចការរដ្ឋបាលប្រចាំថ្ងៃក្នុងសាលាស្រុកល្វាឯមហើយនៅក្នុងការអនុវត្ត តួនាទីនេះនាយករដ្ឋបាលសាលាស្រុកត្រូវ៖[12]

[12] មាត្រា១៥០ អនុក្រឹត្យលេខៈ២១៦.អនក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង ក្រុមប្រឹក្សា គណៈអភិបាលស្រុក

- ធ្វើរបាយការណ៍ និងមានគណនេយ្យភាពចំពោះគណៈអភិបាលស្រុកល្វាឯម និងក្រុមប្រឹក្សាស្រុកល្វាឯម

- រៀបចំ និងដាក់ជូនគណៈអភិបាលស្រុកល្វាឯមពិនិត្យនិងសម្រេចនូវកិច្ចរដ្ឋបាលប្រចាំថ្ងៃក្នុងសាលាស្រុកល្វាឯម នៅក្នុងក្របខ័ណ្ឌសមត្ថកិច្ចរបស់គណៈអភិបាលស្រុកល្វាឯម ហើយត្រូវធានាថាកិច្ចការទាំងនោះត្រូវបានរៀបចំឡើងតាមបទដ្ឋានគតិយុត្ត និងទម្រង់បែបបទនៃលិខិតស្នាមរដ្ឋបាល

- រៀបចំ និងដាក់ជូនគណៈអភិបាលស្រុកល្វាឯម នូវវិធានការនិងគោលការណ៍នៅក្នុងការអនុវត្តដីកានិងសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សាស្រុកល្វាឯម

- ធ្វើសេនាធិការជូនអភិបាលស្រុកល្វាឯម និងប្រធានក្រុមប្រឹក្សាស្រុកល្វាឯមក្នុងការត្រៀមរៀបចំសេចក្តីព្រាងព្រាងរបៀបវារៈ នៃកិច្ចប្រជុំទាំងអស់របស់ក្រុមប្រឹក្សាស្រុកល្វាឯម រួមទាំងការសម្របសម្រួលក្នុងការរៀបចំឯកសារ និងខ្លឹមសារសម្រាប់រៀបចំវារៈនីមួយៗនៃកិច្ចប្រជុំទាំងអស់របស់ក្រុមប្រឹក្សាស្រុកល្វាឯម តាមបទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សារបស់ខ្លួន។ សេចក្តីព្រាងរបៀបវារៈឯកសារ និងខ្លឹមសារទាំងអស់ដែលនាយករដ្ឋបាលសាលាស្រុកល្វាឯម បានរៀបចំសម្រាប់ដាក់កិច្ចប្រជុំក្រុមប្រឹក្សាស្រុកល្វាឯមត្រូវដាក់ជូនក្រុមប្រឹក្សាស្រុកល្វាឯមដើម្បីពិនិត្យនិងផ្តល់យោបល់ជាមុនលើកលែងតែមានការកំណត់ផ្សេងដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា

- ធ្វើជាសេនាធិការជូនក្រុមប្រឹក្សាស្រុកល្វាឯមនៅក្នុងការរៀបចំនិងបែងចែងលិខិតអញ្ជើញប្រជុំការរៀបចំទីកន្លែងប្រជុំ និងកំណត់ហេតុគ្រប់កិច្ចប្រជុំទាំងអស់របស់ក្រុមប្រឹក្សាស្រុកល្វាឯម

- ត្រៀមរៀបចំ កិច្ចការនានាសម្រាប់បម្រើអោយកិច្ចប្រជុំទាំងអស់របស់ គណៈអភិបាលស្រុកល្វាឯមតាមការ ណែនាំរបស់អភិបាលស្រុកល្វាឯមគឺ លោក **ភឹម ភីរ៉ា**

- ធានាក្នុងការទទួល និងបែងចែកលិខិតស្នាមឯកសារនានាអោយបានត្រឹមត្រូវដល់ក្រុមប្រឹក្សាស្រុកល្វាឯមព្រមទាំងក្រសួង ស្ថាប័ន មន្ទីរអង្គភាពការិយាល័យ និងអ្នកពាក់ព័ន្ធនានា

- គ្រប់គ្រង និងប្រើប្រាស់ត្រារដ្ឋបាលស្រុកល្វាឯមអោយបានត្រឹមត្រូវតាមការកំណត់

- ធានារក្សាទុកដាក់អោយបានត្រឹមត្រូវ និងគង់វង្សនូវឯកសារលិខិតបទដ្ឋានគតិយុត្តទាំងអស់របស់ក្រុមប្រឹក្សាស្រុកល្វាឯម និងគណៈអភិបាលស្រុកល្វាឯម និងរដ្ឋបាលស្រុក

- បំពេញភារកិច្ចផ្សេងទៀត តាមការប្រគល់ភារកិច្ចពីក្រុមប្រឹក្សាស្រុកល្វាឯម គណៈអភិបាលស្រុកល្វាឯម ឬដែលតម្រូវដោយច្បាប់ និងលិខិតស្នាមបទដ្ឋានគតិយុត្តនានា ។

- មានសិទ្ធិចូលរួម និងបញ្ចេញយោបល់គ្រប់កិច្ចប្រជុំក្រុមប្រឹក្សាស្រុកល្វាឯម កិច្ចប្រជុំគណៈកម្មាធិការអនុគណៈកម្មាធិការ និងក្រុមការងារនានារបស់ក្រុមប្រឹក្សាស្រុកល្វាឯម និងកិច្ចប្រជុំគណៈអភិបាលស្រុកល្វាឯម

ក៏ប៉ុន្តែពុំមានសិទ្ធិបោះឆ្នោតឡើយឃ្លើកលែងនាយករដ្ឋបាលសាលាស្រុកល្វាឯមនេះជាសមាជិកគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារណាមួយនោះ ។

- នៅក្នុងកិច្ចការប្រជុំ និងការអនុវត្តការងារប្រចាំថ្ងៃនាយករដ្ឋបាលសាលាស្រុកល្វាឯមអាចផ្តល់យោបល់ដល់ក្រុមប្រឹក្សាស្រុកល្វាឯម គណៈកម្មាធិការ អនុគណៈកម្មាធិការនិងក្រុមការងារនានារបស់ក្រុមប្រឹក្សាស្រុកល្វាឯម និងគណៈអភិបាលស្រុកល្វាឯមរបស់ស្រុកអំពីបញ្ហាច្បាប់ និងបច្ចេកទេសដើម្បីធានាថាសេចក្តីសម្រេច និងសកម្មភាពនានារបស់ក្រុមប្រឹក្សាស្រុកល្វាឯម គណៈអភិបាលស្រុកល្វាឯម និងអភិបាលស្រុកល្វាឯមមានលក្ខណៈសមស្របតាមរដ្ឋធម្មនុញ្ញច្បាប់ និងលិខិតបទដ្ឋានគតិយុត្តព្រមទាំងបទដ្ឋានជាតិសម្រាប់សុវត្ថិភាព និងគុណភាពដែលបានកំណត់ព្រមទាំងការលើកកម្ពស់ប្រសិទ្ធភាពការងារនៅក្នុងសាលាស្រុកល្វាឯម ។
- ត្រូវធានាអោយការិយាល័យមន្ត្រី បុគ្គលិកទាំងអស់អនុវត្តការងារបានត្រឹមត្រូវ ទៅតាមច្បាប់លិខិតបទដ្ឋានគតិយុត្តនីតិវិធីនានា និងតាមការសម្រេចរបស់ក្រុមប្រឹក្សាស្រុកល្វាឯម និងគណៈអភិបាលស្រុកល្វាឯមរបស់ស្រុក។

គណៈអភិបាលស្រុកល្វាឯម ឬអភិបាលស្រុកល្វាឯមអាចធ្វើប្រតិភូកម្មដល់នាយករដ្ឋបាលសាលាស្រុកល្វាឯមអោយលើកឡើងលើកិច្ចការណាមួយដែលបានស្ថិតនៅក្នុងវិសាលភាព នៃតួនាទីភារកិច្ចរបស់ខ្លួន ដើម្បីគណៈអភិបាលស្រុកល្វាឯម ឬអភិបាលស្រុកល្វាឯមពិនិត្យសម្រេចតាមការចាំបាច់ ។

### ២.១.៤ គណៈកម្មាធិការផ្សេងៗរបស់ក្រុមប្រឹក្សាស្រុកល្វាឯម

ក្រុមប្រឹក្សាស្រុកល្វាឯម មានកាតព្វកិច្ចរៀបចំអោយមាន គណៈកម្មាធិការដូចខាងក្រោម៖ គណៈកម្មាធិការ សម្របសម្រួលបច្ចេកទេស

- គណៈកម្មាធិការ ពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ
- គណៈកម្មាធិការ លទ្ធកម្ម។

ក្រៅពីគណៈកម្មាធិការទាំងបីខាងលើនេះក្រុមប្រឹក្សា អាចបង្កើតគណៈកម្មាធិការផ្សេងទៀតដើម្បីជួយការងាររបស់ក្រុមប្រឹក្សាតាមការចាំបាច់។

- ក្រុមប្រឹក្សាអាចតែងតាំងសមាជិកក្រុមប្រឹក្សា បុគ្គលិកក្រុមប្រឹក្សាស្រុកល្វាឯម ជាសមាជិកគណៈកម្មា-ធិការបាន។ ម្យ៉ាងទៀតគណៈគម្មាធិការខាងលើនេះ មិនត្រូវមានតួនាទីនិងភារកិច្ចត្រួតគ្នាជាមួយនិងតួនាទីភារកិច្ច របស់គណៈកម្មាធិការទាំងបីរបស់ក្រុមប្រឹក្សាស្រុកល្វាឯម ឬតួនាទី ភារកិច្ចរបស់គណៈអភិបាលឡើយ។
- ក្រុមប្រឹក្សាស្រុកល្វាឯម ត្រូវសម្រេចអំពីចំនួនសមាជិកគណៈកម្មាធិការនីមួយៗអំពីការតែងតាំងប្រធាន អនុប្រធាន និងអំពីការកំណត់តួនាទីភារកិច្ចសកម្មភាពរបស់គណៈកម្មាធិការនីមួយៗដែលខ្លួនបានបង្កើតឡើង

- ក្រុមប្រឹក្សាស្រុកល្វាឯមអាចអនុញ្ញាតអោយ គណៈកម្មាធិការនីមួយៗជ្រើសរើសយកបុគ្គលិកដែលមិនមែនជាសមាជិកក្រុមប្រឹក្សាស្រុកល្វាឯមធ្វើជាប្រឹក្សាតាមការចាំបាច់។

- ក្រុមប្រឹក្សាស្រុកល្វាឯម ត្រូវធានាអោយមានតំណាងស្ត្រីនៅក្នុងគណៈកម្មាធិការរបស់ខ្លួនរួមទាំងប្រធាន ឬអនុប្រធានគណៈកម្មាធិការផង។

- គណៈកម្មាធិការនីមួយៗ នៃក្រុមប្រឹក្សាស្រុកល្វាឯម ត្រូវរាយការណ៍អំពីសកម្មភាពរបស់ខ្លួនអោយបានទៀងទាត់អោយក្រុមប្រឹក្សា និងគណៈអភិបាល។

- ក្រុមប្រឹក្សាស្រុកល្វាឯម អាចបញ្ឈប់សមាជិកណាមួយពីគណៈកម្មាធិការដែលខ្លួនបានបង្កើតឡើង។ ក្នុងករណីដែលសមាជិកគណៈកម្មាធិការនោះជាសមាជិកក្រុមប្រឹក្សាសមាជិកនោះនៅតែជាសមាជិកក្រុមប្រឹក្សាដដែល។

- ក្រុមប្រឹក្សាស្រុកល្វាឯម ត្រូវទទួលខុសត្រូវរាល់សេចក្តីសម្រេច និងសកម្មភាពរបស់គណៈកម្មាធិការនានា ដែលខ្លួនបានបង្កើតឡើង និងទទួលខុសត្រូវចំពោះផលវិបាកពីសកម្មភាពរបស់គណៈកម្មាធិការទាំងនោះ។

- ក្រុមប្រឹក្សាស្រុក ត្រូវផ្តល់ការគាំទ្រកិច្ចការផ្នែកលេខាធិការដ្ឋាន និងការគាំទ្រដទៃទៀតដល់គណៈកម្មា-ធិការនានាដែលខ្លួនបានបង្កើតឡើង។

❖ **គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស៖** មានសមាសភាពដូចតទៅ៖

-អភិបាលស្រុក ជាប្រធាន

-ប្រធានអង្គភាពទាំងអស់ របស់ក្រុមប្រឹក្សា

-ប្រធានហិរញ្ញវត្ថុ របស់ក្រុមប្រឹក្សា

-ប្រធានអង្គភាពនៃ ក្រសួង ស្ថាប័ននានារបស់រដ្ឋាភិបាលដែលផ្តល់សេវាសម្ភារៈ ឬហេដ្ឋារចនាសម្ព័ន្ធដោយផ្ទាល់នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា។

❖ **គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ៖** ត្រូវជ្រើសរើសចេញពីក្នុងចំណោមសមាជិកក្រុមប្រឹក្សាជាស្ត្រីនៅក្នុងក្រុមប្រឹក្សានោះឬ ស្ត្រី និងបុរសនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាស្រុក គណៈកម្មា-ធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារមានសិទ្ធិ និងមានភារកិច្ចផ្តល់យោបល់និងលើក អនុសាសន៍ជូនក្រុមប្រឹក្សា គណៈអភិបាល អភិបាល និងគណៈកម្មាធិការដទៃទៀតរបស់ក្រុមប្រឹក្សាលើបញ្ហាពាក់ព័ន្ធនិងសមភាពយេនឌ័រ បញ្ហាស្ត្រី និងកុមារដែលស្ថិតនៅក្នុងអំណាចមុខងារ និងភារកិច្ច របស់ក្រុមប្រឹក្សា។

❖ **គណៈកម្មាធិការលទ្ធកម្ម៖** មានសិទ្ធ និងភារកិច្ចធានាអោយមានសកម្មភាពកិច្ចការលទ្ធកម្មទាំងអស់

របស់រដ្ឋបាលថ្នាក់ក្រោមជាតិ

ប្រព្រឹត្តធ្វើឡើងប្រកបដោយភាពស្មោះត្រង់ បើកចំហ តម្លាភាព មិនលម្អៀងដោយអនុលោមតាមច្បាប់បទបញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ ដើម្បីការពារផលប្រយោជន៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រជាពលរដ្ឋរបស់ខ្លួន។ ការបង្កើតការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្មត្រូវកំណត់ដោយប្រកាសអន្តរក្រសួង រវាងក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ២.២ យន្តការផ្ទៃក្នុងស្រុកល្វាឯម

ចំពោះការគ្រប់គ្រងរដ្ឋបាល នៅក្នុងសាលាស្រុកល្វាឯមមានការរៀបចំនូវរចនាសម្ព័ន្ធនៃការគ្រប់គ្រងផ្ទៃក្នុង ចំពោះសមាជិកនៃមន្ត្រីរាជការនៅក្នុងស្រុកល្វាឯម ដែលក្នុងនោះមានការរៀបចំនូវបទបញ្ជាផ្ទៃក្នុង និងការគោរពនូវតួនាទី ភារកិច្ច របស់ខ្លួននៅតាមឋានៈនៃមុខងារដែលត្រូវបំពេញ។ ព្រមទាំងការិយាល័យរដ្ឋបាលទូទៅ និងហិរញ្ញវត្ថុហើយការិយាល័យផែនការនិងគាំទ្រឃុំ និងការិយាល័យអន្តរវិស័យក្នុងការជួយបន្ថែមនូវការពង្រឹងនូវកិច្ចការអភិវឌ្ឍក្នុងស្រុកល្វាឯមផងដែរ។ ជាពិសេសមន្ត្រីការិយាល័យជំនាញទាំងអស់បានជួយបំពេញភារកិច្ចរបស់ខ្លួននូវផ្នែកផ្សេងៗពីគ្នាដើម្បីជួយដល់ការគ្រប់គ្រងអោយប្រសើរឡើងជាមួយនិងពាក្យថា "**អភិបាលកិច្ចល្អនៅក្នុងស្រុក**" ។[13]

### ២.២.១ ការិយាល័យចំណុះសាលាស្រុក

❖ **ការិយាល័យកសិកម្ម**

ក្នុងការិយាល័យនេះ មានការទទួលបន្ទុកយ៉ាងសំខាន់សម្រាប់ការផ្គត់ផ្គង់ ស្បៀងអាហារ ជាពិសេសគឺដំណាំស្រូវ និងបន្លែបង្ការគ្រប់ប្រភេទដែលមាន លោក **ញ៉ែម សារ៉ន** ជាប្រធាន និង លោក **ហង្ស សម័យ** ជាអនុប្រធាន។ ចំពោះភារកិច្ចរបស់ពួកគាត់ចុះតាមដានក្រុមបណ្តុំ ទាំង១២បន្ត និងចុះតាមដានការអនុវត្តដាំដុះរបស់កសិករនិងបញ្ហាប្រឈមផ្សេងៗ។ ដើម្បីពង្រឹងនូវការដាំដុះលើដំណាំគ្រប់ប្រភេទនៅក្នុងស្រុកល្វាឯម ជាពិសេសគឺដំណាំកសិកម្មសម្រាប់ប្រជាពលរដ្ឋទទួលបាននូវ ទិន្នផលខ្ពស់ក្នុងការដាំដុះ លើការអនុវត្តការងារហើយក្នុងនោះការិយាល័យនេះបានជួយបណ្តុះបណ្តាលនូវចំណេះដឹងបន្ថែមចំពោះពលរដ្ឋដែលមិនសូវមានបទពិសោធន៍ដែលបានសហការជាមួយអង្គការស៊ីវិលនានាដើម្បី ជួយអភិវឌ្ឍស្រុកល្វាឯម អោយកាន់តែជឿនលឿននាពេលអនាគតអោយពលរដ្ឋទទួលបានភាពរីកចម្រើន។[14]

❖ **ការិយាល័យរិយាល័យផែនការ**

[13] មាត្រា១៦៥ អនុក្រឹត្យលេខៈ២១៦.អនក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង ក្រុមប្រឹក្សា គណៈអភិបាលស្រុក

[14] មាត្រា១១៦ អនុក្រឹត្យលេខៈ២១៦.អនក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង ក្រុមប្រឹក្សា គណៈអភិបាលស្រុក

ក្នុងការិយាល័យនេះគឺបន្តធ្វើរបាយការណ៍ស្ថានភាពប្រែលប្រួលប្រចាំខែ ជូនទៅនាយករដ្ឋបាលហើយត្រូវបញ្ជូនទៅអភិបាលស្រុកល្វាឯម និងតាមដានការធ្វើទិន្នន័យតាមឃុំ ទាំង១៥ ប្រមូលទិន្នន័យត្រួតពិនិត្យ និងបញ្ជូនទៅមន្ទីផែនការខេត្ត។ សម្រាប់ការិយាល័យនេះមានលោកស្រី **ថេង សុធា** ជាប្រធាន និងជាអនុប្រធានផងដែរ។

❖ **ការិយាល័យបរិស្ថាន**

នៅក្នុងការិយាល័យនេះមាន លោក **សំ អុល** ជាប្រធានផង និងជាអនុប្រធានផងដែលមានតួនាទីចុះពិនិត្យ អប់រំណែនាំតាមបណ្ដាលសិប្បកម្មអាជីវកម្ម។ ម្យ៉ាងទៀតបានចុះពិនិត្យឃ្លាំមើលនៅតាមបណ្ដាលចំណុះទីតាំងដែលធ្លាប់បង្កើតសំណល់ សម្រាម បរិស្ថានខ្យល់ ទឹក សារធាតុពុល រឹងរាវ និងសម្លេង។ ការិយាល័យនេះមានការបណ្ដុះបណ្ដាលអោយប្រជាពលរដ្ឋចេះស្រលាញ់បរិស្ថាន និងរួមគ្នាថែរក្សានូវការបំពុលផ្សេងៗមកលើបរិស្ថាននិងអោយ ប្រជាពលរដ្ឋសហការជាមួយគណៈកម្មការថ្នាក់ស្រុក រកដំណោះស្រាយលើបញ្ហាសម្រាមដែលមានសារធាតុគីមីជាពិសេសថ្នាំសម្លាប់សត្វល្អិត ដែលប៉ះពាល់ដល់បរិស្ថាន។ លើសពីនេះទៅទៀតនៅទីប្រជុំជនតែម្ដងដែលមានការបំពុលច្រើននៅក្នុងផ្សារហើយមានការបោះចោលនូវកាកសំណល់មិនបានត្រឹមត្រូវ។

❖ **ការិយាល័យធម្មការនិង សាសនា**

ការិយាល័យនេះមាន លោក **ជុំ រតនៈ** ជាប្រធាន ដែលមានតួនាទីចូលរួមការប្រឡងយក វិញ្ញាប័ណ្ណប័ត្រ ថ្នាក់ត្រីទោឯកនៅមណ្ឌលប្រឡងស្រុក នឹងចុះតាមដានវត្តក្នុងស្រុកល្វាឯមដើម្បីត្រួតពិនិត្យរបាយការណ៍ស្ដីពីចំណូលចំណាយរបស់វត្តនីមួយៗ។ ហើយម្យ៉ាងទៀតជួយដោះស្រាយរាល់បញ្ហាដែលកើតមានឡើង រវាងអាចារ្យ និងព្រះសង្ឃ ឬ ព្រះសង្ឃ រវាង ព្រះសង្ឃ ដែលសហការជាមួយអនុគណស្រុកល្វាឯម និងរៀបចំនូវសណ្ដាប់ធ្នាប់នៃវត្តនីមួយៗអោយមានការគោរពប្រតិបត្តិចំពោះ ព្រះពុទ្ធសាសនា អោយបានត្រឹមត្រូវនៅក្នុងស្រុកហើយស្រុកល្វាឯមមានវត្តចំនួន ១៦ វត្ត ។

❖ **ការិយាអប់រំ យុវជន និង កីឡា**

ជាមួយការអប់រំ ចំពោះសិស្សសាលាស្រុកល្វាឯម មានការពង្រីកនូវចំណេះដឹងទៅដល់ពួកគេក្នុងការសិក្សានៅតាមសាលានានានៅក្នុងស្រុកល្វាឯម ហើយការិយាល័យនេះក៏បានជួយទៅដល់យុវជនដែលមិនទាន់បានចូលរៀននៅតាមសាលាដោយបង្កើតនូវវគ្គបណ្ដុះបណ្ដាលក្រៅប្រពន្ធ័សម្រាប់ជួយដល់ **អក្ខរកម្ម ។** ម្យ៉ាងទៀតក៏បានរៀបចំធ្វើជាសៀវភៅ ផែនការប្រតិបត្តិប្រចាំឆ្នាំ ២០២០ របស់ការិយាល័យអប់រំ យុវជន និងកីឡាស្រុកនិងសាលារៀន ព្រមទាំងធ្វើរបាយការណ៍សមិទ្ធិកម្មប្រចាំឆ្នាំ ២០១៩ ជូនមន្ទីអប់រំយុវជននិងកីឡាខេត្តបន្ទាប់មកទៀតចុះត្រួតពិនិត្យ តាមដាននិងវាយតម្លៃមត្តេយ្យសិក្សារដ្ឋនិងសហគមន៍ដែលមាន លោក **នូ វិសុទ្ធ** ជាប្រធាន និងលោកស្រី **កែវ សារៈ** ជាអនុប្រធានដែលបានចុះដឹកនាំផ្សព្វផ្សាយតាមមូលដ្ឋានអោយ ឪពុក-

ម្តាយនាំកូនទៅចុះឈ្មោះចូលរៀន។ ចំណែកវិស័យកីឡាវិញ ការិយាល័យនេះបានធ្វើការរៀបចំការប្រកួតជារៀងរាល់ឆ្នាំនូវ **កីឡាបាល់ទាត់ និង បាល់ទះ** ដើម្បីពង្រឹងនូវសុខភាព ឫកម្លាំងថាមពលសម្រាប់កូនសិស្សផងដែរ ជាពិសេសដើម្បីអោយសិស្សស្គាល់គ្នា និងរួបរួមសាមគ្គីគ្នាតាមរយៈការលេងកីឡាដើម្បីទ្រទ្រង់ជាតិជាមួយ និងការចេះសហការគ្នាក្នុងការប្រកួត ។

❖ **ការិយាល័យសង្គមកិច្ច អតីតយុវជន និងយុវនីតិសម្បទា**

ចំពោះការិយាល័យ នេះបានរៀបចំការងារចំពោះប្រជាពលរដ្ឋ ក្នុងការផ្តល់នូវជំនួយថវិកាទៅអោយទាហានដែលពិការមន្ត្រីរាជការដែលចូលនិវត្តន៍កុមារកំព្រានៅក្នុងស្រុកល្វាឯម ។ ក្នុងនោះមានលោកស្រី **សុខ គន្ធា** ជាមន្ត្រីការិយាល័យសង្គមកិច្ចដែលបានផ្សព្វផ្សាយ និងពង្រីកបន្ថែមសមាជិកសមាគមន៍អតីតយុទ្ធ-ជនបន្តការតាមដាន និងធ្វើសមាហរណកម្មកុមារជាមួយអង្គការនានា និងធ្វើសំណុំឯកសារផ្សេងៗជូនមុខសញ្ញាអតីតយុទ្ធជន ។

❖ **ការិយាល័យកិច្ចការនារី**

ដោយមើលឃើញចំពោះស្ត្រីដែលត្រូវមានការការពារពី បញ្ហាផ្សេងៗក្នុងនោះការិយាល័យមានតួនាទីក្នុងការផ្សព្វផ្សាយនូវ វិស័យយេនឌ័រ អំពីអំពើហិង្សានៅក្នុងគ្រួសារដោយអោយប្តីប្រពន្ធចេះយល់ចិត្តគ្នា។ ដោយមានលោកស្រី **អាង សំអាត** ជាប្រធាន និង លោកស្រី **យន លក្ខិណា** ជាអនុប្រធាន ។ ម្យ៉ាងវិញទៀតសម្រាប់ជួយដល់ស្ត្រីទៅលើការអភិវឌ្ឍគ្រួសារសុខភាព អនាម័យ ការការពារតាមផ្លូវច្បាប់ការសម្រេចចិត្ត ឫការលើកទឹកចិត្តនិងការលើកកម្ពស់ចំណេះដឹងផ្សេងៗដល់ស្ត្រីតាមរយៈការបណ្តុះបណ្តាល និងពន្យល់ណែនាំស្ត្រីកុំអោយងាយចាញ់បោកជនខិលខូចមួយចំនួនជាពិសេសលុបបំបាត់អំពើហិង្សានៅក្នុងគ្រួសារតែម្តង ដើម្បីជួយអោយមានការលុបបំបាត់ទាំងស្រុងនៅក្នុងស្រុកល្វាឯមតែម្តង ។

❖ **ការិយាល័យភូមិបាល**

ចំពោះការិយាល័យនេះមាន លោក **អ៊ុក ឡៀប** ជាប្រធាន និងលោក **ឈាន ម៉ាណ្ណនី** ជាអនុប្រធាននៅក្នុងការិយាល័យនេះមាន តួនាទីពន្លឿនការចុះបញ្ជីដីធ្លី និងពន្យល់ប្រជាពលរដ្ឋអោយចូលរួមក្នុងការចុះបញ្ជីដីធ្លីអោយបានច្រើនថែមទាំងណែនាំប្រជាជនអោយមានការយល់ដឹង អំពីការសុំច្បាប់សាងសងសំណង់ និងផ្សព្វផ្សាយច្បាប់ភូមិបាលអោយប្រជាជនយល់ដឹងកាន់តែច្បាស់។ លើសពីនេះទៅទៀត គឺបានជួយដោះស្រាយបញ្ហាដែលឈ្លោះប្រកែកគ្នាទៅលើទំនាស់ដីធ្លីនៅបណ្តាលឃុំមួយចំនួន ក្នុងនោះការិយាល័យបានរៀបចំវិធានការចំពោះប្រជាពលរដ្ឋដែលលង់តូប ឫផ្ទះសម្បែងដែលស្របតាមច្បាប់អោយរុះរើ និងដាកពិន័យចំពោះប្រជាពលរដ្ឋណាដែលមិនគោរព តាមបទបញ្ជារបស់សាលាស្រុកល្វាឯម ។

❖ **ការិយាល័យសាធារណៈការ និងដឹកជញ្ជូន**

បើមើលលើវិស័យដឹកជញ្ជូន មានការកើនឡើងខ្ពស់នៅក្នុងការិយាល័យនេះដែរដោយមាន លោក **នួន ប៊ុនធឿន** ជាប្រធាន។ ចំពោះវិស័យដឹកជញ្ជូននៅក្នុងស្រុកល្វាឯម ត្រួតពិនិត្យទៅលើស្លាកលេខបច្ចេកទេស និងការដឹកទំនិញលើស ទម្ងន់ របស់យានយន្តដែលដឹកទំនិញឆ្លងកាត់ស្រុកល្វាឯម និងយានយន្តដែលមិនមានស្លាកលេខ គឺស្រុកបានណែនាំដល់ពលរដ្ឋអោយចូលមក ធ្វើស្លាកលេខសម្គាល់យានយន្តរបស់ពួកគាត់ដើម្បីការពារពិបញ្ហា ចោរកម្ម ឫការប្លន់ពីឧក្រិដ្ឋជនដើម្បីងាយស្រួលរក្សាសន្តិសុខ និងងាយស្វែងរកយានយន្តនៅពេលមានបញ្ហាកើតឡើងម្តងៗនៅក្នុងស្រុករាល់ឆ្នាំ ។

- **ការិយាល័យអភិវឌ្ឍជនបទ**

ការិយាល័យនេះ ត្រូវបានរៀបចំឡើងដើម្បីរាល់ការធ្វើផែនការ ជាមួយការធ្វើសំណើទៅដល់មន្ទីរនៅសាលាខេត្តក្នុងការជួសជុលផ្លូវលំ និងផ្លូវដែលបានខូចខាត។ ជាមួយការរៀបចំនូវប្រព័ន្ធទឹកស្អាតការសាងសងបង្គន់អនាម័យដែលមានសហការជាមួយអង្គការនានាដែលបានជួយមកកាន់ស្រុកល្វាឯមដែលមាន លោក **ប៊ិត ចាន់តឿ** ជាប្រធាន និងលោក **សឿង រុន** ជាអនុប្រធានហើយការិយាល័យនេះបានចុះទៅទាំង ១៥ឃុំ ក្នុងការបណ្តុះបណ្តាល អោយយល់ដឹងពីការរស់នៅដោយមានអនាម័យសម្រាប់សុខភាពហើយបន្តការបើកវគ្គបណ្តុះបណ្តាលគណៈកម្មាធិការអភិវឌ្ឍភូមិ និងបានចុះផ្សព្វផ្សាយអំពីការភ្ជាប់បណ្តាញទឹកស្អាតជូនគ្រួសារក្រីក្រដែលស្ថិតនៅក្នុង ឃុំកោះកែវ និងឃុំសំបួរ ។

- **ការិយាល័យធនធានទឹក និង ឧតុនិយម**

លោក **មាស ណារិន** ជាប្រធាននៃការិយាល័យនេះដែលមានតួនាទីសម្រាប់ពិនិត្យ ឧតុនិយម ប្រព័ន្ធធារាសាស្ត្រ និងការអភិរក្សលើប្រព័ន្ធធារាសាស្ត្រ ។ លើសពីនេះទៅទៀតបន្តសហការជាមួយអាជ្ញាធរ ភូមិ ឃុំ ចុះពិនិត្យនិងតាមដានស្ថានភាពទឹកនៅតាមចំណុចប្រព័ន្ធធារាសាស្ត្រតាមបណ្តា ឃុំ ក្នុងស្រុកដើម្បីជួយអន្តរាគមន៍។ ម្យ៉ាងទៀតត្រូវសហការជាមួយមន្ទីរ និងក្រសួងធនធានទឹកបន្តស្តារ និងសាងសង់សំណង់ធារាសាស្ត្រនៅចំណុចទំនប់ជោជន់រាំងជាតាកេក្នុងឃុំល្វាសរ។ ប្រឡាយមេធ្យូងនៅក្នុង ឃុំពាមឧញ៉ាអុង តាមដានស្ថានភាពទឹកទន្លេ និងទឹកបឹងនៅពេលរដូវទឹកទន្លេមេគង្គឡើង ។

- **ការិយាល័យវប្បធម៌ និងវិចិត្រសិល្បៈ**

ការថែរក្សានូវទំនៀមទម្លាប់ប្រពៃណីរបស់ខ្មែរ ពិតជាមានសារៈសំខាន់ណាស់ហើយនៅក្នុងការិយាល័យនេះមាន លោក **ហែន តុលា** ជាប្រធានដែលមានតួនាទីសំខាន់ៗលើការផ្សព្វផ្សាយអប់រំទំនៀមទម្លាប់ដល់ប្រជាពលរដ្ឋ និងការថែរក្សាឫអភិរក្សនូវកន្លែងបុរាណ និងចុះត្រួតពិនិត្យស្រាវជ្រាវរកទួលបុរាណ និងអាស្រមដែលនៅក្នុងស្រុកល្វាឯម។ ជាមួយគ្នានេះដែលការិយាល័យនេះបានចុះផ្សព្វផ្សាយជំរុញអោយអាជីវករធ្វើច្បាប់ប្រកបអាជីវកម្មតាមយន្តការច្រកចេញចូលតែមួយ និងបន្តចុះតាមដានការហ្វឹកហាត់របស់ក្រុមល្ខោនខោលជារៀងរាល់

សប្តាហ៍និងចុះស្រង់ស្ថិតិទុក "ង" ធ្វើសំណើសុំចូលរួមប្រឡងប្រណាំងថ្នាក់ខេត្ត និងរាជធានីភ្នំពេញ។

### ២.២.២ ការិយាល័យស្រុកប្រតិបត្តិ

លោក **អ៊ូ ច័ន្ទតារាមុន្នី** ជាប្រធានដែលមានតួនាទី ចំពោះផ្នែកសុខាភិបាលនៅក្នុងស្រុកល្វាឯម ក្នុងនោះការិយាល័យនេះបានជួយចំពោះពលរដ្ឋដែលមានបញ្ហាលើជំងឺផ្សេងៗ ក្នុងការចាក់ថ្នាំបង្ការការពិគ្រោះជំងឺដែលមានការសង្ស័យ និងជួយសម្រាលកូនជូនពលរដ្ឋ។ ការិយាល័យនេះត្រូវមានការត្រួតពិនិត្យ យ៉ាងជិតដល់ចំពោះបញ្ហាជំងឺរាតត្បាតផ្សេងៗសម្រាប់ធ្វើការទប់ស្កាត់ និងរាយការណ៍មកក្រសួងដើម្បីជួយដោះស្រាយនៅពេលជួបប្រទះបញ្ហាទាំងអស់នេះ។

### ២.២.៣ មន្ទីរពេទ្យបង្អែកស្រុក

សកម្មភាពជារួមរបស់មន្ទីរពេទ្យ និងមណ្ឌលសុខភាពទាំង ១១ ក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋមានភាពសកម្ម មានការយកចិត្តទុកដាក់បង្កើនការទទួលខុសត្រូវព្រមទាំងមានការចូលរួមចំណែកក្នុងការបម្រើសេវាជូនប្រជាពលរដ្ឋប្រកបដោយវិជ្ជាជីវៈ។ ផ្នែកសុខភាពនៅក្នុងស្រុកល្វាឯម គឺទទួលបាននូវការថែរក្សាពីសេវាសាធារណៈសម្រាប់តាមដាននូវមុខជំងឺផ្សេងៗ ដែលអាចកើតមានដូចជាការពិនិត្យផ្ទៃពោះមុនពេលសម្រាល និងពិនិត្យថៃទាំក្រោយពេលសម្រាល។ សព្វថ្ងៃនៅស្រុកល្វាឯម មានការផ្តល់ថ្នាំបង្ការគ្រប់មុខដល់កុមារមានដូចជា៖ ផ្តល់ថ្នាំជីវជាតិអា ដល់កុមារថ្នាំជាតិដែកដល់ស្ត្រី និងកុមារថ្នាំបង្ការតេតាណូសដល់ស្ត្រីមានផ្ទៃពោះ ថ្នាំបង្ការតេតាណូសដល់ស្ត្រី អាយុ១៥-៤៤ឆ្នាំថ្នាំទម្លាក់សត្វល្អិតដល់ស្ត្រី និងកុមារ។ មន្ទីរពេទ្យ និងមណ្ឌលសុខភាពចុះធ្វើការអប់រំសុខភាពដល់ សហគមន៍ និងផ្តល់យុទ្ធនាការណ៍ពិនិត្យវះកាត់ភ្នែកក្រោមកិច្ចសហការជាមួយមន្ទីរពេទ្យជ័យជំនះ និងកម្មវិធីជាតិសុខភាពភ្នែក។ ម្យ៉ាងទៀតមណ្ឌលសុខភាពបានធ្វើយុទ្ធនាការណ៍ផ្តល់ថ្នាំជីវជាតិអា និងថ្នាំទម្លាក់ព្រូនដល់កុមារ អាយុក្រោម៥ឆ្នាំទូទាំងស្រុកល្វាឯម។ លើសពីនេះទៅទៀតមណ្ឌលសុខភាពបានផ្តល់ថ្នាំអាល់បេតសម្លាប់ដង្កូវទឹកដល់ប្រជាពលរដ្ឋ ១៣ ឃុំ និងផ្តល់ថ្នាំបន្ថែមដល់កុមារក្រោមអាយុ ១ឆ្នាំទូទាំងស្រុកល្វាឯម ។

## ២.៣ ការទំនាក់ទំនងជាមួយស្ថាប័នផ្សេងៗ

### ២.៣.១ ការទំនាក់ទំនងពីថ្នាក់ស្រុកទៅខេត្ត

ក្រៅពីការទំនាក់ទំនងនានាដែលបានកំណត់ក្នុង តួនាទី ភារកិច្ច និងរបៀបរបបការងាររបស់ក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្តកណ្តាល ក្រុមប្រឹក្សាស្រុកល្វាឯម គណៈអភិបាលស្រុកល្វាឯម រដ្ឋបាលខេត្តកណ្តាល រដ្ឋបាលស្រុកល្វាឯម ត្រូវមានការទំនាក់ទំនងមួយចំនួនរួមមាន ៖

- ក្រុមប្រឹក្សាខេត្តកណ្តាល ត្រូវសហការជាមួយក្រុមប្រឹក្សាស្រុកល្វាឯមដើម្បីពិគ្រោះយោបល់ជាមួយក្រុម-ប្រឹក្សាឃុំដែលស្ថិតនៅក្នុងខេត្តកណ្តាល ក្នុងគោលបំណងឆ្លើយតបតម្រូវការចាំបាច់របស់ក្រុមប្រឹក្សាឃុំនីមួយៗ

ដើម្បីអភិវឌ្ឍនៅក្នុងស្រុកល្វាឯម ។

- គណៈអភិបាលខេត្តកណ្តាល គណៈអភិបាលស្រុកល្វាឯម ត្រូវមានភារកិច្ចអនុវត្តកិច្ចការងាប្រចាំថ្ងៃនៅក្នុងការទំនាក់ទំនងទៅវិញទៅមករវាងខេត្តកណ្តាល ស្រុកល្វាឯមក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន ។
- ក្រុមប្រឹក្សាខេត្តកណ្តាល ត្រូវបានទទួលការធ្វើប្រតិភូកម្មអំណាច ក្នុងនាមរាជរដ្ឋាភិបាលដើម្បីផ្តល់ការគាំទ្រ និងការត្រួតពិនិត្យនីត្យានុកូលភាពលើសេចក្តីសម្រេច និងសកម្មភាពរបស់ស្រុកល្វាឯមដើម្បីធានាថារដ្ឋបាលស្រុកល្វាឯមបានបំពេញមុខងារ និងភារកិច្ចដែលបានប្រគល់ឬបានធ្វើប្រតិភូកម្មស្របតាមរដ្ឋធម្មនុញ្ញច្បាប់លិខិតបទដ្ឋានគតិយុត្តនានា និងស្របទៅតាមគោលនយោបាយរបស់ជាតិ។ ចំពោះការធ្វើប្រតិភូកម្មនេះរួមមានៈ

- ការវាយតម្លៃ និងការរៀបចំយុទ្ធសាស្ត្រសមស្របសម្រាប់ការគាំទ្រខាងសមត្ថភាពដល់ ក្រុមប្រឹក្សាស្រុកល្វាឯមព្រមទាំងបុគ្គលិកនៃក្រុមប្រឹក្សាស្រុកល្វាឯម
- ការណែនាំ និងសម្របសម្រួលការគាំទ្រដល់ក្រុមប្រឹក្សាស្រុកល្វាឯម និងការអនុវត្តមុខងារភារកិច្ចនិងធនធានដែលបានប្រគល់អោយស្របទៅតាមច្បាប់លិខិតបទដ្ឋានគតិយុត្តនានា និងគោលនយោបាយរបស់ថ្នាក់ជាតិត្រូវធានាថារដ្ឋបាលស្រុកល្វាឯម បានធ្វើការគាំទ្រយ៉ាងត្រឹមត្រូវដល់ឃុំនីមួយៗដែលស្ថិតនៅក្នុងស្រុកល្វាឯម ។
- ក្រុមប្រឹក្សាខេត្តកណ្តាល ត្រូវបំពេញតួនាទីខាងលើនេះលើមូលដ្ឋាននៃការធានាស្វ័យភាពរបស់ស្រុកល្វាឯមអោយស្របតាមគោលការណ៍នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំច្បាប់អនុក្រឹត្យ លិខិតបទដ្ឋានគតិយុត្តនានាព្រមទាំងការសម្រេចរបស់ គ. ជ. អ .ប

- ក្រុមប្រឹក្សាខេត្តកណ្តាល ត្រូវបានទទួលប្រតិភូកម្មពីរាជរដ្ឋាភិបាល ដើម្បីផ្តល់ការគាំទ្រការសម្របសម្រួលនិងការធ្វើសហប្រតិបត្តិការជាមួយ រដ្ឋបាលស្រុកល្វាឯម ដើម្បីរួមគ្នាសម្រេចអោយបាននូវគោលនយោបាយរបស់ថ្នាក់ជាតិ ។
- ក្រុមប្រឹក្សាខេត្តកណ្តាល ត្រូវធានារដ្ឋបាលស្រុកល្វាឯមត្រូវបំពេញមុខងារ និងភារកិច្ចដែលបានប្រគល់ឬបានធ្វើប្រតិភូកម្មអោយស្របទៅតាម រដ្ឋធម្មនុញ្ញ ច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តនានា និងគោលនយោបាយរបស់ជាតិ។
- ក្រុមប្រឹក្សាខេត្តកណ្តាល ក្រុមប្រឹក្សាស្រុកល្វាឯម និងក្រុមប្រឹក្សាឃុំ ដែលត្រូវមានព្រំប្រទល់ជាប់គ្នាត្រូវធ្វើទំនាក់ទំនងកិច្ចសហប្រតិបត្តិការ និងការពិគ្រោះយោបល់ និងការសម្របសម្រួលជាមួយគ្នាលើមុខងារនិងភារកិច្ចមួយឬច្រើន និងបញ្ហានានាដែលមានការពាក់ព័ន្ធគ្នា។

ក្រុមប្រឹក្សាស្រុកល្វាឯមមានសិទ្ធិអំណាច ក្នុងការធ្វើសេចក្តីសម្រេចនិងការចាត់ចែង មុខងារភារកិច្ច

និងធនធាននានាដែលបានប្រគល់ ឬបានធ្វើប្រតិភូកម្មស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការការគ្រប់គ្រងរដ្ឋបាល ឃុំ និងត្រូវធានាធ្វើអោយមានចីរភាពដល់ការអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យនៅក្នុងដែនសមត្ថកិច្ចរៀងៗខ្លួន។ ឯកសារលិខិតស្នាម ពីរាជរដ្ឋាភិបាលក្រសួងស្ថាប័ន នានាទៅ រដ្ឋបាលខេត្តកណ្តាល ស្រុកល្វាឯមត្រូវបញ្ជូនទៅខេត្តកណ្តាល។ ហើយក្នុងនោះអភិបាលខេត្ត កណ្តាលត្រូវធានាបែងចែក និងបញ្ជូនឯកសារលិខិតស្នាមទាំងនេះអោយបានត្រឹមត្រូវ និងទាន់ពេលវេលាដល់ ថ្នាក់រដ្ឋបាល ឬបុគ្គលិកដែលពាក់ព័ន្ធសម្រាប់ដាក់បង្ហាញអោយពលរដ្ឋដឹងជាសាធារណៈ។

### ២.៣.២ ការទំនាក់ទំនងពីថ្នាក់ស្រុកទៅ ឃុំ សង្កាត់

ក្រៅពីទំនាក់ទំនងនានាដែលបានកំណត់ក្នុងតួនាទី ភារកិច្ច និងការរៀបចំរបបការងាររបស់ក្រុមប្រឹក្សា ស្រុកល្វាឯម គណៈអភិបាលស្រុកល្វាឯម រដ្ឋបាលស្រុកល្វាឯមត្រូវមានទំនាក់ទំនងមួយចំនួនជាមួយរដ្ឋបាល ឃុំនីមួយៗរួមមានពីរចំណុចសំខាន់ៗគឺ ការគាំទ្ររបស់រដ្ឋបាលស្រុកល្វាឯមចំពោះឃុំទាំង ១៥ និងការទំនាក់ ទំនងរវាងរដ្ឋបាលស្រុកនិងរដ្ឋបាលឃុំ ។

**ក. ការគាំទ្ររបស់រដ្ឋបាលស្រុកល្វាឯមចំពោះឃុំទាំង ១៥**

- ដើម្បីបង្កើត និងជំរុញធ្វើអោយមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិតេយ្យ ក្រុមប្រឹក្សាស្រុក ល្វាឯម៖

- ជួយក្រុមប្រឹក្សាឃុំដែលស្ថិតនៅក្នុងស្រុកអោយ បង្កើត ជំរុញ និងធ្វើអោយមានចីរភាពដល់ការអភិវឌ្ឍ តាមបែបប្រជាធិតេយ្យ ។

- រួមជាមួយក្រុមប្រឹក្សាឃុំក្នុងស្រុក ដើម្បីជំរុញអោយមានការចូលរួម ពីសាធារណជនក្នុងដំណើរការ អភិបាលកិច្ចនៅក្នុងស្រុកល្វាឯម និងឃុំទាំង ១៥ ។

- ស្វែងយល់ និងឆ្លើយតបចំពោះតម្រូវការក្នុងស្រុកល្វាឯម និងចំពោះដំណើរការរបស់ក្រុមប្រឹក្សាស្រុក នីមួយៗ ។

- ដើម្បីអោយក្រុមប្រឹក្សាឃុំ នៅក្នុងស្រុកល្វាឯមមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលបានមុខងារនិង ធនធានកាន់តែច្រើនក្រុមប្រឹក្សាស្រុកល្វាឯម ត្រូវពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាឃុំដែលពាក់ព័ន្ធដើម្បី៖

- វាយតម្លៃសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ នីមួយៗយ៉ាងហោចណាស់មួយឆ្នាំម្តង

- ធ្វើការបណ្តុះបណ្តាលកសាងសមត្ថភាពដល់ក្រុមប្រឹក្សាឃុំ និងបុគ្គលិករបស់ក្រុមប្រឹក្សាឃុំដោយផ្អែក តាមការវាយតម្លៃខាងលើនេះ

- អប់រំផ្សព្វផ្សាយអំពីអភិបាលកិច្ចមូលដ្ឋានតាមបែបប្រជាធិបតេយ្យ និងវិមជ្ឈការ វិសហមជ្ឈការដល់

ប្រជាពលរដ្ឋដើម្បីលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើការ **អភិបាលកិច្ចល្អ** នៅក្នុងស្រុកល្វាឯម និងឃុំនីមួយៗដែលស្ថិតនៅក្នុងស្រុក

- ផ្អែកតាមការវាយតម្លៃសមត្ថភាព និងការពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាស្រុកល្វាឯមត្រូវសម្របសម្រួល និងគាំទ្រដល់ការបង្កើនសមត្ថភាពផ្នែករដ្ឋបាល ឬធនធានផ្នែករដ្ឋបាលដែលចាំបាច់ដល់ក្រុមប្រឹក្សា ឃុំ សម្តៅធានាអោយធនធានផ្នែករដ្ឋបាលគ្រប់គ្រាន់ និងមានជាអចិន្ត្រៃយ៍ដើម្បីៈ

- ជំរុញ និងធ្វើអោយមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ឬដើម្បីបំពេញមុខងារនិងភារកិច្ចចាំបាច់នានា ។

- បំពេញសមត្ថភាពផ្នែករដ្ឋបាល និងធនធានផ្នែករដ្ឋបាលរួមទាំងបុគ្គលិក ឧបករណ៍ ទ្រព្យសម្បត្តិនិងសម្ភារៈចាំបាច់នានា

- ក្នុងការរៀបចំចាត់ចែងបង្កើនសមត្ថភាពផ្នែករដ្ឋបាល ឬធនធានផ្នែករដ្ឋបាលនៅក្នុងឃុំ ក្រុមប្រឹក្សាស្រុកល្វាឯម អាចសម្របសម្រួលអោយមានការស្រុះស្រួលគ្នាក្នុងចំណោមក្រុមប្រឹក្សាឃុំ ដើម្បីប្រើប្រាស់រួមគ្នានូវបុគ្គលិកឧបករណ៍ ទ្រព្យសម្បត្តិ ឬសម្ភារៈខ្លះ ឬទាំងអស់តាមការចាំបាច់។ លើសពីនេះទៀតក្រុមប្រឹក្សាស្រុកល្វាឯមអាចធ្វើការពិគ្រោះយោបល់ និងសម្របសម្រួលជាមួយក្រុមប្រឹក្សាឃុំពាក់ព័ន្ធក្នុងការប្រើប្រាស់នូវបុគ្គលិករបស់រដ្ឋបាលស្រុកល្វាឯមដើម្បីជួយគាំទ្រធនធានផ្នែករដ្ឋបាល និងសមត្ថភាពផ្នែករដ្ឋបាលដល់រដ្ឋបាលឃុំ តាមការចាំបាច់ផងដែរ។ បុគ្គលិករបស់ស្រុកល្វាឯម ដែលបានចាត់អោយជួយគាំទ្រហើយត្រូវមានគណនេយ្យភាពចំពោះក្រុមប្រឹក្សាស្រុកអំពីការងារគោរព និងអនុវត្តភារកិច្ចស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា។

- ក្នុងករណីក្រុមប្រឹក្សាស្រុកល្វាឯម ត្រូវបានប្រឹងប្រែងសម្របសម្រួលបង្កើនសមត្ថភាពផ្នែករដ្ឋបាល ឬធនធានផ្នែករដ្ឋបាលដល់ក្រុមប្រឹក្សាឃុំរួចហើយ ក៏ប៉ុន្តែក្រុមប្រឹក្សាឃុំនោះនៅតែមិនអាចបំពេញភារកិច្ចជាមូលដ្ឋាន និងចាំបាច់របស់ខ្លួនបាន ឬមិនអាចជំរុញដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យអោយបានគ្រប់គ្រាន់ ក្រុមប្រឹក្សាស្រុកល្វាឯម ត្រូវពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាឃុំ ដើម្បីធ្វើសេចក្តីរាយការណ៍ជាលាយលក្ខណ៍អក្សរជាបន្ទាន់ទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដោយដាក់បញ្ចូលនូវអនុសាសន៍សមស្របដើម្បីកែតម្រូវកង្វះខាតទាំងនេះឬតម្រូវការចាំបាច់ណាមួយដែលក្រុមប្រឹក្សាស្រុកល្វាឯម និងក្រុមប្រឹក្សាឃុំមិនអាចបំពេញបាន។

**ខ. ការទំនាក់ទំនងរវាងរដ្ឋបាលស្រុក និងរដ្ឋបាលឃុំ**

ដើម្បីលើកកម្ពស់គណនេយ្យភាព របស់ក្រុមប្រឹក្សាស្រុកល្វាឯម ចំពោះប្រជាពលរដ្ឋរបស់ខ្លួនក្នុងការប្រើប្រាស់អំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិរបស់ខ្លួនក្រុមប្រឹក្សាស្រុកល្វាឯម ត្រូវបានរៀបចំអោយមានយន្តការពិគ្រោះពិភាក្សាជាមួយក្រុមប្រឹក្សាឃុំ ដែលស្ថិតនៅក្នុងស្រុកសំដៅធានាអោយបានថាជម្រើសសេចក្តីសម្រេច និងសកម្មភាពរបស់ក្រុមប្រឹក្សាស្រុកល្វាឯម មានការឆ្លើយតបចំពោះតម្រូវការជាអាទិភាពរបស់ក្រុមប្រឹក្សាឃុំ

ដែលនៅក្នុងស្រុកនិងប្រជាពលរដ្ឋទាំងអស់ក្នុងស្រុកល្វាឯម។ ដើម្បីលើកកម្ពស់ការផ្តល់សេវា និងការអភិវឌ្ឍ ក្រុមប្រឹក្សាស្រុកល្វាឯមត្រូវធានាអោយមានកិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលគ្នា រវាង ក្រុមប្រឹក្សាឃុំ ដែលស្ថិតនៅក្នុងស្រុក រវាង ក្រុមប្រឹក្សាស្រុកល្វាឯមជាមួយក្រុមប្រឹក្សាឃុំ ព្រមទាំងកិច្ចសហប្រតិបត្តិការ រវាង ក្រុមប្រឹក្សាស្រុកល្វាឯមជាមួយក្រុមប្រឹក្សា ដែលមានព្រំប្រទល់ជាប់គ្នា និងក្រុមប្រឹក្សាប្រភេទផ្សេងទៀត។ ក្នុង នោះក្រុមប្រឹក្សាស្រុកល្វាឯមត្រូវធ្វើការ ពិគ្រោះពិភាក្សាជាមួយក្រុមប្រឹក្សាឃុំដើម្បីដាក់បញ្ចូលយុទ្ធសាស្ត្រកម្មវិធី និងសកម្មភាពសម្រាប់ឆ្លើយតបតម្រូវការ និងសំណើររបស់ក្រុមប្រឹក្សាឃុំក្នុង២ចំណុចគឺទី១ **ផែនការអភិវឌ្ឍរយៈពេលប្រាំឆ្នាំក្រុមប្រឹក្សាស្រុកល្វាឯម និងផែន ការអភិវឌ្ឍរយៈពេលប្រាំឆ្នាំរបស់ក្រុមប្រឹក្សាឃុំ** ទី២ **កម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាល្វាឯម និងកម្មវិធីវិនិយោគប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាឃុំ**។ ជាមួយគ្នានេះដែរក្រុមប្រឹក្សាស្រុកល្វាឯម ត្រូវធ្វើការពិគ្រោះពិភាក្សាជាមួយក្រុមប្រឹក្សាឃុំដើម្បីរៀបចំដាក់បញ្ចូល និងឆ្លុះបញ្ចាំងទៅវិញទៅមកនូវគម្រោងថវិកាប្រចាំឆ្នាំ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមរបស់ក្រុមប្រឹក្សាស្រុកល្វាឯមនិងរបស់ក្រុមប្រឹក្សាឃុំ ដើម្បីអោយស្របតាមបែបបទនីតិវិធីនៃការរៀបចំថវិកាប្រចាំឆ្នាំ និងការរៀបចំក្របខ័ណ្ឌចំណាយរយៈពេលមធ្យមរបស់ស្រុកល្វាឯម និងឃុំនានា។ ក្រុមប្រឹក្សាស្រុកល្វាឯម ត្រូវចាត់សមាជិកក្រុមប្រឹក្សាស្រុក មួយរូប ឬច្រើនរូប អោយធ្វើជាតំណាងក្រុមប្រឹក្សាស្រុកល្វាឯមដើម្បីចូលរួមកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ ដែលស្ថិតនៅក្នុងស្រុកល្វាឯម។ តំណាងដែលចូលរួមប្រជុំនេះត្រូវជម្រាបជូនក្រុមប្រឹក្សាឃុំអំពីសកម្មភាពនិងការសម្រេចនានារបស់ក្រុមប្រឹក្សាស្រុកល្វាឯម និងការស្រាយបំភ្លឺលើបញ្ហានានា ដែលស្នើឡើងដោយក្រុមប្រឹក្សាឃុំ ព្រមទាំងប្រមូលយកនូវសំណើរសំណូមពរ និងបញ្ហាប្រឈមនានារបស់ឃុំដែលក្រុមប្រឹក្សាឃុំ មិនអាចដោះស្រាយបាន។ សមាជិកក្រុមប្រឹក្សាស្រុកល្វាឯមដែលចាត់អោយចូលរួមប្រជុំជាមួយក្រុមប្រឹក្សាឃុំ ត្រូវធ្វើសេចក្តីរាយការណ៍ជាលាយលក្ខណ៍អក្សរអំពីការចូលរួមប្រជុំខាងលើនេះដោយរួមបញ្ចូលទាំង សំណើសំណូមពរ និងបញ្ហាប្រឈមនានាដែលបានលើកឡើងដោយក្រុមប្រឹក្សាឃុំ។ សេចក្តីរាយការណ៍នេះត្រូវ បញ្ជូនមកគណៈអភិបាលស្រុកល្វាឯម ដើម្បីធ្វើការពិនិត្យនិងដោះស្រាយជាបន្ទាន់នូវសំណើសំណូមពរឬបញ្ហាប្រឈមទាំង ឡាយណាដែលស្ថិតក្នុងក្របខ័ណ្ឌតួនាទី សមត្ថកិច្ចរបស់គណៈអភិបាល។ ចំពោះសំណើសំណូមពរ និងបញ្ហាប្រឈមទាំងឡាយណាដែលស្ថិតក្នុងក្របខ័ណ្ឌ តួនាទីសមត្ថកិច្ចរបស់ក្រុមប្រឹក្សាគណៈអភិបាលត្រូវចាត់ចែងធ្វើការសិក្សាពិគ្រោះយោបល់រៀបចំបែបបទដើម្បីដាក់ជូនក្រុមប្រឹក្សាពិនិត្យសម្រេច។ ចំណែកតំណាងក្រុមប្រឹក្សាស្រុកល្វាឯមដែលចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាឃុំ ត្រូវគោរពបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ និងមិនមានសិទ្ធិអនុម័តនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាឃុំបានឡើយ។ មេឃុំក្នុងនាមក្រុមប្រឹក្សា របស់ខ្លួនមានសិទ្ធិចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាស្រុកល្វាឯមដើម្បីធ្វើការផ្តល់យោបល់ និងលើកសំណូមពរលើកិច្ចការណាមួយដែលពាក់ព័ន្ធផលប្រយោជន៍នៃឃុំរបស់ខ្លួនជូនក្រុមប្រឹក្សាស្រុកល្វាឯម ដើម្បីអោយក្រុមប្រឹក្សាពិនិត្យពិចារណា

មុននិងស្រុកធ្វើការសម្រេចលើកិច្ចការនោះ។ មេឃុំដែលចូលរួមប្រជុំក្នុងកិច្ចប្រជុំក្រុមប្រឹក្សាស្រុកល្វាឯមត្រូវគោរពបទបញ្ជាផ្ទៃក្នុងនៃកិច្ចប្រជុំ និងមិនមានសិទ្ធិអនុម័តក្នុងកិច្ចប្រជុំក្រុមប្រឹក្សាស្រុកល្វាឯមបានឡើយ។ ក្នុងនោះមេឃុំត្រូវរាយការណ៍ជូនក្រុមប្រឹក្សារបស់ខ្លួន និងត្រូវធ្វើការផ្សព្វផ្សាយជូនប្រជាពលរដ្ឋអំពីសេចក្ដីសម្រេចនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាស្រុកល្វាឯម។ បញ្ជាក់អោយដឹងបន្ថែមថាក្នុងដំណើរមការគាំទ្រ និងជួយបំពេញសមត្ថភាពផ្នែករដ្ឋបាលឬធនធានផ្នែករដ្ឋបាលដល់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាឃុំក្រុមប្រឹក្សាស្រុកល្វាឯមត្រូវមាន២ចំណុចសំខា-ន់ៗគឺទី១ ធានាអំពីគោលការណ៍ស្វ័យភាពរបស់ក្រុមប្រឹក្សាឃុំ ដែលត្រូវបានប្រជាពលរដ្ឋបោះឆ្នោតជ្រើសរើសឡើងដោយផ្ទាល់ ទី២ លើកកម្ពស់ភាពជាម្ចាស់ដល់ក្រុមប្រឹក្សាឃុំ ក្នុងការបំពេញមុខងារ និងភារកិច្ចចាំបាច់មួយឬច្រើនទៅតាមឃុំនីមួយៗដោយមិនត្រូវធ្វើជំនួសនោះឡើយ។

### ២.៣.៣ ការទំនាក់ទំនងពីថ្នាក់ស្រុកទៅក្រសួង និងស្ថាប័ន

ចំពោះការទំនាក់ទំនងរវាងរដ្ឋបាលស្រុកល្វាឯម ជាមួយក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលជាមួយក្រុមប្រឹក្សាស្រុកល្វាឯមត្រូវស្ថិតនៅក្នុងក្របខ័ណ្ឌ នៃអំណាចប្រតិបត្តិរបស់ជាតិ។ នៅក្នុងក្របខណ្ឌនៃអំណាចប្រតិបត្តិរបស់ជាតិ និងរាជរដ្ឋាភិបាលមានសិទ្ធិណែនាំ និងត្រូវពិនិត្យនីត្យានុកូលភាពនៃការសម្រេច និងការធ្វើសកម្មភាពរបស់ក្រុមប្រឹក្សាដើម្បីធានាអោយបានថាក្រុមប្រឹក្សាគោរពយ៉ាងត្រឹមត្រូវនូវរដ្ឋធម្មនុញ្ញ ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងគោលនយោបាយរបស់ជាតិ។ ដោយស្ថិតនៅក្នុងការអនុវត្តការងារប្រចាំថ្ងៃគណៈអភិបាលខេត្តកណ្ដាលគឺ ជាខ្សែរយៈទំនាក់ទំនងទៅវិញទៅមករវាងរដ្ឋាភិបាល ក្រសួង ស្ថាប័ននានានៃរដ្ឋាភិ-បាលជាមួយរដ្ឋបាលស្រុកល្វាឯម ព្រមទាំងការគាំទ្រដល់រដ្ឋបាលស្រុកល្វាឯមដែលស្ថិតនៅក្នុងខេត្តកណ្ដាល។ ចំពោះក្រសួង ស្ថាប័ននានាអាចធ្វើការទំនាក់ទំនងកិច្ចសហការដោយផ្ទាល់ជាមួយរដ្ឋបាលស្រុកល្វាឯមតាមការចាំបាច់ប៉ុន្តែត្រូវជូនដំណឹងដល់រដ្ឋបាលខេត្តកណ្ដាល។ ក្នុងនោះក្រសួងស្ថាប័ននានាអាចធ្វើការទំនាក់ទំនងនិងកិច្ចសហការដោយផ្ទាល់ជាមួយរដ្ឋបាលស្រុកល្វាឯម តាមការចាំបាច់ប៉ុន្តែត្រូវជូនដំណឹងដល់រដ្ឋបាលខេត្តក-ណ្ដាល។ នៅក្នុងចំណែកក្រសួងមហាផ្ទៃត្រូវធ្វើការសម្របសម្រួលដោះស្រាយស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា នៅពេលមានភាពមិនចុះសម្រុងគ្នារវាងរដ្ឋបាលខេត្តកណ្ដាលជាមួយរដ្ឋបាលស្រុកល្វាឯមហើយ គ.ជ.អ.ប ត្រូវសម្របសម្រួលដោះស្រាយផ្អែកតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា នៅពេលមានភាពមិនចុះសម្រុងគ្នារវាងក្រសួង ស្ថាប័ននានារបស់រដ្ឋាភិបាលជាមួយក្រុមប្រឹក្សាស្រុកល្វាឯម ដែលនៅក្នុងខេត្តកណ្ដាល។ ក្នុងករណីមិនអាចសម្របសម្រួលដោះស្រាយបាន គ.ជ.អ.ប ត្រូវធ្វើសេចក្ដីរាយការណ៍ជូនប្រមុខរដ្ឋាភិបាលពិនិត្យនិងសម្រេច។ចំពោះក្រុមប្រឹក្សាខេត្តកណ្ដាលត្រូវធានាអោយមានការពិគ្រោះយោបល់សមស្របជាមួយ រដ្ឋបាលស្រុកល្វាឯម នៅក្នុងខេត្តកណ្ដាលសម្រាប់ជាមូលដ្ឋានក្នុងការពិគ្រោះពិភាក្សាជាមួយ គ.ជ.អ.ប និងក្រសួង ស្ថាប័ននានាអំពីការបែងចែកមុខងារធនធានទ្រព្យសម្បត្តិការគ្រប់គ្រង និងការកៀងគររកចំណូល

ព្រមទាំងការកែសម្រួលឡើងវិញនូវបុគ្គលិកថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។ បើផ្អែកតាមការសម្រេចរបស់ គ.ជ អ.ប ក្រុមប្រឹក្សាខេត្តកណ្ដាល ត្រូវធានាធ្វើការសម្របសម្រួលជាមួយរដ្ឋបាលស្រុកល្វាឯម ដើម្បីបែងចែកមុខងារ ធនធានទ្រព្យសម្បត្តិការគ្រប់គ្រង និងកៀតគរចំណូលព្រមទាំងបុគ្គលិកអោយបានសមស្របតាមស្ថានភាពជាក់ស្តែងនៃតំបន់នីមួយៗរួមទាំងតំបន់ប្រជុំជន និងតំបន់ជនបទដែល ស្ថិតនៅក្នុងខេត្តកណ្តាល។ ចំពោះក្រសួងស្ថាប័ននានាត្រូវចូលរួម និងគាំទ្រយ៉ាងសកម្មចំពោះដំណើរការនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមរយៈនយោបាយ វិមជ្ឈការ និងសហវិមជ្ឈការ នៅថ្នាក់ស្រុកល្វាឯមហើយក្រសួង ស្ថាប័ននីមួយៗត្រូវធ្វើការប្រគល់ និងធ្វើប្រតិភូកម្មមុខងារ និងភារកិច្ចសមស្របដោយភ្ជាប់ជាមួយនូវធនធានហិរញ្ញវត្ថុបុគ្គលិក និងសមត្ថភាពទៅអោយក្រុមប្រឹក្សាស្រុកល្វាឯម។ ក្នុងនោះក្រសួងស្ថាប័ននានាត្រូវទទួលខុសត្រូវក្នុងការកំណត់គោលនយោបាយសម្រាប់វិស័យរបស់ខ្លួនទូទាំងប្រទេសការដាក់ចេញលិខិតបទដ្ឋានគតិយុត្ត ដើម្បីកំណត់អំពីបែបបទនីតិវិធីសម្រាប់ក្រុមប្រឹក្សាស្រុកល្វាឯមត្រូវអនុវត្តមុខងារដែលបានប្រគល់ ឬបានធ្វើប្រតិភូកម្ម។

### ២.៣.៤ ការទំនាក់ទំនងជាមួយកងកម្លាំងប្រដាប់អាវុធ

ចំពោះសកម្មភាពនៃការទំនាក់ទំនងជាមួយអធិការនគរបាលស្រុក មេបញ្ជាការកងរាជអាវុធហត្ថស្រុក និង មេបញ្ជាការរងស្រុកគឺត្រូវបានរៀបចំនូវសណ្តាប់ធ្នាប់សន្តិសុខ ការធានាបាននូវសុខសុវត្ថិភាពរបៀបរៀបរយសង្គម និងភាពសុខសាន្តជូនប្រជាពលរដ្ឋ នៅក្នុងស្រុកទាំងមូល។ ការធ្វើទំនាក់ទំនងរវាងគណៈអភិបាលស្រុកល្វាឯម **ចារកម្ម សភាពការណ៍អសន្តិសុខនានា** ជាពិសេសគឺ **ក្មេងទំនើង** ដែលអាចបង្កអោយមានភាពមិនល្អនៅតាមទីសាធារណៈ។ ដូច្នេះហើយទើបគណៈអភិបាលស្រុកល្វាឯមបានបង្កើតបញ្ជាការឯកភាពស្រុកល្វាឯម ឡើងក្នុងការផ្តល់ភាពសុខសាន្តដល់ប្រជាពលរដ្ឋរស់នៅក្នុងស្រុកតែម្តងដើម្បីអោយស្របតាមគោលនយោបាយ «**ភូមិឃុំមាន សុវត្ថិភាព**» ហើយសមាសភាពដែលត្រូវបានចូលរួមក្នុងការអនុវត្តនូវសកម្មភាពការងារនេះរួមមាន៖

| | |
|---|---|
| ១. លោក **ភឹម ភីរ៉ា** ជាអភិបាលស្រុក | ជាប្រធាន |
| ២. លោក **កន សុកាយ** ជាអភិបាលរងស្រុក | ជាអនុប្រធាន |
| ៤. លោក **វរៈសេនីយ៍ត្រី ហេង សុផល** ជាអធិការនគរបាលស្រុក | សមាជិកអចិន្ត្រៃយ៍ |
| ៥. លោក **វរៈសេនីយ៍ឯក ហាយ សុភាន** ជាមេបញ្ជាការកងរាជអាវុធហត្ថស្រុក | ជាសមាជិក |
| ៦. លោក **វរៈសេនីយ៍ត្រី ហួន ភារម្យ** ជាមេបញ្ជាការផ្នែកសឹករងស្រុក | ជាសមាជិក |
| ៧. លោក **ញឹក សាត** ជានាយករដ្ឋបាលសាលាស្រុក | ជាសមាជិក |
| ៨. លោក **ជួន តារាពង្ស** ជានាយករដ្ឋបាលរងសាលាស្រុក | ជាសមាជិក |

៩. លោក **មេឃុំ គ្រប់ឃុំ** ជាសមាជិក

គណៈបញ្ជាការឯកភាពទាំងនេះ គឺមានតួនាទី ភារកិច្ចសហការណ៍គ្នាចូលរួមក្នុងការកសាងកម្លាំងទប់ស្កាត់រាល់បញ្ហាកើតមានឡើង និងការអនុវត្តសកម្មភាពដូចតទៅនេះ ៖

- ធ្វើការសម្របសម្រួល និងចាត់ចែងរាល់កម្លាំងប្រដាប់អាវុធរបស់ស្រុកល្វាឯម និងចាត់ការងារដើម្បីឆ្លើយតបតាមសំណូមពរចាំបាច់នៃ ភារកិច្ច សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងបទល្មើសេដ្ឋកិច្ចនៅតាមមូលដ្ឋាន
- តាមដានក្តាប់អោយជាប់សភាពការណ៍សកម្មភាព មុខសញ្ញាចោរកម្ម ភេរវកម្ម ចោរកម្មដែលមានបំណងធ្វើសកម្មភាពក្នុងមូលដ្ឋានស្រុកល្វាឯម
- មានវិធានការគ្រប់គ្រងស្ថិតិប្រជាពលរដ្ឋចេញពីស្រុកចូលមកស្រុកស្នាក់នៅក្នុងលំនៅដ្ឋាន ភូមិ ឃុំ មូលដ្ឋានសិប្បកម្មអាជីវកម្មសំខាន់ៗមួយចំនួន និងការដ្ឋាននានានៅទូទាំងស្រុកល្វាឯមដើម្បីមានមូលដ្ឋានស្រាវជ្រាវរកឃើញមុខសញ្ញាប្រព្រឹត្តបទល្មើស ឬការបង្កអោយមានអសន្តិសុខនៅក្នុងដែនដីរបស់យើង
- បង្ការ និងបង្រ្កាបអោយទាន់ពេលវេលានូវកុងត្រូលជជុះសកម្មភាពលួច ឆក់ ប្លន់ប្រដាប់អាវុធកាប់សម្លាប់ ចាប់មនុស្សជំរិតយកប្រាក់អំពើរត់គេចពន្ធសំដៅការការពារអោយបានសុវត្ថិភាព និងសន្តិសុខជូនប្រជាពលរដ្ឋការពារផ្លូវគមនាគមន៍ ជើងគោក ជើងទឹកការពារសមិទ្ធផលសង្គមជាតិក្នុងភូមិសាស្ត្រទទួលខុសត្រូវរបស់ខ្លួនក្នុងការផ្តល់ប្រយោជន៍ជូនពលរដ្ឋ ជាពិសេសផ្តល់ជូនរដ្ឋាភិបាលក្នុងការដឹកនាំ
- មានវិធានការពង្រឹងមូលដ្ឋាន អំពីរបៀបរបបការងារលើគ្រប់ផ្នែកពិសេសពង្រឹងរដ្ឋអំណាច ភូមិ ឃុំ ពង្រឹងនគរបាលប៉ុស្តិ៍រដ្ឋបាលគ្រប់ឃុំ និងអនុវត្តអោយបានត្រឹមត្រូវតាមច្បាប់ អនុក្រឹត្យ ប្រកាស របស់ក្រសួងមហាផ្ទៃ និងបទដ្ឋាននានារបស់រាជរដ្ឋាភិបាល។

# ជំពូកទី៣

# សមិទ្ធផលដែលសម្រេចបាន និងចក្ខុវិស័យនៅក្នុងស្រុកល្វាឯម

ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាល និងជាមួយការសហការគ្នារបស់មន្ត្រីរាជការទាំងអស់ នៅក្នុងសាលាស្រុកល្វាឯមដោយស្ថិតនៅក្រោមការខិតខំប្រឹងប្រែងរបស់ គណៈអភិបាលស្រុក និងក្រុមប្រឹក្សាស្រុកជាមួយ និងសមាជិកទាំងឡាយដែលបានចូលរួមគ្នាក្នុងការអនុវត្តនូវភារកិច្ចតួនាទីរៀងៗខ្លួនដើម្បីសម្រេចបាននូវសមិទ្ធផលជាច្រើនសម្រាប់ជួយដល់ប្រជាពលរដ្ឋ ដែលរស់នៅក្នុងស្រុកល្វាឯមបច្ចុប្បន្នដើម្បីទទួលបាននូវការរីកចម្រើននាពេលអនាគតក្នុងការផ្តល់ជូនពលរដ្ឋ។

## ៣.១ សមិទ្ធផលដែលទទួលបាន

ការអនុវត្តតាមបែបប្រជាធិបតេយ្យ ធ្វើអោយស្រុកល្វាឯមទទួលបាននូវការអនុវត្ត នៅក្នុងការរស់នៅបានយ៉ាងល្អប្រសើរក្នុងនោះការអនុវត្តនូវ អភិបាលកិច្ចល្អ នៅក្នុងស្រុកធ្វើអោយមានការចូលរួមពីប្រជាពលរដ្ឋនិងជាមួយការទទួលបាននូវការរីកចម្រើនគ្រប់វិស័យ ជាច្រើនដែលវិស័យទាំងអស់នោះបានជំរុញអោយមានការអភិវឌ្ឍទៅតាម លំដាប់លំដោយពីមួយឆ្នាំទៅមួយឆ្នាំនៅក្នុងស្រុកល្វាឯម។

### ៣.១.១ វិស័យសេដ្ឋកិច្ច

នៅក្នុងស្រុកល្វាឯមគឺជា ទឹកដីដែលសម្បូទៅដោយព្រែកបឹងបួ ជាពិសេសមានទឹកទន្លេមេគង្គ ទន្លេតូចស្ថានភាពបែបនេះធ្វើអោយសម្បូរ ធនធានធម្មជាតិ ដីមានជីជាតិសម្រាប់ដាំដំណាំកសិកម្មហើយមានលក្ខណៈអំណោយផលយ៉ាងល្អប្រសើរដល់ការបង្កបង្កើនផលរបស់ប្រជាពលរដ្ឋនិងជាប្រភពសេដ្ឋកិច្ចដ៏សំខាន់របស់ស្រុកតែម្តង។ ក្នុងនោះស្រុកល្វាឯមមានស្ថានភាពធម្មជាតិទឹកភ្លៀងក្នុងមួយឆ្នាំមានភ្លៀងធ្លាក់ចំនួន៣៥ លើក ដែលមាន កម្ពស់១២៩៦,៩ម.ម ធៀបរយៈពេលដូចគ្នានិងឆ្នាំ២០១៨ ទាបជាង១៩៤,៤ម.ម។ ចំពោះផ្ទៃដីដែលបង្កបង្កើនផល ដំណាំស្រូវ ភ្ជួររាស់សរុបមានចំនួន ៧៨៨៧ហ.ត ហើយភាគច្រើនប្រជាពលរដ្ឋប្រកបមុខរបរកសិកម្មលើដំណាំស្រូវជាចម្បង និងមានមុខរបរបន្ទាប់បន្សំទៀតសម្រាប់ទ្រទ្រង់ជីវភាពប្រចាំថ្ងៃ ចំពោះផ្ទៃដីសម្រាប់ផលិតស្រូវវស្សាមាន ចំនួន ៨៥៥ ហិចតា ស្រូវប្រាំងមានចំនួន ៧០១៤ហិចតា ដែលមានផែនការសរុប ៧៨៦៩ហិចតា។ ចំណែកដំណាំ រួមផ្សំវិញចំពោះបន្លែគរប់មុខមាន ពោតក្រហម អនុវត្តបាន ១៣៩៩ ហិចតា ( ស្មើនិង៩៨.៦៦%នៃផែនការ ) សណ្តែកអនុវត្តបាន ២៦ហិចតា បន្លែចំរុះ អនុវត្តបាន ១១៦ហិចតា ( ស្មើនិង ៨៧,៨៧%នៃផែនការ ) ម្ទេស ៨ ហិចតា ស្លឹកគ្រៃ ២៥០ ហិចតា ចេក ៤៥ ហិចតា ល្ហុង ៧៣ ហិចតា ឈូក ៧៦៨ ហិចតា ( ស្មើនិង១០០%នៃ ផែនការ ) ដំណាំស្វាយកែវរមៀត ៧៧៤ហិចតា ដូង ២៣ ហិចតា ល្មុត ៤ ហិចតា និងដំណាំរួមផ្សំផ្សេងៗ ២៣ហិចតា។ ការប្រមូលផលស្រូវលើផ្ទៃដីចំនួន ៧៨៦៩ ហិចតា បរិមាណផល

សរុប ៣២,៦៧៩តោន និងការប្រមូលផលពោតលើផ្ទៃដីចំនួន ១៣៩៩ ហិចតា មានបរិមាណផលសរុប ៥៥៩៦ តោន។ ម្យ៉ាងវិញទៀតការដឹកជញ្ជូនក៏បានចូលរួមចំណែកយ៉ាងសកម្មក្នុងលការជំរុញនូវសេដ្ឋកិច្ចអោយមាន ការរីកចម្រើននៅក្នុងស្រុកល្វាឯម។ ដោយសារស្រុកល្វាឯមស្ថិតនៅជាប់រាជធានីភ្នំពេញខណ្ឌដោយទន្លេចតុមុខ បង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋធ្វើដំណើរនិងដឹកកសិផលទៅលក់នៅរាជធានីភ្នំពេញ។ ចំពោះការ ផ្តល់សេវាកម្មសម្រាប់បម្រើអោយប្រជាពលរដ្ឋវិញ គឺបានផ្តល់អោយនូវពាណិជ្ជកម្មមុខជំនួញកសិផលបន្លែបង្កា ផ្សេងៗ និងការងារគម្រោងអភិវឌ្ឍកសិកម្មដែលជំរុញកំណើនសេដ្ឋកិច្ចនិងបានធ្វើផែនការមុខរបរសមាជិកក្រុម ដើម្បីខ្ចីទុនមុខរបរបន្តសមាជិកក្រុមកែលម្អទុនបង្វិលបាន អនុវត្តបង់ការប្រាក់ដល់ក្រុមបានទៀងទាត់ប្រចាំខែ ក្រុមកែលម្អទុនបង្វិលទាំង ២៤ក្រុម មានការកើនឡើងនៃសាច់ប្រាក់ក្នុងក្រុមតាមរយៈការប្រាក់ប្រចាំខែរបស់ សមាជិកក្រុមដែលបានធ្វើការកម្ចីប្រកបមុខរបរកសិកម្មចន្លោះពី ៦៨លានរៀល ទៅ៧៨លានរៀលរបស់ក្រុម នីមួយដោយធៀប និងសាច់ប្រាក់ដើមមានចំនួនត្រឹមតែ ៤៨លានរៀលក្នុងមួយ ក្រុមៗ ( អត្រាកើន៧៧%ក្នុង រយៈពេល៥ឆ្នាំ )។ មន្ត្រីកសិកម្មស្រុកបានសហការជាមួយ មន្ត្រីការិយាល័យផ្សព្វផ្សាយកសិកម្មខេត្តនិង ផ្សព្វផ្សាយឃុំរៀបចំជ្រើសរើសកសិករចងក្រងក្រុមបណ្តុំចំនួន ១២ និងជួយអោយមានការកាត់បន្ថយនូវភាពក្រី-ក្ររបស់ប្រជាពលរដ្ឋក៏បានជួយកាត់បន្ថយនូវការលំបាកពីរដ្ឋាភិបាល ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចដល់ប្រទេសក៏ដូច ជាការបានចូលរួមចំណែកកាត់បន្ថយនូវការលំបាកនានារបស់ប្រជាពលរដ្ឋដែលធ្លាប់បាន ជួបប្រទះកាលពីមុន ដែលចំណុចទាំងអស់នេះទើបធ្វើអោយមានការពង្រឹងនូវការងារបន្ថែមជាលំដាប់នៅក្នុងស្រុក។

### ៣.១.២ វិស័យសង្គមកិច្ច

នៅទូទាំងស្រុកល្វាឯមគ្រប់ភូមិ ឃុំ មានការសិក្សាបានផ្តល់ឱកាសអោយយុវជន និងកុមារបានចូលរៀន ដែលប្រកបទៅដោយគុណភាពដែលមានសាលាមតេយ្យរដ្ឋចំនួន ២១សាលាមានកុមារចូលរៀនចំនួន ១,៤០១ នាក់ មានថ្នាក់ ៤១ថ្នាក់គ្រូមាន ៤០នាក់ និងមតេយ្យសហគមន៍មាន ២១កន្លែង មានអាគារសិក្សាចំនួន១២៧ ខ្នង ស្មើនឹង ៥៤៥បន្ទប់ ក្នុងនោះមានអាគារសិក្សាជាអំណោយដ៏ថ្លៃថ្លារបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែនចំនួន ៤៨ខ្នង ស្មើនឹង ២៥៩បន្ទប់ កុមារបានចូលរៀនចំនួន ៦៥១នាក់ ដែលមានគ្រូបង្រៀនចំនួន ២១ នាក់។ ចំពោះបឋមសិក្សាវិញមានចំនួន ៣៣កន្លែងមានថ្នាក់ ៣២៨ ថ្នាក់ មានបន្ទប់ ៣០២ ដែលមានគ្រូ ៣០៦នាក់ ដែល មានសិស្សចូលរៀន ១០,៤៨០នាក់ ។ ក្នុងនោះមានអនុវិទ្យាល័យ ១៤កន្លែង មានថ្នាក់ ៩០ ថ្នាក់ មានគ្រូ ២៣៤នាក់ ដែលមានសិស្សសរុប ៣,៣៥២នាក់ ដែលមានបន្ទប់រៀន ១០៨ បន្ទប់ ហើយមានវិទ្យា-ល័យ ៣កន្លែង មានថ្នាក់៣៥ថ្នាក់ មានគ្រូ ៨៨នាក់ ដែលមានសិស្សសរុប ១,៨២៤នាក់ដែលមានបន្ទប់៤១បន្ទប់ បើយើងសរុបទាំងវិទ្យាល័យ និងអនុវិទ្យាល័យសិស្សទាំងអស់មានចំនួន៥,១៧៦ ដែលមានមធ្យមភាគរួមវិទ្យា-

ល័យមានចំនួន២០.៧% និងអនុវិទ្យាល័យមានចំនួន ១៤.៣%។

ម្យ៉ាងវិញទៀតសុខាភិបាលមានមន្ត្រីរាជការចំនួន ៦៣នាក់ ដែលមានស្រុកប្រតិបត្តិ១កន្លែងមន្ទីរពេទ្យបង្អែក១កន្លែង ហើយមានមណ្ឌលសុខភាពចំនួន ១១កន្លែង និងមានគ្រែចំនួន ៦៣គ្រែ ដែលបានទទួលពិនិត្យពិគ្រោះជំងឺពលរដ្ឋ ៥៥,៤៨២ ។ ចំពោះសុខភាពបន្តពូជមាតា និងទារកបានពិនិត្យអ្នកមានផ្ទៃពោះ ៦,៩២១នាក់ និងមានសេវាសំរាកពេទ្យ ៤,៣៩៨ នាក់ បានផ្តល់ថ្នាំបង្ការគ្រប់មុខដល់កុមារមានចំនួន ២៨,៩៦១ចំណាក់ កុមារបានទទួលថ្នាំបង្ការគ្រប់មុខមានចំនួន ១,៨៧០ នាក់ហើយនៅក្នុងនោះក៏មានអ្នកកំពុងនិងប្រើប្រាស់សេវារបេង ដូតស៍ មានចំនួន ៤៣នាក់ បានធ្វើការស្រាវជ្រាវ សកម្ម ដើម្បីរក អ្នកផ្ទុករបេងមានចំនួន ១,៥៨៤នាក់ ការពិនិត្យ និងព្យាបាលជំងឺភ្នែកមានចំនួន ៧៨៥នាក់ ការពិនិត្យនិងព្យាបាល ធ្មេញមានចំនួន ៧៣៩នាក់ និងមានអ្នកកំពុងប្រើប្រាស់សេវាពន្យាកំណើតមានចំនួន ២,០៥៤ អ្នកកំពុងទទួលការ ថែទាំព្យាបាលជំងឺអេដស៍មានចំនួន ១៦៥នាក់ បានផ្តល់ថ្នាំបង្ការ តេតាណូសដល់ស្ត្រីមានផ្ទៃពោះមានចំនួន ២,១៦៩នាក់ ផ្តល់ថ្នាំជាតិដែកដល់ស្ត្រី និងកុមារមានចំនួន ៥,៤១៨នាក់ ផ្តល់ថ្នាំជីវជាតិអា កុមារមានចំនួន ២២,៥១១នាក់ ផ្តល់ថ្នាំទំលាក់សត្វល្អិតដល់ ស្ត្រី និងកុមារមានចំនួន ៦២,៧៩១នាក់ និងមណ្ឌលសុខភាពបានចុះធ្វើការអប់រំសុខភាពដល់សហគមន៍បានជាច្រើនផងដែរ។

ចំណែកសិប្បកម្ម អាជីវកម្មដែលជាមុខរបរសំខាន់ៗក្នុងស្រុកល្វាឯមចំពោះពលរដ្ឋរួមមាន តម្បាញក្រម៉ាសូត្រ ការផ្គត់ផ្គង់ទឹកស្អាត បណ្តាញអគ្គិសនី មុខរបរជំនួញសិប្បកម្ម បញ្ចូលអាគុយ ជាងកាត់ដេរ អ៊ុតសក់កាត់សក់បុរស-នារី ផ្លាកយីហោ សំអាងការ ចម្លាក់ពុម្ពស៊ីម៉ង់ត៍ និងជាងជួសជុល រថយន្ត កង់ម៉ូតូដែលជាមុខរបរបន្ទាប់បន្សំដើម្បីរកប្រាក់ចំណូលបន្ថែម ក្នុងការលើកស្ទួយកម្រិតជិវភាពរស់នៅរបស់ប្រជាពលរដ្ឋទូទាំងស្រុក។ ជាមួយគ្នានេះដែលវប្បធម៌ និងវិចិត្រសិល្បៈនៅក្នុងស្រុកល្វាឯមត្រូវមានការចុះត្រួតពិនិត្យ និងស្រាវជ្រាវរកទូលបុរាណ និងអាស្រមដែលជាមរតកដ៏ថ្លៃថ្លារបស់ដូនតាយើងពីជំនាន់ដើមតាំងពីសម័យនគរភ្នំ។ នៅក្នុងពេលបច្ចុប្បន្ននេះស្រុកល្វាឯម នៅសល់មរតកមួយចំនួនដែលសព្វថ្ងៃការិយាល័យវប្បធម៌ និងវិចិត្រសិល្បៈស្រុកបានចុះទៅស្រាវជ្រាវជារៀងរាល់ខែទៅស្វែងរកទូលបុរាណនិងអាស្រមស័ក្តិសិទ្ធិទូទាំងស្រុកល្វាឯម។ ហើយក្នុងនោះខាងវប្បធម៌បានចុះតាមដានសកម្មភាពនិងត្រួតពិនិត្យតាមដានការហ្វឹកហាត់របស់ក្រុមល្ខោនខោលជារៀងរាល់សប្តាហ៍និងបានចុះស្រង់ស្ថិតិទុក "ង" ធ្វើសំណើសុំចូលរួមប្រឡងប្រណាំងថ្នាក់ខេត្ត និងរាជធានីភ្នំពេញ។ វិស័យយេនឌ័រ ស្រុកបានរៀបចំនូវរចនាសម្ព័ន្ធដែលមានស្ត្រីចូលរួមក្នុងសមាជិកក្រុមប្រឹក្សាស្រុកចំនួន ៥នាក់ សមាសភាពគណៈតិទុក "ង" និងធ្វើសំណើសុំចុះចូលរួមប្រលងប្រណាំងថ្នាក់ខេត្ត និងរាជធានីភ្នំពេញ។ ចំពោះអភិបាលរង ១នាក់ ប្រធានការិយាល័យ ១នាក់ និងមេភូមិ ២នាក់ ជាស្ត្រី ហើយក្រុមប្រឹក្សាជានារី ៣នាក់។

នៅក្នុងនោះការងាររបស់ស្ត្រីនៅក្នុងស្រុកដែលបានដឹកនាំការងារផ្សេងៗ ដែលបានចុះទៅអនុវត្តសកម្មភាពនានានៅតាមឃុំ ទាំង១៥ ទូទាំងស្រុកល្វាឯមហើយនារីទាំងអស់នោះបានអនុវត្តការងារស្ថិតិ និងលទ្ធផលនៅតាមឃុំមួយចំនួនមានដូចជា ៖

- ធ្វើការផ្សព្វផ្សាយស្តីពី សុខុភាពមាតានិងទារក ជាមួយច្បាប់ស្តីអំពីអំពើហិង្សាក្នុងគ្រួសារ
- ធ្វើការផ្សព្វផ្សាយស្តីពី ការធ្វើចំណាក់ស្រុក និង យេនឌ័រ
- ធ្វើការផ្សព្វផ្សាយស្តីពី សុខភាពអនាម័យ និងច្បាប់ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ។

### ៣.១.៣ វិស័យដីធ្លី និងធនធានធម្មជាតិ និងបរិស្ថាន

នៅស្រុកល្វាឯម មានផ្ទៃដីសរុប ២៦០៩២ ម៉ែត្រការេ ក្នុងនោះផ្ទៃដីកសិកម្មមានចំនួន ១១៣៧៨ ហិកតាដីទាំងនោះមានជីវជាតិសម្រាប់ដំណាំកសិកម្ម ហើយប្រជាជនប្រមាណ ៨៥%ជាកសិករទន្ទឹមនិងសក្តា-នុពលនិងផលប្រយោជន៍ដូចបានរៀបរាប់ខាងលើនេះការគ្រប់គ្រងប្រើប្រាស់ដីធ្លីនៅមានបញ្ហាប្រឈមមួយចំនួនរួមមានការសាងសង់លំនៅដ្ឋានមិនគោរពតាមបទដ្ឋានបច្ចេកទេសសំណង់គ្មានច្បាប់អនុញ្ញាត បញ្ហាទំនាស់ដីធ្លីដីបានខ្សោះជីវជាតិពីមួយឆ្នាំទៅមួយឆ្នាំដោយសារដីព្រៃថយចុះ និងការទន្ទ្រានយកដីលិចទឹក និងដីបឹងកាន់តែរាក់រួមតូចៗទៅ ។

ចំណែកធនធានក្រៅពីដីធ្លីគឺស្រុកល្វាឯមមានព្រៃលិចទឹក ស្ទឹង បឹង និងទន្លេ ព្រៃក ធនធានទាំងនេះបានរួមចំណែកធ្វើអោយជីវភាពប្រជាពលរដ្ឋកាន់តែប្រសើរឡើងជារៀងរាល់ថ្ងៃ។ ដូចនេះហើយគណៈអភិបាលនិងក្រុមប្រឹក្សាស្រុកបាននាំគ្នាខិតខំថែរក្សា និងទប់ស្កាត់ការបំផ្លាញព្រៃឈើទាំងនេះពីពលរដ្ឋដែលខិលខូចដើម្បីទុកអោយប្រជាពលរដ្ឋ ទាញយកផលប្រយោជន៍ពីធនធានធម្មជាតិ អោយបានត្រឹមត្រូវលែងអោយមានការបំផ្លាញព្រៃលិចទឹកការទន្ទ្រានយកដី បឹង ស្ទឹង និងការនេសាទខុសច្បាប់បើសិនជាមានករណីនេះកើតឡើងស្រុកនិងយកជននោះមកដាក់ទោសកំហុសតាមផ្លូវច្បាប់បានហាមឃាត់ហើយមិនអោយមាន អំពើពុករលួយកើតឡើងនៅក្នុងស្រុកនាពេលបច្ចុប្បន្ន។ ពិព្រោះថាព្រៃលិចទឹកទាំងនោះទុកសម្រាប់ត្រីពង សម្រាប់បន្តពូជហើយក៏ជាជម្រកដ៏សំខាន់ ចំពោះសត្វស្លាបគ្រប់ប្រភេទ និងជាកន្លែងដែលធ្វើអោយមានភាពទាក់ទាញពីភ្ញៀវទេសចរណ៍ផងដែរ ។

ម្យ៉ាងវិញទៀត ការរៀបចំបរិស្ថាននៅក្នុងស្រុកល្វាឯមមានបរិស្ថានល្អ ដោយសារតែមានតំបន់វាលទំនាបដែលសម្បូរទៅដោយបឹងបួរ និងតំបន់លិចទឹកជាច្រើន ដែលទទួលបានឥទ្ធិពលពីតាមដងទន្លេមេគង្គដងទន្លេតូច ដែលសម្បូទៅដោយធនធានធម្មជាតិ។ ប៉ុន្តែនៅក្នុងស្រុកបច្ចុប្បន្ន ក៏នៅតែមានការទទួលរងគ្រោះយ៉ាងធ្ងន់ធ្ងរ ពិសេសលើជីវចម្រុះការបំពុលបរិយាកាស បណ្តាលមកពីការចោលកាកសំណល់ និងការប្រើប្រាស់ជីគីមី ថ្នាំបំពុល សត្វពុំបានត្រឹមត្រូវតាមបច្ចេកទេសរបស់ប្រជាពលរដ្ឋដែលបានធ្វើចំពោះដំណាំកសិកម្ម។ ដូច្នេះ

ហើយទើបលោក អភិបាលស្រុកល្វាឯម បានធ្វើការចុះណែនាំនិងត្រួតពិនិត្យផ្ទាល់ដល់ទីតាំងសិប្បកម្មអប់រំ និងផ្សព្វផ្សាយដល់ប្រជាពលរដ្ឋអោយពួកគាត់ចេះគ្រប់គ្រង សំណល់រឹង រាវ នៅតាមបណ្តាទីតាំង សិប្បកម្មផលិ-តទឹកកកបានចំនួន ៤លើក ស្មើ ៦មូលដ្ឋានឃុំ សិប្បកម្មផលិតទឹកត្រី បានចំនួន ៣លើក ស្មើ ១មូលដ្ឋានឃុំ អាជីវកម្មកាប់ជ្រូកបានចំនួន ៤លើក ស្មើ ៤មូលដ្ឋានឃុំ ចុះពិនិត្យផ្សារបានចំនួន ៦លើក ស្មើនិង ៤មូល-ដ្ឋានឃុំ និងចុះពិនិត្យ អាជីវកម្មទិញ-លក់ អេតចាយ បានចំនួន ៤លើក ស្មើ ២មូលដ្ឋាននៅឃុំអរិយក្សត្រ។ រីឯការគ្រប់គ្រងធម្មជាតិ វិញស្ថានភាពទឹកជំនន់ទន្លេមេគង្គចាប់ផ្តើមកំហុកឡើង ពីដើមខែកញ្ញា រហូតដល់ពាក់កណ្តាល ខែកញ្ញាដែលបណ្តាលអោយប៉ះពាល់ និងខូចខាតដល់ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធធារាសាស្ត្រតាមបណ្តាលឃុំមួយចំនួនទំនប់អាងទឹកទទឹងថ្ងៃនៅភូមិបឹងគ្រំក្រោម ឃុំបឹងគ្រំ ប្រវែង១៣៦ម៉ែត្រ ទំនប់អាងទឹកយុទ្ធសាស្ត្រទី២នៅភូមិព្រែកតាប្រាំង ឃុំភូមិធំ ប្រវែង៣៥០ម៉ែត្រ និងទំនប់អាងទឹកចាស់ ភូមិព្រែករ៉ៃ ឃុំព្រែករ៉ៃ ប្រវែង ៩០ម៉ែត្រ។ ស្រុកបានសហការជាមួយការិយាល័យធនធានទឹក និងឧតុនិយមបានចុះសិក្សាគម្រោងស្តារប្រឡាយមេព្រែកតាក្រូច ដែលស្ថិតនៅភូមិ អន្លង់ទ្រា ឃុំព្រែកឫស្សី មានប្រវែង ៥,៧០០ម៉ែត្រ អនុវត្តបាន១០០% ហើយមន្ទីរធនធានទឹកខេត្តបានចុះសិក្សា គម្រោងស្តារមេព្រែកថ្មីមានប្រវែង ១,១០០ម៉ែត្រ នៅភូមិបឹងគ្រំលើ ឃុំបឹងគ្រំ អនុវត្តបាន១០០%។ ម្យ៉ាងវិញទៀតការិយាល័យបានធ្វើរបាយការណ៍ស្ថានភាពទឹកជំនន់ទន្លេមេគង្គឡើងកំហុកបណ្តាលអោយប៉ះពាល់ និងខូចខាតប្រព័ន្ធធារាសាស្ត្រជូនមន្ទីរ និងធ្វើសំណើសុំសំបកបាវសម្រាប់ត្រៀមទប់ទំនប់អាងទឹកដែលខូចខាតនៅពេលទឹកស្រកខាងមុខ ដើម្បីរក្សាទឹកទុកសម្រាប់ការងារបង្កបង្កើនផលស្រូវប្រាំងរបស់ប្រជាពលរដ្ឋ។

### ៣.១.៤ វិស័យក្នុងការគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់

ស្រុកល្វាឯមបានអនុវត្តនូវ ការគ្រប់គ្រងប្រព័ន្ធរដ្ឋបាលតាមបែបប្រជាធិបតេយ្យ ដោយគោរពទៅតាមច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខ័ណ្ឌ ដែលមានការិល័យចំណុះ ៣ និងមានការិយាល័យជំនាញជុំវិញស្រុក ១២ សម្រាប់អនុវត្តការងារប្រចាំថ្ងៃ និងបានជួយគាំទ្រឃុំក្នុងការអនុវត្តគោលនយោបាយ វិមជ្ឈការ និងសហវិមជ្ឈការនៅក្នុងស្រុកល្វាឯមដើម្បីអោយស្របទៅតាមពាក្យថា **អភិបាលកិច្ចល្អ** ក្នុងការបម្រើសេវាផងសាធារណៈជូនពលរដ្ឋនៅក្នុងស្រុក។ ម្យ៉ាងវិញទៀតការចុះស្រង់ស្ថិតិវាគឺជាប្រព័ន្ធទិន្នន័យមួយយ៉ាងសំខាន់ផងដែរ ដែលថ្នាក់រដ្ឋបាលនីមួយៗត្រូវតែមានស្ថិតិប្រជាពលរដ្ឋ ដែលចំណាកស្រុកចូលមកនៅក្នុងស្រុកជាពិសេសទៅលើ ការចុះអត្រានុកូលដ្ឋានហើយស្រុកបានអនុវត្តទៅលើការងារអត្តសញ្ញាណប័ណ្ណបានពលរដ្ឋចំនួន ១៣១២នាក់ ប្រុស ៥៨៥នាក់ និងកំពុងបន្តធ្វើវិលជុំតាមបណ្តាលឃុំ និងនៅអធិការដ្ឋានស្រុកល្វាឯម។ ការផ្តល់សៀវភៅក២៖ សៀវភៅស្នាក់ ( ក២ ) ផ្តល់ថ្មីចំនួន៩៧០ គ្រួសារ ទុតិយតា:២១១ក្បាល ថែមសមាជិក ១៥០ក្បាល និងការធ្វើ សៀវភៅគ្រួសារ ( ក៤ ) ធ្វើជូនប្រជាពលរដ្ឋ បំបែកគ្រួសារថ្មីបានចំនួន៣៩៨

គ្រួសារទុតិយតាៈ១០១ថែមសមាជិក ៩៩គ្រួសារ។ រីឯការរៀបអាពាហ៍ពិពាហ៍ជនជាតិខ្មែរជាមួយបរទេសមាន ៤លើក ស្មើ ៤គូរ រៀបអាពាហ៍ពិពាហ៍ រវាងជនបរទេសសញ្ជាតិម៉ាឡេស៊ី និងពលរដ្ឋខ្មែរ ១គូរ រៀបអាពាហ៍ពិពាហ៍រវាងជនបរទេសសញ្ជាតិអាមេរិក និងពលរដ្ឋខ្មែរ ១គូរ រៀបអាពាហ៍ពិពាហ៍ រវាងជនជាតិវៀត-ណាម និងវៀតណាម ១គូរ និងការរៀបអាពាហ៍ពិពាហ៍រវាងជនជាតិវៀតណាម និង ខ្មែរ ១គូរ ដែលរៀបអាពាហ៍ពិពាហ៍នៅក្នុងស្រុកល្វាឯម។

បើនិយាយចំពោះការងារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ គឺជាការងារដែលចាំបាច់ដែលអាជ្ញាធរគ្រប់លំដាប់ថ្នាក់ត្រូវយកចិត្តទុកដាក់អនុវត្តអោយខានតែបាន ដើម្បីធានាសុវត្ថិភាពជូនប្រជាពលរដ្ឋរស់នៅសុខសាន្តតាមរយៈការអនុវត្តគោលនយោបាយ **ភូមិឃុំ មានសុវត្ថិភាព** ។ ការអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព គណៈបញ្ជាការឯកភាពឃុំគ្រប់ឃុំ បានធ្វើការផ្សព្វផ្សាយ ពីគោលនយោបាយភូមិ ឃុំ មានសុវ-ត្ថិភាពទាំង ៩ចំណុច និងកត្តាគ្រោះថ្នាក់នៃការប្រើប្រាស់គ្រឿងញៀនជូនប្រជាពលរដ្ឋបាន ១១៥៧លើក ប្រជាពលរដ្ឋចូលរួមមានចំនួន ២១៣៣១នាក់ ស្រី ១២៧៥៧នាក់។ ក្នុងនោះស្ថានភាពចាត់ការមកលើសន្តិសុខសណ្តាប់ធ្នាប់នេះរួមមានគ្រោះថ្នាក់ចរាចរណ៍កើតមានចំនួន ១៧លើក ដែលធ្វើអោយខូចខាតម៉ូតូចំនួន ២៧គ្រឿង រថយន្តមានចំនួន ២គ្រឿង កង់បីមានចំនួន ៣គ្រឿង កង់ចំនួន ១គ្រឿង និងរងរបួសធ្ងន់ ២៤នាក់ និងអ្នករងរបួសស្រាលចំនួន ២៣នាក់។ ចំណែកករណីអត្តឃាតបានកើតឡើង ២លើក ធ្វើឱ្យស្លាប់មនុស្ស ២នាក់ករណីទាំងពីរនេះគឺមិនមានការប្រែប្រួលអ្វីបន្ថែមទៀតនោះទេ។ រីឯគ្រោះថ្នាក់ធម្មជាតិបានកើតឡើង ៤លើក គឺខ្យល់កន្ត្រាក់ បណ្តាលអោយខូចខាត ផ្ទះចំនួន ៣២គ្រួសារករណីបាក់ច្រាំងទន្លេកើតឡើងមានចំនួន ៣លើកបានប៉ះពាល់ដល់ផ្ទះប្រជាពលរដ្ឋសរុប ចំនួន ១៣គ្រួសារដែលរស់នៅក្នុងឃុំ ចំនួន៣ មានឃុំសារិកាកែវ ឃុំពាមឧកញ៉ាអុង ឃុំល្វាស និងឃុំកោះកែវ។ ហើយគ្រោះថ្នាក់ដោយទឹកជំនន់បានកើតឡើងធ្វើអោយប៉ះពាល់ដល់ប្រជាពលរដ្ឋចំនួន ៣៤០គ្រួសារ/ខ្នងផ្ទះជម្លៀស ចេញពី លំនៅដ្ឋានចំនួន ២៧គ្រួសារ លិចផ្លូវចំនួន ១៩ខ្សែ ស្មើនិង ៩,៨១០ម៉ែត្រ ក្នុងឃុំចំនួន៦។ ម្យ៉ាងវិញទៀតការរុករកអាវុធជាច្រើន និងបានប្រទះឃើញគ្រាប់មិនទាន់ផ្ទុះនៅតាមបណ្តាល ឃុំ រួមមានដូចជាៈ

- នៅឃុំសំបួរប្រទះឃើញគ្រាប់ចំនួន០២គ្រាប់រួមមានៈ គ្រាប់ B40 ចំនួន ១គ្រាប់ គ្រាប់A60ចំនួន ១គ្រាប់
- នៅឃុំសារិកាកែវប្រទះឃើញគ្រាប់ចំនួន ៥គ្រាប់ រួមមានៈគ្រាប់ផ្លោង 76ចំនួន ១គ្រាប់ គ្រាប់ផ្លោង105 ចំនួន ១គ្រាប់ គ្រាប់M79 ចំនួន ១គ្រាប់ គ្រាប់ត្បាល់ ចំនួន ២គ្រាប់។
- នៅឃុំថ្មគរប្រទះឃើញគ្រាប់ចំនួន ១គ្រាប់ ប្រភេទម៉ាក M79

- នៅឃុំអរិយក្សត្រប្រទះឃើញគ្រាប់ចំនួន២២គ្រាប់ប្រភេទ៖ ម៉ាក M79 ចំនួន២១គ្រាប់ គ្រាប់ផ្លោងចំនួន ១គ្រាប់។
- ឃុំព្រែកឬស្សីប្រទះឃើញគ្រាប់ចំនួន ២គ្រាប់ប្រភេទ៖ ម៉ាក MK82 ចំនួន ១គ្រាប់ គ្រាប់រ៉ូកែតចំនួន ១គ្រាប់។

កិច្ចសហប្រតិបត្តិការ រវាងស្រុកជាមួយកងកម្លាំងឬកងកម្លាំងប្រជាការពារតាមបណ្តាឃុំ និងសហការជាមួយកងកម្លាំងប៉ុស្តិ៍រដ្ឋបាលរក្សាសន្តិភាពសណ្តាប់ធ្នាប់សាធារណៈនៅក្នុង ឆ្នាំ ២០១៩ នេះសមត្ថកិច្ចនគរបាលយើងបានចុះធ្វើវេទិកាសាធារណៈនិយាយពីភូមិ ឃុំមានសុវត្ថិភាព និងបានចុះធ្វើការផ្សព្វផ្សាយអំពីផលប៉ះពាល់ និងច្បាប់ស្តីពីគ្រឿងញៀនដល់សិស្សានុសិស្ស នៅតាមបណ្តាវិទ្យាល័យចូលរួមចំនួន ២២៧១នាក់ ស្រី១១៧៥នាក់។ ហើយក្នុងនោះមានការចូលរួមពីសំណាក់ក្រុមការងារថ្នាក់ស្រុក ក្រុមប្រឹក្សាឃុំ នគរបាលមេភូមិ ជំនួយការភូមិនាយកសាលាអ្នកធ្វើការនៅក្នុងមណ្ឌលសុខភាព ដែលបានចុះធ្វើការផ្សព្វផ្សាយច្បាប់ចរាចរណ៍ផ្លូវគោកដល់សិស្សានុសិស្សនៅតាមបណ្តាសាលារៀនសមាសភាពចូលរួមសរុបចំនួន ២៥៥៥នាក់ ស្រី ១៣៤៣នាក់ និងបានធ្វើការអប់រំដល់អ្នកបើកបរជាមួយអ្នករួមដំណើរ ដែលមិនបានពាក់មួកសុវត្ថិភាព និងពាក់មិនបានត្រឹមត្រូវបានចំនួន ៧លើក សរុបបាន ៩៩១នាក់ និងផ្តល់មួកសុវត្ថិភាពជូនដល់ពួកគាត់បានចំនួន ១១៥ មួក ចេញប័ណ្ណផាកពិន័យចំនួន ៤៥ ប័ណ្ណបានថវិកា ៧០០,០០០រៀល។

### ៣.១.៥ ផលលំបាកដែលមាន

នៅក្នុងស្រុកល្វាឯមបានជួបផលលំបាកជាច្រើន ក្នុងការអនុវត្តលើសកម្មភាពនានាដែលត្រូវបានអភិបាលស្រុក និងក្រុមប្រឹក្សាស្រុករួមគ្នាដោះស្រាយទៅលើបញ្ហាទាំងអស់នោះ ដែលវាបានជះឥទ្ធិពលមកលើស្រុកល្វាឯមជារៀងរាល់ឆ្នាំក្នុងនោះរួមមានទាំងកត្តាធម្មជាតិ និងមនុស្សដែលជាបញ្ហាចម្បងតែម្តងនៅក្នុងឆ្នាំ ២០១៩ នេះ ស្រុកល្វាឯមបានជួបផលលំបាកមួយចំនួន ដូចជាការជួបប្រទះគ្រោះទឹកជំនន់ នៅតាមបណ្តាឃុំមួយចំនួន ឃុំបឹងគ្រំក្រោម ឃុំភូមិធំ ឃុំព្រែករ៉ៃ និងប៉ះពាល់ដល់ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធធារាសាស្ត្រនៅតាមឃុំផ្សេងៗ។ ជាមួយបញ្ហារួមផ្សំផ្សេងទៀតផងដែរ ដែលរួមមានបញ្ហាចិញ្ចឹមសត្វគ្រប់ប្រភេទក៏មានការជួបប្រទះយ៉ាងធ្ងន់ធ្ងរគួរអោយកត់សម្គាល់ផងដែរ រីឯផ្នែកនីតិកម្មវិញនាពេលថ្មីៗនេះមន្ត្រីពិនិត្យនីតិកម្ម ក៏បានចុះណែនាំដល់អាជីវករលក់សម្ភារៈកសិកម្មគ្រប់ប្រភេទនៅតាមទីតាំងលក់ដូររបស់អាជីវករ និងបានឃាត់ទុកជីកសិកម្មក្លែងក្លាយមួយចំនួនហើយរហូតមកដល់ពេលនេះអាជីវករលក់សម្ភារៈកសិកម្ម ក៏បានឆ្លងកាត់វគ្គបណ្តុះបណ្តាលអំពីច្បាប់អាជីវកម្មបានជាច្រើនផងដែរ។ ដោយមានការជួយដោះស្រាយនិងអនុវត្តទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិ-បាល និងក្រុមប្រឹក្សាស្រុកឬមន្ត្រីកសិកម្មស្រុកបានសហការជាមួយការល័យផ្សព្វផ្សាយកសិកម្មខេត្តនិងភ្នាក់ងារផ្សព្វផ្សាយក៏បានធ្វើការចុះត្រួតពិនិត្យទីតាំងដែលមានផលប៉ះពាល់ ជាមួយការជំរុញអោយកសិករប្រើប្រាស់ពូជ

ស្រូវសែនក្រអូប ក្នុងការស្តារឡើងវិញលើផ្ទៃដីដែលបានខូចខាត និងបានចុះណែនាំតាមមូលដ្ឋានបន្ថែមទៀតពីបច្ចេកទេសដាំដំណាំស្រូវដល់កសិកម្មនៅគ្រប់ឃុំ និងតាមភូមិនានានៅក្នុងស្រុកល្វាឯមដើម្បីសម្រេចអោយបាននូវការកើនឡើងទិន្នផលស្រូវនិងកំណើន នៃការដាំដុះដល់ប្រជាពលរដ្ឋ។

## ៣.២ ចក្ខុវិស័យនាពេលអនាគតនៅក្នុងស្រុកល្វាឯម

ទិសដៅនៃកិច្ចការងាររបស់ស្រុកល្វាឯម កំពុងតែមានការបន្តនូវសកម្មភាព ក្នុងការសម្រេចអោយបាននូវលទ្ធផលល្អ និងភាពប្រសើរឡើងនៃកិច្ចការងារនានា ជាពិសេសលើការគ្រប់គ្រងប្រព័ន្ធរដ្ឋបាលជាមួយការអនុវត្តនូវគោលនយោបាយ របស់រដ្ឋាភិបាលភូមិឃុំមានសុវត្ថិភាព និងកិច្ចការប្រឡងប្រណាំងលើភូមិឃុំគំរូជាពិសេសលើគោលនយោបាយនៃ **អភិបាលកិច្ចល្អ** នៅក្នុងពេលអនាគតដើម្បីសម្រេចអោយបាននូវភាពរីកចម្រើន និងសុវត្ថិភាពជូនប្រជាពលរដ្ឋរស់នៅយ៉ាងសុខសាន្តនៅក្នុងស្រុក។

### ៣.២.១ ការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិល

នៅក្នុងស្រុកកម្មវិធីនៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិល ( ២០១៩-២០២១ )គឺដើម្បីឆ្លើយតបទៅនិងផែនការអភិវឌ្ឍក្នុងរយៈពេល៥ឆ្នាំ និងតម្រង់ទិសរដ្ឋបាលស្រុកក្នុងការអភិវឌ្ឍសេដ្ឋកិច្ច នៅក្នុងមូលដ្ឋានដើម្បីលើកកម្ពស់គុណភាពសេវាកម្មកែលម្អជីវភាពរស់នៅ និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ អោយកាន់តែប្រសើរឡើងដែលសម្តៅរួមចំណែកកាត់បន្ថយភាពក្រីក្រពីមួយឆ្នាំទៅមួយឆ្នាំ។ កម្មវិធីវិនិយោគបីឆ្នាំរំកិលនេះត្រូវបានចាប់ផ្តើមអនុវត្តនៅពេលដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាស្រុកល្វាឯម នាកិច្ចប្រជុំវិសាមញ្ញ ដែលគណៈអភិបាលស្រុកត្រូវធ្វើការផ្សព្វផ្សាយកម្មវិធីនេះដល់ប្រជាពលរដ្ឋ និងពាក់ព័ន្ធនានានៅក្នុងដែនសមត្ថកិច្ចដោយមានការសម្របសម្រួល និងកៀរគរធនធាននានាក្នុងការអនុវត្តកម្មវិធីនេះដើម្បីប្រកបដោយការចូលរួមតម្លាភាពគណនេយ្យភាពនិងមានប្រសិទ្ធភាពខ្ពស់។ ដោយកម្មវិធីនេះមានសារៈសំខាន់ចំពោះស្រុកល្វាឯមអភិបាលស្រុកនិងក្រុមប្រឹក្សាស្រុកជាមួយមន្ត្រីការិយាល័យជំនាញទាំង ១២ បានខិតខំចាប់ផ្តើមរៀបចំអនុវត្តនូវកម្មវិធីនេះបន្ទាប់បានអនុម័តរួចរាល់នោះដើម្បី ធ្វើអោយស្រុកល្វាឯមទទួលបាននូវភាពរីកចម្រើន និងជឿនលឿន នាពេលខាងមុខជាពិសេស គឺអាចធ្វើអោយប្រជា-ជនទទួលបាននូវភាពធូរធារ និងរស់នៅយ៉ាងសុខសប្បាយដែលមានប្រាក់គ្រប់គ្រាន់ក្នុងការចំណាយផ្សេងៗនៅក្នុងគ្រួសារ។

### ៣.២.២ ការពង្រឹងនៃការអនុវត្ត ភូមិ ឃុំ មានសុវត្ថិភាព

ដោយមើលឃើញនូវភាពអសន្តិសុខនៅក្នុងស្រុក ក៏ដូចជាមានការអុកឡុក និងមានភាពរញ៉េរញ៉ៃរបស់ពួកក្មេងទំនើងនៅតាមទីសាធារណៈនានាជាពិសេសតាមបុណ្យទានផ្សេងៗ និងពិធីមង្គលការផងដែរនោះរដ្ឋ-បាលស្រុកល្វាឯមបានធ្វើការសហការជាមួយកងកម្លាំងគ្រប់ប្រដាប់អាវុធក្នុងការការពាររាល់បញ្ហា និងសុវត្ថិភាពជូនប្រជាពលរដ្ឋនៅគ្រប់ទីកន្លែង និងគ្រប់ពេលវេលាតាមរយៈការតស៊ូលុបបំបាត់បទល្មើសគ្រប់ប្រភេទក្នុងមូល

ដ្ឋានភូមិ ឃុំទូទាំងស្រុកដើម្បីបង្កភាពអនុគ្រោះ ដល់ដំណើរការការអភិវឌ្ឍសេដ្ឋកិច្ចសង្គមកិច្ចនៅតាមមូលដ្ឋាន និងឈានទៅបង្កើនល្បឿនកាត់បន្ថយនូវភាពក្រីក្រ អោយកាន់តែប្រសើរថែមទៀត។ ម្យ៉ាងទៀតបានធ្វើការបំផុសបំផុល អោយមានកិច្ចសហការចូលរួមជាមួយសមត្ថកិច្ចអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ពីគណបក្សនយោបាយ អង្គការក្រៅរដ្ឋាភិបាលផ្នែកឯកជន និងប្រជាពលរដ្ឋគ្រប់រូបដើម្បីកសាងកម្លាំងសរុបវិធានការសរុប និងមធ្យោ-បាយសរុបដើម្បីលុបបំបាត់អោយអស់នូវបទល្មើស លួច ឆក់ ប្លន់គ្រប់ប្រភេទដែលតែងតែកើតមានឡើងនៅតាមភូមិឃុំ និងកាត់ផ្តាច់ជាមួយការលុបបំបាត់ អោយបានពីការផលិតចែកចាយ និងប្រើប្រាស់គ្រឿងញៀនខុសច្បាប់នៅតាមភូមិ ឃុំ ដោយផ្អែកតាមផែនការណែនាំផ្សេងៗនៃអគ្គស្នងការដ្ឋាននគរបាលជាតិ។ បន្ទាប់មកធ្វើការលុបបំបាត់រាល់អំពើ អនាចារ ការជួញដូរស្ត្រី និងកុមារអំពើហឹង្សាក្នុងគ្រួសារដើម្បីការពារសន្តិសុខសុវត្ថិ-ភាពជូនប្រជាពលរដ្ឋជាពិសេសស្ត្រី និងកុមារអោយរួចផុតពីការជួញដូរ អំពើរត់ពន្ធ ការធ្វើអាជីវកម្មលើកម្លាំងពលកម្មក្នុងការធ្វើអាជីវកម្មផ្លូវភេទ និងអំពើហឹង្សា និងធ្វើការទប់ស្កាត់ និងបង្ក្រាបសកម្មភាពក្មេងទំនើងអោយបានទាន់ពេលវេលា និងអោយមានប្រសិទ្ធភាពដើម្បីធានារក្សាបរិយាកាសសន្តិសុខសុវត្ថិភាពភូមិ ឃុំអោយបានល្អប្រសើរជាមួយការពង្រឹង នៃការលុបបំបាត់រាល់ល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទការប្រើប្រាស់អាវុធព្រមទាំងបទល្មើសផ្សេងៗទៀតនៅក្នុងភូមិ ឃុំ ដោយអនុវត្តតាមច្បាប់ពាក់ព័ន្ធនានាជាធរមានដើម្បីអោយស្របនូវពាក្យថា **អភិបាលកិច្ចល្អ** នៅក្នុងស្រុកល្វាឯមនាពេលអនាគតសម្រាប់ ប្រជាជនមានភាពសុខសាន្តជានិច្ច។

### ៣.២.៣ ការប្រឡងប្រណាំងលើ ភូមិ ឃុំ គំរូនៅក្នុងស្រុកល្វាឯម

នៅក្នុងការអនុវត្តដោយគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាពនេះស្រុកបានធ្វើអោយ ឃុំទាំង ១៥ធ្វើការប្រកួតប្រជែងលើការអនុវត្តនូវគោលការណ៍នេះ និងធ្វើការបំពេញទៅតាមការដឹកនាំតាមប្រជាធិបតេយ្យដែលបានកើតចេញពី **អភិបាលកិច្ចល្អ** នៅក្នុងភូមិ ឃុំ ដើម្បីអនុវត្តនូវសកម្មភាពហើយការធ្វើផែនការនៃប្រណាំងនេះគឺ ឃុំ និមួយៗត្រូវយកភូមិមួយ ជាគោលដៅសម្រាប់អនុវត្តការងាររដ្ឋបាល ការបំពេញនូវសេវាសាធារណៈអោយបានល្អប្រសើរនៅក្នុងឃុំដែលដឹកនាំអោយមានការរីកចម្រើនជឿនលឿននៅក្នុង ភូមិ ឃុំ និងក្រុមប្រឹក្សាបានខិតខំអនុវត្តអោយមានភាពរីកចម្រើន។

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានបកស្រាយនូវខ្លឹមសារ នៃទម្រង់ក្នុងការដឹកនាំជាលក្ខណៈ **អភិបាលកិច្ចល្អ** របស់ស្រុកល្វាឯមនៅក្នុង សារណា នេះអាចបញ្ជាក់អោយយើងបានដឹងច្បាស់ថាប្រព័ន្ធរដ្ឋបាលនៅក្នុងស្រុក គឺមានការគោរពទៅតាមគោលនយោបាយរបស់រដ្ឋាភិបាលជាពិសេសគឺការអភិវឌ្ឍតាមបែបវិមជ្ឈការ និង សហវិមជ្ឈការនៅថ្នាក់ក្រោមជាតិ។ នៅក្នុងនោះការរៀបចំនៃការគ្រប់គ្រងរដ្ឋបាលនៅក្នុងស្រុកល្វាឯម គឺបានអនុវត្តទៅតាមនូវអ្វីដែលថ្នាក់ជាតិបានដាក់ ចេញនូវគោលការណ៍ដឹកនាំតាមបែបប្រជាធិតេយ្យដោយមានការធ្វើប្រតិភូកម្មអោយស្រុកមានសិទ្ធិសម្រេចក្នុងការ គ្រប់គ្រងរដ្ឋបាលនៅក្នុងស្រុកអោយបានល្អ ជាពិសេសពីការគ្រប់គ្រងមកជាការបម្រើសេវាសាធាណៈចំពោះពលរដ្ឋនៅក្នុងស្រុកវិញ។ ជាមួយគ្នានេះដែលបើមើលទៅ ការគ្រប់គ្រងរដ្ឋបាលនៅស្រុកល្វាឯមនាពេលបច្ចុប្បន្ននេះ គឺមានការអនុវត្តបានយ៉ាងល្អប្រសើរ បើក្រលេកមើលទៅលើការរីកចម្រើនគ្រប់ផ្នែកទូទាំងស្រុកជាមួយការថយចុះនូវគ្រោះថ្នាក់ផ្សេងៗ ហើយមានការបម្រើនូវសេវាធារណៈបានយ៉ាងល្អប្រសើរ និងបានអនុវត្តគោលនយោបាយរបស់រដ្ឋាភិ- បាលនៃ ភូមិ ឃុំ មានសុវត្ថិភាពជាពិសេសការធ្វើអោយមានការគ្រប់គ្រងជាលក្ខណៈអភិបាលកិច្ចល្អនៅក្នុងស្រុកយើងអោយប្រសើរឡើងដោយបានអនុវត្តតាម ៩ ចំណុចនៃអភិបាលកិច្ចដែលបានចែងនៅក្នុងក្រសួងមហាផ្ទៃ។

បន្ទាប់ពីយើងខ្ញុំបានចុះទៅធ្វើការស្រាវជ្រាវអស់មួយរយៈពេលរួចមក យើងខ្ញុំបានសង្កេតឃើញថាការអនុវត្តលើកិច្ចការងាររដ្ឋបាល មានភាពប្រសើរឡើងដែលចំពោះការគោរពតាមច្បាប់បានកំណត់ ពីថ្នាក់ជាតិនោះ។ អមជាមួយគ្នានេះដែលការបំពេញតួនាទីរបស់មន្ត្រីសាលាស្រុក មិនសូវមានភាពសហការគ្នានោះទេក្នុងពេលបំពេញតួនាទីហើយការចូលបម្រើសេវាសាធារណៈ មានការយឺតយ៉ាវឬចេញមុនម៉ោងធ្វើការងារ ជាពិសេសមន្ត្រីការិយាល័យ គឺមានការផ្តល់ទិន្នន័យមិនទាន់ពេលវេលាសម្រាប់មន្ត្រីសាលាស្រុកបូកសរុបការងារប្រចាំខែឬឆ្នាំក្នុងការបញ្ជូនព័ត៌មានទៅដល់ថ្នាក់លើ ឬសម្រាប់អង្គការក្រៅរដ្ឋាភិបាល និងនិស្សិតដែលត្រូវការទិន្នន័យសម្រាប់ដឹងអំពីស្ថានភាពនៃការគ្រប់គ្រងរដ្ឋបាល ឬការជួបប្រទះបញ្ហានានាដែលប្រជាពលរដ្ឋមានការលំបាក។

ទន្ទឹមនឹងនេះផងដែលការដាក់នូវទ្រឹស្តីពាក្យថា **អភិបាលកិច្ចល្អ** ពិតជាមានអត្ថន័យមែនទែនសម្រាប់ពលរដ្ឋគ្រប់រូប ប៉ុន្តែចំពោះមន្ត្រីដែលត្រូវអនុវត្តចំពោះវិធានការនេះពិតជាមានការលំបាកខ្លាំងណាស់សម្រាប់ពួកគាត់ជាមន្ត្រីរាជការ ដោយសារតែជីវភាពពួកគាត់មានភាពខ្វះខាតដែលទទួលបានប្រាក់ខែតិចតួចណាស់ដែលសម្រាប់អោយពួកគាត់ចាំបាច់មកបំពេញតួនាទីមិនបានទាន់ពេលវេលា និងត្រូវបង្ខំចិត្តរកការងារផ្សេងៗដើម្បីទៅតាមតម្រូវការនៅក្នុងគ្រួសារ។ ដូច្នេះដើម្បីអោយពួកគាត់មានការគោរពតួនាទី និងពេលវេលាសម្រាប់កិច្ចការងារនៅក្នុងសាលាស្រុកបានល្អលុះត្រាតែរដ្ឋាភិបាល ត្រូវតែតំឡើងប្រាក់ជូនពួកគាត់អោយបានសាកសមការរស់នៅរបស់ពួកគាត់និងត្រូវធ្វើការដាក់ពិន័យ អោយបានតឹងរឹងទៅលើមន្ត្រីមួយចំនួនដែលខ្ជិលធ្វើការងារនិង

មកមិនទាន់ពេលវេលា និងចេញមុនម៉ោងធ្វើការងារដើម្បីអោយពលរដ្ឋទទួលបាននូវការបម្រើសេវាសាធារណៈអោយបានទាន់ពេលវេលា និងតាមតម្រូវការដើម្បីអោយស្របតាមពាក្យថា **អភិបាលកិច្ចល្អ** នៅក្នុងទ្រឹស្តីទាំង ៩ ចំណុចនៅក្នុងសៀវភៅក្រសួងមហាផ្ទៃ និងធ្វើអោយប្រជាពលរដ្ឋមានការគោរពស្រលាញ់មន្ត្រីគ្រប់លំដាប់ថ្នាក់ និងការទទួលបាននូវភាពកក់ក្តៅយកចិត្តទុក ដាក់ថែរក្សាដែលចេះជួយគ្នាទៅវិញទៅមកនៅពេលមានបញ្ហាកើតឡើងដែលប្រៀបបានមន្ត្រីទាំងនោះដូចជាឪពុក ម្តាយ ចំណែកពលរដ្ឋដូចជាកូនៗដែលត្រូវតែចាំបាច់ថែរក្សាអោយបានល្អនៅក្នុងស្រុកល្វាឯម។ ជាមួយគ្នានេះដែល សូមអោយមន្ត្រីរាជការ នៅក្នុងសាលាស្រុកល្វាឯម ធ្វើការកែទម្លាប់អាក្រក់ទាំងអស់នេះចោលហើយត្រូវធ្វើការសហការគ្នាអោយបានស៊ីជម្រៅចំពោះបម្រើកិច្ចការនានាទៅដល់ប្រជាពលរដ្ឋ អោយកាន់តែប្រសើរឡើងថែមទៀត ជាពិសេសត្រូវតែសម្រេចអោយបាននូវកិច្ចការងាររបស់រដ្ឋាភិបាលនូវគោលនយោបាយ អភិបាលកិច្ចល្អ នៅក្នុងស្រុកអោយកាន់កាន់តែប្រសើរឡើងៗ ដើម្បីអោយប្រជាពលរដ្ឋទទួលបាននូវភាពកក់ក្តៅ និងមានទំនុកចិត្តទៅលើមន្ត្រីរាជការទាំងអស់នៅក្នុងស្រុកល្វាឯម ក្នុងការធានាភាពសុខសាន្តរបៀបរៀបរយនៅតាមឃុំនីមួយៗ ជាពិសេសលើសន្តិសុខនិងការការពារដោយមានប្រសិទ្ធភាពចំពោះពលរដ្ឋដើម្បីទទួលបាននូវពាក្យថា ភូមិ ឃុំមានសុវត្ថិភាពជាមួយ ការលុបបំបាត់អោយអស់នូវរាល់សកម្មភាពអសកម្មនានា និងបទល្មើសមិនល្អទាំងឡាយ។ កុំអោយមានតែមានការសរសេរនៅក្នុងសៀវភៅបានយ៉ាងល្អប៉ុន្តែចំពោះការអនុវត្តមិនបានល្អទេដូច្នេះមន្ត្រីទាំងអស់ គឺត្រូវតែមានការគោរពតួនាទី ភារកិច្ច របស់ខ្លួនដើម្បីអោយទទួលបាននូវពាក្យថាការគ្រប់គ្រងប្រកបដោយភាពរីកចម្រើន និងមានគុណធម៌ហើយទទួលបាននូវភាពអភិវឌ្ឍនៅក្នុងមូលដ្ឋានជានិរន្តភាព។

# ការផ្តល់អនុសាសន៍

រដ្ឋបាលថ្នាក់ស្រុក គឺពិតជាមានភារកិច្ចចាំបាច់ណាស់ដែលត្រូវមានលទ្ធភាព និងសម្ភារៈគ្រប់គ្រាន់សម្រាប់ប្រើប្រាស់ ក្នុងការអនុវត្តតួនាទីរបស់ខ្លួន និងអាចសម្រេចជាលទ្ធផលល្អប្រសើរសម្រាប់សង្គមជាតិ។ ដោយផ្អែកទៅលើសេចក្តីសន្និដ្ឋានដូចដែលបានរៀបរាប់ខាងលើ យើងខ្ញុំសូមបញ្ចេញនូវមតិផ្ទាល់ខ្លួនខ្លះៗក្នុងការជួយពង្រឹងនូវគោលការណ៍អភិបាលកិច្ចល្អក្នុងមូលដ្ឋានៈ

- សូមអោយមន្ត្រីទាំងអស់នៅក្នុងសាលាស្រុកល្វាឯម មានកិច្ចសហការគ្នាក្នុងការអនុវត្តការងារនៅក្នុងស្រុក។
- សូមអោយមន្ត្រីទាំងអស់គោរពតួនាទី និងមកធ្វើការងារទាន់ពេលវេលា ហើយមិនចេញមុនម៉ោង។
- ត្រូវធ្វើការបម្រើនូវសេវាសាធារណៈអោយមានភាពត្រឹមត្រូវ តម្លាភាព គុណធម៌។
- សូមអោយមន្ត្រីការិយាល័យជំនាញទាំង១២ផ្តល់នូវរបាយការណ៍ប្រចាំខែ ឬឆ្នាំ អោយបានទាន់ពេលវេលា
- សូមអោយមន្ត្រីទាំងអស់យកចិត្តទុកដាក់លើកិច្ចការរដ្ឋបាលនៅក្នុងមូលដ្ឋានអោយបានល្អ។
- សូមអោយមានការពង្រឹងនូវធនធានមនុស្ស និងសមត្ថភាពមន្ត្រីជំនាញនៅក្នុងមូលដ្ឋានភូមិ ឃុំ សង្កាត់ជាពិសេសថ្នាក់ស្រុក។
- គួរតែបន្តជម្រុញអោយប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានបានយល់ដឹងអំពីសិទ្ធិរបស់ខ្លួនផ្ទាល់។
- ក្រុមប្រឹក្សាស្រុក គួរណាតែបង្កើតគម្រោងចុះអប់រំផ្សព្វផ្សាយអំពីច្បាប់ព្រហ្មទណ្ឌ ច្បាប់រដ្ឋប្បវេណី ច្បាប់ភូមិបាល និងច្បាប់នានាព្រមទាំងទោសទណ្ឌនៅតាមបណ្តាល ឃុំ នានាអោយប្រជាពលរដ្ឋបានយល់ដឹង។
- ថ្នាក់ស្រុកគួរតែជម្រុញផ្សព្វផ្សាយនូវព័ត៍មានទាំងឡាយ និងផ្តល់ឱកាសដល់ប្រជាពលរដ្ឋ ជាពិសេសជនដែលងាយរងគ្រោះ ជនក្រីក្រ និងស្ត្រី។

# ឯកសារយោង

៚❋៚

## ➢ លិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញនៃព្រះរាជណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១
- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០១២
- ច្បាប់ភូមិបាល ឆ្នាំ២០០១
- អនុក្រឹត្យលេខៈ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងរបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- អនុក្រឹត្យលេខៈ ២៦ អនក្រ/បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនសមាជិកក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- អនុក្រឹត្យលេខៈ ១០៣ អនក្រ/បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ ២០០០ ស្តីពីអត្រានុកូលដ្ឋាន
- អនុក្រឹត្យលេខៈ ៦០ អនក្រ/បក ស្តីពីការកែសម្រួលមាត្រា ៨ និងមាត្រា ៥៩ នៃអនុក្រឹត្យ លេខ១០៣ អនក្រ/បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ស្តីពីអត្រានុកូលដ្ឋាន
- អនុក្រឹត្យលេខៈ ១៧៨៧ អនក្រ.កត ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៩ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៩ តែងតាំងមន្ត្រីរាជការ
- ផែនការចាត់តាំងអនុវត្តគោលនយោបាយ ភូមិ ឃុំមានសុវត្ថិភាព លេខ ០២០ ជ.ក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១០

## ➢ បទបញ្ជាផ្សេងៗ

- សារាចរលេខៈ០៤ ស.រ របស់នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០០ ស្តីពីវិធានការបង្ការទប់ស្កាត់និងបង្ក្រាបសកម្មភាពក្មេងទំនើង
- ប្រកាសលេខៈ៤២៧៥ ប្រ/ក របស់ក្រសួងមហាផ្ទៃ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារនៅក្នុងក្រុមប្រឹក្សា រាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- ប្រកាសលេខៈ១៩៥០ ប្រ/ក របស់ក្រសួងមហាផ្ទៃ ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ២០០២ ស្តីពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធនៃនាយករដ្ឋបាលមូលដ្ឋាន

- **សៀវភៅឯកសារយោង**

- សៀវភៅអភិបាលកិច្ចល្អរបស់ក្រុមការងារគាំទ្រក្រុង ស្រុក ខណ្ឌ ក្រសួងមហាផ្ទៃ បោះពុម្ពនៅ ខែមិថុនា ឆ្នាំ២០១០
- សៀវភៅណែនាំស្តីពី តួនាទី ភារកិច្ច និងរបៀបរបបការងាររបស់រដ្ឋបាលស្រុកល្វាឯម ខែកក្កដា ឆ្នាំ២០១១
- សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលពីឆ្នាំ ២០១៩-២០២១ របស់ស្រុកល្វាឯម ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៩
- របាយការណ៍ប្រចាំឆ្នាំ ២០១៧ និង២០១២ របស់ស្រុកល្វាឯម

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ


| ល.រ | បញ្ជីរាយនាម | ទំព័រ |
|---|---|---|
| ១ | រចនាសម្ព័ន្ធរដ្ឋបាលស្រុកល្វាឯម | ១ |
| ២ | ផែនទីស្រុកល្វាឯម ខេត្តកណ្តាល | ២ |
| ៣ | អនុក្រឹត្យលេខៈ២៨៦.អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពី នីតិវិធីសម្រាប់ការរៀបចំ ការកែប្រែ និងការលុបចោលដីការបស់ក្រុមប្រឹក្សារាជធានីក្រុម ប្រឹក្សា ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌ | ៣ |
| ៤ | អនុក្រឹត្យលេខៈ២២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនសមាជិកក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ សម្រាប់អាណត្តិទី៣ | ១៣ |
| ៥ | សារាចរលេខៈ០៤ ស.រ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៩ ស្តីពី វិធានការបង្ការ ទប់ស្កាត់ និងបង្ក្រាបសកម្មភាព "ក្មេងទំនើង" | ២៣ |
| ៦ | សេចក្តីសម្រេចស្តីពី ការធ្វើសមាហរណកម្មបុគ្គលិក និងការងាររៀបចំមុខតំណែងគ្រប់គ្រងនៅក្នុងរចនាសម្ព័ន្ធនៃរដ្ឋបាលស្រុកល្វាឯមនៃខេត្តកណ្តាល | ២៦ |
| ៧ | ឯកសារព័ត៌មានស្ថានភាព លេខៈ៨០៦ ចុះខែធ្នូ ឆ្នាំ២០១៨ ស្តីពី សេដ្ឋកិច្ចសង្គមកិច្ច ឆ្នាំ២០១៩ | ៣១ |
| ៨ | របាយការណ៍ប្រចាំឆ្នាំ២០១៩ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៩ ស្តីពី ការអនុវត្តការងាររបស់រដ្ឋបាលស្រុកល្វាឯម | ១០១ |


រចនាសម្ព័ន្ធរដ្ឋបាលស្រុកល្វាឯម
ក្រុមប្រឹក្សា
គណៈកម្មាធិការសម្រេចសម្រួលបច្ចេកទេស
គណៈកម្មាធិការលទ្ធកម្ម
គណៈកម្មការពិគ្រោះយោបល់កិច្ចការនារី
គណៈកម្មាធិការផ្សេងៗទៀត
ការិយាល័យជំនាញ
គណៈអភិបាល
នាយករដ្ឋបាល
ការិយាល័យផែនការ និងឃុំសង្កាត់
ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ
ការិយាល័យអន្តរវិស័យ


ផែនទីស្រុកល្វាឯម ខេត្តកណ្ដាល
ល្វាឯម
ខេត្តព្រៃវែង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ២៧៦...អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## នីតិវិធីសម្រាប់ការរៀបចំ ការកែប្រែ និងការលុបចោលដីការបស់ ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌ

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៣/០១២ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា២៨នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងរបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ

- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងរបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និង ក្រុមប្រឹក្សា គណៈអភិបាលស្រុក
- យោងតាមសំណើប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

អនុក្រឹត្យនេះ មានគោលបំណងធានាការប្រើប្រាស់សិទ្ធិអំណាចបញ្ញត្តិរបស់ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌ។

មាត្រា ២.-

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីនីតិវិធីនៃការរៀបចំ ការកែប្រែ និងការលុបចោលដីកាដែលមានលក្ខណៈជាបទបញ្ជាទូទៅរបស់ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌ។

មាត្រា ៣.-

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តនៅរដ្ឋបាលរាជធានី រដ្ឋបាលខេត្ត រដ្ឋបាលក្រុង រដ្ឋបាលស្រុក និងរដ្ឋបាលខណ្ឌ។

មាត្រា ៤.-

វាក្យសព្ទបច្ចេកទេសនៅក្នុងអនុក្រឹត្យនេះមានន័យដូចតទៅ៖

- **ដីកា** គឺជាវិធានខាងផ្លូវច្បាប់ មានលក្ខណៈជាបទបញ្ជាទូទៅ ឬមានលក្ខណៈជាឯកត្តកូត ដែលអនុម័តដោយក្រុមប្រឹក្សាក្នុងព្រំដែននៃសិទ្ធិអំណាចរបស់ខ្លួន សម្រាប់អនុវត្តក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ដីកាអាចជាដីកាដើម ឬដីកាដែលកែប្រែដីកាដើម ឬដីកាដែលកែប្រែដីកាមួយផ្សេងទៀត ឬដីកាដែលលុបចោលដីកាមួយផ្សេងទៀត។
- **ដីកាដែលមានលក្ខណៈជាបទបញ្ជាទូទៅ** គឺជាការណែនាំការអនុវត្ត ឬបញ្ជាក់បន្ថែមខ្លឹមសាររបស់ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងប្រកាស និងជាការណែនាំការអនុវត្តកិច្ចការដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា។ ដីកាដែលមានលក្ខណៈជាបទបញ្ជាទូទៅ ត្រូវអនុម័តដោយក្រុមប្រឹក្សា និងចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សា។
- **ដីកាដែលមានលក្ខណៈជាឯកត្តកូត** គឺជាដីកាដែលទាក់ទង ឬសំដៅចំឈ្មោះបុគ្គល។ ដីកាដែលមានលក្ខណៈជាឯកត្តកូតត្រូវអនុម័តដោយក្រុមប្រឹក្សា និងចុះហត្ថលេខាដោយអភិបាល។
- **ដីកាដើម** សំដៅដល់ដីកាដំបូងដែលបានរៀបចំ និងអនុម័តដោយក្រុមប្រឹក្សា។

- **ដែនសមត្ថកិច្ច** គឺជាតំបន់ ជាមុខងារ និងជាភារកិច្ច ដែលស្ថិតនៅក្រោមសិទ្ធិអំណាចរបស់ក្រុមប្រឹក្សា។
- **ប្រតិសកម្ម** សំដៅដល់អានុភាពអនុវត្តត្រឡប់ក្រោយចំពោះស្ថានភាព ឬករណីទាំងឡាយណាដែលបានកើតមានឡើងមុនដីកាចូលជាធរមាន។
- **ការពិនិត្យនីត្យានុកូលភាព** គឺជាការត្រួតពិនិត្យ ដើម្បីធានាថា ដីការបស់ក្រុមប្រឹក្សាត្រូវបានរៀបចំឡើងស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន។
- **នគរបាលយុត្តិធម៌** សំដៅដល់មន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ និងមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត ដែលច្បាប់ដោយឡែកប្រគល់អំណាចឱ្យធ្វើការពិនិត្យបទល្មើសខ្លះៗក្នុងវង្វង់សមត្ថកិច្ចរបស់ខ្លួន។ នគរបាលយុត្តិធម៌ គឺជាជំនួយរបស់អំណាចតុលាការ។ នគរបាលយុត្តិធម៌មានភារកិច្ចធ្វើការត្រួតពិនិត្យបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ កំណត់អត្តសញ្ញាណ និងចាប់ជនល្មើស ព្រមទាំងប្រមូលភស្តុតាង។

## ជំពូកទី២

## គោលការណ៍សំខាន់ៗនៃការដាក់ចេញដីកា

**មាត្រា ៥.-**

ដីកាដែលមានលក្ខណៈជាបទបញ្ជាទូទៅ ត្រូវអនុម័តដោយក្រុមប្រឹក្សា និងត្រូវចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សា។

**មាត្រា ៦.-**

ដីកាដែលចែងផ្ទុយពីបទបញ្ញត្តិណាមួយនៃរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន ដីកានោះនឹងមិនមានសុពលភាពបានឡើយ។

**មាត្រា ៧.-**

ដីកាណាមួយដែលធ្វើឡើងដោយមានការរើសអើង ក្នុងន័យជាអវិជ្ជមាន ឬអនុវត្តចំពោះបុគ្គលណាម្នាក់ ឬក្រុមមនុស្សណាមួយ ដោយផ្អែកលើកត្តាជាតិសាសន៍ សាសនា ជំនឿ ភេទ អាយុ ពណ៌សម្បុរ ជាតិ ឬជាតិកំណើត ឬអសមត្ថភាពខាងស្មារតីឬខាងកាយសម្បទា ដីកានោះនឹងមិនមានសុពលភាពបានឡើយ។

**មាត្រា ៨.-**

ក្រុមប្រឹក្សា ត្រូវធានាឱ្យមានការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនានាក្នុងដំណើរការរៀបចំដីកា លើកលែងតែក្នុងករណីចាំបាច់ដែលតម្រូវឱ្យក្រុមប្រឹក្សាត្រូវដាក់ចេញនូវដីកាដើម្បីដោះស្រាយ ឬចាត់វិធានការបន្ទាន់ណាមួយ។

**មាត្រា ៩.-**

ដីកាដែលក្រុមប្រឹក្សាបានអនុម័តរួច ត្រូវចូលជាធរមាននៅថ្ងៃដែលដីកានោះត្រូវបានចុះហត្ថលេខា ឬអាចកំណត់យកកាលបរិច្ឆេទណាមួយនាពេលអនាគតសម្រាប់ការចូលជាធរមាននូវដីកាទាំងមូល ឬផ្នែកខ្លះនៃដីកា។

**មាត្រា ១០.-**

ដីកាមិនអាចមានអានុភាពប្រតិសកម្មបានឡើយ។

## ជំពូកទី៣

## សិទ្ធិអំណាចរបស់ក្រុមប្រឹក្សាក្នុងការចេញដីកា

**មាត្រា ១១.-**

ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌប្រើប្រាស់សិទ្ធិអំណាចខាងបញ្ញត្តិតាមរយៈការដាក់ចេញដីកា ការកែប្រែ និងការលុបចោលដីកាស្របតាមនីតិវិធី ដែលមានចែងនៅក្នុងបទបញ្ញត្តិនានានៃអនុក្រឹត្យនេះ។

**មាត្រា ១២.-**

ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌមានសិទ្ធិដាក់ចេញដីកា ដើម្បីកំណត់ ដើម្បីហាមឃាត់ ឬដើម្បីត្រួតពិនិត្យលើសកម្មភាព លើនីតិវិធី ឬលើកិច្ចការណាមួយដែលស្ថិតនៅក្នុងវិសាលភាពនៃមុខងារ និងធនធានរបស់ខ្លួនរួមមាន ៖

- តួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សា
- មុខងារ និងឬធនធានដែលប្រគល់ទៅឱ្យក្រុមប្រឹក្សា
- មុខងារ និងឬធនធានដែលបានធ្វើប្រតិភូកម្មទៅឱ្យក្រុមប្រឹក្សា ក្នុងករណីដែលការធ្វើប្រតិភូកម្មនោះមិនកំណត់ដោយផ្នែកខ្លះ ឬទាំងស្រុងនូវសិទ្ធិក្នុងការអនុម័តដីកា និង
- កិច្ចការណាមួយដែលច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន ដែលតម្រូវឱ្យក្រុមប្រឹក្សាដាក់ចេញដីកា។

**មាត្រា ១៣.-**

ដីកាអាចដាក់បញ្ចូលនូវបទបញ្ញត្តិស្តីពីការពិន័យជាប្រាក់ ដោយមិនទាន់គិតពីទោសព្រហ្មទណ្ឌនិងការទទួលខុសត្រូវរដ្ឋប្បវេណីផ្សេងៗទៀតចំពោះការបំពានលើបទបញ្ញត្តិមួយ ឬច្រើនដែលមានចែងនៅក្នុងដីកា។

**មាត្រា ១៤.-**

បែបបទ និងនីតិវិធីនៃការរៀបចំបទបញ្ញត្តិសម្រាប់ការពិន័យជាប្រាក់ដោយដីការបស់ក្រុមប្រឹក្សា និងកម្រិតនៃប្រាក់ពិន័យនេះត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ជំពូកទី៤

## ការរៀបចំ និងការអនុម័តដីកា

### ផ្នែកទី១

### ការកំណត់អំពីតម្រូវការនៃការដាក់ចេញដីកា

**មាត្រា ១៥.-**

តម្រូវការនៃការដាក់ចេញដីកា ត្រូវបានកំណត់ដោយផ្អែកតាមតម្រូវការនៃច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន និងឬតម្រូវការក្នុងមូលដ្ឋាន។

ការផ្តួចផ្តើមអំពីតម្រូវការនៃការដាក់ចេញដីកាដោយផ្អែកតាមតម្រូវការក្នុងមូលដ្ឋាន អាចស្នើឡើងដោយ ៖

- ប្រធានក្រុមប្រឹក្សា ឬ
- សមាជិកក្រុមប្រឹក្សាមួយភាគបី(១/៣)នៃសមាជិកក្រុមប្រឹក្សាទាំងមូល ឬ
- គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា ឬ
- អភិបាល ឬគណៈអភិបាល ឬ
- សមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់នៅក្នុងដែនសមត្ថកិច្ចនីមួយៗ ឬ
- តំណាងគ្រួសារចំនួនមួយភាគដប់(១/១០)នៃចំនួនគ្រួសារសរុបដែលមាននៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានីមួយៗ។

**មាត្រា ១៦.-**

តម្រូវការនៃការដាក់ចេញដីកាត្រូវអនុម័តដោយក្រុមប្រឹក្សា។

## ផ្នែកទី២
## ការរៀបចំសេចក្តីព្រាងដីកា

**មាត្រា ១៧.-**

ការរៀបចំសេចក្តីព្រាងដីកាត្រូវផ្អែកតាមគោលការណ៍ ឬវិធាននានានៃច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន និង ឬតម្រូវការនៅមូលដ្ឋានក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា។

ក្នុងការរៀបចំសេចក្តីព្រាងដីកា ក្រុមប្រឹក្សាអាចរៀបចំឱ្យមានការសិក្សាជាមុនអំពីក្របខ័ណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ បញ្ហា និងតម្រូវការជាក់ស្តែងនៅក្នុងមូលដ្ឋានរបស់ខ្លួន។ ក្នុងការសិក្សានេះ ក្រុមប្រឹក្សាអាចស្វែងរកការពិគ្រោះយោបល់ ឬការស្នើសុំឱ្យមានការគាំទ្រផ្នែកបច្ចេកទេស និងធនធាន ឬសេវាទីប្រឹក្សាពីក្រសួង ស្ថាប័ន មន្ទីរ អង្គភាព ផ្នែកឯកជន អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានា។

**មាត្រា ១៨.-**

ក្នុងការរៀបចំសេចក្តីព្រាងដីកា ក្រុមប្រឹក្សាអាចប្រគល់ភារកិច្ចឱ្យ ៖

- សមាជិកក្រុមប្រឹក្សា ឬ
- គណៈអភិបាល ឬ
- គណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារណាមួយរបស់ក្រុមប្រឹក្សា ឬ
- អង្គភាពណាមួយរបស់ក្រុមប្រឹក្សា។

សេចក្តីព្រាងដីកា ត្រូវរៀបចំឡើងដោយផ្អែកតាមទម្រង់ដីកាដែលកំណត់ដោយសេចក្តីណែនាំ របស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា ១៩.-**

ក្រុមប្រឹក្សាត្រូវធានាឱ្យមានការចូលរួមពីអ្នកពាក់ព័ន្ធនានា ជាពិសេសតំណាងស្ត្រី យុវជន កុមារ ជនងាយរងគ្រោះ និងជនជាតិដើមភាគតិច ក្នុងការរៀបចំសេចក្តីព្រាងដីកា។

មាត្រា ២០.-

ក្នុងពេលរៀបចំសេចក្តីព្រាងដីកា ក្រុមប្រឹក្សា ឬគណៈអភិបាលអាចលើកសំណើជាលាយលក្ខណ៍អក្សរសុំយោបល់ពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រសិនបើយល់ឃើញថាបញ្ហាទាំងនោះជាបញ្ហាស្មើប ឬមិនច្បាស់លាស់។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវឆ្លើយតបវិញយ៉ាងយូរសាមសិប(៣០)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានសំណើនោះ។

## ផ្នែកទី៣
## ការពិគ្រោះយោបល់ និងការបិទផ្សាយសេចក្តីព្រាងដីកាជាសាធារណៈ

មាត្រា ២១.-

រាល់សេចក្តីព្រាងដីកា ត្រូវមានការពិគ្រោះយោបល់ជាមួយគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ និងឬគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា មុននឹងដាក់ជូនគណៈអភិបាលពិនិត្យ និងផ្តល់យោបល់ ដើម្បីដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងឯកភាពជាបឋមទៅលើសេចក្តីព្រាងដីកានេះ។

មាត្រា ២២.-

សេចក្តីព្រាងដីកាដែលបានការឯកភាពជាបឋមពីក្រុមប្រឹក្សា ត្រូវមានការពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ដែលពាក់ព័ន្ធ សាធារណជន និងអ្នកពាក់ព័ន្ធដទៃទៀត និងត្រូវជូនដំណឹងនិងបិទផ្សាយជាសាធារណៈឱ្យបានទូលំទូលាយនៅក្នុងរដ្ឋបាលរបស់ខ្លួន និងនៅទីសាធារណៈ ដើម្បីឱ្យសាធារណជន និងអ្នកពាក់ព័ន្ធនានាបានទទួលព័ត៌មានអំពីខ្លឹមសារនៃសេចក្តីព្រាងដីកា និងមានឱកាសផ្តល់យោបល់។

ការជូនដំណឹង និងការបិទផ្សាយជាសាធារណៈនេះ ត្រូវមានរយៈពេលយ៉ាងតិចដប់(១០)ថ្ងៃនៃថ្ងៃធ្វើការ មុននឹងដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងអនុម័ត លើកលែងតែករណីចាំបាច់ និងបន្ទាន់ក្នុងការដាក់ចេញនូវដីកានោះដូចមានចែងក្នុងមាត្រា៨នៃអនុក្រឹត្យនេះ។

មាត្រា ២៣.-

ក្រុមប្រឹក្សាត្រូវធានាឱ្យមានយន្តការច្បាស់លាស់ ក្នុងការទទួលយកព័ត៌មានត្រឡប់ពីសាធារណជន និងអ្នកពាក់ព័ន្ធនានាអំពីសេចក្តីព្រាងដីកា ដោយរៀបចំឱ្យមានទីកន្លែង មធ្យោបាយ មន្ត្រីទទួលបន្ទុកសម្រាប់ទទួលយកយោបល់ត្រឡប់ពីសាធារណជន និងអ្នកពាក់ព័ន្ធនានា។

មាត្រា ២៤.-

អភិបាលត្រូវធានាថា រាល់យោបល់ដែលទទួលបានពីការពិគ្រោះយោបល់ និងការបិទផ្សាយជាសាធារណៈ ត្រូវបានយកមកពិចារណាក្នុងការកែសម្រួលសេចក្តីព្រាងដីកា និងត្រូវធានាឲ្យមានការរៀបចំរបាយការណ៍អំពីលទ្ធផលនៃការពិគ្រោះយោបល់ និងការបិទផ្សាយជាសាធារណៈនេះ ដើម្បីភ្ជាប់ជាមួយនឹងសេចក្តីព្រាងដីកាដែលបានកែសម្រួលសម្រាប់ដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងអនុម័ត។

## ជំពូកទី៤
## ការពិនិត្យ និងការអនុម័តដីកា

**មាត្រា ២៥.-**

សេចក្តីព្រាងដីកាដែលបានកែសម្រួលរួច ត្រូវដាក់ជូនគណៈអភិបាលពិនិត្យ និងរៀបចំដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងអនុម័ត ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ស្តីពីលទ្ធផលនៃការពិគ្រោះយោបល់ និងការបិទផ្សាយជាសាធារណៈ និងសេចក្តីថ្លែងហេតុស្តីពីកិច្ចដំណើរការរៀបចំ និងខ្លឹមសារនៃសេចក្តីព្រាងដីកា។

**មាត្រា ២៦.-**

ក្រោយពេលទទួលបាននូវសេចក្តីព្រាងដីកា ប្រធានក្រុមប្រឹក្សាត្រូវរៀបចំកិច្ចប្រជុំក្រុមប្រឹក្សារបស់ខ្លួន ដើម្បីពិនិត្យ និងអនុម័តលើសេចក្តីព្រាងដីកានោះ។

ក្នុងកិច្ចប្រជុំក្រុមប្រឹក្សា ប្រធានក្រុមប្រឹក្សាត្រូវធានាឱ្យមានការចូលរួមពីគណៈអភិបាល មន្ទីរ អង្គភាព និងអ្នកជំនាញដែលពាក់ព័ន្ធ ព្រមទាំងបង្កលក្ខណៈងាយស្រួលដល់ការចូលរួមរបស់សាធារណជន និងអ្នកពាក់ព័ន្ធផ្សេងៗទៀត។

**មាត្រា ២៧.-**

ដំណើរការនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាដើម្បីពិនិត្យ និងអនុម័តលើសេចក្តីព្រាងដីកា ត្រូវអនុវត្តតាមបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន។

ក្រុមប្រឹក្សាត្រូវអនុម័តសេចក្តីព្រាងដីកា ដោយសំឡេងលើសពីពាក់កណ្តាលនៃចំនួនសមាជិកក្រុមប្រឹក្សាទាំងមូល។

**មាត្រា ២៨.-**

បន្ទាប់ពីក្រុមប្រឹក្សាបានអនុម័តលើសេចក្តីព្រាងដីកា អភិបាលត្រូវរៀបចំកែសម្រួល និងដាក់ជូនប្រធានក្រុមប្រឹក្សាចុះហត្ថលេខា ឬត្រូវបំពេញភារកិច្ចផ្សេងទៀតផ្អែកតាមការសម្រេចរបស់ក្រុមប្រឹក្សា។

## ជំពូកទី៥
## ការកែប្រែ និងការលុបចោលដីកា

**មាត្រា ២៩.-**

ក្រុមប្រឹក្សាអាចសម្រេចកែប្រែ ឬលុបចោលដីកាណាមួយដែលខ្លួនបានអនុម័តរួច ដោយផ្អែកតាមស្ថានភាព បញ្ហា តម្រូវការ ឬសំណូមពរពីមូលដ្ឋាន និង ឬដោយផ្អែកតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ឬលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន ឬតាមការណែនាំពីក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល។

**មាត្រា ៣០.-**

ការកែប្រែដីកាអាចធ្វើឡើងដោយបន្ថែមប្រការថ្មី និងឬកែប្រែប្រការណាមួយនៃដីកាដែលមានស្រាប់។

ការកែប្រែដីកាត្រូវអនុវត្តតាមនីតិវិធីស្តីពីការរៀបចំ និងការអនុម័តដីកា ដូចមានចែងក្នុងជំពូកទី៤ នៃអនុក្រឹត្យនេះ។

**មាត្រា ៣១.-**

ក្រុមប្រឹក្សាអាចសម្រេចលុបចោលដីកាណាមួយតាមរយៈដីកាបស់ខ្លួន។

## ជំពូកទី៦

## ការអនុវត្តដីកា

**មាត្រា ៣២.-**

ដីកាដែលអាចអនុវត្តបាន លុះត្រាតែដីកានោះបានចូលជាធរមាន ដូចដែលមានចែងក្នុងមាត្រា៩នៃអនុក្រឹត្យនេះ។

ក្រុមប្រឹក្សាត្រូវធានាថា រាល់ដីកាដែលបានអនុម័តរួច ត្រូវធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់សាធារណជន និងអ្នកពាក់ព័ន្ធនានា។

**មាត្រា ៣៣.-**

ការអនុវត្តដីកាត្រូវធ្វើឡើងនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាទាំងមូល លើកលែងតែដីកាចែងផ្សេងពីនេះ ឬលើកលែងតែច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋាន គតិយុត្តជាធរមានណាមួយបានតម្រូវឱ្យដកចេញពីដីកានូវតំបន់ដែលមានការកំណត់ដែនសមត្ថកិច្ចច្បាស់លាស់។

**មាត្រា ៣៤.-**

ក្រុមប្រឹក្សាត្រូវអនុវត្ត និងពង្រឹងការអនុវត្តដីកាទាំងអស់របស់ខ្លួន។

គណៈអភិបាលក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន ត្រូវទទួលខុសត្រូវក្នុងការចាត់ចែងអនុវត្ត និងពង្រឹងការអនុវត្តដីកាទាំងអស់របស់ក្រុមប្រឹក្សា ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព និងត្រូវធ្វើរបាយការណ៍ជាប្រចាំ ឬតាមការកំណត់របស់ក្រុមប្រឹក្សា។ ក្នុងការចាត់ចែងអនុវត្តដីកានេះ គណៈអភិបាលត្រូវធានាឱ្យមានការចូលរួមពីមន្ទីរ អង្គភាពជំនាញ សាធារណជន និងអ្នកពាក់ព័ន្ធនានា។

ក្នុងករណីចាំបាច់ គណៈអភិបាលអាចពង្រឹងការអនុវត្តដីកាតាមរយៈ ឬដោយមានកិច្ចសហការជាមួយនគរបាលយុត្តិធម៌។

នគរបាលយុត្តិធម៌ត្រូវជួយក្រុមប្រឹក្សា ដើម្បីពង្រឹងការអនុវត្តដីការបស់ក្រុមប្រឹក្សានៅពេលមានការស្នើសុំជាលាយលក្ខណ៍អក្សរពីគណៈអភិបាល។

**មាត្រា ៣៥.-**

ក្រុមប្រឹក្សាត្រូវធានាឱ្យមានយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តដីការបស់ខ្លួន។

## ជំពូកទី៧

## ការពិនិត្យនីត្យានុកូលភាពនៃដីកា

**មាត្រា ៣៦.-**

ផ្លែបាលរាជធានី ខេត្តត្រូវបញ្ជូននូវរាល់ដីកាដែលបានអនុម័តដោយក្រុមប្រឹក្សារបស់ខ្លួនទៅក្រសួងមហាផ្ទៃយ៉ាងយូរប្រាំ(០៥)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃចេញដីកា ដើម្បីធ្វើការពិនិត្យនីត្យានុកូលភាព។

អភិបាលរាជធានី ខេត្តត្រូវបានទទួលប្រតិភូកម្មពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃក្នុងការពិនិត្យនីត្យានុកូលភាពលើដីកាដែលអនុម័តដោយក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌ។

រដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវបញ្ជូននូវរាល់ដីកាដែលបានអនុម័តដោយក្រុមប្រឹក្សារបស់ខ្លួន ទៅអភិបាលរាជធានី ខេត្តសាមីយ៉ាងយូរប្រាំ(០៥)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃចេញដីកាដើម្បីធ្វើការពិនិត្យនីត្យានុកូលភាព។

**មាត្រា ៣៧.-**

ក្រសួងមហាផ្ទៃ ឬអភិបាលរាជធានី ខេត្តត្រូវសហការជាមួយក្រសួង ស្ថាប័ន មន្ទីរ អង្គភាពពាក់ព័ន្ធនានាក្នុងការពិនិត្យនីត្យានុកូលភាពលើដីការបស់ក្រុមប្រឹក្សា។

**មាត្រា ៣៨.-**

ក្នុងករណីពិនិត្យឃើញថា ដីកាណាមួយមានអនីត្យានុកូលភាព ក្រសួងមហាផ្ទៃ ឬអភិបាលរាជធានី ខេត្តត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាដែលចេញដីកានោះ ដោយបញ្ជាក់អំពីហេតុផល ឬចំណុចដែលផ្ទុយពីបទបញ្ញត្តិណាមួយនៃរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន ដើម្បីឱ្យក្រុមប្រឹក្សាធ្វើការកែតម្រូវឡើងវិញ។

ក្រោយពេលទទួលបានសេចក្តីជូនដំណឹងពីក្រសួងមហាផ្ទៃ ឬអភិបាលរាជធានី ខេត្តសាមី ក្រុមប្រឹក្សាដែលចេញដីកាត្រូវកែតម្រូវដីកានោះឡើងវិញក្នុងអំឡុងពេលសាមសិប(៣០)ថ្ងៃនៃថ្ងៃធ្វើការ។ ក្នុងការកែតម្រូវនេះ ក្រុមប្រឹក្សាត្រូវអនុវត្តតាមនីតិវិធីស្តីពីការរៀបចំ និងការអនុម័តដីកាដូចមានចែងក្នុងជំពូកទី៨នៃអនុក្រឹត្យនេះ។

ក្នុងករណីដែលក្រុមប្រឹក្សាណាមួយ មិនបានធ្វើការកែតម្រូវតាមការជូនដំណឹងរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬអភិបាលរាជធានី ខេត្ត រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬអភិបាលរាជធានី ខេត្តត្រូវចាត់វិធានការចាំបាច់នានាដើម្បីឱ្យមានការកែតម្រូវ ឬលុបចោលដីកានោះ។

## ជំពូកទី៨

## បទបញ្ញត្តិដោយឡែក

**មាត្រា ៣៩.-**

ដីកាដែលមានលក្ខណៈជាឯកត្តកូត ត្រូវចុះហត្ថលេខាដោយអភិបាលក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន បន្ទាប់ពីទទួលបានការអនុម័តពីក្រុមប្រឹក្សា។

កិច្ចដំណើរការនៃការដាក់ចេញដីកាដែលមានលក្ខណៈជាឯកត្តកូត ត្រូវអនុវត្តតាមនីតិវិធីដែលមានចែងនៅក្នុងលិខិតបទដ្ឋានគតិយុត្តនានាជាធរមានពាក់ព័ន្ធទៅនឹងការគ្រប់គ្រងមន្ត្រីបុគ្គលិក ដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ។

## ជំពូកទី៩

## អន្តរបញ្ញត្តិ

**មាត្រា ៤០.-**

រាល់ដីកាដែលក្រុមប្រឹក្សា ឬអភិបាលបានដាក់ចេញមុនពេលអនុក្រឹត្យនេះចូលជាធរមាន ត្រូវនៅមានសុពលភាពរហូតដល់ដីកាទាំងនោះតម្រូវឱ្យមានការកែប្រែ ឬការរៀបចំជាថ្មី។

ការកែប្រែ ឬការរៀបចំជាថ្មីនូវដីកាទាំងនោះ ត្រូវអនុវត្តទៅតាមបទបញ្ញត្តិនានានៃអនុក្រឹត្យនេះ។

## ជំពូកទី១០

## អវសានបញ្ញត្តិ

**មាត្រា ៤១.-**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៤២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ក្រុមប្រឹក្សា និងគណៈអភិបាលនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី**

**នៃព្រះរាជាណាចក្រកម្ពុជា**

សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប.**

**ស ខេង**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ២២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់ចំនួនសមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ សម្រាប់អាណត្តិទី៣

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៩/០០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៩/០០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ០២ អនក្រ.បក ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៩ ស្តីពីការបង្កើតក្រុងកោះរ៉ុង នៃខេត្តព្រះសីហនុ

- បានឃើញអនុក្រឹត្យលេខ ០៣ អនក្រ.បក ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៩ ស្តីពីការបង្កើតខណ្ឌបឹងកេងកង នៃរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៩ ស្តីពីការបង្កើតខណ្ឌកំបូល នៃរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ.បក ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៩ ស្តីពីការបង្កើតស្រុកតាំងគោក នៃខេត្តកំពង់ធំ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៩ ស្តីពីការបង្កើតស្រុកបុរីអូរស្វាយសែនជ័យ នៃខេត្តស្ទឹងត្រែង
- បានឃើញអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៩ ស្តីពីការបង្កើតស្រុកតាលោសែនជ័យ នៃខេត្តពោធិ៍សាត់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.-**

ត្រូវបានកំណត់ចំនួនសមាជិកក្រុមប្រឹក្សារាជធានី និងសមាជិកក្រុមប្រឹក្សាខេត្តនីមួយៗសម្រាប់អាណត្តិទី៣ ដោយអនុលោមតាមមាត្រា១៨ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលរួមមានដូចខាងក្រោម៖

| | | |
|---|---|---|
| ១- រាជធានីភ្នំពេញ | មានចំនួនសមាជិកក្រុមប្រឹក្សា | ២៧ នាក់ |
| ២- ខេត្ត កណ្តាល | មានចំនួនសមាជិកក្រុមប្រឹក្សា | ២៧ នាក់ |
| ៣- ខេត្ត កំពង់ចាម | មានចំនួនសមាជិកក្រុមប្រឹក្សា | ២៧ នាក់ |
| ៤- ខេត្ត បាត់ដំបង | មានចំនួនសមាជិកក្រុមប្រឹក្សា | ២៧ នាក់ |
| ៥- ខេត្ត ព្រៃវែង | មានចំនួនសមាជិកក្រុមប្រឹក្សា | ២៧ នាក់ |
| ៦- ខេត្ត សៀមរាប | មានចំនួនសមាជិកក្រុមប្រឹក្សា | ២៧ នាក់ |
| ៧- ខេត្ត តាកែវ | មានចំនួនសមាជិកក្រុមប្រឹក្សា | ២៧ នាក់ |
| ៨- ខេត្ត ត្បូងឃ្មុំ | មានចំនួនសមាជិកក្រុមប្រឹក្សា | ២៥ នាក់ |
| ៩- ខេត្ត បន្ទាយមានជ័យ | មានចំនួនសមាជិកក្រុមប្រឹក្សា | ២៥ នាក់ |
| ១០-ខេត្ត កំពង់ស្ពឺ | មានចំនួនសមាជិកក្រុមប្រឹក្សា | ២៥ នាក់ |
| ១១-ខេត្ត កំពង់ធំ | មានចំនួនសមាជិកក្រុមប្រឹក្សា | ២៥ នាក់ |
| ១២-ខេត្ត កំពត | មានចំនួនសមាជិកក្រុមប្រឹក្សា | ២៥ នាក់ |
| ១៣-ខេត្ត កំពង់ឆ្នាំង | មានចំនួនសមាជិកក្រុមប្រឹក្សា | ២៣ នាក់ |
| ១៤-ខេត្ត ស្វាយរៀង | មានចំនួនសមាជិកក្រុមប្រឹក្សា | ២៣ នាក់ |
| ១៥-ខេត្ត ពោធិ៍សាត់ | មានចំនួនសមាជិកក្រុមប្រឹក្សា | ២១ នាក់ |
| ១៦-ខេត្ត ក្រចេះ | មានចំនួនសមាជិកក្រុមប្រឹក្សា | ២១ នាក់ |

| | | |
|---|---|---|
| ១៧-ខេត្ត ព្រះសីហនុ | មានចំនួនសមាជិកក្រុមប្រឹក្សា | ១៩ នាក់ |
| ១៨-ខេត្ត កោះកុង | មានចំនួនសមាជិកក្រុមប្រឹក្សា | ១៩ នាក់ |
| ១៩-ខេត្ត ព្រះវិហារ | មានចំនួនសមាជិកក្រុមប្រឹក្សា | ១៩ នាក់ |
| ២០-ខេត្ត រតនគិរី | មានចំនួនសមាជិកក្រុមប្រឹក្សា | ១៩ នាក់ |
| ២១-ខេត្ត ឧត្តរមានជ័យ | មានចំនួនសមាជិកក្រុមប្រឹក្សា | ១៩ នាក់ |
| ២២-ខេត្ត ស្ទឹងត្រែង | មានចំនួនសមាជិកក្រុមប្រឹក្សា | ១៧ នាក់ |
| ២៣-ខេត្ត មណ្ឌលគិរី | មានចំនួនសមាជិកក្រុមប្រឹក្សា | ១៥ នាក់ |
| ២៤-ខេត្ត ប៉ៃលិន | មានចំនួនសមាជិកក្រុមប្រឹក្សា | ១៥ នាក់ |
| ២៥-ខេត្ត កែប | មានចំនួនសមាជិកក្រុមប្រឹក្សា | ១៥ នាក់។ |

**មាត្រា ២.-**

ត្រូវបានកំណត់ចំនួនសមាជិកក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ នីមួយៗសម្រាប់អាណត្តិទី៣ ដោយអនុលោមតាមមាត្រា១៨ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលរួមមានដូចខាងក្រោម៖

**១.រាជធានីភ្នំពេញ**

| | | |
|---|---|---|
| ១- ខណ្ឌ មានជ័យ | មានចំនួនសមាជិកក្រុមប្រឹក្សា | ២១ នាក់ |
| ២- ខណ្ឌ ច្បារអំពៅ | -ដ- | ២១ នាក់ |
| ៣- ខណ្ឌ ទួលគោក | -ដ- | ២១ នាក់ |
| ៤- ខណ្ឌ ឫស្សីកែវ | -ដ- | ២១ នាក់ |
| ៥- ខណ្ឌ សែនសុខ | -ដ- | ២១ នាក់ |
| ៦- ខណ្ឌ ពោធិ៍សែនជ័យ | -ដ- | ២១ នាក់ |
| ៧- ខណ្ឌ ចំការមន | -ដ- | ១៩ នាក់ |
| ៨- ខណ្ឌ ដង្កោ | -ដ- | ១៩ នាក់ |
| ៩- ខណ្ឌ ដូនពេញ | -ដ- | ១៩ នាក់ |
| ១០-ខណ្ឌ ៧មករា | -ដ- | ១៩ នាក់ |
| ១១-ខណ្ឌ បឹងកេងកង | -ដ- | ១៧ នាក់ |
| ១២-ខណ្ឌ កំបូល | -ដ- | ១៧ នាក់ |
| ១៣-ខណ្ឌ ជ្រោយចង្វារ | -ដ- | ១៧ នាក់ |
| ១៤-ខណ្ឌ ព្រែកព្នៅ | -ដ- | ១៧ នាក់ |

**២.ខេត្ត កណ្តាល**

| | | |
|---|---|---|
| ១៥-ក្រុង តាខ្មៅ | មានចំនួនសមាជិកក្រុមប្រឹក្សា | ២១ នាក់ |
| ១៦-ស្រុក កៀនស្វាយ | -ដ- | ២១ នាក់ |
| ១៧-ស្រុក ស្អាង | -ដ- | ២១ នាក់ |

| | | |
|---|---|---|
| ១៨-ស្រុក កោះធំ | -ដ- | ២១ នាក់ |
| ១៩-ស្រុក ខ្សាច់កណ្ដាល | -ដ- | ២១ នាក់ |
| ២០-ស្រុក ពញាឮ | -ដ- | ២១ នាក់ |
| ២១-ស្រុក កណ្ដាលស្ទឹង | -ដ- | ២១ នាក់ |
| ២២-ស្រុក អង្គស្នួល | -ដ- | ១៩ នាក់ |
| ២៣-ស្រុក មុខកំពូល | -ដ- | ១៩ នាក់ |
| ២៤-ស្រុក ល្វាឯម | -ដ- | ១៩ នាក់ |
| ២៥-ស្រុក លើកដែក | -ដ- | ១៧ នាក់ |
| **៣.ខេត្ត កំពង់ចាម** | | |
| ២៦-ស្រុក ស្ទឹងត្រង់ | មានចំនួនសមាជិកក្រុមប្រឹក្សា | ២១ នាក់ |
| ២៧-ស្រុក ចំការលើ | -ដ- | ២១ នាក់ |
| ២៨-ស្រុក កំពង់សៀម | -ដ- | ២១ នាក់ |
| ២៩-ស្រុក ព្រៃឈរ | -ដ- | ២១ នាក់ |
| ៣០-ស្រុក បាធាយ | -ដ- | ២១ នាក់ |
| ៣១-ស្រុក ស្រីសន្ធរ | -ដ- | ២១ នាក់ |
| ៣២-ស្រុក កងមាស | -ដ- | ២១ នាក់ |
| ៣៣-ស្រុក ជើងព្រៃ | -ដ- | ២១ នាក់ |
| ៣៤-ស្រុក កោះសូទិន | -ដ- | ១៩ នាក់ |
| ៣៥-ក្រុង កំពង់ចាម | -ដ- | ១៧ នាក់ |
| **៤.ខេត្ត បាត់ដំបង** | | |
| ៣៦-ក្រុង បាត់ដំបង | មានចំនួនសមាជិកក្រុមប្រឹក្សា | ២១ នាក់ |
| ៣៧-ស្រុក ថ្មគោល | -ដ- | ២១ នាក់ |
| ៣៨-ស្រុក មោងឫស្សី | -ដ- | ២១ នាក់ |
| ៣៩-ស្រុក សង្កែ | -ដ- | ២១ នាក់ |
| ៤០-ស្រុក បាណន់ | -ដ- | ២១ នាក់ |
| ៤១-ស្រុក បវេល | -ដ- | ២១ នាក់ |
| ៤២-ស្រុក ឯកភ្នំ | -ដ- | ១៩ នាក់ |
| ៤៣-ស្រុក ភ្នំព្រឹក | -ដ- | ១៧ នាក់ |
| ៤៤-ស្រុក កំរៀង | -ដ- | ១៧ នាក់ |
| ៤៥-ស្រុក សំឡូត | -ដ- | ១៧ នាក់ |
| ៤៦-ស្រុក រុក្ខគិរី | -ដ- | ១៧ នាក់ |
| ៤៧-ស្រុក សំពៅលូន | -ដ- | ១៧ នាក់ |

| | | |
|---|---|---|
| ៤៨-ស្រុក តេនមណ្ឌល | -ដ- | ១៥ នាក់ |
| ៤៩-ស្រុក គាស់ក្រឡ | -ដ- | ១៥ នាក់ |

**៥.ខេត្ត ព្រៃវែង**

| | | |
|---|---|---|
| ៥០-ស្រុក ពារាំង | មានចំនួនសមាជិកក្រុមប្រឹក្សា | ២១ នាក់ |
| ៥១-ស្រុក ព្រះស្ដេច | -ដ- | ២១ នាក់ |
| ៥២-ស្រុក កំពង់ត្របែក | -ដ- | ២១ នាក់ |
| ៥៣-ស្រុក ស្វាយអន្ទរ | -ដ- | ២១ នាក់ |
| ៥៤-ស្រុក មេសាង | -ដ- | ២១ នាក់ |
| ៥៥-ស្រុក បាភ្នំ | -ដ- | ១៩ នាក់ |
| ៥៦-ស្រុក ស៊ីធរកណ្ដាល | -ដ- | ១៩ នាក់ |
| ៥៧-ស្រុក កញ្ជ្រៀច | -ដ- | ១៩ នាក់ |
| ៥៨-ស្រុក ពាមជរ | -ដ- | ១៩ នាក់ |
| ៥៩-ស្រុក កំចាយមារ | -ដ- | ១៩ នាក់ |
| ៦០-ស្រុក ពាមរក៍ | -ដ- | ១៧ នាក់ |
| ៦១-ស្រុក ពោធិ៍រៀង | -ដ- | ១៧ នាក់ |
| ៦២-ក្រុង ព្រៃវែង | -ដ- | ១៥ នាក់ |

**៦.ខេត្ត សៀមរាប**

| | | |
|---|---|---|
| ៦៣-ក្រុង សៀមរាប | មានចំនួនសមាជិកក្រុមប្រឹក្សា | ២១ នាក់ |
| ៦៤-ស្រុក ជីក្រែង | -ដ- | ២១ នាក់ |
| ៦៥-ស្រុក ពួក | -ដ- | ២១ នាក់ |
| ៦៦-ស្រុក សូទ្រនិគម | -ដ- | ២១ នាក់ |
| ៦៧-ស្រុក ប្រាសាទបាគង | -ដ- | ១៩ នាក់ |
| ៦៨-ស្រុក ក្រឡាញ់ | -ដ- | ១៩ នាក់ |
| ៦៩-ស្រុក អង្គរជុំ | -ដ- | ១៩ នាក់ |
| ៧០-ស្រុក វ៉ារិន | -ដ- | ១៧ នាក់ |
| ៧១-ស្រុក បន្ទាយស្រី | -ដ- | ១៥ នាក់ |
| ៧២-ស្រុក ស្រីស្នំ | -ដ- | ១៥ នាក់ |
| ៧៣-ស្រុក ស្វាយលើ | -ដ- | ១៥ នាក់ |
| ៧៤-ស្រុក អង្គរធំ | -ដ- | ១៣ នាក់ |

**៧.ខេត្ត តាកែវ**

| | | |
|---|---|---|
| ៧៥-ស្រុក បាទី | មានចំនួនសមាជិកក្រុមប្រឹក្សា | ២១ នាក់ |
| ៧៦-ស្រុក ត្រាំកក់ | -ដ- | ២១ នាក់ |

| | | |
|---|---|---|
| ៧៧-ស្រុក សំពោង | -ដ- | ២១ នាក់ |
| ៧៨-ស្រុក ទ្រាំង | -ដ- | ២១ នាក់ |
| ៧៩-ស្រុក គិរីវង់ | -ដ- | ២១ នាក់ |
| ៨០-ស្រុក ព្រៃកប្បាស | -ដ- | ២១ នាក់ |
| ៨១-ស្រុក អង្គរបូរី | -ដ- | ១៧ នាក់ |
| ៨២-ស្រុក កោះអណ្តែត | -ដ- | ១៧ នាក់ |
| ៨៣-ក្រុង ដូនកែវ | -ដ- | ១៧ នាក់ |
| ៨៤-ស្រុក បុរីជលសារ | -ដ- | ១៥ នាក់ |

**៨.ខេត្ត ត្បូងឃ្មុំ**

| | | |
|---|---|---|
| ៨៥-ស្រុក ត្បូងឃ្មុំ | មានចំនួនសមាជិកក្រុមប្រឹក្សា | ២១ នាក់ |
| ៨៦-ស្រុក មេមត់ | -ដ- | ២១ នាក់ |
| ៨៧-ស្រុក ពញាក្រែក | -ដ- | ២១ នាក់ |
| ៨៨-ស្រុក ក្រូចឆ្មារ | -ដ- | ២១ នាក់ |
| ៨៩-ស្រុក អូររាំងឪ | -ដ- | ១៩ នាក់ |
| ៩០-ស្រុក តំបែរ | -ដ- | ១៩ នាក់ |
| ៩១-ក្រុង សួង | -ដ- | ១៥ នាក់ |

**៩.ខេត្ត បន្ទាយមានជ័យ**

| | | |
|---|---|---|
| ៩២-ស្រុក មង្គលបូរី | មានចំនួនសមាជិកក្រុមប្រឹក្សា | ២១ នាក់ |
| ៩៣-ស្រុក ព្រះនេត្រព្រះ | -ដ- | ២១ នាក់ |
| ៩៤-ក្រុង សិរីសោភ័ណ | -ដ- | ១៩ នាក់ |
| ៩៥-ក្រុង ប៉ោយប៉ែត | -ដ- | ១៩ នាក់ |
| ៩៦-ស្រុក ស្វាយចេក | -ដ- | ១៩ នាក់ |
| ៩៧-ស្រុក ថ្មពួក | -ដ- | ១៩ នាក់ |
| ៩៨-ស្រុក អូរជ្រៅ | -ដ- | ១៧ នាក់ |
| ៩៩-ស្រុក ភ្នំស្រុក | -ដ- | ១៧ នាក់ |
| ១០០-ស្រុក ម៉ាឡៃ | -ដ- | ១៧ នាក់ |

**១០.ខេត្ត កំពង់ស្ពឺ**

| | | |
|---|---|---|
| ១០១-ស្រុក បសេដ្ឋ | មានចំនួនសមាជិកក្រុមប្រឹក្សា | ២១ នាក់ |
| ១០២-ស្រុក គងពិសី | -ដ- | ២១ នាក់ |
| ១០៣-ស្រុក ឧដុង្គ | -ដ- | ២១ នាក់ |
| ១០៤-ស្រុក សំរោងទង | -ដ- | ២១ នាក់ |
| ១០៥-ស្រុក ភ្នំស្រួច | -ដ- | ២១ នាក់ |

| | | |
|---|---|---|
| ១០៦-ស្រុក ថ្ពង | -ដ- | ១៧ នាក់ |
| ១០៧-ក្រុង ច្បារមន | -ដ- | ១៧ នាក់ |
| ១០៨-ស្រុក ឱរ៉ាល់ | -ដ- | ១៥ នាក់ |

**១១.ខេត្ត កំពង់ធំ**

| | | |
|---|---|---|
| ១០៩-ស្រុក បារាយណ៍ | មានចំនួនសមាជិកក្រុមប្រឹក្សា | ២១ នាក់ |
| ១១០-ស្រុក ស្ទោង | -ដ- | ២១ នាក់ |
| ១១១-ស្រុក កំពង់ស្វាយ | -ដ- | ២១ នាក់ |
| ១១២-ស្រុក សន្ទុក | -ដ- | ២១ នាក់ |
| ១១៣-ស្រុក តាំងគោក | -ដ- | ១៩ នាក់ |
| ១១៤-ស្រុក ប្រាសាទបល្ល័ង្គ | -ដ- | ១៧ នាក់ |
| ១១៥-ស្រុក សណ្ដាន់ | -ដ- | ១៧ នាក់ |
| ១១៦-ក្រុង ស្ទឹងសែន | -ដ- | ១៧ នាក់ |
| ១១៧-ស្រុក ប្រាសាទសំបូរ | -ដ- | ១៥ នាក់ |

**១២.ខេត្ត កំពត**

| | | |
|---|---|---|
| ១១៨-ស្រុក ទឹកឈូ | មានចំនួនសមាជិកក្រុមប្រឹក្សា | ២១ នាក់ |
| ១១៩-ស្រុក ឈូក | -ដ- | ២១ នាក់ |
| ១២០-ស្រុក កំពង់ត្រាច | -ដ- | ១៩ នាក់ |
| ១២១-ស្រុក បន្ទាយមាស | -ដ- | ១៩ នាក់ |
| ១២២-ស្រុក អង្គរជ័យ | -ដ- | ១៩ នាក់ |
| ១២៣-ស្រុក ដងទង់ | -ដ- | ១៧ នាក់ |
| ១២៤-ស្រុក ជុំគីរី | -ដ- | ១៧ នាក់ |
| ១២៥-ក្រុង កំពត | -ដ- | ១៥ នាក់ |

**១៣.ខេត្ត កំពង់ឆ្នាំង**

| | | |
|---|---|---|
| ១២៦-ស្រុក រលាប្អៀរ | មានចំនួនសមាជិកក្រុមប្រឹក្សា | ២១ នាក់ |
| ១២៧-ស្រុក កំពង់ត្រឡាច | -ដ- | ១៩ នាក់ |
| ១២៨-ស្រុក សាមគ្គីមានជ័យ | -ដ- | ១៩ នាក់ |
| ១២៩-ស្រុក កំពង់លែង | -ដ- | ១៧ នាក់ |
| ១៣០-ស្រុក បរិបូណ៌ | -ដ- | ១៧ នាក់ |
| ១៣១-ស្រុក ទឹកផុស | -ដ- | ១៧ នាក់ |
| ១៣២-ក្រុង កំពង់ឆ្នាំង | -ដ- | ១៥ នាក់ |
| ១៣៣-ស្រុក ជលគិរី | -ដ- | ១៥ នាក់ |

**១៤.ខេត្ត ស្វាយរៀង**

| | | |
|---|---|---|
| ១៣៤-ស្រុក រមាសហែក | មានចំនួនសមាជិកក្រុមប្រឹក្សា | ២១ នាក់ |
| ១៣៥-ស្រុក ស្វាយជ្រំ | -ដ- | ២១ នាក់ |
| ១៣៦-ស្រុក កំពង់រោទិ៍ | -ដ- | ១៩ នាក់ |
| ១៣៧-ស្រុក រំដួល | -ដ- | ១៧ នាក់ |
| ១៣៨-ស្រុក ស្វាយទាប | -ដ- | ១៧ នាក់ |
| ១៣៩-ក្រុង ស្វាយរៀង | -ដ- | ១៥ នាក់ |
| ១៤០-ក្រុង បាវិត | -ដ- | ១៥ នាក់ |
| ១៤១-ស្រុក ចន្ទ្រា | -ដ- | ១៥ នាក់ |

**១៥.ខេត្ត ពោធិ៍សាត់**

| | | |
|---|---|---|
| ១៤២-ស្រុក បាកាន | មានចំនួនសមាជិកក្រុមប្រឹក្សា | ២១ នាក់ |
| ១៤៣-ស្រុក ក្រគរ | -ដ- | ២១ នាក់ |
| ១៤៤-ក្រុង ពោធិ៍សាត់ | -ដ- | ១៧ នាក់ |
| ១៤៥-ស្រុក ភ្នំក្រវាញ | -ដ- | ១៧ នាក់ |
| ១៤៦-ស្រុក កណ្ដៀង | -ដ- | ១៧ នាក់ |
| ១៤៧-ស្រុក តាលោសែនជ័យ | -ដ- | ១៥ នាក់ |
| ១៤៨-ស្រុក វាលវែង | -ដ- | ១៣ នាក់ |

**១៦.ខេត្ត ក្រចេះ**

| | | |
|---|---|---|
| ១៤៩-ស្រុក ស្នួល | មានចំនួនសមាជិកក្រុមប្រឹក្សា | ១៩ នាក់ |
| ១៥០-ស្រុក ព្រែកប្រសព្វ | -ដ- | ១៩ នាក់ |
| ១៥១-ស្រុក សំបូរ | -ដ- | ១៩ នាក់ |
| ១៥២-ស្រុក ចិត្របុរី | -ដ- | ១៩ នាក់ |
| ១៥៣-ស្រុក ឆ្លូង | -ដ- | ១៧ នាក់ |
| ១៥៤-ក្រុង ក្រចេះ | -ដ- | ១៥ នាក់ |

**១៧.ខេត្ត ព្រះសីហនុ**

| | | |
|---|---|---|
| ១៥៥-ក្រុង ព្រះសីហនុ | មានចំនួនសមាជិកក្រុមប្រឹក្សា | ១៩ នាក់ |
| ១៥៦-ស្រុក ព្រៃនប់ | -ដ- | ១៩ នាក់ |
| ១៥៧-ក្រុង កោះរ៉ុង | -ដ- | ១១ នាក់ |
| ១៥៨-ស្រុក កំពង់សីលា | -ដ- | ១១ នាក់ |
| ១៥៩-ស្រុក ស្ទឹងហាវ | -ដ- | ១១ នាក់ |

**១៨.ខេត្ត កោះកុង**

| | | |
|---|---|---|
| ១៦០-ក្រុង ខេមរភូមិន្ទ | មានចំនួនសមាជិកក្រុមប្រឹក្សា | ១៥ នាក់ |

| | | |
|---|---|---|
| ១៦១-ស្រុក ស្រែអំបិល | -ដ- | ១៥ នាក់ |
| ១៦២-ស្រុក បទុមសាគរ | -ដ- | ១៣ នាក់ |
| ១៦៣-ស្រុក មណ្ឌលសីមា | -ដ- | ១១ នាក់ |
| ១៦៤-ស្រុក គិរីសាគរ | -ដ- | ១១ នាក់ |
| ១៦៥-ស្រុក កោះកុង | -ដ- | ១១ នាក់ |
| ១៦៦-ស្រុក ថ្មបាំង | -ដ- | ១១ នាក់ |

**១៩.ខេត្ត ព្រះវិហារ**

| | | |
|---|---|---|
| ១៦៧-ស្រុក រវៀង | មានចំនួនសមាជិកក្រុមប្រឹក្សា | ១៧ នាក់ |
| ១៦៨-ស្រុក ជាំក្សាន្ត | -ដ- | ១៧ នាក់ |
| ១៦៩-ស្រុក គូលែន | -ដ- | ១៥ នាក់ |
| ១៧០-ស្រុក ជ័យសែន | -ដ- | ១៣ នាក់ |
| ១៧១-ស្រុក សង្គមថ្មី | -ដ- | ១៣ នាក់ |
| ១៧២-ស្រុក ឆែប | -ដ- | ១៣ នាក់ |
| ១៧៣-ក្រុង ព្រះវិហារ | -ដ- | ១៣ នាក់ |
| ១៧៤-ស្រុក ត្បែងមានជ័យ | -ដ- | ១១ នាក់ |

**២០.ខេត្ត រតនគិរី**

| | | |
|---|---|---|
| ១៧៥-ក្រុង បានលុង | មានចំនួនសមាជិកក្រុមប្រឹក្សា | ១៥ នាក់ |
| ១៧៦-ស្រុក អូរជុំ | -ដ- | ១៣ នាក់ |
| ១៧៧-ស្រុក វើនសៃ | -ដ- | ១៣ នាក់ |
| ១៧៨-ស្រុក បរកែវ | -ដ- | ១៣ នាក់ |
| ១៧៩-ស្រុក លំផាត់ | -ដ- | ១៣ នាក់ |
| ១៨០-ស្រុក កូនមុំ | -ដ- | ១៣ នាក់ |
| ១៨១-ស្រុក អូរយ៉ាដាវ | -ដ- | ១៣ នាក់ |
| ១៨២-ស្រុក អណ្ដូងមាស | -ដ- | ១១ នាក់ |
| ១៨៣-ស្រុក តាវែង | -ដ- | ១១ នាក់ |

**២១.ខេត្ត ស្ទឹងត្រែង**

| | | |
|---|---|---|
| ១៨៤-ក្រុង ស្ទឹងត្រែង | មានចំនួនសមាជិកក្រុមប្រឹក្សា | ១៥ នាក់ |
| ១៨៥-ស្រុក ថាឡាបរិវ៉ាត់ | -ដ- | ១៥ នាក់ |
| ១៨៦-ស្រុក សេសាន | -ដ- | ១៣ នាក់ |
| ១៨៧-ស្រុក សៀមប៉ាង | -ដ- | ១៣ នាក់ |
| ១៨៨-ស្រុក សៀមបូក | -ដ- | ១៣ នាក់ |
| ១៨៩-ស្រុក បុរីអូរស្វាយសែនជ័យ | -ដ- | ១១ នាក់ |

**២២.ខេត្ត ឧត្តរមានជ័យ**

| | | |
|---|---|---|
| ១៩០-ក្រុង សំរោង | មានចំនួនសមាជិកក្រុមប្រឹក្សា | ១៧ នាក់ |
| ១៩១-ស្រុក ត្រពាំងប្រាសាទ | -ដ- | ១៧ នាក់ |
| ១៩២-ស្រុក បន្ទាយអំពិល | -ដ- | ១៥ នាក់ |
| ១៩៣-ស្រុក អន្លង់វែង | -ដ- | ១៥ នាក់ |
| ១៩៤-ស្រុក ចុងកាល់ | -ដ- | ១៣ នាក់ |

**២៣.ខេត្ត មណ្ឌលគិរី**

| | | |
|---|---|---|
| ១៩៥-ស្រុក កែវសីមា | មានចំនួនសមាជិកក្រុមប្រឹក្សា | ១៣ នាក់ |
| ១៩៦-ស្រុក កោះញែក | -ដ- | ១៣ នាក់ |
| ១៩៧-ស្រុក អូររាំង | -ដ- | ១១ នាក់ |
| ១៩៨-ស្រុក ពេជ្រាដា | -ដ- | ១១ នាក់ |
| ១៩៩-ក្រុង សែនមនោរម្យ | -ដ- | ១១ នាក់ |

**២៤.ខេត្ត ប៉ៃលិន**

| | | |
|---|---|---|
| ២០០-ក្រុង ប៉ៃលិន | មានចំនួនសមាជិកក្រុមប្រឹក្សា | ១៥ នាក់ |
| ២០១-ស្រុក សាលាក្រៅ | -ដ- | ១៥ នាក់ |

**២៥.ខេត្ត កែប**

| | | |
|---|---|---|
| ២០២-ក្រុង កែប | មានចំនួនសមាជិកក្រុមប្រឹក្សា | ១៣ នាក់ |
| ២០៣-ស្រុក ដំណាក់ចង្អើរ | -ដ- | ១៣ នាក់។ |

**មាត្រា ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃសុក្រ ៥ រោចខែ បុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ✓
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មករា ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:....០៤...សរ.........

# សារាចរ
## ស្តីពី
## វិធានការបង្ការទប់ស្កាត់ និងបង្ក្រាបសកម្មភាព "ក្មេងទំនើង"

កន្លងមក ក្រសួង ស្ថាប័នពាក់ព័ន្ធ ក៏ដូចជារដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ បានខិតខំអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួនយ៉ាងសកម្ម ទទួលបានលទ្ធផលការងារល្អប្រសើរ ជាពិសេស ធានាបានសុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសង្គម និងភាពសុខសាន្តជូនប្រជាពលរដ្ឋ ។ ជាក់ស្តែង នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ សកម្មភាពបទល្មើសនានា បានថយចុះ គួរឱ្យកត់សម្គាល់ ។

ដោយឡែក នាពេលថ្មីៗនេះ រាជរដ្ឋាភិបាលបានពិនិត្យឃើញថា សកម្មភាពនៃ "ក្មេងទំនើង" បានបន្តរីករាលដាលក្រោមរូបភាពផ្សេងៗរហូតដល់ទីជនបទ ។ ក្មេងទំនើងទាំងនេះ តែងបានប្រមូលផ្តុំគ្នាជាក្រុម ធ្វើសកម្មភាពអុកឡុកដល់សង្គមតាមតែអំពើចិត្តដោយមិនញញើត ឬគោរពកោតខ្លាចច្បាប់រដ្ឋ ឬក៏សមត្ថកិច្ចអ្វីឡើយ ដូចជាបង្កការអុកឡុករំខាននៅតាមទីកន្លែងសាធារណៈ នៅតាមសាលារៀន នៅតាមពិធីជប់លៀង វាយកំសាន្តនានាធ្វើការគំរាមកំហែងដល់សាធារណជន ជិះរថយន្ត ឬម៉ូតូប្រដេញគ្នាតាមផ្លូវសាធារណៈឬជិះម៉ូតូបង្អោះ ។ល។ ហើយពេលខ្លះ ក្មេងទំនើងទាំងនេះ បានធ្វើសកម្មភាពឈានទៅដល់ការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ និងសកម្មភាពល្មើសផ្សេងៗទៀត បណ្តាលឱ្យប៉ះពាល់ដល់ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និង ភាពសុខសាន្តរបស់ប្រជាពលរដ្ឋ ។

ដើម្បីគ្រប់គ្រងស្ថានការណ៍នេះ និងចាត់វិធានការបង្ការទប់ស្កាត់និងបង្ក្រាបសកម្មភាព របស់ក្មេងទំនើងល្មើសទាំងនេះ ឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាព ក្នុងគោលដៅធានារក្សា បរិយាកាសសង្គមល្អប្រសើរ ប្រកបដោយ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ភាពសុខសាន្ត និងសេចក្តីថ្លៃថ្នូរ រាជរដ្ឋាភិបាល សូមដាក់ចេញវិធានការដូចខាងក្រោម :

១- ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ ក្រសួងយុត្តិធម៌ ក្រសួងទេសចរណ៍ ក្រសួងអប់រំយុវជន និងកីឡា រដ្ឋបាលរាជធានី-ខេត្ត និងក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ត្រូវបង្កើនការយកចិត្តទុកដាក់គ្រប់គ្រង ឬចាត់វិធានការគ្រប់គ្រងមុខសញ្ញា និងសកម្មភាពនៃក្រុមក្មេងទំនើង ដែលបង្កការអុកឡុករំខានដល់ប្រជាពលរដ្ឋ និង ធ្វើឱ្យប៉ះពាល់ដល់ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ត្រូវមានវិធានការអប់រំ វិធានការរដ្ឋបាល ឬវិធានការច្បាប់ ដែលចាំបាច់និងសមស្រប ដើម្បីបង្ការទប់ស្កាត់ និងបង្ក្រាបអោយមានប្រសិទ្ធភាព ។

២ - អគ្គស្នងការដ្ឋាននគរបាលជាតិ បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស គណៈបញ្ជាការឯកភាពរាជធានី-ខេត្ត និងក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ត្រូវចាត់វិធានការជាក់ស្តែងនានា នៅក្នុងសមត្ថកិច្ចរបស់ខ្លួន ធ្វើអន្តរាគមន៍បង្ការទប់ស្កាត់និងបង្រ្កាបឱ្យបានទាន់ពេលវេលា នូវរាល់សកម្មភាពអុកឡុកបង្កការប៉ះពាល់ដល់សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងសកម្មភាពល្មើស របស់ក្រុមក្មេងទំនើងនៅតាមមូលដ្ឋាននីមួយៗ ។ ក្នុងករណីចាំបាច់ មន្ត្រីនគរបាលយុត្តិធម៌ គណៈបញ្ជាការឯកភាពរាជធានី ខេត្ត អាចចាត់វិធានការអន្តរាគមន៍ផ្នែករដ្ឋបាល តាមស្ថានភាពជាក់ស្តែងនានា និងអាចធ្វើការនាំខ្លួនក្រុមក្មេងទំនើង ដែលបានធ្វើសកម្មភាពបង្កការអុកឡុកទាំងនោះ មកអង្គភាពរបស់ខ្លួន ដើម្បីធ្វើការអប់រំណែនាំដោយមានការចូលរួមទទួលខុសត្រូវពីឪពុក ម្តាយ ឬអាណាព្យាបាល ។

៣- ក្នុងករណីសកម្មភាពអុកឡុករបស់ក្មេងទំនើង បង្កើតបានជាបទល្មើសព្រហ្មទណ្ឌ អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់នីតិវិធីនិងប្រើអំណាចតាមផ្លូវច្បាប់ ធ្វើអន្តរាគមន៍ឱ្យបានទាន់ពេលវេលា ដើម្បីបង្រ្កាបនិងកសាងសំណុំរឿងបញ្ជូនទៅអយ្យការ ដើម្បីចាត់ការជាសមត្ថកិច្ចតាមនីតិវិធីនៃច្បាប់ ។

៤- ក្រសួងទេសចរណ៍ រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ ក្រសួង ស្ថាប័ន និង អាជ្ញាធរពាក់ព័ន្ធមានសមត្ថកិច្ចចេញអាជ្ញាប័ណ្ណ ត្រូវដាក់ចេញនូវវិធានការណែនាំ និងហាមឃាត់ចំពោះការប្រមូលផ្តុំគ្នារបស់ក្មេងទំនើង នៅតាមផ្ទះសំណាក់ សណ្ឋាគារ ឬក្លិបកំសាន្ត ជាដើម ដើម្បីធ្វើសកម្មភាពល្មើសច្បាប់នានា ។ អ្នកគ្រប់គ្រង ផ្ទះសំណាក់ សណ្ឋាគារ ឬក្លិបកំសាន្ត ត្រូវសហការរាយការណ៍ជាបន្ទាន់ ដល់អាជ្ញាធរមានសមត្ថកិច្ច អំពីសកម្មភាពនៃក្រុមក្មេងទំនើង នៅក្នុងទីកន្លែងរបស់ខ្លួនគ្រប់គ្រង ។

៥- ដើម្បីធានារក្សាការពារសន្តិសុខ សណ្តាប់ធ្នាប់របៀបរៀបរយសង្គម និងភាពសុខសាន្តរបស់ប្រជាពលរដ្ឋ នៅក្នុងមូលដ្ឋានរបស់ខ្លួន រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ត្រូវដាក់ចេញនូវ វិធាន បញ្ញត្តិ ឬ បទបញ្ជាផ្នែករដ្ឋបាលចាំបាច់នានា តាមស្ថានភាពជាក់ស្តែង ជាពិសេស ត្រូវកំណត់ធ្វើការហាមឃាត់ នូវសកម្មភាពដែលជាមុខសញ្ញានាំទៅដល់ការប្រមូលផ្តុំគ្នាបង្កើតឱ្យមានជាក្រុមក្មេងទំនើង និងត្រូវលើកទឹកចិត្តដល់ប្រជាពលរដ្ឋ និងអង្គការមិនមែនរដ្ឋាភិបាលនានា ឱ្យចូលរួមសហការ និងរាយការណ៍ផ្តល់ព័ត៌មានទាក់ទងនឹងសកម្មភាពនៃក្មេងទំនើងទាំងនេះ ។

៦- ក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងបំផុសចលនាឱ្យមានការចូលរួមពីប្រជាពលរដ្ឋនៅតាមសហគមន៍ និងអង្គការមិនមែនរដ្ឋាភិបាលនានា ជាពិសេស លោកគ្រូ អ្នកគ្រូ ឪពុក ម្តាយ និងអាណាព្យាបាល ក្នុងការអប់រំណែនាំដល់កូនចៅ បងប្អូន សាច់ញាតិរបស់ខ្លួន សិស្សានុសិស្ស ឱ្យយល់ដឹងអំពីគ្រោះថ្នាក់នៃសកម្មភាពក្រុមក្មេងទំនើង ចៀសវាងការចូលរួម ឬប្រញាប់ដកខ្លួនចេញពីក្រុមនេះ ព្រមទាំងរាយការណ៍វែកមុខ អំពីមុខសញ្ញា និងសកម្មភាពរបស់ក្រុមក្មេងទំនើង ដល់អាជ្ញាធរមានសមត្ថកិច្ចជាបន្ទាន់ ។

ទទួលបានសារាចរនេះ ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ អគ្គស្នងការដ្ឋាននគរបាលជាតិ បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស ក្រសួង ស្ថាប័នពាក់ព័ន្ធ និង គណៈបញ្ជាការឯកភាពរាជធានី ខេត្ត ត្រូវចាត់វិធានការអនុវត្តអោយមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-គ្រប់ក្រសួង ស្ថាប័ន
-រាជធានី-ខេត្ត
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប

ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)

លេខ៖ [illegible]/គ.ជ.អ.ប

## សេចក្ដីសម្រេច

## ស្ដីពី

## ការធ្វើសមាហរណកម្មបុគ្គលិក និងការរៀបចំមុខតំណែងគ្រប់គ្រង នៅក្នុងរចនាសម្ព័ន្ធនៃរដ្ឋបាលស្រុកល្វាឯមនៃខេត្តកណ្ដាល

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប.

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្ដីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្ដីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៧៣ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្ដីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្ដីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ១៨៤ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក
- យោងសំណើរបស់រដ្ឋបាលស្រុកល្វាឯម និងសំណើរបស់រដ្ឋបាលខេត្តកណ្ដាល

៧៦

# សម្រេច

**ប្រការ ១.-**

ត្រូវបានផ្ទេរសមាហរណកម្មបុគ្គលិក និងរៀបចំមុខតំណែងគ្រប់គ្រងនៅក្នុងរចនាសម្ព័ន្ធនៃរដ្ឋបាលស្រុកល្វាឯមនៃខេត្តកណ្តាល ចំនួន៥៨នាក់ដូចមានរាយនាមខាងក្រោម៖

| ល.រ | គោត្តនាម និងនាមខ្លួន | ភេទ | ឋានន្តរស័ក្តិ ថ្នាក់ | ក្របខ័ណ្ឌ | មុខតំណែង |
|---|---|---|---|---|---|
| **១. ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ** | | | | | |
| ១ | កែវ ជូនភិរុណ | ប្រុស | គ.៧ | លេខាធិការរដ្ឋបាល | ប្រធាន |
| ២ | ឈុន ចន្ទី | ស្រី | គ.៩ | លេខាធិការរដ្ឋបាល | មន្ត្រី |
| ៣ | ជួន សុគន្ធា | ស្រី | ខ.៣.៤ | មន្ត្រីក្រមការ | មន្ត្រី |
| ៤ | រស់ ស្រីណែត | ស្រី | គ.១០ | លេខាធិការរដ្ឋបាល | មន្ត្រី |
| **២. អង្គភាពលទ្ធកម្ម** | | | | | |
| ១ | ហង្ស ដាឡែន | ស្រី | គ.៧ | លេខាធិការរដ្ឋបាល | អនុប្រធាន |
| **៣. ការិយាល័យគ្រប់គ្រងធនធានមនុស្ស** | | | | | |
| ១ | សៅ សុភ័ណ | ស្រី | ខ.៣.៣ | មន្ត្រីក្រមការ | អនុប្រធាន |
| ២ | កែវ សីហា | ប្រុស | ខ.៣.៤ | មន្ត្រីក្រមការ | មន្ត្រី |
| **៤. ការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់** | | | | | |
| ១ | ផុន វណ្ណារ៉ាក់ | ប្រុស | គ.២ | លេខាធិការរដ្ឋបាល | ប្រធាន |
| ២ | ចេង សុធា | ស្រី | ខ.៣.២ | មន្ត្រីក្រមការ | អនុប្រធាន |
| ៣ | កែវ ជូនសុគន្ធា | ស្រី | គ.៧ | លេខាធិការរដ្ឋបាល | អនុប្រធាន |
| **៥. ការិយាល័យលេខាធិការក្រុមប្រឹក្សា** | | | | | |
| ១ | ញែម ពៅពិសី | ស្រី | គ.៨ | លេខាធិការរដ្ឋបាល | មន្ត្រី |
| **៦. ការិយាល័យត្រួតពិនិត្យផ្ទៃក្នុង** | | | | | |
| ១ | ឈឹម បូរិន | ស្រី | គ.៨ | លេខាធិការរដ្ឋបាល | អនុប្រធាន |
| ២ | ហ៊ិន ហួង | ប្រុស | គ.៨ | លេខាធិការរដ្ឋបាល | មន្ត្រី |
| **៧. ការិយាល័យអប់រំ យុវជន និងកីឡា** | | | | | |
| ១ | នូ វិសុទ្ធ | ប្រុស | ខ.២.២ | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ប្រធាន |
| ២ | កែវ សារៈ | ស្រី | ខ.២.៣ | គ្រូបង្រៀនកម្រិតមូលដ្ឋាន | អនុប្រធាន |
| ៣ | សុខ វ៉ាន់សេង | ប្រុស | ខ.២.២ | គ្រូបង្រៀនកម្រិតមូលដ្ឋាន | មន្ត្រី |
| ៤ | ប៉ែន សុឃឿន | ស្រី | ខ.៣.២ | គ្រូបង្រៀនកម្រិតមូលដ្ឋាន | មន្ត្រី |
| ៥ | នៃ ចាន់នី | ស្រី | ខ.៣.៣ | គ្រូបង្រៀនកម្រិតមូលដ្ឋាន | មន្ត្រី |

| ល.រ | គោត្តនាម និងនាមខ្លួន | ភេទ | ឋានន្តរស័ក្តិ ថ្នាក់ | ក្របខ័ណ្ឌ | មុខតំណែង |
|---|---|---|---|---|---|
| ៦ | បូ ចរិយា | ស្រី | ខ.៣.២ | គ្រូបង្រៀនកម្រិតមូលដ្ឋាន | មន្ត្រី |
| ៧ | វ៉ាន់ អឿន | ប្រុស | ខ.៣.៤ | គ្រូបង្រៀនកម្រិតមូលដ្ឋាន | មន្ត្រី |
| ៨ | ទឹម កាំងផុ | ប្រុស | គ.៦ | គ្រូបង្រៀនកម្រិតបឋម | មន្ត្រី |
| ៩ | តុក វណ្ណៈ | ប្រុស | គ.៧ | គ្រូបង្រៀនកម្រិតបឋម | មន្ត្រី |
| ១០ | ជុំ ពិសិដ្ឋ | ប្រុស | គ.៧ | គ្រូបង្រៀនកម្រិតបឋម | មន្ត្រី |
| ១១ | ស៊ុន សុទិត្យា | ប្រុស | គ.៧ | គ្រូបង្រៀនកម្រិតបឋម | មន្ត្រី |
| ១២ | យ៉ន ស្រីញ៉ន | ស្រី | គ.៧ | គ្រូបង្រៀនកម្រិតបឋម | មន្ត្រី |
| ១៣ | វឿន សុវណ្ណថា | ស្រី | គ.៧ | គ្រូបង្រៀនកម្រិតបឋម | មន្ត្រី |
| ១៤ | វ៉ា ថាវ៉េត | ស្រី | គ.៨ | គ្រូបង្រៀនកម្រិតបឋម | មន្ត្រី |
| **៨. ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល** | | | | | |
| ១ | អ៊ុក ឡៀប | ប្រុស | ក.៣.១ | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ | ប្រធាន |
| ២ | ឈាន ម៉ាណ្ណារី | ប្រុស | ខ.៣.១ | មន្ត្រីបច្ចេកទេសមធ្យម | អនុប្រធាន |
| ៣ | សេង ស៊ីថារ៉ូ | ប្រុស | គ.៧ | មន្ត្រីបច្ចេកទេសបឋម | មន្ត្រី |
| ៤ | ស៊ឹម សាវ៉េត | ប្រុស | ក.៣.៤ | មន្ត្រីគ្រប់គ្រងរដ្ឋបាល | មន្ត្រី |
| ៥ | អួន មករា | ប្រុស | ក.៣.២ | មន្ត្រីគ្រប់គ្រងរដ្ឋបាល | មន្ត្រី |
| ៦ | ម៉ៅ ណារិន | ប្រុស | គ.៦ | មន្ត្រីបច្ចេកទេសបឋម | មន្ត្រី |
| ៧ | ថា យ៉ារី | ប្រុស | គ.៨ | មន្ត្រីបច្ចេកទេសបឋម | មន្ត្រី |
| ៨ | ពេជ ពន្លក | ប្រុស | ខ.៣.១ | មន្ត្រីបច្ចេកទេសមធ្យម | មន្ត្រី |
| ៩ | គុជ វ៉េត | ប្រុស | ខ.៣.២ | មន្ត្រីបច្ចេកទេសមធ្យម | មន្ត្រី |
| **៩. ការិយាល័យនីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋាន** | | | | | |
| ១ | ខួង រតនៈ | ប្រុស | ក.៣.២ | មន្ត្រីរដ្ឋបាលជាន់ខ្ពស់ | ប្រធាន |
| ២ | ខាន់ សុខុម | ប្រុស | ខ.៣.២ | មន្ត្រីក្រមការ | អនុប្រធាន |
| ៣ | អុន សារ៉ាត់ | ប្រុស | ក.៣.៤ | មន្ត្រីរដ្ឋបាលជាន់ខ្ពស់ | មន្ត្រី |
| **១០. ការិយាល័យកសិកម្ម ធនធានធម្មជាតិ និងបរិស្ថាន** | | | | | |
| ១ | ញ៉ៀម សារ៉ន | ប្រុស | គ.៦ | លេខាធិការរដ្ឋបាល | ប្រធាន |
| ២ | មាស ណារិន | ប្រុស | គ.៣ | លេខាធិការរដ្ឋបាល | អនុប្រធាន |
| ៣ | ឡាច សំអុន | ប្រុស | គ.៨ | លេខាធិការរដ្ឋបាល | អនុប្រធាន |
| ៤ | ហង្ស សម័យ | ប្រុស | គ.៦ | លេខាធិការរដ្ឋបាល | អនុប្រធាន |
| ៥ | ទិត យ៉ន | ប្រុស | គ.៧ | លេខាធិការរដ្ឋបាល | មន្ត្រី |
| ៦ | នូ សុជាតិ | ស្រី | គ.៧ | លេខាធិការរដ្ឋបាល | មន្ត្រី |

| ល.រ | គោត្តនាម និងនាមខ្លួន | ភេទ | ឋានន្តរស័ក្តិ ថ្នាក់ | ក្របខ័ណ្ឌ | មុខតំណែង |
|---|---|---|---|---|---|
| ១១. ការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហគមន៍ | | | | | |
| ១ | វ៉ាន់ ម៉ាំង | ប្រុស | គ.៧ | លេខាធិការរដ្ឋបាល | ប្រធាន |
| ២ | នួន ប៊ុនធឿន | ប្រុស | ខ.៣.២ | មន្ត្រីក្រមការ | អនុប្រធាន |
| ៣ | ប៊ិត ចាន់គឿ | ប្រុស | គ.៨ | លេខាធិការរដ្ឋបាល | អនុប្រធាន |
| ៤ | សឿង រុន | ប្រុស | គ.៨ | លេខាធិការរដ្ឋបាល | អនុប្រធាន |
| ៥ | យូ ចំរើន | ប្រុស | ខ.២.៤ | មន្ត្រីក្រមការ | មន្ត្រី |
| ១២. ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម | | | | | |
| ១ | អាង សំអាត | ស្រី | គ.៧ | លេខាធិការរដ្ឋបាល | ប្រធាន |
| ២ | ជុំ រតនៈ | ប្រុស | ក.៣.៣ | មន្ត្រីគ្រប់គ្រងរដ្ឋបាល | អនុប្រធាន |
| ៣ | ហែន គុលា | ប្រុស | ខ.៣.២ | មន្ត្រីក្រមការ | អនុប្រធាន |
| ៤ | យន លក្ខិណា | ស្រី | គ.៧ | លេខាធិការរដ្ឋបាល | អនុប្រធាន |
| ៥ | សុខ គន្ធា | ស្រី | គ.១០ | លេខាធិការរដ្ឋបាល | មន្ត្រី |
| ៦ | ឡុង តារារ័ត្ន | ប្រុស | គ.៩ | លេខាធិការរដ្ឋបាល | មន្ត្រី |
| ១៣. ការិយាល័យច្រកចេញចូលតែមួយ | | | | | |
| ១ | វ៉ន ឡានីន | ស្រី | គ.១០ | លេខាធិការរដ្ឋបាល | មន្ត្រី |
| ២ | ពុទ្ធ សុជាតា | ស្រី | គ.១០ | លេខាធិការរដ្ឋបាល | មន្ត្រី |

**ប្រការ ២ .-**

គោលការណ៍ បែបបទ និងនីតិវិធីនៃការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់បុគ្គលិក ដូចមានចែងក្នុងប្រការ១នៃសេចក្តីសម្រេចនេះ ត្រូវអនុលោមព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**ប្រការ ៣ .-**

ករណីមានភាពមិនត្រឹមត្រូវណាមួយពាក់ព័ន្ធនឹងក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់បុគ្គលិកណាម្នាក់ដែលមានចែងក្នុងប្រការ១នៃសេចក្តីសម្រេចនេះ ក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់បុគ្គលិកនោះត្រូវកែតម្រូវតាមលិខិតបទដ្ឋានគតិយុត្តជាធរមានដែលបានកំណត់ និងទទួលស្គាល់ដោយក្រសួងមុខងារសាធារណៈ។

**ប្រការ ៤ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ ៥.-**

រដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងមហាផ្ទៃ ក្រុមប្រឹក្សា គណៈអភិបាលខេត្តកណ្តាល ក្រុមប្រឹក្សា គណៈអភិបាលស្រុកល្វាឯម និងសាមីខ្លួនដូចមានឈ្មោះក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ.......... ខែ.......... ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី.......... ខែ.......... ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជា**

**ប្រធាន គ.ជ.អ.ប.**

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ដូចប្រការ ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ឯកសារព័ត៌មានស្ថានភាព

# ស្តីពី

# សេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ 2019

ពីប្រភពទិន្នន័យមូលដ្ឋានឃុំ សង្កាត់ ខែ ធ្នូ ឆ្នាំ 2018

**ស្រុក ៖ ល្វាឯម លេខកូដ ៖ 806**

**ខេត្ត ៖ កណ្តាល**

រៀបរៀងដោយមន្ទីរផែនការខេត្ត

ខែ មីនា ឆ្នាំ 2019

៣១

# កំណត់សំគាល់

១.កំរងឯកសារស្ថានភាពខេត្តនេះ បានរៀបរៀងឡើងតាមរយៈកម្មវិធីកុំព្យូទ័រឈ្មោះ " ទិន្នន័យមូលដ្ឋានឃុំ" ហៅកាត់ស៊ីឌីប៊ី(CDB)។ កម្រងឯកសារនេះមានបំណងជាចម្បងគឺ សំរាប់ប្រើប្រាស់ក្នុងការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគនៅថ្នាក់ក្រោមជាតិ។

២.ទិន្នន័យដើមដែលយកមកថ្លៃនិងបញ្ចូលក្នុងកំរងឯកសារនេះគឺបានស្រង់ចេញមកពីសៀវភៅទិន្នន័យភូមិ និងឃុំសង្កាត់ ដែលបានចងក្រងជារៀងរាល់ឆ្នាំ និងមានរក្សាទុកនៅសាលាឃុំ សង្កាត់ និងមេភូមិឬតំណាងភូមិដែលជាសមាជិក គ.ធ.ថ។

៣.មុននឹងយកមកថ្លៃ ទិន្នន័យភូមិ ទិន្នន័យឃុំសង្កាត់ ត្រូវបានផ្ទៀងផ្ទាត់ដោយស្មៀនឃុំសង្កាត់ ជំទប់ និងមានការឯកភាពចុះហត្ថលេខានិងប្រថាប់ត្រាពីមេឃុំ ចៅសង្កាត់ ដែលជាការធានាភាពត្រឹមត្រូវ និងជាក់លាក់នៃតួលេខស្ថិតិ ។

៤.និយមន័យលំអិតនៃតួលេខស្ថិតិនិមួយៗ មាននៅក្នុងសេចក្តីណែនាំស្តីពីការប្រមូល ទិន្នន័យភូមិ សំរាប់ការកសាងផែនការអភិវឌ្ឍន៍ឃុំសង្កាត់។

៥.ក្រុមប្រឹក្សា ត្រូវប្រើប្រាស់កំរងឯកសារនេះ ក្នុងការពិនិត្យនិងផ្ទៀងផ្ទាត់ពីដំណើរវិវត្តពីមួយឆ្នាំទៅមួយឆ្នាំ និងរៀបចំរបាយការណ៍ស្តីពីភាពរីកចំរើននៅពេលបញ្ចប់អណត្តិរបស់ក្រុមប្រឹក្សា។

៦.ជាចាំបាច់និងពិសេស នៅពេលកសាងផែនការអភិវឌ្ឍន៍ ក៏ដូចជារៀបចំគម្រោងវិនិយោគ ក្នុងផែនការវិនិយោគ ក្រុមការងាររៀបចំផែនការ ត្រូវប្រើប្រាស់កំរងឯកសារនេះធ្វើជាប្រភពព័ត៌មានដំបូងនិងជាស្នូល សំរាប់ការពិភាក្សា និងស្វែងយល់អំពីបញ្ហានានា ដែលកើតមាននៅក្រុង ស្រុក ខណ្ឌ ក្នុងខេត្តរបស់ខ្លួន ។

៧.តារាងទាំងអស់ក្នុងកំរងឯកសារនេះ ពុំមានភ្ជាប់ជាមួយនូវសំណួរនាំមុខឡើយ។ ហេតុនេះនៅពេលពិនិត្យ និងពិចារណាគេព័ត៌មានពីក្នុងតារាងទាំងនេះ គប្បីមានការចងចាំថា ទិន្នន័យឬតួលេខក្នុងតារាងសុទ្ធតែមានខ្លឹមសារ និងអត្ថន័យជាកំណត់របស់វា ។ ការស្វែងយល់ពីខ្លឹមសារឬអត្ថន័យរបស់ទិន្នន័យ ឬតួលេខក្នុងតារាងទាំងនេះ អាចធ្វើតាមបែបត្រង់ៗ ឬ តាមបែបប្រយោល(មិនត្រង់ៗ) ។

៨.ពេលប្រើប្រាស់ឯកសារនេះសម្រាប់កសាងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគក្រុមការងាររៀបចំផែនការ ត្រូវមានឯកសារពិន្ទុវិស័យក្រុងស្រុកខណ្ឌរបស់ខ្លួន(ឯកសារនេះក៏ផលិតចេញពីទិន្នន័យមូលដ្ឋានឃុំសង្កាត់ដែរ)មកធ្វើជាជំនួយ ដល់ភាពច្បាស់លាស់ ងាយស្រួលក្នុងការសម្រេចចិត្ត ។

៩.គ្រប់ដំណាក់កាលនៃដំណើរការកសាងផែនការអភិវឌ្ឍន៍និងផែនការវិនិយោគ ត្រូវមានជាចាំបាច់នូវព័ត៌មានទាន់ពេល ដែលឆ្លុះបញ្ចាំងពិត និងច្បាស់ពីស្ថានភាពចំពោះមុខរបស់ក្រុងស្រុកខណ្ឌ។ អាស្រ័យហេតុនេះ ក្រុមការងាររៀបចំផែនការ ត្រូវមាននិងយកឯកសារកម្រងព័ត៌មាននេះតាមខ្លួននៅរាល់ពេលប្រជុំ ហើយថែទាំឯកសារនេះឱ្យបានល្អប្រសើរ និងងាយស្រួលរកនៅពេលត្រូវការចាំបាច់៕

# មាតិកា


១.ព័ត៌មានទូទៅក្រុងស្រុកខណ្ឌ....................6

១.១.លក្ខណៈរួមអំពីចំនួនប្រជាសាស្ត្រ....................6

១.២.ស្ថានភាពមុខរបរចំបង(អាយុ១៨ឆ្នាំឡើង)....................7

មុខរបរបន្ទាប់បន្សំ....................8

១.៣.លំនៅស្ថាន....................8

១.៤.គ្រួសារនិងលំនៅដ្ឋាន....................9

| ចំនួនករណីទំនាស់កើតរដ្ឋប្បវេណី | 78 | 53 | 72 |
| ផលធៀបករណីទំនាស់កើតរដ្ឋប្បវេណីក្នុងប្រជាជន10ម៉ឺននាក់ | 95.9 | 64.0 | 85.9 |

ក្រាហ្វិក៨.១៣ ៖ ផលធៀបករណីទំនាស់ផ្សេងៗ(កើតព្រហ្មទណ្ឌ)ក្នុងប្រជាជ១០ម៉ឺននាក់




ក្រាហ្វិក៨.១៤ ៖ ផលធៀបករណីទំនាស់កើតរដ្ឋប្បវេណីក្នុងប្រជាជន10ម៉ឺននាក់




## ៨.៦.ស្លាប់ដោយអំពើហឹង្សានិងគ្រោះថ្នាក់ចរាចរ

| បរិយាយ | 2016 | 2017 | 2018 |
|---|---|---|---|
| ចំនួនអ្នកស្លាប់ដោយពីអំពើហឹង្សា | 0 | 0 | 0 |
| ផលធៀបអ្នកស្លាប់ដោយអំពើហឹង្សាក្នុងប្រជាជន10ម៉ឺននាក់ | 0.0 | 0.0 | 0.0 |
| ចំនួនអ្នកស្លាប់ដោយសារគ្រោះថ្នាក់ចរាចរ | 7 | 10 | 11 |
| ផលធៀបអ្នកស្លាប់ដោយសារគ្រោះថ្នាក់ចរាចរក្នុងប្រជាជន10ម៉ឺន នាក់ | 8.6 | 12.1 | 13.1 |

ក្រាហ្វិក៨.១៥ ៖ ផលធៀបអ្នកស្លាប់ដោយអំពើហឹង្សាក្នុងប្រជាជន10ម៉ឺននាក់




ក្រាហ្វិក៨.១៦ ៖ ផលធៀបអ្នកស្លាប់ដោយសារគ្រោះថ្នាក់ចរាចរក្នុងប្រជាជន10ម៉ឺននាក់



# ៩.យេនឌ័រ

## ៩.១.យេនឌ័រសេដ្ឋកិច្ច

### ៩.១.១.ស្ត្រីក្នុងផលិតកម្មនិងសេវាកម្ម

| បរិយាយ | 2016 | 2017 | 2018 |
|---|---|---|---|
| ចំនួនប្រុសមានមុខរបរចំបងក្រៅពីវិស័យកសិកម្ម | 5,238.0 | 5,850.0 | 6,487.0 |
| ចំនួនស្រីមានមុខរបរចំបងក្រៅពីវិស័យកសិកម្ម | 3,985.0 | 4,710.0 | 5,311.0 |
| %ស្រីមានមុខរបរចំបងក្រៅពីវិស័យកសិកម្ម | 43.2 | 44.6 | 45.0 |
| ចំនួនប្រុសមានមុខរបរបន្ទាប់បន្សំក្រៅពីវិស័យកសិកម្ម | 1,065.0 | 1,302.0 | 1,312.0 |
| ចំនួនស្រីមានមុខរបរបន្ទាប់បន្សំក្រៅពីវិស័យកសិកម្ម | 833.0 | 725.0 | 677.0 |
| %ស្រីមានមុខរបរបន្ទាប់បន្សំក្រៅពីវិស័យកសិកម្ម | 43.9 | 35.8 | 34.0 |
| សរុបអ្នកធ្វើការងារតាមទីតាំងផលិតកម្មនិងសេវាកម្ម | 1,105.0 | 1,092.0 | 1,208.0 |
| សរុបស្ត្រីធ្វើការងារតាមទីតាំងផលិតកម្មនិងសេវាកម្ម | 562.0 | 583.0 | 664.0 |
| ផលធៀបស្ត្រីធ្វើការនិងអ្នកធ្វើការផ្នែកផលិតកម្មនិងសេវាកម្ម | 50.9 | 53.4 | 55.0 |

ក្រាហ្វិក៩.១.១ ៖ ភាគរយស្ត្រីមានមុខរបរចំបងក្រៅពីវិស័យកសិកម្ម




ក្រាហ្វិក៩.១.២ ៖ ភាគរយស្ត្រីមានមុខរបរបន្ទាប់បន្សំក្រៅពីវិស័យកសិកម្ម




ក្រាហ្វិក៩.១.៣ ៖ សន្ទស្សន៍ស្ត្រីធ្វើការនៅតាមបណ្ដាផ្នែកផលិតកម្មនិងសេវាកម្ម



### ៩.១.២.ស្ត្រីចំណាកស្រុក

| បរិយាយ | 2016 | 2017 | 2018 |
|---|---|---|---|
| សរុបប្រុសអាយុ១៨ឆ្នាំឡើង | 24,352.0 | 25,101.0 | 25,395.0 |
| សរុបស្រីអាយុ១៨ឆ្នាំឡើង | **26,563.0** | **26,891.0** | **26,718.0** |
| %ប្រុសធ្វើចំណាកស្រុកនៅក្នុងប្រទេស | **10.1** | **13.3** | **14.2** |
| %ស្រីធ្វើចំណាកស្រុកនៅក្នុងប្រទេស | 9.0 | 11.0 | 11.1 |
| ផលធៀបអត្រាស្ត្រីនិងប្រុសធ្វើចំណាកស្រុកក្នុងស្រុក | 88.8 | 82.4 | 78.2 |
| %ប្រុសធ្វើចំណាកស្រុកទៅក្រៅប្រទេស | 2.6 | 2.8 | 3.1 |
| %ស្រីធ្វើចំណាកស្រុកទៅក្រៅប្រទេស | 1.1 | 1.2 | 1.4 |
| ផលធៀបអត្រាស្ត្រីនិងប្រុសធ្វើចំណាកស្រុកទៅក្រៅប្រទេស | 43.3 | 44.0 | 44.3 |

**ក្រាហ្វិក៩.១.៤ ៖ ផលធៀបអត្រាស្ត្រីនិងប្រុសធ្វើចំណាកស្រុកក្នុងស្រុក**




**ក្រាហ្វិក៩.១.៥ ៖ ផលធៀបអត្រាស្ត្រីនិងប្រុសធ្វើចំណាកស្រុកទៅក្រៅប្រទេស**




### ៩.១.៣.ស្ត្រីវិជ្ជាជីវៈ

| បរិយាយ | 2016 | 2017 | 2018 |
|---|---|---|---|
| ចំនួនប្រុសនៅរៀនសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ(អាយុ១៨-៣៥ឆ្នាំ) | 239 | 271 | 265 |
| ចំនួនស្ត្រីនៅរៀនសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ(អាយុ១៨-៣៥ឆ្នាំ) | 162 | 262 | 290 |
| ផលធៀបស្រីក្នុងប្រុស100នាក់ដែលនៅរៀនសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ(អាយុ១៨-៣៥ឆ្នាំ) | 67.8 | 96.7 | 109.4 |
| ចំនួនស្ត្រីជាបុគ្គលិកការិយាល័យកសិកម្មក្រុងស្រុកខណ្ឌ | 1 | 1 | 1 |
| %ស្រីជាបុគ្គលិកការិយាល័យកសិកម្មក្រុងស្រុកខណ្ឌ | 20.0 | 20.0 | 25.0 |

ក្រាហ្វិក៩.១.៦ ៖ ផលធៀបស្ត្រីនៅរៀនសាលាបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងប្រុស100នាក់ដែលមានអាយុ១៨-៣៥ឆ្នាំ




## ៩.២.យេនឌ័រអប់រំ

| បរិយាយ | 2016 | 2017 | 2018 |
|---|---|---|---|
| សរុបសិស្សស្រីនៅរៀនវិទ្យាល័យ | 1,445 | 1,331 | 1,571 |
| សរុបសិស្សប្រុសនៅរៀនវិទ្យាល័យ | 1,631 | 1,526 | 1,704 |
| ផលធៀបស្រីនិងប្រុសរៀននៅវិទ្យាល័យ | 0.9 | 0.9 | 0.9 |
| សរុបសិស្សស្រីនៅរៀនសកលវិទ្យាល័យ | 473 | 560 | 660 |
| សរុបសិស្សប្រុសនៅរៀនសកលវិទ្យាល័យ | 617 | 661 | 583 |
| ផលធៀបស្រីនិងប្រុសរៀននៅសកលវិទ្យាល័យ | 0.8 | 0.8 | 1.1 |

ក្រាហ្វិក៩.២.១ ៖ ផលធៀបស្រីនិងប្រុសរៀននៅវិទ្យាល័យ




ក្រាហ្វិក៩.២.២ ៖ ផលធៀបស្រីនិងប្រុសរៀននៅសកលវិទ្យាល័យ



| បរិយាយ | 2016 | 2017 | 2018 |
|---|---|---|---|
| អត្រាស្រីចេះអក្សរអាយុ១៥-១៧ឆ្នាំ | 0.99 | 0.98 | 0.99 |
| អត្រាប្រុសចេះអក្សរអាយុ១៥-១៧ឆ្នាំ | 0.99 | 0.98 | 0.99 |
| ផលធៀបអត្រាស្រីនិងប្រុសចេះអក្សរអាយុ១៥-១៧ឆ្នាំ | **1.00** | **1.00** | **0.99** |
| ភាគរយស្រីចេះអក្សរអាយុ១៨-៤៥ឆ្នាំ | **96.5** | **96.9** | **97.3** |
| ភាគរយប្រុសចេះអក្សរអាយុ១៨-៤៥ឆ្នាំ | **96.7** | **97.1** | **97.3** |
| ផលធៀបអត្រាស្រីនិងប្រុសចេះអក្សរអាយុ១៨-៤៥ឆ្នាំ | 99.8 | 99.9 | 100.0 |

**ក្រាហ្វិក៩.២.៣ ៖ ផលធៀបអត្រាស្រីនិងប្រុសចេះអក្សរអាយុ១៥-១៧ឆ្នាំ**




**ក្រាហ្វិក៩.២.៤ ៖ ផលធៀបអត្រាស្រីនិងប្រុសចេះអក្សរអាយុ១៨-៤៥ឆ្នាំ**




| បរិយាយ | 2018 | |
|---|---|---|
| | បឋមសិក្សា | អនុវិទ្យាល័យ |
| ចំនួនគ្រូបង្រៀនជាស្ត្រី | 160 | 88 |
| %ស្រីជាគ្រូបង្រៀន | 52.3 | 37.6 |
| ផលធៀបបង្គន់អនាម័យសំរាប់ស្រីតាមសាលាក្នុងសិស្សស្រី100នាក់ | 1.1 | 1.5 |

**ក្រាហ្វិក៩.២.៥ ៖ ភាគរយស្ត្រីជាគ្រូបង្រៀននៅសាលាបឋមសិក្សា**



## ក្រាហ្វិក៩.២.៦ ៖ ភាគរយស្ត្រីជាគ្រូបង្រៀនអនុវិទ្យាល័យ




## ក្រាហ្វិក៩.២.៧ ៖ ផលធៀបបង្គន់អនាម័យសំរាប់ស្រីតាមបឋមសិក្សាក្នុងសិស្សស្រី100នាក់




## ក្រាហ្វិក៩.២.៨ ៖ ផលធៀបបង្គន់អនាម័យសំរាប់ស្រីតាមអនុវិទ្យាល័យក្នុងសិស្សស្រី100នាក់




## ៩.៣.យេនឌ័រងាយរងគ្រោះ

| បរិយាយ | 2016 | 2017 | 2018 |
|---|---|---|---|
| ចំនួនស្ត្រីជាជនពិការ | 165.0 | 162.0 | 182.0 |
| %ស្ត្រីជាជនពិការ | 37.9 | 38.2 | 39.6 |
| ចំនួនស្រីអាយុក្រោម១៨ឆ្នាំដែលរស់នៅតាមចិញ្ចើមថ្នល់ | 1 | 0 | 0 |
| %ស្រីអាយុក្រោម១៨ឆ្នាំដែលរស់នៅតាមចិញ្ចើមថ្នល់ | 33.3 | 0.0 | 0.0 |
| ចំនួនស្រីអាយុក្រោម១៨ឆ្នាំធ្វើការងារពលកម្មធ្ងន់ធ្ងរ | 0 | 0 | 1 |
| %ស្រីអាយុក្រោម១៨ឆ្នាំធ្វើការងារពលកម្មធ្ងន់ធ្ងរ | 0.0 | 0.0 | 33.3 |

ក្រាហ្វិក៩.៣.១ ៖ ភាគរយស្ត្រីជាជនពិការ




ក្រាហ្វិក៩.៣.២ ៖ ភាគរយស្រីអាយុក្រោម១៨ឆ្នាំដែលរស់នៅតាមចិញ្ចើមថ្នល់




ក្រាហ្វិក៩.៣.៣ ៖ ភាគរយស្រីអាយុក្រោម១៨ឆ្នាំធ្វើការងារពលកម្មធ្ងន់ធ្ងរ




## ៩.៤.យេនឌ័រសំរេចចិត្ត

| បរិយាយ | 2018 | | |
|---|---|---|---|
| | សរុប | ស្រី | ភាគរយស្រី |
| មេភូមិ | 43 | 2 | 4.7 |
| ក្រុមប្រឹក្សាឃុំសង្កាត់ | 85 | 17 | 20.0 |
| ក្រុមប្រឹក្សាក្រុងស្រុកខណ្ឌ | 17 | 3 | 17.6 |

ក្រាហ្វិក៩.៤.១ ៖ ភាគរយស្ត្រីជាមេភូមិ




ក្រាហ្វិក៩.៤.២ ៖ ភាគរយស្ត្រីជាក្រុមប្រឹក្សាឃុំសង្កាត់




| បរិយាយ | 2018 | | |
|---|---|---|---|
| | **សរុប** | **ស្រី** | **ភាគរយស្រី** |
| សរុបមន្ត្រីតាមការិយាល័យជំនាញក្រុងស្រុកខណ្ឌ | **50.0** | **17.0** | **34.0** |
| ប្រធានការិយាល័យជំនាញក្រុងស្រុកខណ្ឌ | **10.0** | **2.0** | **20.0** |
| អនុប្រធានការិយាល័យជំនាញក្រុងស្រុកខណ្ឌ | **3.0** | **3.0** | **100.0** |

## ៩.៥.យេនឌ័រសុវត្ថិភាព

| បរិយាយ | | 2016 | 2017 | 2018 |
|---|---|---|---|---|
| សរុបស្រីរងគ្រោះនិងស្លាប់ដោយអំពើហឹង្សាក្នុងគ្រួសារ | | **13** | **10** | **11** |
| ក្នុងនោះ: | ចំនួនស្រីរងគ្រោះដោយពីអំពើហឹង្សាក្នុងគ្រួសារ | **13** | **10** | **11** |
| | ចំនួនស្រីស្លាប់ដោយពីអំពើហឹង្សាក្នុងគ្រួសារ | **0** | **0** | **0** |
| ចំនួនស្រីរងគ្រោះនិងស្លាប់ដោយអំពើហឹង្សាក្នុងគ្រួសារក្នុងស្រី10ម៉ឺននាក់ | | **31.3** | **23.7** | **26.1** |
| ចំនួនស្រីរងគ្រោះដោយចាប់រំលោភ | | **2** | **0** | **0** |
| ចំនួនស្រីរងគ្រោះដោយចាប់រំលោភក្នុងស្រី10ម៉ឺននាក់ | | **4.8** | **0.0** | **0.0** |
| ចំនួនស្រីរងគ្រោះដោយជួញដូរផ្លូវភេទ | | **0** | **0** | **0** |
| ចំនួនស្រីរងគ្រោះដោយជួញដូរផ្លូវភេទក្នុងស្រី10ម៉ឺននាក់ | | **0.0** | **0.0** | **0.0** |

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ៖កណ្ដាល

ស្រុក ៖ល្វាឯម

លេខ ............របក.លឯ

# របាយការណ៍ប្រចាំឆ្នាំ
# ស្ដីពី
# ការអនុវត្តការងាររបស់រដ្ឋបាល
# ស្រុកល្វាឯម

ឆ្នាំ ២០១៩

១០៧

# សេចក្តីផ្តើម

ស្រុកល្វាឯម ជាស្រុកមួយស្ថិតនៅតាមដងទន្លេមេគង្គ ដងទន្លេតូច និងបឹងវាលសំណាប ស្ថានភាពដីស្ថិតនៅក្នុងតំបន់វាលទំនាប សម្បូរទៅដោយបឹងបួរ ព្រែកជាច្រើនស្ថានភាពបែបនេះធ្វើឱ្យសម្បូរ ធនធាន ធម្មជាតិ ដីមានជីជាតិសម្រាប់ដំណាំ កសិកម្ម ។ ស្រុកល្វាឯម ស្ថិតនៅជាប់រាជធានីភ្នំពេញ ខណ្ឌដោយទន្លេចតុមុខបង្កលក្ខណៈងាយស្រួលដល់ ប្រជាពលរដ្ឋធ្វើដំណើរ និងដឹកកសិផលទៅលក់ នៅរាជធានីភ្នំពេញ។ ប៉ុន្តែត្រូវជួបឧបសគ្គជាច្រើន នៅរដូវវស្សា ផ្លូវលំភាគច្រើនខូចខាត និងទឹកហូរកាត់ផ្តាច់ ការលំបាកជាខ្លាំងក្នុងការធ្វើដំណើរ និងដឹកកសិផលទៅឯរាជធានីភ្នំពេញ ព្រមទាំងត្រូវចំណាយថវិកាច្រើនក្នុងការឆ្លងទូកដរទៀតផង ។

អគាររដ្ឋបាលសាលាស្រុក ស្ថិតនៅក្នុងភូមិទឹកឃ្លាំង ឃុំទឹកឃ្លាំង។ស្រុកចែកជា ១៥ឃុំ មាន ៤៣ភូមិ មានផ្ទៃដីសរុប ២៦.០៩២ ហិកតា ស្មើនឹង ២៦០,៩២ គីឡូម៉ែត្រក្រឡា ប្រជាជនសរុប ៨១២៤៦នាក់ ស្រី ៤០៩៧៨នាក់ដងស៊ីតេប្រជាជន ៣១១នាក់ ក្នុង១គីឡូម៉ែត្រក្រឡា ប្រជាជនប្រមាណ ៨៥ % មានមុខរបរពឹងផ្អែកលើរបរកសិកម្មជាចម្បង ក្រៅពីនេះមានមុខរបរផ្សេងៗទៀតដូចជា អាជីវកម្ម សិប្បកម្ម កម្មករ ចិញ្ចឹមសត្វ និងការនេសាទត្រី ដែលជាមូលដ្ឋានដើម្បីបង្កើនផលកម្រៃនៃការលើកស្ទួយជីវភាពគ្រួសារ ។

ស្រុកល្វាឯម មាន ៖

| ល.រ | ការបរិយាយ | សរុប | ឯកតា |
|---|---|---|---|
| ១ | ផ្ទៃដីសរុប | ២៦០,៩២ | គីឡូម៉ែត្រការ៉េ |
| ២ | ចំនួនឃុំ សង្កាត់ | ១៥ | ឃុំ សង្កាត់ |
| ៣ | ចំនួនភូមិ | ៤៣ | ភូមិ |
| ៤ | ចំនួនគ្រួសារ | ១៨៧០០ | គ្រួសារ |
| ៥ | ចំនួនប្រជាពលរដ្ឋសរុប | ៨០៨១៥ | នាក់ |
| ៦ | ចំនួនស្ត្រីសរុប | ៤០៩៦២ | នាក់ |

របាយការណ៍ប្រចាំឆ្នាំ២០១៩គឺជាការបរិយាយអំពីសមិទ្ធផលការងារនៃអាណត្តិទី២ និងអាណត្តិទី៣ របស់ក្រុមប្រឹក្សាស្រុក ដើម្បីឆ្លើយតបនូវគោលដៅអភិវឌ្ឍន៍រយៈពេល០៥ឆ្នាំ(២០១៩-២០២៤) តាមរយៈការ អនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិល។របាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តការងាររបស់រដ្ឋបាលស្រុកមាន៦ផ្នែក ដែលក្នុងនោះ ៖

- **ផ្នែកទី១ ៖ ការគ្រប់គ្រងរដ្ឋបាលស្រុក**

  ផ្នែកទី១នេះ បរិយាយអំពីលទ្ធផលនៃការអនុវត្តការងាររដ្ឋបាល ផែនការនិងការគាំទ្រឃុំ សង្កាត់ ការគ្រប់គ្រងធនធានមនុស្ស ការងារអន្តរវិស័យ និងការងារហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក។
- **ផ្នែកទី២ ៖ ការងាររដ្ឋបាលឃុំ សង្កាត់**

  ផ្នែកទី២នេះ បរិយាយជាសង្ខេបអំពីលទ្ធផលនៃការអនុវត្តការងាររបស់រដ្ឋបាលឃុំ សង្កាត់ និងបញ្ហាប្រឈមដែលឃុំ សង្កាត់បានជួបប្រទះ ព្រមទាំងសំណើដំណោះស្រាយបញ្ហាប្រឈមទាំងនោះ។
- **ផ្នែកទី៣ ៖ ការងាររបស់ការិយាល័យ អង្គភាពជំនាញ**

  ផ្នែកទី៣នេះ បរិយាយអំពីលទ្ធផលនៃការអនុវត្តការងាររបស់ការិយាល័យ អង្គភាពជំនាញនានា ដែលមានទីតាំងនៅក្នុងដែនសមត្ថកិច្ចក្រុង ស្រុក។
- **ផ្នែកទី៤ ៖ បញ្ហាប្រឈម និងដំណោះស្រាយ**

  ផ្នែកទី៤នេះ បរិយាយអំពីបញ្ហាប្រឈមនានាដែលរដ្ឋបាលក្រុង ស្រុក និងការិយាល័យ អង្គភាពជំនាញបានជួបប្រទះ និងសំណើដំណោះស្រាយបញ្ហាប្រឈមទាំងនោះ។
- **ផ្នែកទី៥ ៖ ទិសដៅការងារឆ្នាំបន្ទាប់**

ផ្នែកទី៥នេះ បរិយាយអំពីសកម្មភាពជាអាទិភាព ដែលរដ្ឋបាលក្រុង ស្រុក និងការិយាល័យ អង្គភាពជំនាញ បានគ្រោងសម្រាប់អនុវត្តនៅឆ្នាំបន្ទាប់។

- **ផ្នែកទី៦ ៖ សេចក្តីសន្និដ្ឋាន**

  ផ្នែកទី៦នេះ បរិយាយជាសង្ខេបអំពីការសន្និដ្ឋាននៃការអនុវត្តការងាររបស់រដ្ឋបាលក្រុង ស្រុក ដោយប្រៀបធៀបទៅនឹងផែនការប្រចាំឆ្នាំ ដែលបានគ្រោងទុក។

## ផ្នែកទី១

## ការគ្រប់គ្រងរដ្ឋបាលស្រុក

### ១.១. ការងាររដ្ឋបាល

១.១.១.ការងារលិខិតស្នាម និងឯកសារប្រជាពលរដ្ឋ

នៅក្នុងឆ្នាំ២០១៩ នេះរដ្ឋបាលស្រុកបានដាក់ចេញលិខិតមានចំនួន ៦២៦ច្បាប់ រួមមានៈដីកា ០៣ច្បាប់ សេចក្តីសម្រេច ១៧ច្បាប់, សំណើ ១២១ច្បាប់, បញ្ជាក់សំណើ ៧៥ច្បាប់, លិខិតអនុញ្ញាត ៣៩ច្បាប់, របាយការណ៍ ២៦ច្បាប់, លិខិតបញ្ជាបេសកកម្ម ១៥២ច្បាប់, បញ្ជាំ ០៣ច្បាប់, ឧទ្ទេសនាម ០៧ច្បាប់, ផែនការ ០៣ច្បាប់, សេចក្តីជូនដំណឹង ០៧ច្បាប់, លិខិតអញ្ជើញ ១៤៨ច្បាប់ និងចម្លង ០ច្បាប់។ លិខិតទទួលបាន ៤៥៣ច្បាប់ រួមមានៈ រាជរដ្ឋាភិបាល ១១ច្បាប់, ទីស្តីការគណៈរដ្ឋមន្ត្រី ០៦ច្បាប់, ក្រសួងមហាផ្ទៃ ៣០ច្បាប់, ក្រសួងនានា ៨៤ច្បាប់, អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ ០៤ច្បាប់, អគ្គនាយកដ្ឋានពន្ធដារ ០១ច្បាប់,រដ្ឋបាលខេត្តកណ្តាល ១៧៤ច្បាប់, សាលាដំបូងខេត្តកណ្តាល ០៦ច្បាប់, ស្នងការនគរបាលជាតិ ០២ច្បាប់, ស្នងការនគរបាលខេត្តកណ្តាល ០១ច្បាប់, អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ០៣ច្បាប់ , អាជ្ញាធរអគ្គិសនី ០៤ច្បាប់, អគ្គីសនីកម្ពុជា ០២ច្បាប់, គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត ០១ច្បាប់, គណៈកម្មការជំរឿន ០១ច្បាប់, គណៈកម្មការជាតិ ០១ច្បាប់, គណៈកម្មការជ្រើសរើសថ្នាក់ខេត្ត ០១ច្បាប់, គណៈកម្មាធិការដឹកជញ្ជូនដូវ ០១ច្បាប់, គណៈកម្មការរៀបចំការបោះឆ្នោត ១០ច្បាប់, គណៈកម្មការបុណ្យជាតិ-អន្តរជាតិ ០៦ច្បាប់, គណៈកម្មគ្រប់គ្រងគ្រោះមហន្តរាយ ០១ច្បាប់, សមាគមនក្រុមប្រឹក្សាក្រុង-ស្រុក/ឃុំ-សង្កាត់ ០២ច្បាប់, គណៈបញ្ជាការឯកភាពរដ្ឋបាលខេត្តកណ្តាល ០១ច្បាប់, មន្ទីរនានាជុំវិញខេត្ត ៤១ច្បាប់, សាខាកាកបាទក្រហម ០១ច្បាប់, ក្រុមច្បាប់និងទីប្រឹក្សាអមវិន្ទ ០១ច្បាប់, ការិយាល័យនានា ០៧ច្បាប់, អង្គការ០២ច្បាប់, ឃុំនានា ៤២ច្បាប់ និងផ្សេងៗ ០៩ច្បាប់។

រដ្ឋបាលស្រុកបានអនុវត្តការផ្តល់សេវាជូនប្រជាពលរដ្ឋរួមមានៈ សេវានីត្យាកូលកម្ម បានចំនួន ១,៦៧៥នាក់, ស្រី៧៤៧នាក់។ សេវាអត្រានុកូលដ្ឋានបានចំនួន ២,៩០០នាក់, ស្រី១,២២៦នាក់ (ប្រជាពលរដ្ឋមកផ្ទាល់ចំនួន ១,៣៤៥នាក់, ស្រី៧១៥នាក់ និងតាមប្រពន្ធ័Telegram ១,៥៥៥នាក់, ស្រី៧៦២នាក់) ការចេញលិខិតអនុញ្ញាតបំពេញអាចម៍ដីកម្មសិទ្ធឯកជនបានចំនួន ៤ច្បាប់ ។

តារាងទី១៖ ការងារលិខិតស្នាម និងឯកសារប្រជាពលរដ្ឋ

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | ដីកាដែលបានដាក់ចេញ | ៣ |
| ២ | សេចក្តីសម្រេចដែលបានដាក់ចេញ | ១៧ |
| ៣ | លិខិតរដ្ឋបាលដែលបានដាក់ចេញ | ៦២៧ |
| ៤ | លិខិតដែលបានទទួល | ៤៥៣ |
| ៥ | សៀវភៅស្នាក់នៅ | ១៣៣១ |

១.១.២. ការគ្រប់គ្រងប្រជាពលរដ្ឋ

ក្នុងស្រុកល្វាឯម មានគ្រួសារចំនួន ១៨៧០០ គ្រួសារ ក្នុងនោះ គ្រួសារអចិន្ត្រៃយ៍ ១៨៦៥១ គ្រួសារ គ្រួសារបណ្តោះអសន្ន ៤៩ គ្រួសារ ប្រជាពលរដ្ឋសរុប ៨០៨១៥នាក់ ស្រី៤០៩៦២នាក់ក្នុងនោះប្រជាពលរដ្ឋអចិន្ត្រៃយ៍ ៨០៦៥៣នាក់ស្រី ៤០៨៨២នាក់ ,ប្រជាពលរដ្ឋបណ្តោះអាសន្ន ១៦២នាក់ ស្រី ៨០នាក់ .ប្រជាពលរដ្ឋអាយុ១៨ ឆ្នាំឡើង មានចំនួន៥៥៥១៩នាក់ស្រី២៧៩៤៨នាក់ក្នុងនោះអចិន្ត្រៃយ៍ ៥៥៣៨៨នាក់ ស្រី ២៧៨៩១នាក់ បណ្តោះអាសន្ន ១៣១នាក់ ស្រី ៥៧នាក់ ប្រជាជនធ្វើចំណាក់ស្រុក ១០៥៨ នាក់ ស្រី ៤៣៩ នាក់ ។

តារាងទី២៖ ការគ្រប់គ្រងប្រជាពលរដ្ឋ

| ល.រ. | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | សរុបគ្រួសារ | ១៨៧០០ |
| ២ | គ្រួសារអចិន្ត្រៃយ៍ | ១៨៦៥១ |
| ៣ | គ្រួសារបណ្តោះអាសន្ន | ៤៩ |
| ៤ | ប្រជាពលរដ្ឋសរុប | ៨០៨១៥ |
| ៥ | ប្រជាពលរដ្ឋជាស្ត្រី | ៤០៩៦២ |
| ៦ | ប្រជាពលរដ្ឋដែលមានអាយុ១៨ឆ្នាំឡើង | ៥៥៥១៩ |
| ៧ | ប្រជាពលរដ្ឋចំណាកស្រុក | ១០៥៨ |

១.១.៣. ការងារអត្រានុកូលដ្ឋាន

រដ្ឋបាលស្រុកបានចេញសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទជូនប្រជាពលរដ្ឋរួមមាន៖ សេចក្តីចម្លងសំបុត្រកំណើត ៤៩២សន្លឹក, សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ៥,៩៥២សន្លឹក, សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ២៩៣សន្លឹក និងសេចក្តីចម្លងមរណៈភាព ៥៤សន្លឹក។

តារាងទី៣៖ ការចេញសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | សេចក្តីចម្លងសំបុត្រកំណើត | ៤៩២ |
| ២ | សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត | ៥,៩៥២ |
| ៣ | សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ | ២៩៣ |
| ៤ | សេចក្តីចម្លងសំបុត្រមរណភាព | ៥៤ |

**១.១.៤. ការផ្សព្វផ្សាយព័ត៌មាន ទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិ** (រួមទាំងការងារសមាគម អង្គការមិនមែនរដ្ឋាភិបាល និងការងារចងសម្ព័ន្ធមេត្រីភាព )

- បានបិទផ្សព្វផ្សាយជាសាធារណៈអំពីការប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាស្រុកចំនួន ១១លើក
- បានផ្សព្វផ្សាយព័ត៌មានតាមរយៈបណ្តាញសង្គម ហ្វេសប៊ុក(Facebook) ចំនួន ១១៨លើក, ទទួលបាន Like ចំនួនៈ១៦,៧៧០, Share ចំនួន៣,៥១៩ និងComment ចំនួន៣៤៣។
- ផ្សព្វផ្សាយពីកិច្ចលទ្ធកម្មចំនួន ៩ លើក ។

- បានអមដំណើរ **ឯកឧត្តម ស៊ុយ សែម** រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល ចុះត្រួតពិនិត្យការដ្ឋានសាងសង់រោងចក្រអគ្គិសនីដើរដោយប្រេងខ្មៅ និងឧស្ម័នអនុភាព៤០០មេហ្គាវ៉ាត់ ស្ថិតនៅភូមិកោះរះក្រោម ឃុំកោះរះ

តារាងទី៩៖ ការផ្សព្វផ្សាយព័ត៌មាន និងទំនាក់ទំនងសាធារណៈ

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| **ក). ការផ្សព្វផ្សាយព័ត៌មាន** | | |
| ១ | វិទ្យុ | ០ |
| ២ | ទូរទស្សន៍ | ០ |
| ៣ | បិទផ្សាយលើក្តារព័ត៌មានសាធារណៈ | ១១ |
| ៤ | ព្រឹត្តិបត្រព័ត៌មានទស្សនាវដ្តី សាព័ត៌មាន | ៩ |
| ៥ | ផ្សេងៗ | ១១៨ |
| **ខ). ទំនាក់ទំនងសាធារណៈ** | | |
| ១ | សាធារណៈជនមកទំនាក់ទំនងសាលាក្រុង ស្រុក | ៤៥៧៥ |
| ២ | គណៈប្រតិភូភ្ញៀវជាតិ អន្តរជាតិ | ១ |

១.១.៥. ការងារគណៈអភិបាល(រួមទាំងការអនុវត្តតួនាទីជាតំណាងក្រសួង ស្ថាប័ន)

-ប្រជុំគណៈអភិបាលស្រុកចំនួន ១២ លើក សរុបវត្តមានចូលរួមសរុប ៦០២ នាក់

-ប្រជុំគណៈបញ្ជាការឯកភាពស្រុក១១ លើក សរុបវត្តមានចូលរួមសរុប ៧៣២ នាក់ ។

-បានចូលរួមប្រជុំសាមញ្ញារបស់ក្រុមប្រឹក្សាស្រុក ១១លើក សរុបវត្តមានចូលរួម ៧០៤ នាក់

-បានចូលរួមកិច្ចប្រជុំគណៈអភិបាលខេត្តចំនួន ១១ លើក

- បានចូលរួមកិច្ចប្រជុំគណៈបញ្ជាការឯកភាពរដ្ឋបាលខេត្តចំនួន ១១ លើក

- ប្រជុំគណៈកម្មការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ចំនួន ០៩ លើក

- ប្រជុំគណៈកម្មការគ្រប់គ្រងដីរដ្ឋថ្នាក់ស្រុក ចំនួន ០៨លើក សរុបវត្តមានចូលរួម ១៩៨ នាក់

- បានរៀបចំវេទិកាសាធារណៈតាមបណ្តាលឃុំទាំង ១៥ សរុបអ្នកចូលរួម៥៣៩៤ នាក់ ស្រី៣០៥៣ នាក់ សរុបបញ្ហាសំណូមពរ ១៥៩ ករណី ក្នុងនោះបានដោះស្រាយ ៥៦ ករណី កំពុងដោះស្រាយ៤៥ករណី មិនបានដោះស្រាយ ២៧ ករណី សំណើ៣១ ករណី

- បានអញ្ជើញ ចូលរួមពិធីសំណេះសំណាលជាមួយបងប្អូនកម្មករកម្មការីនីរោងចក្រក្រោមអធិបតីភាព **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានចំនួន ០៦ លើក

- សកម្មភាពភាពការងារសំខាន់ៗ របស់គណៈអភិបាលស្រុក ៖

**១. ផ្នែកសេដ្ឋកិច្ច៖**

- ថ្ងៃទី១៦ខែមករាឆ្នាំ២០១៩ បានបើកកិច្ចប្រជុំពិភាក្សាជាមួយសហគមន៍ផលិតស្រូវសែនក្រអូប ជំរុញការផលិតស្រូវសែនក្រអូបបន្ត ធ្វើស្ថិតិឲ្យបានច្បាស់លាស់ចំនួនឃុំ ចំនួនគ្រួសារនៅ តាមភូមិនីមួយៗនិងផ្ទៃដីបង្កបង្កើនផលស្រូវសែនក្រអូបនិងផែនទីនៃការប្រមូលផលស្រូវសែនក្រអូប( ការទាក់ទងម៉ាស៊ីនច្រូតស្រូវ និងការដឹកជញ្ជូន )របស់បងប្អូនសហគមន៍ប្រជាកសិករទូទាំងស្រុកល្វាឯម។

– ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៩ បានអញ្ជើញចុះពិនិត្យទិន្នផលស្រូវសែនក្រអូបរបស់បងប្អូនប្រជាកសិករនៅឃុំសំបួរ មានលោក សែម សោត្ថិ ប្រធានក្រុមប្រឹក្សាស្រុក ព្រមទាំងលោក លោកស្រីសមាជិកក្រុមប្រឹក្សាស្រុក ប្រធានការិយាល័យកសិកម្មស្រុក ក្រុមប្រឹក្សាឃុំ មេភូមិ

– ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៩ បានអញ្ជើញចុះជួបជាមួយបងប្អូនប្រជាកសិករចំនួន៤៦គ្រួសារ ដែលមានផ្ទៃដីបង្កបង្កើនផលស្រូវពូជសែនក្រអូប ចំនួន៨០ហិចតា ស្ថិតនៅក្នុងឃុំព្រែកឫស្សី ដែលជួបគ្រោះធម្មជាតិ ទឹកទន្លេតូចឡើងលិចផ្ទៃដីបង្កបង្កើនផលស្រូវសែនក្រអូប។

– ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៩ អញ្ជើញចុះពិនិត្យការសម្ភាសន៍របស់មន្ត្រីធ្វើជំរឿនស្រុក-ឃុំ និងមានការសំណេះសំណាលសួរសុខទុក្ខតាមខ្នងផ្ទះរបស់ប្រជាពលរដ្ឋផងដែរ។

– ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៩ បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំវឌ្ឍនៈភាព នៃការអនុវត្តផែនការសកម្មភាពខេត្តរយៈពេល០៥ឆ្នាំ របស់ក្រុមការងារបច្ចេកទេសវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ ជនបទ (PWG) ក្រោមអធិបតីភាពលោកស្រី ជី ថារី ប្រធានមន្ទីរអភិវឌ្ឍន៏ជនបទខេត្ត និងជាប្រធានលេខាធិការដ្ឋាន (PWGs) តំណាង ឯកឧត្តម តាំង ម៉េងលាង អភិបាលរងខេត្តកណ្តាល នៅមន្ទីរអភិវឌ្ឍន៍ជនបទ ក្រុងតាខ្មៅ ខេត្តកណ្ដាល។

– ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៩ បានអញ្ជើញចូលរួមពិធីសម្ពោធបើកឲ្យប្រើប្រាស់ជាផ្លូវការនូវមជ្ឈមណ្ឌលប្រមូលផ្តុំត្រួតពិនិត្យគុណភាព និងចែកចាយបន្លែរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកណ្ដាល ក្រោមអធិបតីភាពឯកឧត្តមអគ្គរាជទូតប្រទេសជប៉ុន ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា និង**ឯកឧត្តមបណ្ឌិត ម៉ៅ ភិរុណ** អភិបាល នៃគណអភិបាលខេត្តកណ្ដាល។

– ថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៩ បានចូលរួមក្នុងកិច្ចប្រជុំប្រមូលតម្រូវការគម្រោង សកម្មភាពនៃកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ២០២០-២០២២ និងផ្សព្វផ្សាយអំពីការចាប់ផ្តើមដំណើរការកសាងផែនការអភិវឌ្ឍន៍ ២០២០-២០២៤ ក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិត ម៉ៅ ភិរុណ** អភិបាលខេត្ត នៃគណៈអភិបាលខេត្តកណ្ដាល។

– ថ្ងៃទី ១៣ខែសីហា ឆ្នាំ២០១៩ បានអញ្ជើញចូលរួមកិច្ចប្រជុំស្តីពីការត្រួតពិនិត្យ និងផ្តល់នីត្យានុកូលភាពលើគម្រោងផែនការថវិកា ចំណូលចំណាយរបស់រដ្ឋបាលក្រុង ស្រុកទាំង១១សម្រាប់អនុវត្តគ្រប់គ្រងឆ្នាំ ២០២០ ក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិត ម៉ៅ ភិរុណ** អភិបាល នៃគណៈអភិបាលខេត្តកណ្ដាល នៅសាលប្រជុំអគារA សាលាខេត្តកណ្ដាល។

– ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ ២០១៩ បានអញ្ជើញអមដំណើរ **ឯកឧត្តមបណ្ឌិត ម៉ៅ ភិរុណ** អភិបាល នៃគណៈអភិបាលខេត្តកណ្ដាល បានអញ្ជើញចុះទៅពិនិត្យ និងផ្សព្វផ្សាយជម្ងឺប៉េស្តអាហ្វ្រិក ដល់មូលដ្ឋានផ្ទះប្រជាពលរដ្ឋដែលមានជ្រូកងាប់ ស្ថិតនៅក្នុងឃុំព្រែកឫស្សី ស្រុកល្វាឯម ខេត្តកណ្ដាល។

## ២.ការងារសង្គមកិច្ច

– ថ្ងៃទី២២ ខែមករា ឆ្នាំ២០១៩ បានរៀបចំវគ្គបណ្តុះបណ្តាល ប្រជុំឆ្លុះបញ្ចាំង "ស្តីពីការណែនាំគូសផែនទីសេវាសង្គមភូមិ និងផែនការសម្រាប់ការវិភាគបញ្ហាតម្រូវការ និងដំណោះស្រាយដើម្បីដាក់បញ្ចូលនៅផែនការអភិវឌ្ឍន៍កម្មវិធីវិនិយោគឃុំ សង្កាត់បីឆ្នាំរំកិល" នៅសាលប្រជុំសាលាស្រុកល្វាឯម។

– ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៩ បានបើកវគ្គបណ្តុះបណ្តាល ស្តីពីតួនាទីភារកិច្ចរបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារស្រុក និងគណៈកម្មការទទួលបន្ទុកកិច្ចស្ត្រី និងកុមារឃុំ នៅសាលប្រជុំ

សាលាស្រុកល្វាឯមក្រោមអធិបតីភាព លោកជំទាវ នួន នារតី សមាជិកក្រុមប្រឹក្សាខេត្ត និងប្រធានគណៈកម្មាធិការពិគ្រោះយោបល់ស្ត្រី និងកុមារខេត្តកណ្តាល។

– ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៩បានរៀបចំពិធីផ្សព្វផ្សាយ និងប្រគល់ប័ណ្ណមូលនិធិសមធម៌(ប.ស.ស) ជូនដល់ក្រុមប្រឹក្សាឃុំ មេភូមិ អនុភូមិ និងសមាជិកភូមិ ទូទាំងស្រុក។

– ថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៩ បានសហការជាមួយយុវជន ស.ស.យ.ក ស្រុក ព្រមទាំងយុវជនស.ស.យ.ក ចំនួន៤ឃុំគឺ(ឃុំថ្មគរ, ឃុំទឹកឃ្លាំង, ឃុំភូមិធំ, ឃុំព្រែករៃ) អតីតសិស្ស និងសិស្សានុសិស្សកំពុងសិក្សាក្នុងវិទ្យាល័យ ហ៊ុន សែន ទឹកឃ្លាំងសរុបប្រមាណ១៩០នាក់ បានចូលរួមសំអាតបរិស្ថានក្នុងវិទ្យាល័យ និងសកម្មភាពមួយចំនួនទៀតដូចជា(លាបថ្នាំសាលាវិទ្យាល័យ ចងទង់ជាតិ ចងបដា) ដើម្បីអបអរសាទរ ពិធីបុណ្យឆ្លងសមិទ្ធផលនានាក្នុងវិទ្យាល័យ ហ៊ុន សែន ទឹកឃ្លាំង ដែលប្រារព្ធធ្វើនៅថ្ងៃទី៧-៨ខែ មិនា ឆ្នាំ២០១៩ និងអបអរសាទរខួប លើកទី១០៨ ទិវាអន្តរជាតិនារី ៨ មិនា ២០១៩ ។

– ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៩ បានបើកកិច្ចប្រជុំត្រួតពិនិត្យ និងប្រមូលលទ្ធផលការងារគូសផែនទីសេវាសង្គមភូមិ និងផែនការសម្រាប់ការវិភាគបញ្ហាតម្រូវការ និងដោះស្រាយដើម្បីដាក់បញ្ចូលទៅក្នុង ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ឃុំ-សង្កាត់ សរុបវត្តមានចូលរួម ៣៥នាក់, ស្រី១៧នាក់ នៅសាលប្រជុំសាលស្រុកល្វាឯម។

– ថ្ងៃទី ២៤ ខែ មិនា ឆ្នាំ២០១៩ បានបើកពិធីការប្រកួតបាល់ទាត់ពានរង្វាន់យុវជនទូទាំងស្រុកល្វាឯម នៅមុខវិទ្យាល័យ ហ៊ុន សែន ទឹកឃ្លាំង ។

– ថ្ងៃទី២៩ខែមីនា ឆ្នាំ២០១៩ បានអញ្ជើញចូលរួមក្នុងវេទិកាផ្សព្វផ្សាយស្តីពីការថែទាំសុខភាពមាតា និងទារក និងអាហារូបត្ថម្ភដល់ប្រជាពលរដ្ឋ ដែលមានកូនតូចស្ត្រីមានផ្ទៃពោះនិងស្ត្រីក្នុងវ័យបន្តពូជ ក្រោមអធិបតីភាពលោកជំទាវ នួន នារតី សមាជិកក្រុមប្រឹក្សាខេត្តនិងជាប្រធានគណៈកម្មាធិការពិគ្រោះ យោបល់កិច្ចការស្ត្រីនិងកុមារខេត្តកណ្តាល នៅឃុំល្វាសរ។

– ថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៩ បានចូលរួមក្នុងពិធីបិទការប្រកួតបាល់ទាត់ ក្របខណ្ឌយុវជន សសយកស្រុក ក្រោមអធិបតីភាពឯកឧត្តម កៅ ថាច អនុប្រធានក្រុមការងារថ្នាក់ជាតិចុះជួយស្រុកល្វាឯម ទទួលបន្ទុកចលនាយុវជនស្រុក នៅមុខវិទ្យាល័យ ហ៊ុន សែន ទឹកឃ្លាំង ។

– ថ្ងៃទី១៣.១៤.១៥ ខែមេសា ឆ្នាំ២០១៩ បានរៀបចំពិធីសង្ក្រាន្តឆ្នាំថ្មី នៅកោះស្នេហ៍ មុខវិទ្យាល័យ ហ៊ុន សែនទឹកឃ្លាំង និង វត្តស្វាយអណ្តែត ។

– ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៩ បានអញ្ជើញចូលរួមទទួលស្វាគមន៍ ឯកឧត្តម ជិត ប៉ុណ្ណារ៉ា ដែលបានដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចំនួន ១២នាក់ ដើម្បីចុះពិនិត្យព្យាបាលជម្ងឺកុមារក្រោមអាយុ១០ឆ្នាំ នៅមន្ទីរពេទ្យបង្អែកស្រុកល្វាឯម ក្រោមការចង្អុលបង្ហាញពី ឯកឧត្តមអគ្គបណ្ឌិត សភាចារ្យ អូន ពន្ធ័ មុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមការងារថ្នាក់ជាតិចុះជួយស្រុកខ្សាច់កណ្តាល ស្រុកល្វាឯម និងស្រុកកៀនស្វាយ ។

– ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៩ បានអញ្ជើញចូលរួមកម្មវិធីចែករង្វាន់ដល់សិស្សឈ្មោះ ស៊ុំ សុខណាភេទស្រី រៀនថ្នាក់ទី១២ នៃវិទ្យាល័យហ៊ុន សែន ទឹកឃ្លាំង ដែលបានប្រឡងជាប់សិស្សពូកែទូទាំងខេត្តចំណាត់ថ្នាក់លេខ៤ មុខវិជ្ជាភាសាខ្មែរ និងបានប្រឡងថ្នាក់ជាតិទទួលបានចំណាត់ថ្នាក់លេខ១៣ ក្នុងចំណោមសិស្សពូកែទូទាំងប្រទេស៨០នាក់ ដោយបានជូនថវិកាលោកគ្រូមុខវិជ្ជាខ្មែរ១នាក់ថវិកា២០០០០០រៀល និងសិស្សជាប់ចំណាត់ថ្នាក់ថវិកា២០០០០០រៀល។

- ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៩ បានអញ្ជើញចូលរួមក្នុងពិធីគោរពវិញ្ញាណក្ខន្ធប្រជាជនកម្ពុជារាប់លាននាក់ដែលបានបាត់បង់អាយុជីវិតយ៉ាងអយុត្តិធម៌ក្រោមរបបប្រល័យពូជសាសន៍ពុល ពត ក្រោមអធិបតីភាព **ឯកឧត្តម គង់ ទិបុល** ប្រតិភូរាជរដ្ឋាភិបាល អនុប្រធានក្រុមការងារជាតិចុះជួយស្រុកល្វាឯម ដែលប្រព្រឹត្តទៅក្នុងបរិវេណវត្តស្វាយអណ្ដែត ស្ថិតនៅក្នុងភូមិតាស្គរ ឃុំសារិកាកែវ ស្រុកល្វាឯម ខេត្តកណ្ដាល។

- ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៩ បានសហការណ៍ជាមួយយុវជន ស.ស.យ.ក ស្រុក នាំយកអំណោយនៃសេចក្ដីស្រលាញ់របស់ស.ស.យ.កស្រុកល្វាឯម ទៅឧបត្ថម្ភជូនដល់ការប្រកួតបាល់ទាត់សិស្សបឋមសិក្សាបន្ទាយម្លូរ អាយុក្រោម១២ឆ្នាំនៅឃុំសំបួរ ស្រុកល្វាឯម អំណោយរួមមានបាល់ទាត់ចំនួន ៨ បាល់ និងទឹកបរិសុទ្ធចំនួន២០០យួរ ក្នុងនោះលោក អ៊ុក ឡៀប ប្រធានការិយាល័យភូមិបាលស្រុកបានឧបត្ថម្ភទឹកបរិសុទ្ធចំនួន១០០យួរ។

- ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៩ បានអញ្ជើញជាអធិបតីភាពក្នុងកិច្ចប្រជុំពិភាក្សាស្ដីពីដំណើរការនៃសមាគមមនុស្សចាស់តាមបណ្ដាឃុំទាំង១៥ ក្នុងស្រុកល្វាឯម នៅសាលប្រជុំ សាលាស្រុកល្វាឯម វត្តមានចូលរួម២១នាក់, ស្រី០៣នាក់។

- ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៩ បានការចូលរួមពីលោក ម៉ម ប៉ូលី អនុប្រធាន និងក្រុមការងាររបស់មន្ទីរអប់រំយុវជន និងកីឡាខេត្តកណ្ដាល ព្រមទាំងសមាជិកក្រុមប្រឹក្សាស្រុក ប្រធាន និងមន្ត្រីការិយាល័យអប់រំស្រុក និងអាជ្ញាធរឃុំ-ភូមិ បានអញ្ជើញត្រួតពិនិត្យអគារសាលាបឋមសិក្សាព្រែកគង់រាជ ១ខ្នង, មានប្រាំមួយបន្ទប់ ដែលកំពុងរងការរុះសសរទ្រូអគារចេញដែក និងមានស្នាមប្រេះស្រុតនៅផ្នែកមួយចំនួនរបស់អគារដែលសិស្សានុសិស្សកំពុងសិក្សារៀងរាល់ថ្ងៃ ស្ថិតនៅឃុំព្រែករៃ ស្រុកល្វាឯម ខេត្តកណ្ដាល។

- ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៩ បានអញ្ជើញចូលរួមក្នុងវេទិការ ផ្សព្វផ្សាយច្បាប់ស្ដីពីការជួញដូរមនុស្ស និងអំពីការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ និងច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ក្រោមអធិបតីលោកជំទាវហ៊ុន កុសនី អភិបាលរងខេត្ត និងអនុប្រធានគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញ ដូរមនុស្ស ខេត្តកណ្ដាល លោកជំទាវ នួន នារតី ប្រធានគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារខេត្ត កណ្ដាល(គ.ក.ស.ក) និង ព្រមទាំងបានការអញ្ជើញចូលរួមពីលោកស្រីឧត្តមសេនិយ៍ត្រី ឈឹម វណ្ណី ស្នងការរងនគរបាលខេត្តកណ្ដាល សរុបអ្នកចូលរួម ២៥០ នាក់

- ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៩ បានអញ្ជើញចូលរួមក្នុងពិធីសំណេះសំណាលជាមួយសិស្សានុសិស្សថ្នាក់ទី១២ និងចែករង្វាន់ដល់សិស្សជាប់ជ័យលាភីលេខមួយ ដល់លេខបីក្នុងប្រឡងសិស្សពូកែលើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា ទាំងបីវិទ្យាល័យ( **ហ៊ុន សែន** ពាមឧកញ៉ាអុង, ទឹកឃ្លាំង និងវិទ្យាល័យ **ហ៊ុន សែន** ល្វាសរ) ក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិត ផាន់ ផល្លា** អនុប្រធានក្រុមការងារថ្នាក់កណ្ដាលទទួលបន្ទុកការងារគ្រូបង្រៀន និង**ឯកឧត្តម ជាវ ជាឆុង** អនុប្រធានក្រុមការងារថ្នាក់កណ្ដាលទទួលបន្ទុកការងារយុវជនតំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម អគ្គបណ្ឌិត សភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានការងារថ្នាក់ជាតិចុះជួយខេត្តកណ្ដាល។

- ថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៩ បានរៀបចំវគ្គបណ្ដុះបណ្ដាល ស្ដីពីការរៀបចំផែនការសកម្មភាព និងថវិកាលើវិស័យសេវាសង្គមឃុំ-សង្កាត់ នៅសាលាស្រុកល្វាឯម ខេត្តកណ្ដាល វត្តមានចូលរួម៥៥នាក់, ស្រី២០នាក់។

– ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៩ បានផ្សព្វផ្សាយគោលនយោបាយនៃការអនុវត្តបេឡាជាតិរបបសន្តិសុខសង្គម(ប.ស.ស) ព្រមទាំងបានការអញ្ជើញចូលរួមជាកិត្តិយសពីលោក សែម សោត្ថិ ប្រធានក្រុមប្រឹក្សាស្រុក និងលោក-លោកស្រីអភិបាលរងស្រុក សរុបវត្តមានចូលរួមចំនួន៨៥នាក់, ស្រី២១នាក់ នៅសាលប្រជុំសាលាស្រុកល្វាឯម។

– ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៩ បានផ្សព្វផ្សាយ សៀវភៅណែនាំ ការគ្រប់គ្រងមត្តេយ្យសហគមន៍សម្រាប់ឃុំ-សង្កាត់ និងមានការចូលរួមដោយលោកស្រីរ៉េន កន្និកា អភិបាលរងស្រុក, លោកញ៉ឹក សាត នាយករដ្ឋបាលសាលាស្រុក, លោកគ្រូ អ្នកគ្រូ និងក្រុមការងារសម្របសម្រួលវគ្គបណ្តុះបណ្តាលប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុស្រុក, ប្រធាន អនុប្រធានការិយាល័យផែនការគាំទ្រឃុំ-សង្កាត់ស្រុក, លោក-លោកស្រីមន្ត្រីរាជការសាលាស្រុក មន្ត្រីទទួលបន្ទុកអប់រំកុមារតូចនៃការិយាល័យអប់រំស្រុក មេឃុំ ឬតំណាងមេឃុំទាំង១៥ ស្មៀនឃុំទាំង១៥ឃុំ ជនទទួលបន្ទុកកិច្ចនារី និងកុមារឃុំ និងនាយកសាលាដែលជាសមាជិក គ.ក.ន.ក សរុបវត្តមានសិក្ខាកាមចូលរួមវគ្គបណ្តុះបណ្តាលចំនួន៧២នាក់, ស្រី២២នាក់។

– ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៩ បានបើកកិច្ចប្រជុំរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក ដើម្បីរៀបចំសមាសភាព និងត្រៀមលក្ខណៈជួយសង្គ្រោះប្រជាពលរដ្ឋក្នុងស្រុកនារដូវទឹកជំនន់ ដោយមានការចូលរួមដោយ លោក-លោកស្រី អភិបាលរងស្រុក, នាយក នាយករងរដ្ឋបាលសាលាស្រុក, មេបញ្ជាការ មេបញ្ជាការរងកងកម្លាំងទាំងបី, ប្រធាន ការិយាល័យ-អង្គភាព ជំនាញ និងចំណុះសាលាស្រុក, មន្ត្រីរាជការសាលាស្រុក មេឃុំ តំណាងមេឃុំទាំង១៥ឃុំ សរុបវត្តមានចូលរួមចំនួន៤៥នាក់, ស្រី០៦នាក់។

– ថ្ងៃទី១០ សីហា ២០១៩ បានអញ្ជើញចូលរួមក្នុងពិធីសំណេះសំណាលសាកសួរសុខទុក្ខសមាជិក ស.អ.ក(ពិការ) ក្រុងតាខ្មៅ និងស្រុកកៀនស្វាយ ចំនួន៣១១នាក់ ក្រោមអធិបតីភាព **ឯកឧត្តមនាយឧត្តមសេនីយ៍ គន់ គីម** ទេសរដ្ឋមន្ត្រី អនុប្រធានទី១ និងជាអគ្គលេខាធិការសមាគមអតីតយុទ្ធជនកម្ពុជា។

- នៅរសៀលថ្ងៃអង្គារ ទី១៨ ខែមិថុនា ឆ្នាំ២០១៩ បានអញ្ជើញចូលរួមក្នុងពីធីសូត្រមន្តក្នុងឱកាសព្រះរាជាពិធីបុណ្យចម្រើនព្រះវស្សា **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ក្រោមអធិបតីភាព**ឯកឧត្តម នួន ផា** អនុប្រធានកិត្តិយសសាខាកាកបាទក្រហមកម្ពុជា ខេត្តកណ្តាល តំណាង **ឯកឧត្តមបណ្ឌិត ម៉ៅ ភិរុណ** ប្រធានកិត្តិយសសាខាកាកបាទក្រហមខេត្តកណ្តាល នៅទីស្នាក់ការកាកបាទក្រហមក្រុងតាខ្មៅ ខេត្តកណ្តាល។

– ថ្ងៃទី១៧ .១៨ ខែកញ្ញា ឆ្នាំ២០១៩ បានអញ្ជើញចូលរួម ពិធីសំណេះសំណាលជាមួយប្អូនៗប្រឡងជាប់សញ្ញាបត្រទុតិយភូមិ និងសិស្សានុសិស្សថ្នាក់ទី១១ និងទី១២ថ្មី ឆ្នាំសិក្សា២០១៩-២០២០ ក្រោមអធិបតីភាព **ឯកឧត្តម ជាប ជាទុធ** អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ តំណាងដ៏ខ្ពង់ ខ្ពស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមការងារថ្នាក់ជាតិចុះជួយខេត្តកណ្តាល និងមានការចូលរួមពីលោក សែម សោត្ថិ ប្រធានក្រុមប្រឹក្សាស្រុកនិងលោក កន សុខកាយ អភិបាលរងស្រុក សរុបវត្តមានចូលរួមចំនួន១០៣៥នាក់។

– ថ្ងៃទី១២.១៣ ខែតុលា ឆ្នាំ២០១៩ បានដឹកនាំទូកងទាំង៦(ទូកង៤ និងទូកខ្ចាតអន្តរជាតិ២) ដើម្បីចូលរួមពិធីអុំទូកនៅក្រុងតាខ្មៅ ។

– ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៩ បានចូលរួមពិធីបើកការប្រកួតបាល់ទាត់ដណ្តើមពានរង្វាន់សហភាពសហព័ន្ធយុវជនកម្ពុជាខេត្តកណ្តាល ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិត ម៉ៅ ភិរុណ** អភិបាលខេត្ត

ណ្ដាល និងបានចូលរួមជាអធិបតី **ឯកឧត្តម គីម រិទ្ធី** ប្រធានសហភាពសហព័ន្ធយុវជនកម្ពុជាខេត្តកណ្ដាល នៅទីលានបាល់ទាត់ខេត្តកណ្ដាល។

– ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៩ បានអញ្ជើញជាអធិបតីភាពក្នុងពិធីបើកបវេសនកាលឆ្នាំសិក្សាថ្មី២០១៩-២០២០ នៅវិទ្យាល័យទាំងបី ដោយមានការចូលរួមពី សមាជិកក្រុមប្រឹក្សាស្រុក, លោក នាយក រដ្ឋបាលស្រុក, លោកប្រធានការិយាល័យអប់រំស្រុក, មន្ត្រីរាជការសាលាស្រុក, ក្រុមប្រឹក្សាឃុំពាមឧកញ៉ាអុងកម្លាំងនគរបាលរដ្ឋបាលឃុំពាមឧកញ៉ាអុង, លោកគ្រូ-អ្នកគ្រូកំពុងបង្រៀន, គ្រូបង្រៀនចូលនិវត្តន៍ និងសិស្សានុសិស្សនៃវិទ្យាល័យ សរុបវត្តមានចូលរួមប្រមាណ១៦០០នាក់។

– នៅព្រឹកថ្ងៃសៅរ៍ ទី០៩ ខែវិច្ឆិកា ឆ្នាំ២០១៩ បានអញ្ជើញចូលរួមក្នុងពិធីហូបអំបុកខ្មែរដើម្បីការពារជាតិ សាសនា និងព្រះមហាក្សត្រ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមអគ្គបណ្ឌិត សភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមការងារថ្នាក់ជាតិចុះជួយខេត្តកណ្ដាល និងបានការអញ្ជើញចូលរួមជាគណៈអធិបតី **ឯកឧត្តម គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាល អនុប្រធានក្រុមការងារជាតិចុះជួយស្រុកល្វាឯម។ **បញ្ជាក់:** នៅក្នុងពិធីនោះក៏មានការអុំទូកថ្នាក់ស្រុកផងដែរ នៅមាត់ទន្លេ ឃុំពាមឧកញ៉ាអុង សរុបវត្តមានចូលរួមប្រមាណ៣៨០០នាក់។

– ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៩ បានដឹកនាំមន្ត្រីរាជការសាលាស្រុក ចុះទៅសួរសុខទុក្ខ លោក ព្រំ ព្រឿន សមាជិកក្រុមប្រឹក្សាស្រុក ដែលកំពុងមានជម្ងឺលើសសម្ពាធឈាមកំពុងសំរាកព្យាបាលជំងឺនៅគេហដ្ឋាននៅភូមិកោះរះលើ ឃុំកោះរះ។

– ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៩ បានចូលរួមពិធីចែកអំណោយជូនសិស្សានុសិស្សចំនួន ៧០០នាក់ នៅឃុំភូមិធំ ដែលមានសមាសភាពចូលរួម លោក លោកស្រីថ្នាក់ជាតិចុះជួយឃុំភូមិធំ លោកប្រធានការិយាល័យអប់រំ យុវជន និងកីឡា ក្រុមការងារ តំណាងក្រុមហ៊ុនទាំង៤ អាជ្ញាធរភូមិឃុំ ប្រជាការពារ លោកនាយកសាលា លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សចំនួន៧០០នាក់។

– ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៩ បានដឹកនាំកិច្ចរៀបចំសមាសភាពចូលរួមគាំទ្រក្លឹបបាល់ទាត់របស់ ស. ខែវិច្ឆិកា និងត្រៀមលក្ខណៈក្នុងការដឹកនាំសមាជិក យុវជន ២៤ក ត្រូវប្រកួតវគ្គផ្ដាច់ព្រ័ត្ត នៅថ្ងៃទីក ស្រុ.យ.ស នៃការបង្កើតសហភាពសហព័ន្ធយុវជនកម្ពុជា ៤១ក ស្រុកទៅចូលរួមពិធីអបអរសាទរខួបទី.យ.ស.សនៅវិមានឈ្នះឈ្នះ ដែលមានសមាសភាពចូលរួម២៥នាក់ ស្រី០៥នាក់។

– ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៩ លោក គឹម គីវ៉ា អភិបាលស្រុក និងលោក សែម សោត្ថិ ប្រធានក្រុមប្រឹក្សាស្រុក បានអញ្ជើញចូលរួមពិធីអបអរសាទរខួប១ឆ្នាំ នៃការបញ្ចូលល្ខោនខោលវត្តស្វាយអណ្ដែត ជាបេតិកភ័ណ្ឌពិភពលោក ស្ថិតនៅវត្តស្វាយអណ្ដែត ក្រោមអធិបតីភាព **ឯកឧត្តម គឹម ពេជ្រវិនុន** អនុរដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ តំណាងលោកជំទាវ ភឿន សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ព្រមព្រះសុជមុនី ភោគ រស់ ព្រះអនុគុណស្រុក និងបាននិមន្ត និងអញ្ជើញជាគណៈអធិបតីព្រះមហា ជា ប៊ុនធឿន ព្រះចៅអធិការវត្តស្វាយអណ្ដែត និងលោក សែម សោត្ថិ ប្រធានក្រុមប្រឹក្សាស្រុក សមាសភាពចូលរួម ឯកឧត្តម លោកជំទាវរួមដំណើរ លោក លោកស្រីសមាជិកក្រុមប្រឹក្សាស្រុក លោក លោកស្រីអភិបាលរងស្រុក នាយក នាយករងរដ្ឋបាលសាលាស្រុក មេបញ្ជាការ មេបញ្ជាការរងកងកម្លាំងទាំងបី ប្រធានការិយាល័យ អង្គភាពជំនាញជុំវិញស្រុក មន្ត្រីរាជការសាលាស្រុក សមាជិកក្រុមប្រឹក្សាឃុំស្វាយអណ្ដែត ព្រះសង្ឃ គណៈកម្មការវត្ត តាជី យាយជី សរុបវត្តមាន៣០០នាក់។

– ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៩ បានចូលរួមកម្មវិធីចែកប័ណ្ណសង្គមកិច្ច និងបើកផ្តល់របបគោលនយោបាយជូន ជនពិការនៅតាមសហគមន៍ ក្រោមអធិបតីភាព **ឯកឧត្តម ញឹម វណ្ណដា** រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និង**ឯកឧត្តម តាំង ម៉េងលាង** អភិបាលរងខេត្ត តំណាង **ឯកឧត្តមបណ្ឌិត ម៉ៅ ភិរុណ** អភិបាលខេត្តកណ្តាល នៅស្រុកខ្សាច់កណ្តាល។

– ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៩ បានអញ្ជើញចូលរួមពិធីអបអរទិវាអន្តជាតិនៃអ្នកស្ម័គ្រចិត្ត កាកបាទក្រហមកម្ពុជា ខេត្តកណ្តាល ក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិត ម៉ៅ ភិរុណ** អភិបាលខេត្ត និងជាប្រធានកិត្តិយសសាខាកាកបាទក្រហមខេត្តកណ្តាល នៅក្រុងតាខ្មៅ ខេត្តកណ្តាល។

– ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ ២០១៩ បានរួមដំណើរ**ជាមួយ លោកជំទាវ ឡៅ វណ្ណារ័ត្ន** អនុប្រធានគកសកខេត្ត និង**លោកជំទាវម៉ុន រមណី** អនុប្រធានគកសកខេត្ត ព្រមទាំងក្រុមប្រឹក្សាឃុំ និងអាជ្ញាធរ ចុះពិនិត្យមើលការបង្រៀនមត្តេយ្យសហគមន៍ទាំងបីសាលា ស្ថិតនៅឃុំសំបួរ និងបានឧបត្ថម្ភថវិកាចំនួន ១០០ដុល្លារ ក្នុងការទិញ តុកៅអី ជូនមត្តេយ្យសហគមន៍ភូមិព្រែកចារផងដែរ។

**៣.គ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ**

– ថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៩ បានដឹកនាំកម្លាំងចម្រុះស្រុក ចុះហាមឃាត់ និងចាប់យកគ្រឿងចក្រជីកដីនៅចំណុចដីដុះ ភូមិខ្សាច់ ឃុំអរិយក្សត្រ ដែលមានម្ចាស់ទីតាំងឈ្មោះ ង៉ាក់ ចេង។

– ថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៩ បានបើកកិច្ចប្រជុំសម្រុះសម្រួលបញ្ហាដីធ្លីនៅចំណុចមុខសាលាបឋមសិក្សាពោធិ៍ធំ ភូមិពោធិ៍ធំ ឃុំអរិយក្សត្រ រវាងព្រះគ្រូចៅអធិការវត្ត-គណៈកម្មការអាចារ្យវត្តសារិកាកែវ និងអតីតលោកគ្រូអ្នកគ្រូបឋមសិក្សាពោធិ៍ធំចំនួន៥នាក់ នៅសាលប្រជុំសាលាស្រុកល្វាឯម។

– ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៩ បានចុះត្រួតពិនិត្យផ្លូវបេតុងមួយកន្លែងដែលមាន ទទឹង៧ម៉ែត្រ, បណ្តោយ៤០៤ម៉ែត្រ,កម្រាស់០,១៥ម៉ែត្រ ស្ថិតនៅភូមិអរិយក្សត្រ ឃុំអរិយក្សត្រ ស្រុកល្វាឯម ខេត្តកណ្តាល។

– ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំពិភាក្សាដោះស្រាយដីធ្លីនៅឃុំស្វាយជ្រុំ ឃុំព្រែកតាកូវ និងឃុំព្រែកលួង ស្រុកខ្សាច់កណ្តាល ក្រោមអធិបតីភាព ឯកឧត្តម ហាស់ សារ៉េត និងឯកឧត្តមបណ្ឌិត ម៉ៅ ភិរុណ អភិបាល នៃគណៈអភិបាលខេត្តកណ្តាល។

– ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៩ បានបើកកិច្ចប្រជុំសម្រុះសម្រួលករណីផ្លូវទេះចុះទៅមាត់ទន្លេ(មុខវត្តពោធិ៍មាស)ស្ថិតនៅភូមិវាលធំ ឃុំពាមឧកញ៉ាអុង។

– ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៩ បានបើកកិច្ចប្រជុំសម្រុះសម្រួលករណី ដីជាន់គ្នារវាងលោកចាន់ អង និងលោកស្រី ចាន់ថន នៅចំណុចភូមិខ្មោការ ឃុំបារុង ស្រុកល្វាឯម នៅសាលប្រជុំសាលាស្រុក។

– ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩ បានដឹកនាំគណៈកម្មការគ្រប់គ្រងដីរដ្ឋថ្នាក់ស្រុក ចុះមកពិនិត្យមើលទីតាំងដីស្នើសុំចុះបញ្ជីរបស់លោក ស្រី ចាន់ថន ស្ថិតនៅឃុំកោះរះ និងឃុំព្រែកក្មេង ។

– ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩ បានបើកកិច្ចប្រជុំផ្សព្វផ្សាយ ស្តីពីការគ្រប់គ្រងសំរាម និងសំណល់រឹងនៅតាមបណ្តាលឃុំ តាមផ្សារនិងទីប្រជុំជន ទូទាំងស្រុក។

– ថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ២០១៩ បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំត្រួតពិនិត្យលើសេវាសំរាមការងារផ្តល់កិច្ចសន្យាសេវាសំរាមរបស់ក្រុង-ស្រុក ក្រោមអធិបតីភាព ឯកឧត្តម គង់ សោភ័ណ្ឌ អភិបាលរងខេត្តកណ្តាល នៅសាលប្រជុំអគារ A សាលាខេត្តកណ្តាល។

- ថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ២០១៩ បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំគណៈកម្មការសុរិយោដីខេត្ត និងគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិត ម៉ៅ ភិរុណ អភិបាល នៃគណៈអភិបាលខេត្ត នៅសាលប្រជុំអគារខ សាលាខេត្តកណ្ដាល។

- ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩ បានបើកកិច្ចប្រជុំសម្រុះសម្រួលវិវាទដីធ្លីនៅចំណុចមុខបឋមសិក្សាពោធិ៍ធំ ក្នុងភូមពោធិ៍ធំ ឃុំអរិយក្សត្រ រវាងគណៈកម្មការអាចារ្យ-ពុទ្ធបរិស័ទចំណុះជើងវត្តសារិកាកែវ និងអតីតលោកគ្រូអ្នកគ្រូបឋមសិក្សាពោធិ៍ធំចំនួន០៥នាក់ នៅសាលប្រជុំសាលាស្រុកល្វាឯម។

- ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៩ បានចុះពិនិត្យការដ្ឋានសាងសង់ផ្លូវបេតុង១ខ្សែ នៅចំណុចមុខវត្តពេជ្រម្កុដ-ឆ្ពោះទៅកំពង់ចម្លងអរិយក្សត្រ ស្ថិតក្នុងភូមិអរិយក្សត្រ ឃុំអរិយក្សត្រ។

- ថ្ងៃទី០២ខែមីនាឆ្នាំ២០១៩បានដឹកនាំក្រុមការងារស្រុកចុះពិនិត្យទីតាំងអាជីវកម្មទឹកស្អាត ក្នុងភូមិអរិយក្សត្រ ឃុំអរិយក្សត្រ ដើម្បីសិក្សាអំពីបញ្ហាខ្វះខាតទឹកប្រើប្រាស់ ដែលជាបញ្ហាប្រឈមរបស់ប្រជាពលរដ្ឋ។

- ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៩ បានចុះបើកការដ្ឋានជួសជុលផ្លូវលំដីស ដែលបានការឧបត្ថម្ភដោយអង្គការមនុស្សធម៌មអភិវឌ្ឍសង្គម ប្រវែង៣៦០៣ម៉ែត្រ ទទឹង៨ម៉ែត្រ នៅចំណុចក្បាលជ្រោយស្ថិតនៅភូមិតាស្គរ ឃុំសារិកាកែវ ស្រុកល្វាឯម ដោយមានការចូលរួមពីអាជ្ញាធរឃុំ-ភូមិ នគរបាល ប្រជាការពារ ប្រជាជន សរុប ១០០នាក់។

- ថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៩ បានបើកកិច្ចប្រជុំពាក់ព័ន្ធនឹងព្រះចៅអធិការវត្តព្រះនាម សៀន សយ ប្តឹងលោកនាយកអនុវិទ្យាល័យស្វាយអណ្តែតរំលោភដីវត្តសាងសង់សាលារៀនដែលមានការចូលរួមពីមន្ត្រីរបស់មន្ទីរអប់រំខេត្តកណ្ដាល ការិយាល័យអប់រំស្រុកអាជ្ញាធរឃុំ-ភូមិនឹងអ្នកពាក់ព័ន្ធផ្សេងទៀត នៅសាលាឃុំសារិកាកែវស្រុកល្វាឯម។

- ថ្ងៃទី១៩ ខែមិនា ឆ្នាំ២០១៩ បានដឹកនាំក្រុមការងារថ្នាក់ស្រុកដែលមានសមាសភាព លោក ណាង តារា អធិការរងនគរបាលស្រុក លោក ឌួង រតនៈ ប្រធានការិយាល័យអន្តរវិស័យ លោក វ៉ាន មាំង ប្រធានការិយាល័យរ៉ែ និងថាមពល អាជ្ញាធរឃុំ-ភូមិ និងកម្លាំងប៉ុស្តិ៍រដ្ឋបាលឃុំបារុង បានចុះណែនាំ និងហាមឃាត់ប្រជាពលរដ្ឋ០១គ្រួសារដែលបានកំពុងសាងសង់សំណង់លើទីតាំងដីសាធារណៈរបស់រដ្ឋស្ថិត នៅចំណុចជំរុំត្នោត ដែលមានទីតាំងស្ថិតនៅភូមិបារុង ឃុំបារុង។

- ថ្ងៃទី២៤ខែមីនាឆ្នាំ២០១៩ បានអញ្ជើញចុះត្រួតពិនិត្យផ្លូវមួយកន្លែងគិតពីចំណុចព្រំប្រទល់ភូមិថ្មគរឃុំថ្មគរ ទល់នឹងភូមិកោះរះក្រោម ឃុំកោះរះ ហូតដល់ភូមិផ្លូវត្រី ឃុំថ្មគរ ដែលគ្រោងនិងជាផ្លូវបេតុង នៅពាក់កណ្តាលឆ្នាំ២០១៩ដោយមានការរួមដំណើរដោយកញ្ញា កែវ ជូនសុគន្ធា អនុប្រធានការិ.ផែនការ និងគាំទ្រឃុំ-សង្កាត់ លោក លន់ ឌុំ មន្ត្រីបច្ចេកទេសស្រុក និងអាជ្ញាធរ ឃុំ-ភូមិ ។

- ថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៩ បានបើកកិច្ចប្រជុំផ្សព្វផ្សាយស្តីពីសេចក្តីប្រកាសកំណត់តំបន់ធ្វើការវិនិច្ឆ័យសំរាប់ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធនៅភូមិពោធិ៍ធំ ឃុំអរិយក្សត្រ ដោយមានការចូលរួមលោក ព្រុំ ធាត អនុប្រធានមន្ទីរដ.ន.ស.ភ ខេត្តកណ្ដាល វត្តមានចូលរួម៩៧នាក់។

- ថ្ងៃទី២២ខែមេសា ២០១៩ បានចូលរួមក្នុងកិច្ចប្រជុំការងារដោះស្រាយផលប៉ះពាល់ដីធ្លី សំណង់ ផ្ទះសម្បែង និងដើមឈើរបស់ប្រជាពលរដ្ឋ សម្រាប់គម្រោងសាងសង់ខ្សែបញ្ជូនអគ្គីសនី ២៣០គីឡូវ៉ុល និង៥០០គីឡូវ៉ុល ពីខេត្តព្រះសីហនុ មករាជធានីភ្នំពេញ នៅសាលាខេត្តកណ្ដាល ។

- ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៩ បានចូលរួមកិច្ចប្រជុំគណៈកម្មការសុរិយោដីខេត្ត និងគណៈកម្មការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ដើម្បីពិនិត្យ និងពិភាក្សាលើការងារជំរុញការចុះបញ្ជីដីរដ្ឋ គ្រប់ករណីក្នុងភូមិ សាស្ត្រ

ខេត្ត និងករណីដីបឹងរាម ស្ថិតនៅឃុំព្រែកអំពិល ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិត ម៉ៅ ភិរុណ អភិបាល នៃគណៈអភិបាលខេត្តកណ្តាល។

– ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៩ បានដឹកនាំក្រុមការងារថ្នាក់ស្រុករួមមាន ប្រធានការិយាល័យអន្តរវិស័យធនធានទឹក មន្ត្រីការិយាល័យសាធារណៈការ និងអាជ្ញាធរភូមិឃុំ បានចុះពិនិត្យមើលទីតាំងចាក់ដីរបស់ឈ្មោះ អោម អុន ដើម្បីបើកផ្លូវចូលទៅដីរបស់ខ្លួននៅខាងក្រោយនៅចំណុចប្រឡាយហ្លួង ស្ថិតក្នុងភូមិទួលទ្រា ឃុំព្រែកក្មេង ។

– ថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៩បានអញ្ជើញដឹកនាំក្រុមការងារថ្នាក់ស្រុក ចុះមកពិនិត្យទីតាំងចិញ្ចឹមជ្រូកមួយកន្លែងរបស់ឈ្មោះ យ៉ា យ៉ុន ស្ថិតក្នុងភូមិក្តីកណ្តាល ឃុំសារិកាកែវ ។

– ថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៩ បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយស្តីពីការប្រមូលពន្ធប្រថាប់ត្រាចំពោះការផ្ទេរសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ ពន្ធលើអចលនទ្រព្យ និងការត្រៀមអនុវត្តប្រកាសស្តីពីការកំណត់មូលដ្ឋានគិតពន្ធប្រថាប់ត្រាចំពោះការផ្ទេរសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិត **ម៉ៅ ភិរុណ** អភិបាល នៃគណអភិបាលខេត្ត ឯកឧត្តម **នួន ផា** ប្រធានក្រុមប្រឹក្សាខេត្តកណ្តាល និងឯកឧត្តម ហេង សុខណាង អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ នៅសាលប្រជុំអគារB សាលាខេត្តកណ្តាល។

– ថ្ងៃទី០៨ ខែឧសភា ឆ្នាំ ២០១៩បានដឹកនាំក្រុមការងារចំរុះថ្នាក់ស្រុក ចុះបើកផ្លូវមួយខ្សែដែលមានប្រវែងប្រហែស១៦០០ម៉ែត្រ ដែលមានទទឹង២០ម៉ែត្រ ឆ្លងកាត់ចំនួន២ឃុំ ចំនួន៣ភូមិ(ភូមិកោះរះលើ ភូមិវាលធំ និងភូមិព្រែកតាអុងទី៣) សមាសភាពចូលរួមសរុប ២៣នាក់។

– ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៩ បានអញ្ជើញចូលរួមក្នុងពិធីបញ្ចុះបឋមសិលាសាងសង់អគាររដ្ឋបាល អគារសាលប្រជុំសាលាស្រុក និងអគាររដ្ឋបាល ឃុំកោះរះ បឹងគ្រំ កោះកែវ សំបួរ និងពិធីបើកការដ្ឋានសាងសង់ផ្លូវបេតុងប្រវែង ៥៥៧០ម៉ែត្រ នៅឃុំថ្មគរ និងឃុំព្រែកក្មេង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមបណ្ឌិត **ម៉ៅ ភិរុណ** អភិបាល នៃគណៈអភិបាលខេត្តកណ្តាល នៅបរិវេណសាលាស្រុកល្វាឯម ខេត្តកណ្តាល។

– ថ្ងៃទី១៨ខែឧសភា ឆ្នាំ២០១៩ បានចុះពិនិត្យការដ្ឋានស្ពានបេតុងព្រះអង្គខ្មៅ ដែលមានប្រវែង៥០ម៉ែត្រ ទទឹង ៥ម៉ែត្រ ជាគម្រោងកំពុងកសាងដោយក្រសួងសាធារណៈ និងដឹកជញ្ជូន ស្ថិតនៅភូមិជ្រោយជ្រៃ ឃុំសំបួរ ស្រុកល្វាឯម ខេត្តកណ្តាល ដោយរួមដំណើរ លោក កែវ ស៊ីណាន នាយករដ្ឋបាលសាលាស្រុក ប្រធានការិយាល័យអន្តរវិស័យស្រុក លោកមេឃុំសំបួរ ព្រមទាំងអាជ្ញាធរឃុំ-ភូមិ ។

– ថ្ងៃទី២១ ខែឧសភាឆ្នាំ ២០១៩ បានចុះពិនិត្យកន្លែងចាក់សម្រាម និងដុតកាកសំណល់សម្រាម នៅចំនុចកំពុងជវត្តខ្សាច់ចាស់ ស្ថិតនៅភូមិខ្សាច់ ឃុំអរិយក្សត្រ ស្រុកល្វាឯម ខេត្តកណ្តាល។

– ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៩ បានចូលរួមក្នុងកិច្ចប្រជុំក្រុមការងារចំពោះកិច្ច ដើម្បីពិនិត្យពិភាក្សាលើការចុះអង្កេតវាស់វែងដីរដ្ឋសម្រាប់ការចុះបញ្ជីក្បាលដីទុកជាទ្រព្យសម្បត្តិរបស់រដ្ឋ ក្រោមអធិបតីភាព លោក ស្រេង លីមហួ នាយករងរដ្ឋបាលសាលាខេត្ត និងជាប្រធានក្រុមការងារចំពោះកិច្ច នៅសាលាខេត្តកណ្តាល។

– ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៩ បានអញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សា ស្តីពីសំណើសុំការសម្របសម្រួលដោះស្រាយទិញដីនៅឃុំកោះរះ ស្រុកល្វាឯម ខេត្តកណ្តាល ដើម្បីកសាងរោងចក្រផលិតថាមពលអគ្គីសនី ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិត ម៉ៅ ភិរុណ អភិបាល នៃគណៈអភិបាលខេត្តកណ្តាលឯកឧត្តម ប្រាំង ផលសា អគ្គនាយករង អគ្គីសនីកម្ពុជា នៅសាលាខេត្តកណ្តាល។

– ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៩ បានដឹកនាំគណៈកម្មការគ្រប់គ្រងដីរដ្ឋថ្នាក់ស្រុក (នាយករងរដ្ឋបាល, លោកប្រធានការិយាល័យ ដនសក, មន្ត្រីតំណាងការិយាល័យអន្តរវិស័យ, លោកប្រធានការិយាល័យ ធនធានទឹក និងឧតុនិយម, លោកប្រធានការិយាល័យ កសិកម្ម, លោកប្រធានការិយាល័យ បរិស្ថាន, លោកប្រធានការិយាល័យ ជលផល, លោកប្រធានការិយាល័យ អភិវឌ្ឍន៍ជនបទ, លោកប្រធានការិយាល័យ សាធារណៈការ និងកងកំលាំង ចំរុះបានអញ្ជើញចុះកំណត់យកនិយាមការដើម្បីចុះបញ្ជី(ដីបឹងឈូងគរ) ស្ថិតនៅភូមិផ្លូវត្រី ឃុំថ្មគរ និងភូមិទឹកឃ្លាំង ឃុំទឹកឃ្លាំង ស្រុកល្វាឯម ខេត្តកណ្តាល ទៅជាសម្បត្តិរដ្ឋ។

– ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៩ បានបើកកិច្ចប្រជុំពិភាក្សារកដំណោះស្រាយរំដោះទឹកដែលស្ទះនៅពេលភ្លៀង បង្កជាក្លិនស្អុយប៉ះពាល់ដល់ការរស់នៅរបស់ប្រជាពលរដ្ឋ ស្ថិតក្នុងភូមិវាលធំ ឃុំពាមឧកញ៉ាអុង។ បន្ទាប់ពីប្រជុំចប់ លោកអភិបាលរង បានដឹកនាំក្រុមការងារចុះទៅពិនិត្យទីតាំងផ្ទាល់ដើម្បីស្វែងរកផ្លូវរំដោះទឹក។

– ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៩ បានអញ្ជើញជាអធិបតីភាពក្នុងកិច្ចប្រជុំបើកសំណើដេញថ្លៃគម្រោងមូលនិធិឃុំ ឆ្នាំ២០១៩ របស់ស្រុក ចំនួន៤ឃុំ ដែលជាម្ចាស់គម្រោងមាន៖ ឃុំភូមិធំ, ព្រែកឬស្សី, ល្វាសរ នឹងឃុំកោះកែវ នៅសាលប្រជុំសាលាស្រុកល្វាឯម ខេត្តកណ្តាល វត្តមានចូលរួម៣៥នាក់, ស្រី១០នាក់។

– ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៩ បានសហការ ជាមួយអាជ្ញាធរអគ្គីសនីកម្ពុជា រួមជាមួយអាជ្ញាធរឃុំ និងចុះបោះបង្គោលកំណត់ទីតាំងដីដែលត្រូវសាងសង់រោងចក្រផលិតថាមពលអគ្គីសនីកំលាំង៤០០ មេកាវ៉ាត់ ស្ថិតនៅភូមិ កោះរះក្រោម ឃុំកោះរះ។

– ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ ២០១៩ បានដឹកនាំគណៈកម្មការដីរដ្ឋថ្នាក់ស្រុក បានចុះមកពិនិត្យទីតាំងដីស្នើសុំឈូសឆាយពង្រាបលើកព្រំរបស់ឈ្មោះ សាម ប៊ុនឡោម ស្ថិតនៅកន្លែងជ្រុង ក្នុងភូមិព្រែករៃ ឃុំព្រែករៃ នៅសាលាឃុំព្រែករៃ ស្រុកល្វាឯម។

– ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៩ បានចុះត្រួតពិនិត្យទីតាំងដីស្នើសុំសង់បង្គោលអង់តែន ទូរស័ព្ទរបស់ក្រុមហ៊ុនសែលកាត(Cellcard) ដែលស្ថិតក្នុងភូមិពាមតាឯក ឃុំពាមឧកញ៉ាអុង។

– ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ បានរៀបចំធ្វើវេទិកាផ្សព្វផ្សាយ និងពន្យល់ស្តីពីការកាត់ចំណីបឹង, ព្រែក, អូរ និងប្រឡាយ តាមអនុក្រឹត្យលេខ៩៨ និងស្តីពីការរួមគ្នាដើម្បីកំណត់ដីរបស់រដ្ឋនៅបរិវេណវត្តជ្រោយពិសី ស្ថិតនៅភូមិជ្រោយពិសី ឃុំទឹកឃ្លាំង ស្រុកល្វាឯម វត្តមានចូលរួមសរុប១០៨នាក់, ស្រី៧០នាក់។

– ថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៩ បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំពិភាក្សាលើសំណើសុំជួយសម្របសម្រួលការទិញដីប្រជាពលរដ្ឋ ដើម្បីសាងសង់រោងចក្រអគ្គិសនី៤០០MW ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិត ម៉ៅ ភិរុណ** អភិបាល នៃគណៈអភិបាលខេត្តកណ្តាល និង**ឯកឧត្តម ប្រាំង ជលសា** អគ្គនាយករងអគ្គិសនីកម្ពុជា នៅសាលាស្រុកល្វាឯម ខេត្តកណ្តាល វត្តមានចូលរួមសរុបចំនួន១៣៩នាក់។

– ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៩ បានដឹកនាំមន្ត្រីរួមមាន លោក កែវ ស៊ីណន នាយករងរដ្ឋបាលសាលាស្រុក ប្រធានការិយាល័យធនធានទឹកស្រុក, ជលផលស្រុក មន្ត្រីការិយាល័យភូមិបាលស្រុក, អាជ្ញាធរឃុំ-ភូមិ និងកម្លាំងប៉ុស្តិ៍រដ្ឋបាលឃុំពាមឧកញ៉ាអុង និងប៉ុស្តិ៍រដ្ឋបាលឃុំសារិកាកែវ បានចូលរួមជាមួយក្រុមការងារថ្នាក់ខេត្តរួមមាន(មន្ទីរ ដណសកខេត្ត, ធនធានទឹកទឹកខេត្ត និងមន្ទីរជលផលខេត្ត) ដែលក្រោមការដឹកនាំផ្ទាល់របស់ **ឯកឧត្តម នួចម៉េង ច័ន្ទតារា** អភិបាលរងខេត្ត បានចុះបោះបង្គោលកំណត់ទីតាំងដីស្ថិតក្នុងអនុក្រឹត្យលេខ២៥ ក្នុងឃុំសារិកាកែវ ដោយសម្រេចបានត្រឹមតែពីរបង្គោលតែប៉ុណ្ណោះ ព្រោះមានការតវ៉ា និងមិនពេញចិត្តពីប្រជាពលរដ្ឋដែលមានដីស្ថិតក្នុងទីតាំងដីអនុក្រឹត្យនោះ ដែលធ្វើឲ្យក្រុមការងារចុះបោះបង្គោលកំណត់ទី

តាំងដីនោះសម្រេចដកកម្លាំង ដើម្បីពិភាក្សារកពិធីដោះស្រាយ និងចុះបោះបង្គោលទីតាំងដីនោះនៅថ្ងៃស្អែកបន្តទៀត។

– ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៩ បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំផ្សព្វផ្សាយការចុះបញ្ជីក្បាលដីជាប្រព័ន្ធ នៅបរិវេណវត្តសុវណ្ណតេជោ ភូមិតាជោ ឃុំសារិកាកែវ ស្រុកល្វាឯមក្រោមអធិបតីភាព **ឯកឧត្តម គង់ សោភ័ណ្ឌ** អភិបាលរងខេត្តកណ្ដាល

– ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៩ បានអញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សាស្តីពីការអនុវត្តមុខងារគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ក្រោមអធិបតីភាព **ឯកឧត្តម សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន នៅក្រសួងបរិស្ថាន រាជធានីភ្នំពេញ។

– ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៩ បានអញ្ជើញជាអធិបតីភាពក្នុងកិច្ចប្រជុំសម្របសម្រួលពាក្យបណ្ដឹងរបស់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ ពីការវាស់វែង និងចេញប័ណ្ណតាមលក្ខណៈប្លង់គោល នៅវត្តសុវណ្ណសាគរ ឃុំអរិយក្សត្រ វត្តមានចូលរួម២០០នាក់។

– ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៩ បានចូលរួមប្រជុំពិនិត្យ និងកែសម្រួលផែនការហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និង ប្លង់គោលប្រើប្រាស់ដីរវាងមន្ទីរពាក់ព័ន្ធ និងរដ្ឋបាលស្រុកល្វាឯម នៅសាលប្រជុំមន្ទីរ ដ.ន.ស.ភ ខេត្តកណ្ដាល។

– ថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៩ បានចូលរួមប្រជុំត្រួតពិនិត្យ ពិភាក្សាស្តីពីប្លង់គោល និងការងារពន្ធដារខេត្តកណ្ដាលក្រោមអធិបតីយភាព **ឯកឧត្តមបណ្ឌិត ម៉ៅ ភិរុណ** អភិបាល នៃគណៈអភិបាលខេត្តកណ្ដាល នៅសាលប្រជុំសាលាខេត្តកណ្ដាល។

– ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៩ បានអញ្ជើញជាអធិបតីភាពក្នុងវេទិកាពិគ្រោះយោបល់ ស្តីពីការអនុវត្តប្លង់គោល(Master Plan) នៅភូមិខ្សាច់ ឃុំអរិយក្សត្រ ស្រុកល្វាឯម ខេត្តកណ្ដាល សមាជិកចូលរួមសរុបប្រមាណ៣០០នាក់ នៅវត្តខ្សាច់ពោធិ៍អារ្យ ឃុំអរិយក្សត្រ ស្រុកល្វាឯម។

– ថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៩ បានអញ្ជើញជាអធិបតីភាពក្នុងកិច្ចប្រជុំផ្សព្វផ្សាយ លិខិតបទដ្ឋាននានាដែលពាក់ព័ន្ធការងាររ៉ែ និងថាមពល ការងារសាធារណការ និងដឹកជញ្ជូន ដោយមានការចូលរួមពីសំណាក់លោក-លោកស្រីអភិបាលរងស្រុក, នាយក នាយករងរដ្ឋបាលសាលាស្រុក, លោក ហេង សុផល អធិការនគរបាលស្រុកលោក ហាយ សុភាន មេបញ្ជាការកងរាជអាវុធហត្ថស្រុក សរុបវត្តមានចូលរួមចំនួន៤៦នាក់, ស្រី០៥នាក់។

– ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩ បានអញ្ជើញជាអធិបតីភាព ក្នុងវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ស្តីពីការរៀបចំប្លង់ហេដ្ឋារចនាសម្ព័ន្ធ ក្នុងភូមិពោធិ៍ធំ ឃុំអរិយក្សត្រ ព្រមទាំងមានការចូលរួមដោយលោក កន សុខកាយអភិបាលរងស្រុក, សមាជិកក្រុមប្រឹក្សាស្រុក, ប្រធានការិយាល័យភូមិបាលស្រុក, ការិយាល័យអន្តរវិស័យ មន្ត្រីរាជការសាលាស្រុក, មន្ត្រីពាក់ព័ន្ធមកពីមន្ទីរ ដ.ន.ស.ស ខេត្ត, មេឃុំ-ក្រុមប្រឹក្សាឃុំ និងប្រជាពលរដ្ឋក្នុងភូមិពោធិ៍ធំ ឃុំអរិយក្សត្រ សរុបវត្តមានចូលរួមចំនួនប្រមាណ២០០នាក់។

– នៅព្រឹកថ្ងៃចន្ទ ទី១៦ ខែកញ្ញា ឆ្នាំ២០១៩ បានអញ្ជើញចូលរួមចុះត្រួតពិនិត្យមើលគុណភាពសំណង់អគាររដ្ឋបាល និងអគារសាលប្រជុំ តាមលក្ខណៈបច្ចេកទេសនៃការកំណត់របស់ក្រសួង នៅសាលាស្រុកល្វាឯម ដឹកនាំដោយលោក សួន តារា អគ្គនាយករង នៃអគ្គនាយដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ និងមានចូលរួមដោយលោក កន សុខកាយ អភិបាលរងស្រុកលោក ញ៉ឹក សាត នាយករដ្ឋបាលស្រុក, លោក ឡេង វឌ្ឍនា ទី

ប្រឹក្សាបច្ចេកទេស, លោក និន ពិសាល វិស្វករ និងលោក ចាន់ ថារិទ្ធិ តំណាងក្រុមហ៊ុនទទួលការងារសាងសង់ (USS)។

– ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩ បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយខ្លឹមសារអនុក្រឹត្យ ស្តីពីការគ្រប់គ្រងប្រព័ន្ធលូរ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ និងការបណ្តុះបណ្តាលមន្ត្រីការិយាល័យ ច្រកចេញ-ចូលតែមួយក្រុង-ស្រុក ទៅលើមុខងារ ដែលបានប្រតិភូកម្ម ក្រោមអធិបតីភាព **ឯកឧត្តម សួន រចនា** រដ្ឋលេខាធិការ និងជាអនុប្រធានប្រចាំការនៃគណៈកម្មការដឹកនាំកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ នៃក្រសួងសាធារណៈការ និងដឹកជញ្ជូន **ឯកឧត្តម ម៉ុន សុវណ្ណៈ** សមាជិកក្រុមប្រឹក្សាខេត្ត និង**លោកជំទាវ ឯក សុវណ្ណាធិរៈ** អភិបាលរងខេត្តស្វាយរៀង នៅខេត្តស្វាយរៀង។

– ថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៩ បានអញ្ជើញចុះពិនិត្យផ្លូវត្រង់ចំណុចស្ពានតូចក្បែរប៉ុស្តិ៍រដ្ឋបាលឃុំអរិយក្សត្រ ស្ថិតក្នុងភូមិអរិយក្សត្រ ឃុំអរិយក្សត្រ ដែលមានសភាពតូចចង្អៀតដែលមានទទឹងត្រឹមតែ4m និងបណ្តាយ25m មិនសមាមាត្រនឹងផ្លូវទំហំផ្លូវបេតុង ដែលមានទំហំ10m បច្ចុប្បន្ន ពិបាកក្នុងការឆ្លងកាត់ ទៅវិញទៅមក មានការកកស្ទះត្រង់ចំណុចនេះ ។

– ថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ២០១៩ បានចូលរួមត្រួតពិនិត្យការដ្ឋានសាងសង់រោងចក្រអគ្គិសនីដើរដោយប្រេងខ្មៅ និងឧស្ម័នអនុភាព៨០០មេហ្គាវ៉ាត់ ស្ថិតនៅភូមិកោះរះក្រោម ឃុំកោះរះ ក្រោមអធិបតីភាព **ឯកឧត្តម ស៊ុយ សែម** រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល។

– ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៩ បានអញ្ជើញជាអធិបតីភាព បើកសំណើដេញថ្លៃគម្រោងមូលនិធិស្រុក ចំនួន ០២គម្រោង សមាសភាពចូលរួម លោកស្រីប្រធាន និងមន្ត្រីការិយាល័យលទ្ធកម្មសាធារណៈ នៃមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត លោក លោកស្រី គណៈកម្មាធិការលទ្ធកម្ម លោក កែវ ដួនកិរុណ ប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ លោកស្រី ហង្ស ដាឡែន អនុប្រធានអង្គភាពលទ្ធកម្មស្រុក តំណាងក្រុមហ៊ុនទាំង០៦ នៅសាលាស្រុកល្វាឯម។

– ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩ បានដឹកនាំកិច្ចប្រជុំត្រួតពិនិត្យប្លង់ប្រើប្រាស់ដីបច្ចុប្បន្នស្រុក សមាសភាពចូលរួម លោក សេន សុភក្តិ មន្ត្រីមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ ភូមិបាល លោកប្រធានការិយាល័យរៀបចំដែនដីនគរូបនីយកម្ម សំណង់ ភូមិបាល មន្ត្រីអន្តរវិស័យ លោក លោកស្រីមេឃុំទាំង១៥ឃុំ។

– ថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ បានអញ្ជើញចុះពិនិត្យទីតាំងដី ដែលត្រូវសាងសង់ អគារសមាគមន៍កាយរិទ្ធ នារីកម្ពុជា ដែលមានទីតាំងស្ថិតនៅភូមិព្រែកតាប្រាំង ឃុំភូមិធំ សមាសភាពចូលរួម លោក ចេង ឌីណា អភិបាលរងស្រុក លោក លន់ ឌុំ សមាជិកក្រុមប្រឹក្សាស្រុក ប្រធានការិយាល័យអប់រំ យុវជន និងកីឡាស្រុក លោកមេឃុំភូមិធំ។

– ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៩ បានដឹកនាំក្រុមការងារថ្នាក់ស្រុកចុះទៅពិនិត្យ និងសម្របសម្រួល នៅចំណុចក្រោមស្ពានដែលកងវិស្វកម្មកំពុងសាងសង់ ស្ថិតនៅក្នុងភូមិពាមស្តី ឃុំព្រែកឬស្សី ដែលប្រជាជនបានស្នើសុំកាយដីបើកមុខទឹក ដើម្បីបង្ហូរទឹកយកទៅស្រែរបស់គាត់ ។ ដោយមានការចូលរួមពីលោក ញ៉ែម សារ៉ែន ប្រធានការិយាល័យកសិកម្មស្រុក មន្ត្រីការិយាល័យធនធានទឹក និងឧតុនិយម អាជ្ញាធរភូមិ-ឃុំ និងប្រជាពលរដ្ឋដែរ។

**៥.ការងារគ្រប់គ្រងសណ្តាប់ធ្នាប់**

– ថ្ងៃទី០៤ ខែមិនា ឆ្នាំ២០១៩ បានសហការណ៍ជាមួយសមាជិកស.ស.យ.ក ស្រុក ចូលរួមក្នុងសកម្មភាពផ្សព្វផ្សាយអំពីច្បាប់ចរាចរណ៍ផ្លូវគោក និងអំពីបញ្ហាគ្រឿងញៀននៅក្នុងមូលដ្ឋាន ដល់សិស្សានុសិស្សដែលកំពុងសិក្សាចំនួនពីរវិទ្យាល័យ(វិទ្យាល័យហ៊ុន សែន ពាមឧកញ៉ាអុងនិងវិទ្យាល័យ ហ៊ុន សែន ទឹកឃ្លាំង) និងបានធ្វើពិធីចែកមួកសុវត្ថិភាពដល់សិស្សានុសិស្សក្នុងមួយវិទ្យាល័យចំនួន១០០មួក សរុបពីរវិទ្យាល័យ២០០មួក និងបារស់ចំនួនពីរជូនដល់វិទ្យាល័យទាំងពីរ។

– ថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៩ បានរៀបចំកិច្ចប្រជុំបែកចែកសមាសភាព និងត្រៀមរៀបចំពិធីបុណ្យសង្ក្រាន្ត ដើម្បីអបអរសាទរពិធីបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរ ក្រោមអធិបតីភាពលោក គឹម គីរ៉ា អភិបាល នៃគណៈអភិបាលស្រុកល្វាឯម នៅសាលប្រជុំសាលាស្រុកល្វាឯម វត្តមានចូលរួម៤២នាក់,ស្រី០៨នាក់។

– ថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៩ បានដឹកនាំកម្លាំងចំរុះ ចុះត្រួតពិនិត្យទីតាំងកោះស្នេហ៍សម្រាប់រៀបចំសណ្តាប់ធ្នាប់ សុខសុវត្ថិភាពជូនដល់បងប្អូនដែលមកកំសាន្តក្នុងថ្ងៃចូលឆ្នាំថ្មី ស្ថិតនៅភូមិជ្រោយពិសី ឃុំទឹកឃ្លាំង។

– ថ្ងៃទី០៤ខែមេសាឆ្នាំ២០១៩ បានអញ្ជើញចូលរួមសន្និបាតបូកសរុបលទ្ធផលការងារ ភូមិ-ឃុំមានសុវត្ថិភាពក្នុងខេត្តកណ្តាល ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិត ម៉ៅ ភិរុណ អភិបាល នៃគណៈអភិបាលខេត្តកណ្តាល។

– ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៩ តំណាងលោក គឹម គីរ៉ា អភិបាល នៃគណៈអភិបាលស្រុក និងជាប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលស្រុកល្វាឯម បានអញ្ជើញដឹកនាំកិច្ចប្រជុំបែងចែកផែនការ និងត្រៀមរៀបចំកម្លាំងដើម្បីការពាររៀបចំសណ្តាប់ធ្លាប់សុខសុវត្ថិភាពជូនប្រពលរដ្ឋក្នុងការលេងកំសាន្ត នាឱកាសថ្ងៃបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរនាថ្ងៃទី១៤-១៥-១៦ ខែមេសា ឆ្នាំ២០១៩។

– ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៩ បានដឹកនាំក្រុមការងារចុះផ្សព្វផ្សាយអំពីបញ្ហាគ្រឿងញៀន (ផលប៉ះពាល់ និងគុណវិបត្តិ)ដល់ប្អូនៗសិស្សានុសិស្ស និងសំណេះសំណាលជាមួយលោកគ្រូ អ្នកគ្រូនៅវិទ្យាល័យហ៊ុន សែន ល្វាសរ ឃុំល្វាសរ ស្រុកល្វាឯម ខេត្តកណ្តាលដោយអញ្ជើញចូលរួមលោកវរៈសេនិយ៍ទោពិន ច័ន្ទតារា មេបញ្ជាការរងកងរាជអាវុធហត្ថខេត្តកណ្តាល។

– ថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៩ បានអញ្ជើញចូលរួមពិធីបញ្ចុះបឋមសិលាបើកការដ្ឋានសាងសង់មជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនខេត្តកណ្តាល ក្រោមអធិបតីភាព**ឯកឧត្តមបណ្ឌិត ម៉ៅ ភិរុណ** អភិបាល នៃគណៈអភិបាលខេត្តកណ្តាល នៅស្រុកស្អាង ខេត្តកណ្តាល។

– ថ្ងៃពុធ ទី០៤ ខែកញ្ញា ឆ្នាំ២០១៩ បានចូលរួមពិធីសម្ពោធដាក់អោយប្រើប្រាស់មជ្ឈមណ្ឌលថែទាំ និងស្តារនីតិសម្បទាជនវិបល្លាសស្មារតី ក្រោមអធិបតីភាព **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តំណាងដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល។

– ថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៩ បានការពារពិធីហូបអំបុកខ្មែរដើម្បីការពារជាតិ សាសនា និងព្រះមហាក្សត្រ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមអគ្គបណ្ឌិត សភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមការងារថ្នាក់ជាតិចុះជួយខេត្តកណ្តាល និងបានការអញ្ជើញ

ចូលរួមជាគណៈអធិបតី **ឯកឧត្តម គង់ ទិបុល** ប្រតិភូរាជរដ្ឋាភិបាល អនុប្រធានក្រុមការងារជាតិចុះជួយស្រុកល្វាឯម។ បញ្ជាក់ៈ នៅក្នុងពិធីនោះក៏មានការអុំទូកថ្នាក់ស្រុកផងដែរ នៅមាត់ទន្លេ ឃុំពាមឧកញ៉ាអុង សរុបវត្តមានចូលរួមប្រមាណ៣៨០០នាក់។

– ថ្ងៃទី១០.១១.១២ ខែតុលា ឆ្នាំ២០១៩ បានការពារព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប អកអំបុក និងសំពះព្រះខែ នៅចំណុចកំពុងដរអរិយក្សត្រ ឃុំអរិយក្សត្រ និងការពារក្រុមទូកង ទៅចូលរួមប្រណាំងនៅរាជធានីភ្នំពេញ ។

– នៅរសៀលថ្ងៃព្រហស្បតិ៍ ទី១២ ខែធ្នូ ឆ្នាំ ២០១៩ បានចុះធ្វើបច្ចុប្បន្នភាពជនជាតិតាមខ្នងផ្ទះ)ជនជាតិវៀតណាម (ស្ថិតនៅភូមិអរិយក្សត្រ ឃុំអរិយក្សត្រ ស្រុកល្វាឯម ខេត្តកណ្តាល ដោយបានការដឹកនាំដោយលោក កន សុខកាយ អភិបាលរងស្រុក ព្រមទាំងមានការចូលរួមដោយលោក កែវ ស៊ីណន នាយករងរដ្ឋបាលសាលាស្រុក និងលោក ឡូ សុផាន់ណារិទ្ធ អធិការរងទទួលបន្ទុកជនអន្តោប្រវេសន៍ នៃអធិការដ្ឋាននគរបាលស្រុក សមាសភាពចូលរួមៈលោក ប៉ែន ផល្លុន ជំទប់ទី១ក្រុមប្រឹក្សាឃុំអរិយក្សត្រ ,លោក ខ្លូត សំអឿន មេភូមិអរិក្សត្រ, កម្លាំងផ្នែកជំនាញស្រុកនិងកម្លាំងប៉ុស្តិ៍រដ្ឋបាលឃុំអរិក្សត្រ សរុបវត្តមានចំនួន១២នាក់។

តារាងទី៥៖ កិច្ចប្រជុំគណៈអភិបាល

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | កិច្ចប្រជុំអឌ្ឍមាសរបស់គណៈអភិបាល | ០ |
| ២ | កិច្ចប្រជុំប្រចាំខែ(អឌ្ឍមាសទី២)របស់គណៈអភិបាល | ១២ |

១.១.៦. ការងារក្រុមប្រឹក្សា និងគណៈកម្មាធិការនានា

១).<u>សកម្មភាពលោកប្រធានក្រុមប្រឹក្សាៈ</u>

ក).កិច្ចប្រជុំក្រុមប្រឹក្សាៈ

-លោកប្រធានក្រុមប្រឹក្សាស្រុក បានអញ្ជើញជាអធិបតីភាពនៃកិច្ចប្រជុំសាមញ្ញក្រុមប្រឹក្សាស្រុកល្វាឯម ចំនួន ១១ លើក សមាសភាពចូលរួម ៧០៤ នាក់ ។

-លោកប្រធានក្រុមប្រឹក្សាស្រុក បានអញ្ជើញជាអធិបតីភាពនៃកិច្ចប្រជុំវិសាមញ្ញក្រុមប្រឹក្សាស្រុកល្វាឯមចំនួន ០៤លើក។

-លោកប្រធានក្រុមប្រឹក្សាស្រុក បានអញ្ជើញចូលរួមក្នុងពិធីគោរពទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជា នៃយើងបានចំនួន ៣៨លើក។

-លោកប្រធានក្រុមប្រឹក្សាស្រុក និងលោក-លោកស្រីសមាជិកសមាជិកា ក្រុមប្រឹក្សាស្រុកបានអញ្ជើញចូលរួមក្នុងវេទិកាផ្សព្វផ្សាយថ្នាក់ជាតិនៅបណ្តាឃុំទាំង១៥ ក្នុងស្រុកល្វាឯម។

-លោកប្រធានក្រុមប្រឹក្សាស្រុក បានអញ្ជើញចូលរួមក្នុងវគ្គផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តិស្តីពី គោលការណ៍បែបបទ និងនិតិវិធីគ្រប់គ្រងមន្ត្រីរាជការស៊ីវិល ក្រោមអធិបតីភាព **ឯកឧត្តម ស សាមឌី** អនុរដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ និង**ឯកឧត្តម នួន ម៉េងច័ន្ទតារា** អភិបាលរងខេត្តកណ្តាល។

-លោកប្រធានក្រុមប្រឹក្សាស្រុក និងសាមជិកក្រុមប្រឹក្សាស្រុក០៦រូប ព្រមទាំងអាជ្ញាធរឃុំ-ភូមិ នៃឃុំល្វាសរ បានអញ្ជើញចុះពិនិត្យផ្លូវខាងក្រោយភូមិ និងបន្តដំណើរទៅភូមិព្រែកប្រា នឹងភូមិនានាក្នុងឃុំព្រែកឬស្សី ដើម្បីពិនិត្យអំពីស្ថានភាពប្រជាជន។

-លោកប្រធានក្រុមប្រឹក្សាស្រុក ព្រមទាំងសមាជិកក្រុមប្រឹក្សាស្រុកចំនួន១៩នាក់ បានអញ្ជើញចូលរួមវគ្គក្នុងផ្សព្វផ្សាយស្តីពីគោលនយោបាយនៃការអនុវត្តបេឡាជាតិ របបសន្តិសុខសង្គម(បសស) នៅសាលាស្រុកល្វាឯម។

-លោកប្រធានក្រុមប្រឹក្សាស្រុក បានអញ្ជើញចូលរួមក្នុងវគ្គផ្សព្វផ្សាយគម្រោងលើកកម្ពស់សមត្ថភាពស្ថាប័ន និងការប្រតិបត្តិរបស់សមាគមក្រុមប្រឹក្សាក្រុង/ស្រុក-ខណ្ឌ ឃុំ-សង្កាត់ នៅសាលាខេត្ត កណ្ដាល រយៈពេល ១ថ្ងៃពេញ។

-លោកប្រធានក្រុមប្រឹក្សាស្រុក និងសមាជិកក្រុមប្រឹក្សាស្រុក១រូប អញ្ជើញចូលរួមក្នុងពិធីសំណេះ សំណាលជាមួយប្អូនៗសិស្សានុសិស្សប្រឡងជាប់សញ្ញាប័ត្រមធ្យមសិក្សាប័ត្រទុតិយភូមិ នៅវិទ្យាល័យ **ហ៊ុន សែន** ពាមឧកញ៉ាអុង ឃុំពាមឧកញ៉ាអុង ក្រោមអធិបតីភាព **ឯកឧត្តម ជាប ជាឧុធ** ទទួលបន្ទុកយុវជន តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមអគ្គបណ្ឌិត សភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមការងារថ្នាក់ជាតិជួយខេត្តកណ្ដាល។

-លោកប្រធានក្រុមប្រឹក្សាស្រុក បានអញ្ជើញចូលរួមវគ្គបណ្ដុះបណ្ដាលផ្សេងៗថ្នាក់ខេត្ត និងស្រុកចំនួន ៥លើក។

-លោកប្រធានក្រុមប្រឹក្សាស្រុក បានអញ្ជើញជាគណអធិបតីក្នុងពិធីវេទិកាផ្សព្វផ្សាយថ្នាក់ជាតិចុះជួយមូលដ្ឋានចំនួន ១៣លើក។

-លោកប្រធានក្រុមប្រឹក្សាស្រុក និងសមាជិកក្រុមប្រឹក្សាស្រុកចំនួន៥រូបអញ្ជើញចូលរួមមហាសន្និបាតអាណត្តិទី៣របស់សមាគមក្រុមប្រឹក្សាក្រុង/ស្រុក-ខណ្ឌ ឃុំ-សង្កាត់ ១លើក ដែលរយៈពេល២ថ្ងៃ នៅសាលប្រជុំ សាលាខេត្តកណ្ដាល។

-លោកប្រធានក្រុមប្រឹក្សាស្រុក និងសមាជិកក្រុមប្រឹក្សាស្រុកល្វាឯមចំនួន១៩រូប បានអញ្ជើញចូលរួមពិធីគោរព **ព្រះវិញ្ញាណក្ខ័ន្ធ ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ ព្រះបរមរតនកោដ្ឋ** គម្រប់ខួប៧ ឆ្នាំ។

-លោកប្រធានក្រុមប្រឹក្សាស្រុក និងលោកស្រីសមាជិកក្រុមប្រឹក្សាស្រុក ព្រមទាំងមានការចូលរួមដោយលោក-លោកស្រីអភិបាលរងស្រុក និងមន្ត្រីរាជការក្នុងស្រុកល្វាឯម បានអញ្ជើញចូលរួមគោរពវិញ្ញាណក្ខ័ន្ធ ឧបាសិកា គ្រុយ ឃីម ដែលត្រូវជាបង្កើតលោក គឹម គីរ៉ា អភិបាលស្រុកល្វាឯមនៅគេហដ្ឋាននៃសពនៅរាជធានីភ្នំពេញ។

-លោកប្រធានក្រុមប្រឹក្សាស្រុក លោក-លោកស្រីសមាជិកក្រុមប្រឹក្សា, លោក-លោកស្រីអភិបាលរងស្រុក មេបញ្ជាការកងកម្លាំងទាំងបី, លោក លោកស្រីមេឃុំទាំង១៥ទូទាំងស្រុក បានអញ្ជើញចូលរួមកិច្ចប្រជុំផ្សព្វផ្សាយអំពីសភាពការណ៍ថ្មីៗនៅកម្ពុជា ក្រោមអធិបតីភាព **ឯកឧត្តម នួន ផា** ប្រធានក្រុមប្រឹក្សាខេត្ត និង **ឯកឧត្តមបណ្ឌិត ម៉ៅ ភិរុណ** អភិបាល នៃគណអភិបាលខេត្តកណ្ដាល ។

-លោកប្រធានក្រុមប្រឹក្សាស្រុក បានអញ្ជើញជាអធិបតីភាពក្នុងការពិធីផ្សព្វផ្សាយសភាពការណ៍ថ្មីៗនៅកម្ពុជា ដើម្បីការពារសកម្មភាពផ្សេងៗរបស់ក្រុមប្រឆាំង និងផែនការសន្តិសុខសុវត្ថិភាពសាធារណៈក្នុងឱកាសបុណ្យអុំទូក អកអំបុកសំពះព្រះខែក្នុងមូលដ្ឋាន នឹង ថ្នាក់ជាតិជូនដល់ក្រុមប្រឹក្សាសឃុំពាមឧកញ៉ាអុង វគ្គមានចូលរួមចំនួន ៣៤នាក់។

-លោកប្រធានក្រុមប្រឹក្សាស្រុក រួមជាមួយលោក គឹម គីរ៉ា អភិបាល នៃគណៈអភិបាលស្រុក បាន អញ្ជើញជាអធិបតីភាពក្នុងពិធីបើកបវេសនកាលឆ្នាំសិក្សា២០១៩-២០២០ នៅវិទ្យាល័យ **ហ៊ុន សែន ពាម ឧកញ៉ាអុង** ពាមឧកញ៉ាអុង ដែលបានការចូលរួមដោយលោក លោកស្រីសមាជិកក្រុមប្រឹក្សាស្រុក មន្ត្រីរាជការ ប្រធាន និងអនុប្រធានការិយាល័យអប់រំស្រុកលោកលោកស្រីសមាជិកក្រុមប្រឹក្សាឃុំពាមឧកញ៉ាអុង លោកគ្រូ-អ្នកគ្រូកំពុងបង្រៀន និងចូលនិវត្ត និងប្អូនៗសិស្សានុសិស្សវត្តមានចូលរួមសរុប ១,៦០០នាក់។

-លោកប្រធានក្រុមប្រឹក្សាស្រុក និងលោក លោកស្រីសមាជិកក្រុមប្រឹក្សាស្រុក ព្រមទាំងលោក លោកស្រីអភិបាល អភិបាលរងស្រុក បានអញ្ជើញចូលរួមក្នុងពិធីខួបអនុស្សាវរីយ៍ទី៦៦ នៃថ្ងៃបុណ្យឯករាជ្យជាតិ និងពិធីហូបអំបុកខ្មែរការពារ "ជាតិ សាសនា ព្រះមហាក្សត្រ" របស់ស្រុកល្វាឯម ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមអគ្គបណ្ឌិត សភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានក្រុមការងារថ្នាក់ជាតិចុះជួយខេត្តកណ្តាល មានការអញ្ជើញចូលរួមជាគណៈអធិបតីពីសំណាក់**ឯកឧត្តម គង់ វិមុល** អនុប្រធានក្រុមការងារថ្នាក់កណ្តាលជួយស្រុកល្វាឯម និងឯកឧត្តម លោកជំទាវ លោក លោកស្រីក្រុមការងារចុះជួយឃុំទាំង១៥ទូទាំងស្រុក រួមទាំងប្រជាពលរដ្ឋក្នុងស្រុកល្វាឯម សរុបប្រមាណ៤,០០០នាក់។

-លោកប្រធានក្រុមប្រឹក្សាស្រុក និងសមាជិកក្រុមប្រឹក្សាស្រុក៣រូប បានអញ្ជើញចូលរួមក្នុងពិធីប្រណាំងទូកនៅក្រុងតាខ្មៅ នឹងពិធីបុណ្យអុំទូក អកអំបុក បណ្តែតប្រទីប សំពះព្រះខែ នៅរាជធានីភ្នំពេញ

-លោកប្រធានក្រុមប្រឹក្សាស្រុក និងសមាជិកក្រុមប្រឹក្សាស្រុក ពីររូបអញ្ជើញជួបសំណេះសំណាលជាមួយកីឡាករទូកងនៅរាជធានីភ្នំពេញ។

-លោកប្រធានក្រុមប្រឹក្សាស្រុក រួមជាមួយលោក គឹម គីរ៉ា អភិបាល នៃគណៈអភិបាលស្រុកព្រមទាំងលោក លោកស្រីសមាជិកក្រុមប្រឹក្សាស្រុក អភិបាលរងស្រុក មន្ត្រីរាជការជុំវិញស្រុក បានអញ្ជើញចូលរួមក្នុងពិធីក្រុងពីលីល្ខោនខោល ដើម្បីអបអរសាទរខួបនៃការដាក់បញ្ចូលជាសម្បត្តិបេតិកភណ្ឌអរូបីយ៍នៃមនុស្សជាតិនៅវត្តស្វាយអណ្តែត ឃុំសារិកាកែវ ក្រោមអធិបតីភាព **ឯកឧត្តម គឹម ពេជ្រពិនន់** អនុរដ្ឋលេខាធិការ ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ និង**ឯកឧត្តម ម៉ៅ កេង** ទីប្រឹក្សាក្រសួងវប្បធម៌ និងវិចិត្រសិល្បៈផងដែរ។

-លោកប្រធានក្រុមប្រឹក្សាស្រុក និងសមាជិកក្រុមប្រឹក្សាស្រុក២រូប រួមដំណើរជាមួយលោក កន សុខកាយ និងលោក ចេង ឌីណា អភិបាលរងស្រុក មេបញ្ជាការកងកម្លាំងទាំង៣ អាជ្ញាធរឃុំ ភូមិ អញ្ជើញអមដំណើរ**ឯកឧត្តម ស៊ុយ សែម** រដ្ឋមន្ត្រីក្រសួង រ៉ែ និងថាមពលចុះពិនិត្យការដ្ឋានសាងសង់រោងចក្រអគ្គីសនីដើរដោយប្រេងខ្មៅនិងឧស្ម័នអនុភាព៨០០/MKW ស្ថិតនៅភូមិកោះរះឃុំកោះរះស្រុកល្វាឯម ខេត្តកណ្តាល។

-លោកប្រធានក្រុមប្រឹក្សាស្រុក និងលោក លោកស្រីសមាជិកក្រុមប្រឹក្សាស្រុក ព្រមទាំងលោក-លោកស្រីអភិបាល អភិបាលរងស្រុក បានអញ្ជើញចូលរួមក្នុងពិធីមិទ្ទីញអបអរសាទរឃួបអនុស្សាវរីយ៍លើកទី៤១ ថ្ងៃបង្កើតរណសិរ្ស សាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជា(០២.១២.១៩៧៨-០២.១២.២០១៩) ក្រោមអធិបតីភាព **ឯកឧត្តម កែន សម្បត្តិ** អនុប្រធានទី៣ក្រុមការងារថ្នាក់កណ្តាលចុះជួយស្រុកល្វាឯម តំណាងដ៏ខ្ពង់ខ្ពស់**ឯកឧត្តម គង់ វិមុល** អនុប្រធានទី១ក្រុមការងារថ្នាក់កណ្តាលចុះជួយស្រុកល្វាឯម។

ខ).<u>សកម្មភាពសមាជិកក្រុមប្រឹក្សាស្រុកៈ</u>

-សមាជិកក្រុមប្រឹក្សាស្រុករួមមាន៖ លោក ឡុង កន, លោក លី ហុង, លោកស្រី អាន សារ៉ែន លោក នូ សាឃឿន, លោក ទូច ខេង, លោក ឆាយ លាងឈាង, លោក លន់ ឌុំ, លោក ហ៊ុន ស៊ិន, លោកស្រីគង់ សារី,

លោក ញ៉ែម អ៊ន់, លោកស្រី ពុទ្ធ សុខានី, លោក បេ សារ៉ុម, លោកស្រី ផែង យ៉ាន, លោក ឈា តុងលាង, លោកស្រី សុខ ស៊ីនឿន, លោក ណាង តា៉ និងលោក ប៊ិន រដ្ឋា បានចូលរួមកិច្ចប្រជុំប្រចាំខែ របស់ក្រុមប្រឹក្សាឃុំទាំង១៥ ចំនួន១៥៦ដង ក្នុងទូទាំងស្រុកល្វាឯម។

-លោក ញ៉ែម អ៊ន់ សមាជិកក្រុមប្រឹក្សាស្រុក និងជាអនុប្រធានក្រុមការងារលេខាធិការដ្ឋានចុះឃុំសំបួរ បានរួមដំណើរជាមួយលោក ជុំ រតនៈប្រធានការិយាល័យធម្មការស្រុកអញ្ជើញប្រកាសចៅអធិការវត្តស្តីទី នៅវត្តបន្ទាយម្លូ ស្ថិតនៅឃុំសំបួរ ស្រុកល្វាឯម ក្រោមព្រះវត្តមានព្រះសុធម្មនី ភោគ រស់ ព្រអនុគណស្រុក នឹងព្រះតេជគុណព្រះមន្រ្តីសង្ឃស្រុកចំនួន ៤អង្គ និងមានពុទ្ធបរិស័ទ្ធតាជីយាយជីប្រមាណ ៦៥នាក់, ស្រី ៤៥នាក់។

គ).<u>សកម្មភាពគ.ក.ស.កស្រុក:</u>

-ចូលរួមកិច្ចប្រជុំគណៈអភិបាលនៅសាលាស្រុកល្វាឯមចំនួន ៥ លើក

-លោកស្រីពុទ្ធ សុខានី ប្រធាន និងអនុប្រធាន និងសមាជិក គ.ក.ស.កស្រុក ចូលរួមកិច្ចប្រជុំបូកសរុប និងវាយតម្លៃលទ្ធផលការងារឆមាសទី១ និងលើកទីសដៅអនុវត្តក្នុងឆមាសទី២ ឆ្នាំ២០១៩ របស់ការងារគ.ក.ស.ក ខេត្តកណ្តាល។

-លោកស្រីប្រធាន គ.ក.ស.ក ស្រុក បានរួមដំណើរជាមួយលោកស្រី វ៉ែន កន្និកា អភិបាលរងស្រុកនិងស្រីសមាជិក បានចូលចូលរួមកិច្ចប្រជុំគ.ក.ន.ក នៅឃុំបារ៉ុងក្រោមអធិបតីភាពលោកជំទាវ នួន នារតី សមាជីកករូមប្រឹក្សាខេត្ត និង ជាប្រធាន គ.ក.ស.ក ខេត្ត។

-លោកស្រីប្រធាន បានចូលរួមកិច្ចប្រជុំ គ.ក.ន.ក ឃុំនានាទូទាំងស្រុក បានចំនួន ១៤លើក។

-លោកស្រីប្រធាន បានចូលរួមវគ្គបណ្តុះបណ្តាលរំលឹកឡើងវិញស្តីពីរបៀបកត់ត្រាអាត្រានុកូលដ្ឋាន និងសៀវភៅស្រង់ស្ថិតិកំណើត, អាពាហ៏ពិពាហ៏, មរណៈភាព និងលិខិតបទដ្ឋានគតិយុត្តិថ្មីៗ នៅសាលាខេត្តកណ្តាល ។

-គ.ក.ស.ក ស្រុក បានចុះតាមដាន និង ពិនិត្យសកម្មភាព របស់គ.ក.ន.ក ឃុំបានចំនួន ១៣ឃុំ និងត្រៀមចុះជាបន្តបន្ទាប់ទៀត។ ឃុំដែលមិនទាន់បានទទួលបានការគាំទ្ររួមមាន៖ ឃុំបារ៉ុង ពាមឧកញ៉ាអុង, បឹងគ្រំ, ល្វាសរ, ព្រែករ៉ៃ និងឃុំភូមិធំ។ ចំពោះឃុំដែលមានបញ្ហាប្រឈមមានឃុំកោះរះ ជួបបញ្ហាទឹកលិចដក់ក្នុងភូមិ នឹងសាលាបឋមសិក្សាភូមិក្រោម និង១ខ្នងមានការប្រេះស្រាំសសរ និងជញ្ជាំង។

-ឃុំព្រែកឬស្សី មត្តេយ្យសហគមន៍ភូមិព្រែកជ្រៃ រៀននៅក្រោមសាលាដែលសិស្សានុសិស្សចំនួន៤០នាក់ខ្វះតុសម្រាប់សិស្សអង្គុយរៀន ចំពោះថ្នាករៀនមិនស្របតាមនិយាមគរុកោសល្យ ដោយបាំងនូវកៅស៊ូតង់ចាស់ៗ។

-ឃុំសារិកាកែវ មានទឹកដក់នៅទីធ្លាសាលាបឋម និងអនុវិទ្យល័យ។

-ឃុំអរិយក្សត្រ មានបញ្ហាវាងឃុំ និងគ្រូមេត្តេយ្យសហគមន៍(ឃុំចង់រើសថ្មី មិនចង់យកគ្រូចាស់)

-លោកស្រីប្រធាន គ.ក.ស.កស្រុក បានចូលរួមក្នុងកិច្ចប្រជុំសាមញ្ញលើកទី៣ អាណត្តិទី៣របស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារស្រុក ដោយមានការចូលរួមពីលោក លោកស្រីសមាជិកគណៈកម្មាធិការពិគ្រោះយោបល់ស្ត្រី និងកុមារស្រុក វត្តមានចូលរួមចំនួន ២៧នាក់, ស្រី២៣នាក់។

-លោកស្រីប្រធាន គ.ក.ស.ក.ស្រុក និងអនុប្រធានចំនួន២រូប បានចុះត្រួតពិនិត្យទីតាំងមេត្តេយ្យ សហគមន៍ ឃុំអរិយក្សត្រ ដែលបានផ្អាកអស់រយៈពេល១ឆ្នាំកន្លងមក ឲ្យដំណើរការឡើងវិញ ក្នុងឆ្នាំសិក្សា ២០១៩-២០២០ នេះ។

-លោកស្រីប្រធាន គ.ក.ស.ក ស្រុកបានរួមដំណើរជាមួយ**លោកជំទាវ នួន នារតី** សមាជិកក្រុមប្រឹក្សាខេត្ត និងជាប្រធានគ.ក.ស.កខេត្ត ដឹកនាំសហការី អញ្ជើញចុះជួយគាំទ្រ និងពិនិត្យកិច្ចប្រជុំប្រចាំខែរបស់គ.ក.ន.ក នៅឃុំសារិកាកែវ និងពិនិត្យមើលដំណើរការមត្តេយ្យសិក្សាសហគមន៍ចំនួន៥ កន្លែងនៅឃុំសំបួរ ដោយមានការចូលរួមពីលោកស្រីអភិបាលរងស្រុក និងលោកស្រីជាសមាជិកគ.ក.ស.ក ស្រុក។ កិច្ចប្រជុំបានដំណើរការតាមគម្រោងដែលបានគ្រោងទុកសរុបវត្តមានចូលរួមមានចំនួន ២៦នាក់, ស្រី០៨នាក់។ ក្នុងនោះលោកជំទាវបានផ្តល់អនុសាសន៍ និងជម្រុញឲ្យរៀបចំគណៈកម្មាធិការគ្រប់គ្រងមត្តេយ្យសហគមន៍ និងផ្តល់ជាការគាំទ្រទាំងសម្ភារៈ និងប្រាក់ឧបត្ថម្ភដល់គ្រូឲ្យបានសមរម្យ ជាងឆ្នាំកន្លងមក។

-លោកស្រីប្រធាន គ.ក.ស.ក ស្រុក បានរួមដំណើរជាមួយលោកស្រី រ៉ែន កន្និកា អភិបាលរងស្រុកនិងជាអនុប្រធានកាកបាទក្រហមស្រុក តំណាងលោក ភឹម ភីរ៉ា អភិបាលស្រុក បាននាំយកអំណោយរបស់អនុសាខាកាកបាទក្រហមស្រុកទៅចែកជូនគ្រួសារក្រីក្រ ចំនួន២គ្រួសារ នៅឃុំល្វាស។ គ្រួសារទី១ ឈ្មោះ ផាន់ ស៊ីណន ភេទស្រី អាយុ៦០ឆ្នាំ, គ្រួសារទី២ ឈ្មោះ ហៀង លាប ភេទស្រី អាយុ៨២ឆ្នាំ។ ក្នុងគ្រួសារមួយគ្រួសារទទួលបានអង្ករ ២៥Kg, សម្ភារៈផ្ទះបាយ១ឈុត, ទឹកត្រី១យួរ, ទឹកស៊ីអ៊ីវ១យួរ, ត្រីខ១យួរ, មុង១ ភួយ១ រួមទាំងថវិកា៥០,០០០៛

**ឃ.គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស**

-ថ្ងៃទី ២០ ខែ មិនា ឆ្នាំ ២០១៩រៀបចំសេចក្តីព្រាង ដីកាស្តីពីការផ្តល់សេវារបស់រដ្ឋបាលស្រុកល្វាឯមក្រោមអធិបតីភាព លោក ភឹម ភីរ៉ា អភិបាលស្រុក ដែលមានសមាសភាពចូលរួម ការិយាល័យ អង្គភាពជំនាញជុំវិញរដ្ឋបាលស្រុក មន្ត្រីបុគ្គលិករដ្ឋបាលស្រុក និង គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា ប្រជាពលរដ្ឋ អង្គការសង្គមស៊ីវិល និងផ្នែកឯកជន សរុបអ្នកចូលរួម ៥៦ នាក់ ស្រី ១៨នាក់

-ថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩ ប្រជុំពិនិត្យ និងផ្តល់យោបល់របស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសលើសេចក្តីព្រាងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលរបស់ស្រុក

**ង.គណៈកម្មាធិការលទ្ធកម្មស្រុក ៖**

បានអនុវត្តកិច្ចលទ្ធកម្មចំនួន ០៥គម្រោង រួមមានលទ្ធកម្មសំណង់ចំនួន ០៣គម្រោងង និងលទ្ធកម្មទំនិញចំនួន ០២គម្រោង ដែលចំណាយអស់ទឹកប្រាក់សរុបចំនួន ៤២០,៩៦៣,១០០រៀល (បួនរយម្ភៃប្រាំបួនរយហុកសិបបីពាន់មួយរយរៀលគត់) ដែលក្នុងនោះមានដូចខាងក្រោម៖

១.លទ្ធកម្មសំណង់ចំនួន០៣គម្រោង ទឹកប្រាស់ចំនួន ៣៩៤,៣៤១,៧០០រៀល

២.លទ្ធកម្មទំនិញចំនួន០២គម្រោង ទឹកប្រាក់ចំនួន២៦,៦២១,៤០០រៀល

តារាងទី៦៖ កិច្ចប្រជុំក្រុមប្រឹក្សា និងគណៈកម្មាធិការនានា

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សា | ១១ |
| ២ | កិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សា | ១ |
| ៣ | កិច្ចប្រជុំសម្ងាត់របស់ក្រុមប្រឹក្សា | ១ |
| ៤ | កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស | ២ |
| ៥ | កិច្ចប្រជុំគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ | ៩ |

តារាងទី៧៖ ការរៀបចំវេទិកា

| ល.រ. | ឈ្មោះវេទិកា | អ្នកចូលរួម | |
|---|---|---|---|
| | | សរុប | ស្រី |
| ១ | - វេទិកាពិគ្រោះយោបល់ការអនុវត្តប្លង់គោលMaster Planភូមិខ្សាច់ ឃុំអរិយក្សត្រ | ៣០០ | ២១៧ |
| ២ | - វេទិកា និងពិគ្រោះយោបល់ស្តីពីការរៀបចំប្លង់ហេដ្ឋារចនាសម្ព័ន្ធ ភូមិពោធិ៍ធំ ឃុំអរិយក្សត្រ | ២០០ | ១១៥ |
| ៣ | បានរៀបចំវេទិកាសាធារណៈតាមបណ្តាលឃុំទាំង ១៥ ក្នុងស្រុក | ៥៣៩៤ | ៣០៥៣ |

## ១.២. ការងារផែនការនិងការគាំទ្រឃុំសង្កាត់

### ១.២.១. ការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគក្រុង-ស្រុក

- ក្រុមការងារកសាងផែនការស្រុក កំពុងរៀបចំជំពូកទី១(ស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច)ផែនការអភិវឌ្ឍន៍ ៥ឆ្នាំ(២០២០-២០២៤)របស់ស្រុក។

តារាងទី៨៖ គម្រោងវិនិយោគបីឆ្នាំរំកិលក្រុង-ស្រុក ២០១៩

| ល.រ | ផ្នែក | ចំនួនគម្រោង | តម្លៃគម្រោង(លានរៀល) |
|---|---|---|---|
| ១ | សេដ្ឋកិច្ច | 5 | 819.128.980៛ |
| ២ | សង្គមកិច្ច | 1 | 2.100.000៛ |
| ៣ | គ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុនិងគ្រោះមហន្តរាយ | 0 | 0 |
| ៤ | រដ្ឋបាល សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ | 2 | 31.290.000៛ |
| សរុប | | 8 | 852.518.980៛ |

### ១.២.២. ការអនុវត្តគម្រោងវិនិយោគក្រុង-ស្រុក

- កំពុងអនុវត្តការងារជួសជុលផ្លូវបេតុងអាមេ នៅឃុំពាមឧកញ៉ាអុង និងឃុំអរិយក្សត្រ ដែលប្រើប្រាស់មូលនិធិស្រុក ឆ្នាំ២០១៩។

តារាងទី៩៖ ការអនុវត្តគម្រោងវិនិយោគក្រុង-ស្រុក
(ព័ត៌មានបន្ថែមមាននៅក្នុងឧបសម្ព័ន្ធទី១)

| ល. | ផ្នែក | សរុប | ស្ថានភាពនៃការអនុវត្ត | | |
|---|---|---|---|---|---|
| | | | មិនទាន់ | កំពុង | បញ្ចប់ |
| ១ | សេដ្ឋកិច្ច | 5 | 1 | 4 | |
| ២ | សង្គមកិច្ច | 1 | | | √ |
| ៣ | គ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុនិងគ្រោះមហន្តរាយ | 0 | | | |
| ៤ | រដ្ឋបាល សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ | 2 | | | √ |
| | សរុប | 8 | 1 | 4 | |

### ១.២.៣. ការអនុវត្តផែនការសកម្មភាព និងថវិកា ផ.អ.៣

**តារាងទី១០៖ ការអនុវត្តផែនការសកម្មភាព និងថវិកា ផអ៣**

| លេខកូដ | ឈ្មោះសកម្មភាព | ស្ថានភាព | %សម្រេច | %ចំណាយ |
|---|---|---|---|---|
| | គាំទ្រសកម្មភាពការងារចុះមូលដ្ឋាន | កំពុងបញ្ចប់ | 100% | 99.98% |

### ១.២.៤. ការគាំទ្រឃុំ-សង្កាត់

- ត្រៀមរៀបចំ ធ្វើសមាហរណកម្មផែនការស្រុក-ឃុំ នៅថ្នាក់ស្រុក

១).ការអនុវត្តគម្រោងមូលនិធិឃុំឆ្នាំ ២០១៩

- នៅក្នុងឆ្នាំ២០១៩នេះ ឃុំទាំង១៥ក្នុងស្រុកបានរៀបចំគម្រោងដែលប្រើប្រាស់មូលនិធិឃុំ២០១៩ មាន ១៦គម្រោងលើ១៥ឃុំ រួមមាន៖

+ គម្រោងផ្លូវបេតុង ៦គម្រោងមាន៖ (ឃុំអរិយក្សត្រ, សារិកាកែវ, បារុង, ពាមឧកញ៉ាអុង, កោះរះ និង ឃុំព្រែករំ)

+ គម្រោងផ្លូវដីស មាន៧គម្រោង៖ (ឃុំភូមិធំ, ឃុំបឹងគ្រំ(២ខ្សែ)ល្វាសរ, សំបួរ, ព្រែកឬស្សី, ថ្មគរ និង ឃុំកោះកែវ(ដាក់លូ))

+ ផ្លូវក្រាលគ្រួសក្រហម ឃុំព្រែកក្មេង

+ គម្រោងស្ពានប្រឡាយ និងសាងសង់កូនទ្វាទឹក(ឃុំទឹកឃ្លាំង)

២).ការអនុវត្តគម្រោងឃុំឆ្នាំ២០១៩

| ល.រ | ឈ្មោះឃុំ | ឈ្មោះគម្រោង | ទីតាំងគម្រោង | ប្រវែង | អនុវត្តន៍ដោយ | លទ្ធផលសម្រេចបាន | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | | | | | 50% | 100% | |
| ១ | អរិយក្សត្រ | សាងសង់ផ្លូវបេតុង | ភូមិខ្សាច់ | | | | | ព្យួរថវិកា |
| ២ | បារុង | សាងសង់ផ្លូវបេតុង | ភូមិបារុង | 240m X 5m | ជួន អេង | | 100% | |
| ៣ | បឹងគ្រំ | ជួសជុលផ្លូវដី ស ២ខ្សែ | ភូមិលើ+ក្រោម | 1422m X 6m | សុខ ស្រីមុំ | | | 10% |
| ៤ | កោះកែវ | ជួសជុលផ្លូវ | ភូមិកោះកែវលើ | 227m X 6m | សេង ណាង | | 100% | |
| ៥ | កោះរះ | សាងសង់ផ្លូវបេតុង | ភូមិកោះរះក្រោម | 203m X 4m | សេង វុទ្ធី | | 100% | |
| ៦ | ល្វាសរ | ជួសជុលផ្លូវដី ស | ភូមិល្វាសរកណ្តាល | 505m X 6m | ម៉ៅ លីហ៊ា | | | 30% |
| ៧ | ពាមឧកញ៉ាអុង | សាងសង់ផ្លូវបេតុង | ល្វាសរកណ្តាល | 263m X 4m | ផល លីហ៊ង | | 100% | |
| ៨ | ភូមិធំ | ជួសជុលផ្លូវដី ស | ភូមិព្រែកតាប្រាំង | 1350m X 6m | ជា មករា | | | មិនទាន់ |
| ៩ | ព្រែកក្មេង | ជួសជុលផ្លូវក្រាលគ្រួសក្រហម | ភូមិព្រែកក្មេង | 464m X 6m | ម៉ៅ លីហ៊ា | | | មិនទាន់ |
| ១០ | ព្រែករំ | សាងសង់ផ្លូវបេតុង | ភូមិព្រែករំ | 181m X5m | ជួន អេង | | 100% | |
| ១១ | ព្រែកឬស្សី | ជួសជុលផ្លូវដី ស | ភូមិព្រែកឬស្សី | 1599m X 6m | ជា មករា | | | កំពុងអនុវត្ត |
| ១២ | សំបួរ | ជួសជុលផ្លូវដី ស | ភូមិជ្រោយជ្រៃ | 353m X6m | ណូវ ជូ | | | 30% |
| ១៣ | សារិកាកែវ | សាងសង់ផ្លូវបេតុង | ភូមិតាដោ | 382m X5m | សេង វុទ្ធី | | | កំពុងអនុវត្ត |
| ១៤ | ថ្មគរ | ជួសជុលផ្លូវដី ស | ភូមិផ្លូវត្រី | 748m X 6m | ជា មករា | | | មិនទាន់ |
| ១៥ | ទឹកឃ្លាំង | ស្ពានប្រឡាយ១ខ្សែ | ភូមិជ្រោយពិសី | | | | | ព្យួរថវិកា |
| | | សាងសង់ទ្វាទឹក | | | | | | |

+គម្រោងដែលនៅសល់ឆ្នាំ២០១៨ មកអនុវត្តន៍ឆ្នាំ២០១៩

| ល.រ | ឈ្មោះឃុំ | ឈ្មោះគម្រោង | ទីតាំងគម្រោង | ប្រវែង | អនុវត្តន៍ដោយ | លទ្ធផលសម្រេចបាន | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| | | | | | | 50% | 100% | បញ្ចប់ | |
| ១ | បឹងគ្រំ | ជួសជុលផ្លូវក្រាលគ្រួសក្រហម | ភូមិបឹងគ្រំលើ | 844m x4m | សុខ ស្រីមុំ | | √ | | |
| ២ | ថ្មគរ | ជួសជុលផ្លូវដី ស | ភូមិថ្មគរ | 370mx6m | ជា មករា | | √ | | |
| ៣ | ល្វាសរ | ជួសជុលផ្លូវដីស | ភូមិល្វាសរកណ្តាល | 485mx10m | សុខ ស្រីមុំ | | | | 30% |
| ៤ | សំបួរ | ជួសជុលផ្លូវដីស | ភូមិសំបួរ | 260mx6m | ញ៉ូវ ប៊ុនហឿន | | √ | | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ៥ | ព្រែករ៉ៃ | ជួសជុលផ្លូវដី ស | ភូមិព្រែករ៉ៃ | 876mx6m | ម៉ៅ លីហ៊ | | √ | | |
| ៦ | ព្រែកក្មេង | ជួសជុលផ្លូវក្រាលគ្រួសក្រហម | ភូមិទួលទ្រា | 1650mx6m | ម៉ៅ លីហ៊ | | | √ | |
| ៧ | ព្រែកឫស្សី | ជួសជុលផ្លូវដី ស | ភូមិព្រែកជ្រៃ | 1478m x8m | ជា មករា | | | √ | |
| ៨ | ភូមិធំ | ជួសជុលផ្លូវក្រាលគ្រួសក្រហម ២ខ្សែ | ភូមិព្រែកក្រូច | 85mX5m | ជា មករា | | | √ | |
| | | | ភូមិព្រែកតាប្រាំង | 500mX6m | ជា មករា | | | √ | |

១.៣.១. ការគ្រប់គ្រងបុគ្គលិក

ស្រុកល្វាឯមមានសមាជិកក្រុមប្រឹក្សាស្រុកចំនួន១៩នាក់, ស្រី០៥នាក់ មន្ត្រីរដ្ឋបាលស្រុកមាន ចំនួន២៥ នាក់, ស្រី១១នាក់ ក្នុងនោះគណៈអភិបាលស្រុក ០៥នាក់, ស្រី០១នាក់ នាយករដ្ឋបាល០១នាក់ នាយករងរដ្ឋបាល ០២នាក់ បែងចែកជា ៣ ការិយាល័យ និង១អង្គភាព រួមមានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ ០៩នាក់, ស្រី០៧នាក់ ការិយាល័យផែនការ និងគាំទ្រឃុំ ០៣នាក់, ស្រី០១នាក់ ការិយាល័យអន្តរវិស័យចំនួន០៤នាក់, ស្រី០១នាក់ អង្គភាពលទ្ធកម្ម០១នាក់, ស្រី០១នាក់។

បានចេញដីកាតម្លើងថ្នាក់ ឋានន្តរស័ក្តិ ជូនមន្ត្រីរាជការស៊ីវិលក្រសួងមហាផ្ទៃសម្រាប់ឆ្នាំ២០១៩ ចំនួន ០៦ នាក់ ក្នុងនោះ មន្ត្រីរដ្ឋបាលជាន់ខ្ពស់ មានចំនួន ០១ នាក់ មន្ត្រីក្រមការ ចំនួន ០៣នាក់ និងមន្ត្រីលេខាធិការរដ្ឋបាល មានចំនួន ០២ នាក់។

ថ្ងៃទី១៥ ខែកុម្ភៈឆ្នាំ២០១៩ រដ្ឋបាលស្រុកបានរៀបចំពិធីផ្សព្វផ្សាយ និងប្រគល់ប័ណ្ណមូលនិធិសមធម៌(ប.ស.ស) ជូនដល់ក្រុមប្រឹក្សាឃុំ មេភូមិ អនុភូមិ និងសមាជិកភូមិ ទូទាំងស្រុក ក្រោមអធិបតីភាពលោក ចេង ឌីណា អភិបាលរងស្រុក តំណាងលោក គឹម គីរ៉ា អភិបាល នៃគណៈអភិបាលស្រុកល្វាឯម និងលោក រ៉ៃ ជារិទ្ធ ប្រធានស្នាក់ការ ប.ស.ស ស្រុកខ្សាច់កណ្ដាល។

បានទទួលប្រកាសស្តីពីការតែងតាំង និងផ្លាស់ប្តូរក្រុមប្រឹក្សាឃុំ មានឃុំព្រែករ៉ៃ ពាមឧកញ៉ាអុង សំបួរ និងឃុំព្រែកក្មេង ។

ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៩ បានរៀបចំពិធីប្រកាសផ្ទេរ និងចូលកាន់មុខតំណែងជាអភិបាលរង នៃគណៈអភិបាលស្រុកល្វាឯម ក្រោមអធិបតីភាព **លោកជំទាវ ហ៊ុន ភុសនី** អភិបាលរងខេត្តកណ្ដាល នៅសាលប្រជុំសាលាស្រុកល្វាឯម ខេត្តកណ្ដាល។

នៅព្រឹកថ្ងៃចន្ទ ទី១៧ ខែមិថុនា ឆ្នាំ២០១៩ បានអញ្ជើញចូលរួមក្នុងពិធីប្រកាសចូលកាន់មុខតំណែងជាក្រុមប្រឹក្សាស្រុកល្វាឯម ក្រោមអធិបតីភាព **ឯកឧត្តម គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមអគ្គបណ្ឌិត សភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមការងារថ្នាក់ជាតិចុះជួយខេត្តកណ្ដាល និង**ឯកឧត្តម គង់ សោភ័ណ្ឌ** អភិបាលរងខេត្ត តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិត ម៉ៅ ភិរុណ** អភិបាល នៃគណៈភិបាលខេត្តកណ្ដាល នៅសាលប្រជុំសាលាស្រុកល្វាឯម សរុបវត្តមានចូលរួម១៥០នាក់, ស្រី២០នាក់។

បានធ្វើសំណើសុំតម្លើងថ្នាក់ ឋានន្តរស័ក្តិ ជូនមន្ត្រីរាជការស៊ីវិលក្រសួងមហាផ្ទៃសម្រាប់ឆ្នាំ២០២០ ចំនួន ០៦ នាក់ សម្រាប់ថ្នាក់គណៈអភិបាលស្រុក និងនាយករដ្ឋបាលស្រុក ជូនក្រសួងមហាផ្ទៃ ។

**តារាងទី១១៖ ស្ថិតិក្រុមប្រឹក្សា និងបុគ្គលិក**

| ល.រ | ការបរិយាយ | សរុប | ស្រី |
|---|---|---|---|
| ១ | សមាជិកក្រុមប្រឹក្សា | ១៨ | ៥ |
| ២ | ប្រធានក្រុមប្រឹក្សា | ១ | ០ |
| ៣ | សមាជិកក្រុមប្រឹក្សាដែលបានផ្លាស់ប្តូរ | ៦ | ២ |
| ៤ | អភិបាល | ១ | ០ |
| ៥ | អភិបាលរង | ៤ | ១ |

| ល.រ | ការបរិយាយ | សរុប | ស្រី |
|---|---|---|---|
| ៦ | នាយករដ្ឋបាល | ១ | ០ |
| ៧ | នាយករងរដ្ឋបាល | ២ | ០ |
| ៨ | ប្រធានការិយាល័យ និងអង្គភាព | ៣ | ០ |
| ៩ | អនុប្រធានការិយាល័យ និងអង្គភាព | ៤ | ៤ |
| ១០ | មន្ត្រីការិយាល័យ | ១០ | ៦ |
| ១១ | បុគ្គលិកកិច្ចសន្យា | ០ | ០ |

១.៣.២. ការកសាងសមត្ថភាព

**តារាងទី១២ ៖ ការកសាងសមត្ថភាព**

| ល.រ | ឈ្មោះវគ្គបណ្តុះបណ្តាល | ចំនួនថ្ងៃ | អ្នកចូលរួម | | រៀបចំដោយ |
|---|---|---|---|---|---|
| | | | សរុប | ស្រី | |
| 1. | បានបើកវគ្គបណ្តុះបណ្តាល ស្តីពីតួនាទីភារកិច្ចរបស់គណៈកម្មាធិ ការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារស្រុក និ គណៈកម្មការទទួលបន្ទុកកិច្ចស្ត្រី និងកុមារឃុំ | ១ | ៨២ | ២៦ | រៀបចំដោយ រដ្ឋបាលស្រុក |
| 2. | បើកវគ្គផ្សព្វផ្សាយ "ខ្លឹមសារលិខិតបទដ្ឋាននានាស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយក្នុងស្រុកល្វាឯម" | ១ | ១៣៩ | ១៩ | រៀបចំដោយ រដ្ឋបាលស្រុក |
| 3. | - វគ្គបណ្តុះបណ្តាលស្តីពីរៀបចំផែនការសកម្មភាព និងថវិកាលើវិស័យសេវាសង្គមឃុំ-សង្កាត់ | ១ | ៥៥ | ២០ | រដ្ឋបាលខេត្តកណ្តាល |
| 4. | - វគ្គបណ្តុះបណ្តាល ស្តីពីការធ្វើអត្តសញ្ញាណកម្មគ្រួសារក្រីក្រទូទាំងស្រុក ឆ្នាំ២០១៩ | ១ | ១០៤ | ២៤ | រដ្ឋបាលខេត្តកណ្តាល |
| 5. | - វគ្គបណ្តុះបណ្តាល ស្តីពីសៀវភៅណែនាំ ការគ្រប់គ្រងមត្តេយ្យសហគមន៍សម្រាប់ឃុំ-សង្កាត់ | ១ | ៧២ | ២២ | រដ្ឋបាលខេត្តកណ្តាល |
| 6. | - វគ្គបណ្តុះបណ្តាលរម្លឹកឡើងវិញស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ-សង្កាត់ | ១ | ៤៧ | ៧ | រដ្ឋបាលខេត្តកណ្តាល |
| 7. | - វគ្គបណ្តុះបណ្តាលស្តីពីបរិយាប័ន្ន និងសមធម៌សង្គម | ១ | ៣៤ | ១៤ | រដ្ឋបាលខេត្តកណ្តាល |
| 8. | - វគ្គបណ្តុះបណ្តាលស្តីពីសៀវភៅប្រតិបត្តិគោល និងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មានសម្រាប់ | ៤ | ៦០ | ៣២ | រដ្ឋបាលខេត្តកណ្តាល |
| | *សរុប* | ១១ | ៥៩៣ | ១៦៤ | |

១.៤. ការងារអន្តរវិស័យ

១.៤.១. ការសម្របសម្រួលតាមវិស័យ:

- បានចូលរួមជាមួយក្រុមការងារថ្នាក់ស្រុកដឹកនាំដោយ លោក យី យ៉េន អភិបាលរងស្រុក ចុះផ្អាក និងដកហូត សម្ភារៈសាងសង់ផេប៉ូប្រេងឥន្ទនៈគេឡាគ្មានច្បាប់អនុញ្ញាតរបស់ឈ្មោះ សំ ផល និង រេន ធារី ស្ថិតនៅភូមិកោះរះក្រោម ឃុំកោះរះ។

- បានចូលរួមជាមួយកម្លាំងចម្រុះស្រុកដឹកនាំដោយ លោក យី យ៉េន អភិបាលរងស្រុក ចុះហាមឃាត់ និងចាប់យកគ្រឿងចក្រដឹកដីគ្មានការអនុញ្ញាតនៅចំណុចដីដុះ ស្ថិតក្នុងភូមិខ្សាច់ ឃុំអរិយក្សត្រ ដែលមានម្ចាស់ទីតាំងឈ្មោះ ង៉ាក់ ចេង។

- បានចូលរួមជាមួយ លោក បូ សារឿន នាយកទីចាត់ការអន្តរវិស័យខេត្ត ដោយមានការចូលរួមពី លោក ហ៊ឹង សុធី អនុប្រធានមន្ទីរជនសស ចុះពិនិត្យ និងស្រាវជ្រាវទីតាំងដីដែលបានស្នើសុំកាន់កាប់របស់ឈ្មោះ លាស់ ញ៉ឹក ទំហំស្នើសុំប្រហែល៨ហិកតា ស្ថិតនៅភូមិព្រែកជ្រៃ ឃុំព្រែកឬស្សី។

- បានចូលរួមជាមួយ លោក ចេង ឌីណា អភិបាលរងស្រុក និងក្រុមការងារតំណាងមន្ទីរសាធារណៈការ និងដឹកជញ្ជូនខេត្តកណ្តាល, សេវាករទឹកស្អាត, សេវាករខ្សែកាបអុបទិកក្រុមហ៊ុនមិត្តហ្វូន, សេវាករអគ្គីសនីកៀនស្វាយ និងអាជ្ញាធរឃុំទឹកឃ្លាំង ចុះពិនិត្យទីតាំងបង្គោលភ្លើង, ខ្សែកាប និងទុយោទឹកបង្កប់ដែលប៉ះពាល់ដល់ការសាងសង់ផ្លូវឱ្យធ្វើការរុះរើ និងកែសម្រួលចាប់ពីមុខវត្តសំពោងដល់មុខវត្តទឹកឃ្លាំង។

- បានចូលរួមជាមួយក្រុមការងារថ្នាក់ស្រុកដឹកនាំដោយ លោក ចេង ឌីណា អភិបាលរងស្រុក ចុះផ្អាកទីតាំងសំណង់របស់ឈ្មោះ នៅ ស៊ីថា ស្ថិតនៅជាប់ផ្លូវ៧០បេ ក្នុងភូមិផ្លូវត្រី ឃុំថ្មគរ។

- បានចូលរួមជាមួយក្រុមការងារថ្នាក់ស្រុកដឹកនាំដោយ លោក កន សុខកាយ អភិបាលរងស្រុក ចុះហាមឃាត់ប្រជាពលរដ្ឋ០១គ្រួសារដែលកំពុងសង់សំណង់លើទីតាំងដីសាធារណៈរបស់រដ្ឋស្ថិតនៅចំណុចជំរុំត្នោត ក្នុងភូមិបារុង ឃុំបារុង។

- បានចូលរួមជាមួយក្រុមការងារថ្នាក់ស្រុកដឹកនាំដោយ លោក កន សុខកាយ អភិបាលរងស្រុក សហការជាមួយអាជ្ញាធរឃុំកោះរះ និងពាមឧកញ៉ាអុង ចុះវាស់វែង និងបោះបង្គោលបើកផ្លូវ១ខ្សែទទឹង២០ម៉ែត្រ និងបណ្តោយប្រហែល១,៦០០ម៉ែត្រ ឆ្លងកាត់ភូមិកោះរះលើ ឃុំកោះរះ និងភូមិវាលធំ ភូមិព្រែកតាអុង៣ ឃុំពាមឧកញ៉ាអុង។

- បានចូលរួមជាមួយក្រុមការងារថ្នាក់ស្រុកដឹកនាំដោយ លោក យី យ៉េន អភិបាលរងស្រុក ចុះពិនិត្យទីតាំងចិញ្ចឹមជ្រូកមួយកន្លែងរបស់ឈ្មោះ យ៉ា យ៉ុន ស្ថិតក្នុងភូមិក្តីកណ្តាល ឃុំសារិកាកែវ ដែលបង្កផលប៉ះពាល់ និងរំខានដល់ការរស់នៅរបស់ប្រជាពលរដ្ឋជុំវិញ។

- បានចូលរួមជាមួយគណៈកម្មការដីរដ្ឋថ្នាក់ស្រុកដឹកនាំដោយ លោក កន សុខកាយ អភិបាលរងស្រុក បានចុះកំណត់យកនិយាមការ ដើម្បីចុះបញ្ជីដីរដ្ឋបឹងឈូងគរ ស្ថិតនៅភូមិផ្លូវត្រី ឃុំថ្មគរ និងភូមិទឹកឃ្លាំង ឃុំទឹកឃ្លាំង។

- បានចូលរួមជាមួយ លោក យី យ៉េន អភិបាលរងស្រុក ក្នុងកិច្ចប្រជុំពិភាក្សារកដំណោះស្រាយរំដោះទឹកដែលស្ទះនៅពេលភ្លៀង បង្កជាក្លិនស្អុយប៉ះពាល់ដល់ការរស់នៅរបស់ប្រជាពលរដ្ឋ ស្ថិតក្នុងភូមិវាលធំ ឃុំពាមឧកញ៉ាអុង។

- បានចូលរួមជាមួយ លោក កន សុខកាយ អភិបាលរងស្រុកអាជ្ញាធររួមជាមួយ ភូមិឃុំពាមឧកញ៉ាអុង ចុះទៅសម្របសម្រួលផលប៉ះពាល់ដីមួយកន្លែងរបស់ឈ្មោះ អ៊ុន ស៊ឹម នៅចំណុចផ្លូវបើកថ្មី ក្នុងភូមិព្រែកតាអុងទី៣ ឃុំពាមឧកញ៉ាអុង។

- បានចូលរួមជាមួយ លោក ចេង ឌីណា អភិបាលរងស្រុក រួមជាមួយអាជ្ញាធរភូមិ-ឃុំពាមឧកញ៉ាអុង ចុះពិនិត្យទីតាំងស្នើសុំតម្លើងអង់តែនទូរស័ព្ទចល័តរបស់ ក្រុមហ៊ុនសេលកាត(Cellcard) ស្ថិតក្នុងភូមិពាមតាឯក ឃុំពាមឧកញ៉ាអុង។

- បានចូលរួមជាមួយ លោក ចេង ឌីណា អភិបាលរងស្រុក ចុះកំណត់និយាមការទីតាំងបឹងដោះដូរដីស្ថិតនៅភូមិបឹងគ្រំក្រោម ឃុំបឹងគ្រំ។

- បានចូលរួមជាមួយ លោក កន សុខកាយ អភិបាលរងស្រុកចុះអនុវត្តដោយបង្ខំឲ្យប្រគល់អចលនវត្ថុមួយកន្លែងស្ថិតនៅកន្លែងជ្រុង ភូមិព្រែករ៉ៃ ឃុំព្រែករ៉ៃ តាមអំណាចសាលក្រមរដ្ឋប្បវេណីលេខ៤០ ចុះ (ឈ) របស់សាលាដំបូងខេត្តកណ្តាល ២០១៩ខែមេសា ឆ្នាំ ២៩ថ្ងៃទី។

- បានចូលរួមជាមួយលោក កន សុខកាយ អភិបាលរងស្រុក ចុះហាមឃាត់ការសាងសង់សំណង់អត់ច្បាប់របស់ឈ្មោះ ង្វៀង យ៉ាំងប្រា ជនជាតិវៀតណាម ស្ថិតនៅចំណុចកំពង់ចម្លងអរិយក្សត្រ ក្នុងភូមិអរិយក្សត្រ ឃុំអរិយក្សត្រ។

- បានចូលរួមជាមួយលោក កន សុខកាយ អភិបាលរងស្រុក ចុះពិនិត្យសំណង់អត់ច្បាប់អនុញ្ញាតដែលបានបាក់ស្រុតរបស់ឈ្មោះថោង វណ្ណី, ថោង ផល្លា និងថោង វណ្ណា នៅភូមិព្រែកក្មេង ឃុំព្រែកក្មេង។

- បានចូលរួមជាមួយ លោក កន សុខកាយ អភិបាលរងស្រុក ចុះផ្អាកសំណង់លំនៅដ្ឋានលើទីតាំងដីកំពុងមានវិវាទស្ថិតនៅចំណុចខាងក្រោយវត្តថ្មគរ ក្នុងភូមិថ្មគរ ឃុំថ្មគរ។

- បានចូលរួមជាមួយ លោក ញ៉ឹក សាត នាយករដ្ឋបាល ចុះពិនិត្យទីតាំងស្នើសុំសាងសង់បង្គោលអង់តែនទូរស័ព្ទ របស់ក្រុមហ៊ុន សេលកាត ចំនួន០២ទីតាំងស្ថិតនៅភូមិតាដោ ឃុំសារិកាកែវ និងភូមិទឹកឃ្លាំង ឃុំទឹកឃ្លាំង។

- បានចូលរួមជាមួយ លោក កន សុខកាយ អភិបាលរងស្រុក ចុះស្រាវជ្រាវលើកទីពីរចំពោះអចលនវត្ថុចំនួន០២ទីតាំង ស្ថិតនៅកន្លែងជ្រុង ភូមិព្រែករ៉ៃ ឃុំព្រែករ៉ៃ តាមអំណាចសាលក្រមរដ្ឋប្បវេណីលេខ៤០ "ឈ" របស់សាលាដំបូងខេត្តកណ្តាល ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៩។

- បានចូលរួមជាមួយការិយាល័យ ដនសក បានចុះផ្អាក់សំណង់អត់ច្បាប់ចំនួនពីរកន្លែងៈ

  ១. ម្ចាស់ឈ្មោះ មា ងួន ស្ថិតនៅភូមិព្រែកតាអុងទី២ ឃុំពាមឧកញ៉ាអុង

  ២. ម្ចាស់ឈ្មោះ លីវ ឃីធឃៀង ស្ថិតនៅភូមិវាលធំ ឃុំពាមឧកញ៉ាអុង

- បានចូលរួមជាមួយ លោក កន សុខកាយ អភិបាលរងស្រុក ចុះផ្អាក និងណែនាំឲ្យរុះរើញ៉ាបដែកសង់លើចំណផ្លូវរបស់ឈ្មោះ ប្រាក់ នី ស្ថិតក្នុងភូមិព្រែកក្មេង ឃុំព្រែកក្មេង។

- ចូលរួមជាមួយលោក កន សុខកាយ អភិបាលរងស្រុក ចុះពិនិត្យសំណង់អត់ច្បាប់អនុញ្ញាតដែលបានបាក់ស្រុតរបស់ឈ្មោះ ថោង ផល្លាថោង វណ្ណី និង ថោង វណ្ណៈ ស្ថិតនៅភូមិព្រែកក្មេង ឃុំព្រែកក្មេង។

- បានចូលរួមជាមួយគណៈកម្មការចម្រុះស្រុកដឹកនាំដោយ លោក កន សុខកាយ អភិបាលរងស្រុក ចុះផ្អាក និងដកហូតសម្ភារៈសំណង់របស់ជនជាតិវៀតណាមឈ្មោះ ង្វៀង យ៉ាំងប្រា ស្ថិតក្នុងភូមិអរិយក្សត្រ ឃុំអរិយក្សត្រ។

- បានចូលរួមជាមួយ លោក ចេង ឌីណា អភិបាលរងស្រុក ចុះផ្អាក និងដកហូតសម្ភារៈសំណង់អត់ច្បាប់អនុញ្ញាត និងរំលោភចំណីផ្លូវរបស់ឈ្មោះ គង់ អាស្នា ស្ថិតនៅភូមិថ្មគរ ឃុំថ្មគរ។

- បានចូលរួមជាមួយក្រុមការងារថ្នាក់ស្រុក ចុះពិនិត្យទីតាំងស្នើសុំចាក់បំពេញអាចម៍ដីចំនួន០២ទីតាំងៈ

1. ទីតាំងទីមួយ មានទំហំ៧៧៥ម៉ែត្រក្រឡា ជម្រៅ៤,៥ម៉ែត្រ ស្ថិតនៅភូមិព្រែកក្មេង ឃុំព្រែកក្មេង

2. ទីតាំងទីពីរ មានទំហំ១,០០០ម៉ែត្រក្រឡា ជម្រៅ២ម៉ែត្រ ស្ថិតនៅភូមិវាលធំ ឃុំពាមឧកញ៉ាអុង។

១.៤.២. ការអនុវត្តមុខងារផ្សេងៗ(មុខងារដែលបានផ្ទេរ)

- បានចូលរួមជាមួយ លោក កន សុខកាយ អភិបាលរងស្រុក ក្នុងកិច្ចប្រជុំផ្សព្វផ្សាយរបស់គណៈកម្មការដីរដ្ឋថ្នាក់ស្រុកអំពីទីតាំងដីបម្រុងទុករបស់រដ្ឋស្ថិតនៅចំនុចបឹងឈូងគ ក្នុងភូមិផ្លូវត្រី ឃុំថ្មគរ និងភូមិទឹកឃ្លាំង ឃុំទឹកឃ្លាំង។

- បានចូលរួមក្នុងកិច្ចប្រជុំគណៈកម្មការគ្រប់គ្រងដីរដ្ឋថ្នាក់ស្រុក ក្រោមអធិបតីភាពលោក គីម គីរ៉ា អភិបាលនៃ គណៈអភិបាលស្រុក និងជាប្រធានគណៈកម្មការគ្រប់គ្រងដីរដ្ឋថ្នាក់ស្រុក។

- បានចូលរួមក្នុងកិច្ចប្រជុំសាមញ្ញលើកទី៤៨ របស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ ក្រោមអធិបតីភាព លោក គីម គីរ៉ា អភិបាល នៃគណៈអភិបាលស្រុកល្វាឯម។

- បានចូលរួមប្រជុំប្រចាំខែរបស់គណៈកម្មការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ។

- បានចូលរួមក្នុងកិច្ចប្រជុំស្តីពីការងារចុះបញ្ជីទីតាំងដីរដ្ឋក្រោមអធិបតីភាព លោក គីម គីរ៉ា អភិបាលស្រុក និងជាប្រធានគណៈកម្មការគ្រប់គ្រងដីរដ្ឋថ្នាក់ស្រុក។

- បានចូលរួមកិច្ចប្រជុំពិភាក្សាលើសំណើសុំជួយសម្របសម្រួលទិញដី ដើម្បីសាងសង់រោងចក្រអគ្គីសនីទំហំ៤០០មេហ្គាវ៉ាត់ ក្នុងស្រុកល្វាឯម ក្រោមអធិបតីភាព **ឯកឧត្តម បណ្ឌិត ម៉ៅ ភិរុណ** អភិបាល នៃគណៈអភិបាលខេត្តកណ្តាល។

- បានចូលរួមក្នុងកិច្ចប្រជុំគណៈកម្មការដីរដ្ឋក្រោមអធិបតីភាព លោក គីម គីរ៉ា អភិបាលស្រុក និងជាប្រធានគណៈកម្មការគ្រប់គ្រងដីរដ្ឋថ្នាក់ស្រុក។

- បានចូលរួមកិច្ចប្រជុំពិនិត្យ និងកែសម្រួលផែនការហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងប្លង់គោលប្រើប្រាស់ដី រវាងមន្ទីរពាក់ព័ន្ធ និងរដ្ឋបាលស្រុកល្វាឯម ក្រោមការដឹកនាំរបស់ លោក វ៉ាន់ វ៉ាត អនុប្រធានមន្ទីររៀបចំ ដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តកណ្តាល និងលោក គីម គីរ៉ា អភិបាលស្រុក។

- បានចូលរួមក្នុងកិច្ចប្រជុំពាក់ព័ន្ធការងារស្នើសុំចុះបញ្ជីដីរបស់ប្រជាពលរដ្ឋចំនួន២១៥គ្រួសារ រស់នៅភូមិអរិយក្សត្រ និងភូមិខ្សាច់ ឃុំអរិយក្សត្រ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**ឯកឧត្តម បណ្ឌិត ម៉ៅ ភិរុណ** អភិបាល នៃគណៈអភិបាលខេត្តកណ្តាល។

- បានចូលរួមដឹកនាំកម្លាំងទូកងរបស់ស្រុក ទៅចូលរួមប្រកួតដើម្បីអបអរសាទរព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប អកអំបុក និងសំពះព្រះខែ នៅមុខព្រះបរមរាជវាំង រាជធានីភ្នំពេញ នៅថ្ងៃទី១១-១២ និងថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៩។

១.៤.៣. <u>ការដោះស្រាយ និងសម្រុះសម្រួលទំនាស់</u>

- បានចូលរួមជាមួយ លោក ញ៉ឹក សាត នាយករដ្ឋបាល ក្នុងការប្រជុំសម្រុះសម្រួលបញ្ចប់ករណីវិវាទដីធ្លីមួយកន្លែងស្ថិតនៅចំណុចទួលប្រលាន ភូមិបារុង ឃុំបារុង រវាងឈ្មោះ ចាប បូ និងឈ្មោះ ស៊ុំ សឹង - ង៉ុយ ពៅ។

- បានចូលរួមរៀបចំសម្របសម្រួលករណីទំនាស់ដីធ្លីរវាងឈ្មោះ ផុន លី - ផុន ឡា និង សួង ប៉ុល ក្រោមការដឹកនាំរបស់ លោក ញ៉ឹក សាត នាយករដ្ឋបាល។ លទ្ធផល៖ ភាគីទាំងពីរ មិនសះជាគ្នា។

- បានចូលរួមជាមួយ លោក ញ៉ឹក សាត នាយករដ្ឋបាល ធ្វើការសម្រុះសម្រួលករណីវិវាទព្រំប្រទល់ដីមួយកន្លែងស្ថិតនៅភូមិជ្រោយជ្រៃ ឃុំសំបួរ រវាងឈ្មោះ បាន ខឿន និង ស្តើង ចង្រិត។ លទ្ធផល៖ ភាគីទាំងពីរ ឯកភាពព្រមព្រៀងសះជាគ្នា។

- បានចូលរួមប្រជុំសម្រុះសម្រួលករណីដីជាន់គ្នារវាងលោក ចាន់ អង និងលោក ស្រី ចាន់ថន នៅចំណុចភូមិ ខ្លោការ ឃុំបារុង ក្រោមអធិតីភាព លោក កន សុខកាយ និងលោក ចេង ឌីណា អភិបាលរងស្រុក។ លទ្ធផលៈ ភាគីទាំងពីរ ឯកភាពព្រមព្រៀងសះជាគ្នា។

- បានចូលរួមជាមួយ លោក កន សុខកាយ អភិបាលរងស្រុក ធ្វើការសម្រុះសម្រួលករណីទំនាស់ដីធ្លីរវាងឈ្មោះ ឈួន សាឡាត់ និងលោក យិន យាន ដែលស្ថិតនៅភូមិវាលធំ ឃុំពាមឧកញ៉ាអុង។ លទ្ធផលៈ ភាគីឈ្មោះ ឈួន សាឡាត់ ឯកភាពបើកផ្លូវទេះនេះឡើងវិញមានទទឹង១,៥០ម៉ែត្រ។

- បានចូលរួមជាមួយ លោក កន សុខកាយ អភិបាលរងស្រុក ក្នុងកិច្ចប្រជុំសម្រុះសម្រួលបញ្ហាដីធ្លីនៅចំណុចមុខសាលាបឋមសិក្សាពោធិ៍ធំ ភូមិពោធិ៍ធំ ឃុំអរិយក្សត្រ រវាងព្រះសង្ឃ គណៈកម្មការអាចារ្យវត្តសារិកាកែវ និងអតីតលោកគ្រូអ្នកគ្រូចំនួន០៥នាក់។ លទ្ធផលៈ ភាគីទាំងសងខាង ឯកភាពព្រមព្រៀងសះជាគ្នា។

- បានចូលរួមប្រជុំសម្រុះសម្រួលដីជាន់គ្នារវាង លោក ស្រី ចាន់ថន និង លោក ស៊ុន សូត្រ ស្ថិតក្នុងភូមិពាមតាឯក ឃុំពាមឧកញ៉ាអុង ក្រោមអធិតីភាព លោក ចេង ឌីណា អភិបាលរងស្រុក។ លទ្ធផលៈ ភាគីទាំងពីរ ឯកភាពព្រមព្រៀងសះជាគ្នា។

- បានចូលរួមសម្រុះសម្រួលករណីជំពាក់ប្រាក់ថ្លៃដឹកអាចម៍ដីរវាងឈ្មោះ ពេញ សិលា និង ឯម ម៉ៅ ក្រោមអធិបតីភាព លោក កន សុខកាយ អភិបាលរងស្រុក។ លទ្ធផលៈ ភាគីទាំងពីរឯកភាពព្រមព្រៀងទូទាត់ប្រាក់ ដើម្បីបញ្ចប់ករណីវិវាទ។

- បានចូលរួមកិច្ចប្រជុំសាកសួរ និងសម្រុះសម្រួលករណីបណ្តឹងរបស់ព្រះគ្រូចៅអធិការវត្ត គណៈកម្មការអា- ចារ្យវត្ត និងពុទ្ធបរិស័ទចំណុះជើងវត្តថ្មគរ ប្តឹងប្រជាពលរដ្ឋចំនួន២៨គ្រួសារ ពីការយកដីដែលបានខ្ចីពីវត្តទៅសង់លំនៅដ្ឋាន ស្ថិតក្នុងភូមិថ្មគរ ឃុំថ្មគរ ក្រោមអធិបតីរបស់ លោក កន សុខកាយ អភិបាលរងស្រុក។

- បានចូលរួមកិច្ចប្រជុំសាកសួរ និងសម្របសម្រួលចំនួនពីរលើកករណីសាងសង់ឃ្លាំងរំលោភចូលព្រំដីដែលមានដើមបណ្តឹងឈ្មោះ សួន ហ៊ុនឡា-សៀក សុខជា និងចុងបណ្តឹងឈ្មោះ ស៊ឹម បុរី ស្ថិតក្នុងភូមិទួលមាស ឃុំអរិយក្សត្រ ក្រោមការដឹកនាំរបស់ លោក ញ៉ឹក សាត នាយករដ្ឋបាល។ លទ្ធផលៈ ភាគីទាំងពីរ មិនសះជាគ្នា។

- បានចូលរួមជាមួយ លោក កន សុខកាយ អភិបាលរងស្រុក ក្នុងកិច្ចប្រជុំបញ្ចប់ករណីទំនាស់រវាងព្រះគ្រូចៅអធិការវត្ត និងគណៈកម្មការអាចារ្យវត្តមាត់ក្រសាស់ និងលោកនាយកអនុវិទ្យាល័យស្វាយអណ្តែត។ លទ្ធផលៈ ភាគីទាំងពីរ ឯកភាពប្តូរឈ្មោះអនុវិទ្យាល័យស្វាយអណ្តែតទៅជា"**អនុវិទ្យាល័យមាត់ក្រសាស់**" វិញ។

- បានចូលរួមជាមួយ លោក ញ៉ឹក សាត នាយករដ្ឋបាល ក្នុងកិច្ចប្រជុំសាកសួរ និងសម្រុះសម្រួលករណីបណ្តឹងរបស់ឈ្មោះ ជា សេងណារី ប្តឹងឈ្មោះ ដៃ សុខុន ពីការធ្វើរបងរំលោភចូលព្រំដីប្រវែង១ម៉ែត្រ ស្ថិតក្នុងភូមិព្រែកក្រូច ឃុំភូមិធំ។ លទ្ធផលៈ ភាគីទាំងពីរ មិនសះជាគ្នា។

- បានចូលរួមជាមួយ លោក ញ៉ឹក សាត នាយករដ្ឋបាល ក្នុងកិច្ចប្រជុំសាកសួរ និងសម្រុះសម្រួលករណីវិវាទកម្មសិទ្ធិដីធ្លីស្ថិតនៅភូមិព្រែកក្រូច ឃុំភូមិធំ រវាងឈ្មោះ ផែង សៀប និងឈ្មោះ ជុំ សុឃន។ លទ្ធផលៈ ភាគីទាំងពីរ មិនសះជាគ្នា។

- បានចូលរួមជាមួយ លោក ញ៉ឹក សាត នាយករដ្ឋបាល ក្នុងការប្រជុំសាកសួរ និងសម្រុះសម្រួលករណីទំនាស់ដីធ្លីមួយកន្លែង ស្ថិតនៅភូមិបារុង ឃុំបារុង រវាងឈ្មោះ អួន ចិន្តា និង អួន ស្រីមុំ។ លទ្ធផលៈ ភាគីឈ្មោះ អួន ស្រីមុំ មិនមកចូលរួមតាមការអញ្ជើញរបស់រដ្ឋបាលស្រុកទាំងពីរលើក។

- បានចូលរួមជាមួយ លោក ញ៉ឹក សាត នាយករដ្ឋបាល ក្នុងការប្រជុំសាកសួរ និងសម្រុះសម្រួលចំនួនពីរលើកករណីទំនាស់ដីធ្លីមួយកន្លែង ស្ថិតនៅភូមិល្វាសរកណ្តាល ឃុំល្វាសរ រវាងឈ្មោះ ឯម សារឿន និងឈ្មោះ ផាត់ សាវ៉ាន។ លទ្ធផលៈ ភាគីទាំងពីរ មិនសះជាគ្នា។

- បានចូលរួមជាមួយ លោក ញ៉ឹក សាត នាយករដ្ឋបាល ក្នុងការប្រជុំសាកសួរ និងសម្រុះសម្រួលករណីវិវាទដីធ្លីមួយកន្លែង ស្ថិតនៅភូមិព្រែកជ្រៃ ឃុំព្រែកឬស្សី រវាងឈ្មោះ សំ សារ៉ែន និង ធុច សាមាន។ លទ្ធផលៈ ភាគីទាំងពីរ មិនសះជាគ្នា។

- បានចូលរួមជាមួយ លោក ញ៉ឹក សាត នាយករដ្ឋបាល ក្នុងការប្រជុំសាកសួរ និងសម្រុះសម្រួលករណីវិវាទដីធ្លីមួយកន្លែង ស្ថិតនៅភូមិព្រែកតាប្រាំង ឃុំភូមិធំ រវាងឈ្មោះ លឹម អាយ និង លឹម មួយ។ លទ្ធផលៈ ភាគីទាំងពីរ មិនសះជាគ្នា។

- បានចូលរួមជាមួយ លោក ញ៉ឹក សាត នាយករដ្ឋបាល ក្នុងការប្រជុំសាកសួរ និងសម្រុះសម្រួលករណីជំពាក់ប្រាក់ទិញលក់ពោត រវាងឈ្មោះ ថន គីមហៀង និងឈ្មោះ សំ អុន, សំ អួន និង សំ អឿន រស់នៅភូមិបឹងគ្រំលើ ឃុំបឹងគ្រំ។ លទ្ធផលៈ ភាគីទាំងពីរ មិនសះជាគ្នា។

- បានចូលរួមក្នុងការប្រជុំសាកសួរ និងសម្រុះសម្រួលករណីវិវាទថ្លៃទូទាត់ប្រាក់ទិញលក់ដីមួយកន្លែង ស្ថិតនៅភូមិកោះរះលើ ឃុំកោះរះ រវាងម្ចាស់ដីឈ្មោះ អ៊ុំ សុផា និងតំណាងអ្នកទិញ ឈ្មោះ ឈិន ម៉ាលីស ក្រោមការដឹកនាំរបស់ លោក ញ៉ឹក សាត នាយករដ្ឋបាល ។ លទ្ធផលៈ ភាគីតំណាងអ្នកទិញ មិនមកចូលរួមតាមការអញ្ជើញរបស់រដ្ឋបាលស្រុក។

- បានចូលរួមក្នុងការប្រជុំសាកសួរ និងសម្រុះសម្រួលចំនួនពីរលើកករណីវិវាទដីធ្លីមួយកន្លែងស្ថិតនៅភូមិសំរោង ឃុំទឹកឃ្លាំងរវាងឈ្មោះ ឈុំ ច័ន្ទី និង ម៉ម សារឿន ក្រោមការដឹកនាំរបស់ លោក ញ៉ឹក សាត នាយករដ្ឋបាល។ លទ្ធផលៈ ភាគីទាំងពីរ មិនសះជាគ្នា។

- បានចូលរួមក្នុងការប្រជុំសាកសួរ និងសម្រុះសម្រួលចំនួនពីរលើកករណីវិវាទដីធ្លីមួយកន្លែងស្ថិតនៅភូមិទឹកឃ្លាំង ឃុំទឹកឃ្លាំង រវាងឈ្មោះ ស៊ុន ផល និង ស៊ុន ផាន ក្រោមការដឹកនាំរបស់ លោក ញ៉ឹក សាត នាយករដ្ឋបាល ។ លទ្ធផលៈ ភាគីទាំងពីរ មិនទាន់សះជា។

- បានចូលរួមក្នុងការប្រជុំសាកសួរ និងសម្រុះសម្រួលករណីវិវាទដីធ្លីមួយកន្លែងស្ថិតនៅភូមិពោធិ៍ធំ ឃុំអរិយក្សត្រ រវាងឈ្មោះ ពុធ សុធា តេង សុគន្ធ និងឈ្មោះ សេង សេម ក្រោមការដឹកនាំរបស់ ,លោក ញ៉ឹក សាត នាយករដ្ឋបាល ។ លទ្ធផលៈ ភាគីទាំងពីរ មិនសះជាគ្នា។

- បានចូលរួមជាមួយ លោក កន សុខកាយ អភិបាលរងស្រុក ក្នុងកិច្ចប្រជុំសាកសួរពាក់ព័ន្ធនឹងសំណើសុំដកពាក្យបណ្តឹងរបស់ឈ្មោះ អ៊ុន ចាន់ និង សៅ ហៀម គណៈកម្មការវត្ត និងជាតំណាងចៅអធិការវត្ត និងពុទ្ធបរិស័ទចំណុះជើងវត្ត សារិកាកែវ ដែលស្ថិតនៅភូមិពោធិ៍ធំ ឃុំអរិយក្សត្រ ដែលបានប្តឹងគ្រូបង្រៀនបឋមសិក្សាពោធិ៍ធំចំនួន០៥នាក់។ លទ្ធផលៈ ភាគីទាំងពីសះជា ហើយដើមបណ្តឹងឯកភាពដកពាក្យបណ្តឹងបញ្ចប់វិវាទ។

- បានចូលរួមក្នុងការប្រជុំសាកសួរ និងសម្រុះសម្រួលករណីបណ្តឹងរវាងឈ្មោះ វង្ស បុប្ផាហូ គឹមឈៀ , (ចុងបណ្តឹង) និងឈ្មោះ ជា ចំរើន (ដើមបណ្តឹង) ស៊ុយ ណាក់ ,ងពាក់ព័ន្ធករណីសង់សំណង់បង្កឲ្យបាក់ស្រុតផ្ទះអ្នកជិតខាង ស្ថិតក្នុងភូមិអរិយក្សត្រ ឃុំអរិយ្យក្សត្រ ក្រោមការដឹកនាំរបស់លោក ញ៉ឹក សាត នាយករដ្ឋបាល។ លទ្ធផលៈ ភាគីទាំងពីរ មិនសះជាគ្នា។

- បានចូលរួមក្នុងការប្រជុំសាកសួរ និងសម្រុះសម្រួលករណីវិវាទដីធ្លីមួយកន្លែង ស (ចំណុចដីជុះ)ស្ថិតក្នុងភូមិពោធិ៍ធំ ឃុំអរិយក្សត្រ រវាងឈ្មោះ អ៊ួន ណារី និងឈ្មោះ ឆាយ អ៊ុន ក្រោមការដឹកនាំរបស់លោក ញ៉ឹក សាត នាយករដ្ឋបាល។ លទ្ធផលៈ ភាគីទាំងពីរ មិនសះជាគ្នា។

- បានចូលរួមក្នុងការប្រជុំសាកសួរ និងសម្រុះសម្រួលករណីសំណើសុំបើកផ្លូវទបង្ហូរទឹកឡើងវិញ ស្ថិតក្នុងភូមិតាដោ ឃុំសារិកាកែវ ក្រោមការដឹកនាំរបស់ លោក ញ៉ឹក សាត នាយករដ្ឋបាល។ លទ្ធផលៈ ភាគីទាំងពីរ មិនសះជាគ្នា។

- បានចូលរួមក្នុងការប្រជុំសម្រុះសម្រួលលើកទីពីរករណីវិវាទព្រំដីស្ថិតក្នុងភូមិទួលមាស ឃុំអរិយក្សត្រ រវាងឈ្មោះ សួន ហ៊ិនឡា-សៀក សុខជា ក្រោមការដឹកនាំ (ចុងបណ្តឹង) និងឈ្មោះ ស៊ឹម បុរី (ដើមបណ្តឹង) ដោយលោក ញ៉ឹក សាត នាយករដ្ឋបាល។ លទ្ធផលៈ ភាគីទាំងពីរនៅតែមិនទាន់សះជាគ្នា។

- បានចូលរួមក្នុងការប្រជុំសម្រុះសម្រួលករណីវិវាទផ្លូវទេះ ស្ថិតនៅភូមិព្រែកតាអុងទី១ ឃុំពាមឧកញ៉ាអុង រវាងឈ្មោះ ម៉ែន ច័ន្ទរិទ្ធិ និងឈ្មោះ ហោ ហេង ក្រោមការដឹកនាំដោយ លោក ញ៉ឹក សាត នាយករដ្ឋបាល។ លទ្ធផលៈ ភាគីទាំងពីរ មិនសះជាគ្នា។

- បានចូលរួមក្នុងការប្រជុំសាកសួរ និងសម្រុះសម្រួលករណីវិវាទកម្មសិទ្ធិដីធ្លី ស្ថិតនៅភូមិព្រែកក្រូច ឃុំភូមិធំ រវាង ឈ្មោះ លឹម ថៃ និង ឈុំ ធុន ក្រោមការដឹកនាំរបស់ លោក ញ៉ឹក សាត នាយករដ្ឋបាល។ លទ្ធផលៈ ភាគីទាំងពីរ មិនសះជាគ្នា។

**តារាងទី១៣ ៖ ការសម្រុះសម្រួលទំនាស់**

| ល.រ | ការបរិយាយ | ចំនួន | | |
|---|---|---|---|---|
| | | ដើមគ្រា | ក្នុងគ្រា | បូកយោង |
| ១ | ករណីដែលបានសម្រុះសម្រួលបញ្ចប់ដោយរដ្ឋបាលក្រុងស្រុក | ២៦ | ០១ | ២៧ |
| ២ | ករណីដែលបានបញ្ជូនទៅស្ថាប័នពាក់ព័ន្ធ | ០៤ | ០០ | ០៤ |
| សរុប | | ៣០ | ០១ | ៣១ |

**១.៨.៨. កិច្ចការច្រកចេញចូលតែមួយ** (សម្រាប់ក្រុង ស្រុក ដែលមានការិយាល័យច្រកចេញចូលតែមួយ)

នៅដើមសប្តាហ៍ទី១ខែមេសា ឆ្នាំ២០១៩ រដ្ឋបាលស្រុកបានដាក់ឲ្យដំណើរការយន្តការច្រកចេញចូលតែមួយ ដើម្បីផ្តល់សេវា ជូនប្រជាពលរដ្ឋ។ ការអនុវត្តយន្តការច្រកចេញចូលតែមួយគឺស្របតាមអនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ របស់រាជរដ្ឋាភិបាលកម្ពុជា និងសេចក្តីណែនាំលេខ០០១ សណន ចុះថ្ងៃពុធ ៣រោច ខែបុស្ស ឆ្នាំច សំរឹទ្ធិ ស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៩ របស់ក្រសួងមហាផ្ទៃ ។

ថ្ងៃសុក្រ ១៥កើត ឆ្នាំកុរ ឯកស័ក ព ស២៥៦៣ ត្រូវនឹងថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩ អង្គភាពយន្តការច្រកចេញចូលតែមួយក្រោមការដឹកនាំរបស់លោកស្រី រ៉ែន កន្និកា អភិបាលរងស្រុក និងមានសមាសភាពចូលរួម លោកប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ មន្ត្រីអង្គភាពយន្តការច្រកចេញចូលតែមួយវិស័យពាណិជ្ជកម្ម វិស័យទេសចរណ៍ និងរួមសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច បានចុះពិនិត្យទីតាំងស្តុកយ័រម្ហូប កន្លែងដែលស្ថិតនៅភូមិអរិយក្សត្រ ឃុំអរិយក្សត្រ ដើម្បីណែនាំដល់អាជីវករមកធ្វើច្បាប់អាជីវកម្មនៅយន្តការច្រកចេញចូលតែមួយ។

យន្តការច្រកចេញចូលតែមួយស្រុកល្វាឯម បានផ្តល់សេវាជូនអតិថិជនគិតចាប់ពីខែ សីហា ដល់ខែធ្នូ ឆ្នាំ២០១៩នេះ បានចំនួន ២,៩១១នាក់ ស្រី ១,១០០ នាក់ ក្នុងនោះមាន ១០ សេវា ចំណូលសរុបមាន

៣១,៥៨៥,០០០ រៀល (សាមសិបមួយលានប្រាំរយប៉ែតសិបប្រាំពាន់រៀលគត់) ក្នុងនោះមានវិស័យ វិស័យសុរិយាដី ៧៩.៨% វិស័យសុខាភិបាល ៤.២% វិស័យអប់រំ ១.៩% វិស័យសំណង់ ៣.៧ % វិស័យរ៉ែ និងថាមពល ០% វិស័យវប្បធម៌ ១.៦% វិស័យកសិកម្ម ០.០៦% វិស័យទេសចរណ៍ ០.៨% វិស័យពាណិជ្ជកម្ម ០.៧%វិស័យឧស្សាហកម្ម និងសិប្បកម្ម ០% វិស័យសាធារណការ០% វិស័យការងាររដ្ឋបាល ១.៩% វិស័យនីត្យានុកូលដ្ឋាន ៥.២% វិស័យអត្រានុកូលដ្ឋាន ០%។

តារាងទី១៤ ៖ កិច្ចការច្រកចេញចូលតែមួយ

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | សេវាសរុបដែលបានផ្តល់ចប់សព្វគ្រប់ | ២,៩១១ |
| ២ | ប្រជាពលរដ្ឋសរុបដែលបានទទួលសេវា | ២,៩១១ |
| ៣ | ប្រជាពលរដ្ឋជាស្ត្រីដែលបានទទួលសេវា | ១,១០០ |
| ៤ | ចំណូលដែលទទួលបានពីការផ្តល់សេវា | ៣១,៥៨៥,០០០ |
| ៥ | ករណីបណ្តឹងដែលទទួលបានសរុប | ០ |
| ៦ | ករណីបណ្តឹងដែលបានដោះស្រាយរួចជាស្ថាពរ | ០ |

### ១.៤.៥. កិច្ចការសេវាសង្គម និងការបង្កើនសិទ្ធិអំណាចស្ត្រី

តារាងទី១៥ ៖ ការអនុវត្តសកម្មភាពសេវាសង្គម និងការងាររបស់ គ.ក.ស.ក

| ល.រ. | សូចនាករ | ផែនការប្រចាំឆ្នាំ | លទ្ធផលសម្រេច | |
|---|---|---|---|---|
| | | | ជាក់ស្តែង | % |
| ១ | ចំនួនកិច្ចប្រជុំប្រចាំខែរបស់ គ.ក.ស.ក នៅថ្នាក់ក្រុង ស្រុក | ១២ | ១០ | ៨៣ |
| ២ | ចំនួនថវិកាប្រចាំឆ្នាំសម្រាប់ចំណាយលើផ្នែកសេវាសង្គម (រៀល) | ៧.៥២៤០០០. | ១.៧៥០.០០០ | ២៣ |
| ៣ | ក្រុង ស្រុកបានចងក្រងទិន្នន័យអត្រានុកូលដ្ឋាន ដែលទទួលបានពីឃុំសង្កាត់ | ០ | ០ | ០ |
| ៤ | ចំនួនបេសកកម្មដែល គ.ក.ស.ក ក្រុង ស្រុកបានចុះគាំទ្រ និងផ្តល់សេវាសង្គម | ១៩៥លើក | ១៤១លើក | ៧២ |
| ៥ | ចំនួនឃុំសង្កាត់ដែល គ.ក.ស.ក ក្រុង ស្រុក បានចុះគាំទ្រ | ១៥ | ១៥ | ១០០ |
| ៦ | ចំនួនវគ្គបណ្តុះបណ្តាលដែល គ.ក.ស.ក ក្រុង ស្រុកបានទទួល | ១ | ១ | ១០០ |

## ១.៥.ការងារហិរញ្ញវត្ថុ៖

### ១.៥.១.ការអនុវត្តចំណូល និងចំណាយ៖

-ក្នុងឆ្នាំ២០១៩នេះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានឧបត្ថម្ភតុល្យភាពថវិកា៤ត្រីមាស ដល់រដ្ឋបាលស្រុកចំនួន1,700.0100,000រៀល ហើយក្នុងនោះរដ្ឋបាលក៏ទទួលបានចំណូលពីការផ្តល់សេវា ចំនួន 96,660,000រៀល ដូច្នេះចំណូលរួមពីការឧបត្ថម្ភធននិងពីការផ្តល់សេវា សរុបរួមមានចំនួន 1,796,670,000រៀល ។

-រដ្ឋបាលស្រុកបានធ្វើការចំណាយទូទាត់ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភក្រុមប្រឹក្សាស្រុកចាប់ពីខែមករា ដល់ខែធ្នូ សរុបទឹកប្រាក់ 817,719,020រៀល និងបានធ្វើការទូទាត់ចំណាយទៅលើលទ្ធកម្មសំណង់ចំនួន៣គម្រោង លទ្ធកម្មទំនិញប្រេងឥន្ធនៈប្រើប្រាស់ឆ្នាំ២០១៩ និងទូទាត់ទិញគ្រឿងសង្ហារឹម និងបានទូទាត់រដ្ឋទេយ្យ៤ជុំ ថវិកាចំនួន 791,745,700រៀល(ជំពូក60,61,62) ចំណាយថវិកាសរុបរួមមានចំនួន 1,609,464,720 រៀលគត់។

តារាងទី១៦ ៖ ការអនុវត្តចំណូល និងចំណាយ

| ជំពូក | ចំណាត់ថ្នាក់ | អនុម័ត | ជាក់ស្តែង | ភាគរយ |
|---|---|---|---|---|
| ផ្នែកចំណូល | | | | |

| ជំពូក | ចំណាត់ថ្នាក់ | អនុម័ត | ជាក់ស្តែង | ភាគរយ |
|---|---|---|---|---|
| ៧០ | ចំណូលសារពើពន្ធ | 0 | 0 | 0% |
| ៧២ | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | 0 | 0 | 0% |
| ៧៣ | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ-និងសេវា | 50,990,000 | 96,660,000 | 175% |
| ៧៤ | ផលពីការពិន័យ និងការដាក់ទណ្ឌកម្ម | 0 | 0 | 0% |
| ៧៥ | ការឧបត្ថម្ភកធន | 1,700,010,000 | 1,700,010,000 | 100% |
| ៧៦ | ផលហិរញ្ញវត្ថុ | 0 | 0 | 0% |
| ៧៧ | ផលផ្សេងៗ និងផលពិសេស | 0 | 0 | 0% |
| ៧៨ | ការងារនៃរដ្ឋទេយ្យ | 0 | 0 | 0% |
| ០៨ | ចំណូលមូលនិធិបម្រុង | 0 | 0 | 0% |
| ១៣ | ឧបត្ថម្ភធនវិនិយោគ | 0 | 0 | 0% |
| | សរុបចំណូល | 1,751,000,000 | 1,796,670,000 | 102% |
| ផ្នែកចំណាយ | | | | |
| ៦០ | ការទិញ | 50,770,000 | 50,770,000 | 100% |
| ៦១ | សេវាខាងក្រៅ | 727,800,000 | 716,045,700 | 98.38% |
| ៦២ | អត្ថប្រយោជន៍សង្គម | 26,170,000 | 24,930,000 | 95,30% |
| ៦៣ | ពន្ធ និងអាករ | 0 | 0 | 0% |
| ៦៤ | បន្ទុកបុគ្គលិក | 946,260,000 | 817,719,020 | 95,50% |
| ៦៥ | ឧបត្ថម្ភកធន | 0 | 0 | 0% |
| ៦៦ | បន្ទុកហិរញ្ញវត្ថុ | 0 | 0 | 0% |
| ៦៧ | បន្ទុកពិសេស | 0 | 0 | 0% |
| ៦៨ | ទាយជ្ជទានឱ្យដល់រំលស់អចលកម្មរូបី | 0 | 0 | 0% |
| ៦៩ | ចំណាយមិនបានគ្រោងទុក | 0 | 0 | 0% |
| ២០ | អចលកម្មអរូបី | 0 | 0 | 0% |
| ២១ | អចលកម្មរូបី | 0 | 0 | 0% |
| | សរុបចំណាយ | 1,751,000,000 | 1,609,464,720 | 91,91% |

### ១.៥.២.ការគ្រប់គ្រងទ្រព្យសម្បត្តិ៖

ឆ្នាំ២០១៩នេះរដ្ឋបាលស្រុកបានទិញគ្រឿងសង្ហារឹម (តុមានរបាំងចំនួន ០១ឈុត, ទូដាក់ឯកសារចំនួន ០១គ្រឿង, កៅអីវង់ចាំចំនួន ០១គ្រឿង និងកៅអីការិយាល័យចំនួន ០៤គ្រឿង) ដោយប្រើប្រាស់ (មូលនិធិស្រុកឆ្នាំ២០១៩) ចំនួន ៧,៣៣៥,០០០រៀល។

**តារាងទី១៧ ៖ ការគ្រប់គ្រងទ្រព្យសម្បត្តិ**

| ល.រ. | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | ទ្រព្យសម្បត្តិ ដែលបានទិញ ឬទទួល (ថ្មី) | ៧ |
| ២ | ទ្រព្យសម្បត្តិ ដែលបានកាត់ចេញ | ០ |

### ១.៦. ការធានាលទ្ធកម្ម

បានអនុវត្តកិច្ចលទ្ធកម្មចំនួន ០៥គម្រោង រួមមានលទ្ធកម្មសំណង់ចំនួន ០៣គម្រោងង និងលទ្ធកម្មទំនិញចំនួន ០២គម្រោង ដែលចំណាយអស់ទឹកប្រាក់សរុបចំនួន ៤២០,៩៦៣,១០០រៀល (បួនរយម្ភៃប្រាំបួនរយហុកសិបបីពាន់មួយរយរៀលគត់) ដែលក្នុងនោះមានដូចខាងក្រោម៖

**១.លទ្ធកម្មសំណង់ចំនួន០៣គម្រោង ទឹកប្រាស់ចំនួន ៣៩៤,៣៤១,៧០០រៀល**

- ពិគ្រោះថ្លៃស្តីពីការងារជួសជុលផ្លូវបេតុងអាមេ២ ខ្សែប្រវែង១៦៧ម៉ែត្រ ក្នុងនោះខ្សែទី១ ប្រវែង៩០ម៉ែត្រទទឹង៥ម៉ែត្រ កម្រាស់០,១៥ម៉ែត្រ នៅភូមិអរិយក្សត្រ ឃុំអរិយក្សត្រ និងខ្សែទី២ ប្រវែង៧៧ម៉ែត្រ ទទឹង៥ម៉ែត្រកម្រាស់០,១៥ម៉ែត្រ ភូមិពាមតាឯក ឃុំពាមឧកញ៉ាអុង ស្រុកល្វាឯមដោយប្រើប្រាស់ (អតិរេក ឆ្នាំ២០១៨) ចំនួន ៩៥,៩៨០,៨០០រៀល ។

- ដេញថ្លៃស្តីពីការងារជួសជុលផ្លូវបេតុងអាមេ១ខ្សែប្រវែង៣៥០ម៉ែត្រ ទទឹង៥ម៉ែត្រ កម្រាស់០,១៥ម៉ែត្រ នៅភូមិអរិយក្សត្រ ឃុំអរិយក្សត្រ ដោយប្រើប្រាស់(មូលនិធិស្រុកឆ្នាំ២០១៩)ចំនួន១៩១,៨៦០,៩០០រៀល ។

- ដេញថ្លៃស្តីពីការងារជួសជុលផ្លូវបេតុងអាមេ១ ខ្សែប្រវែង១៨៤ម៉ែត្រ ទទឹង៥ម៉ែត្រ កម្រាស់០,១៥ម៉ែត្រ នៅភូមិពាមតាឯក ឃុំពាមឧកញ៉ាអុង ដោយប្រើប្រាស់ មូលនិធិគុណប្រយោជន៍ខេត្តឆ្នាំ២០១៩ ចំនួន ១០៦,៥០០,០០០រៀល ។

**២.លទ្ធកម្មទំនិញចំនួន០២គម្រោង ទឹកប្រាក់ចំនួន២៦,៦២១,៤០០រៀល**

- ពិគ្រោះថ្លៃស្តីពីការផ្គត់ផ្គង់ប្រេងឥន្ធនៈសម្រាប់ប្រើប្រាស់ឆ្នាំ២០១៩ ដោយប្រើប្រាស់ (មូលនិធិស្រុកឆ្នាំ២០១៩) ចំនួន ១៩,២៨៦,៤០០រៀល។

- ស្ទង់តម្លៃស្តីពីសង្ហារឹម (តុមានរបាំងចំនួន ០១ឈុត, ទូដាក់ឯកសារចំនួន ០១គ្រឿង, កៅអីវង់ចាំចំនួន ០១គ្រឿង និងកៅអីការិយាល័យចំនួន ០៤គ្រឿង) សម្រាប់ឆ្នាំ២០១៩ ជូនសាលាស្រុកល្វាឯម ដោយប្រើប្រាស់ (មូលនិធិស្រុកឆ្នាំ២០១៩) ចំនួន ៧,៣៣៥,០០០រៀល។

## ផ្នែកទី២
## ការងាររដ្ឋបាលឃុំសង្កាត់

### ២.១. ការងាររដ្ឋបាលឃុំ សង្កាត់

**២.១.១.ស្ថិតិក្រុមប្រឹក្សាឃុំ-សង្កាត់ និងបុគ្គលិក:**

| ល.រ | ការបរិយាយ | សរុប | ស្រី |
|---|---|---|---|
| ១ | សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ | 85 | 16 |
| ២ | សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានផ្លាស់ប្តូរ | 4 | 0 |
| ៣ | មេឃុំ ចៅសង្កាត់ | 15 | 1 |
| ៤ | ជំទប់ទី១ ចៅសង្កាត់រងទី១ | 15 | 0 |
| ៥ | ជំទប់ទី២ ចៅសង្កាត់រងទី២ | 15 | 5 |
| ៦ | ស្មៀនឃុំ សង្កាត់ | 15 | 2 |
| ៧ | បុគ្គលិកកិច្ចសន្យា | 43 | 22 |
| ៨ | មេភូមិ | 43 | 2 |
| ៩ | អនុប្រធានភូមិ | 43 | 2 |
| ១០ | សមាជិកភូមិ | 43 | 39 |
| ១១ | អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារដែលមិនមែនជាសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ | 3 | 3 |

| | | | |
|---|---|---|---|
| ១២ | ជនបង្គោលតាមដានត្រួតពិនិត្យ និងវាយតម្លៃឃុំ សង្កាត់ | 30 | 15 |

២.១.២.ដីកា សេចក្តីសម្រេច និងលិខិត

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | ដីកាដែលបានដាក់ចេញ | 0 |
| ២ | សេចក្តីសម្រេចដែលបានដាក់ចេញ | ១៣៩ |
| ៣ | លិខិតរដ្ឋបាលដែលបានដាក់ចេញ | ១៣៤២៧ |
| ៤ | លិខិតដែលបានទទួល | ៤៧២ |

២.១.៣.កិច្ចប្រជុំក្រុមប្រឹក្សាឃុំ-សង្កាត់ និងគ.ក.ន.ក

- ការិយាល័យផែនការនិងគាំទ្រឃុំបានតាមដានកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ រួចធ្វើរបាយការណ៍ផ្ញើទៅទីចាត់ការផែនការវិនិយោគខេត្តជារៀងរាល់ខែ។

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សា | ១៨០ |
| ២ | កិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សា | ៥២ |
| ៣ | កិច្ចប្រជុំសម្ងាត់របស់ក្រុមប្រឹក្សា | 0 |
| ៤ | កិច្ចប្រជុំ គ.ក.ន.ក | ១៦៥ |

២.១.៤. គម្រោងវិនិយោគដែលមានការសន្យាគាំទ្រដោយថវិកាឃុំ-សង្កាត់:

| ល.រ | ផ្នែក | ចំនួនគម្រោង | តម្លៃគម្រោង |
|---|---|---|---|
| ១ | សេដ្ឋកិច្ច | 16 | 1,677,870,118៛ |
| ២ | សង្គមកិច្ច | 75 | 138,591,873៛ |
| ៣ | ធនធានធម្មជាតិ និងបរិស្ថាន | 0 | 0 |
| ៤ | សេវាកម្មរដ្ឋបាល និងសន្តិសុខ | 0 | 0 |
| ៥ | យេនឌ័រ | 0 | 0 |
| សរុប | | 91 | 1,816,461,991៛ |

២.១.៥. ការអនុវត្តគម្រោងឃុំ-សង្កាត់:

| ល.រ | ផ្នែក | សរុប | ស្ថានភាពនៃការអនុវត្ត | | |
|---|---|---|---|---|---|
| | | | មិនទាន់ | កំពុង | បញ្ចប់ |
| ១ | សេដ្ឋកិច្ច | 16 | 3 | 07 | 3 |
| ២ | សង្គមកិច្ច | 75 | | | 75 |
| ៣ | ធនធានធម្មជាតិ និងបរិស្ថាន | 0 | 0 | 0 | 0 |
| ៤ | សេវាកម្មរដ្ឋបាល និងសន្តិសុខ | 0 | 0 | 0 | 0 |
| ៥ | យេនឌ័រ | 0 | | | √ |

| សរុប | 91 | 3 | 07 | 75 |
|---|---|---|---|---|

២.១.៦.ការអនុវត្តថវិកាឃុំ-សង្កាត់:

| ល.រ | ការបរិយាយ | អនុម័ត | ជាក់ស្តែង | ភាគរយ |
|---|---|---|---|---|
| ១ | ចំណូលសរុប | 4.557.210.978 ៛ | 3.559.397.217៛ | 78.10% |
| ២ | ចំណាយសរុប | 4.557.210.978 ៛ | 2.636.221.288៛ | 58.84% |

២.១.៧.ការគ្រប់គ្រងទ្រព្យសម្បត្តិឃុំ-សង្កាត់

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | ទ្រព្យសម្បត្តិឃុំសង្កាត់ដែលបានទិញឬទទួល (ថ្មី) | ១០២ |
| ២ | ទ្រព្យសម្បត្តិឃុំ សង្កាត់ដែលបានកាត់ចេញ | 0 |
| ៣ | ទ្រសម្បត្តិឃុំ សង្កាត់សរុប | ១០២ |

២.១.៨.ការអភិវឌ្ឍសមត្ថភាព:

| ល.រ | ឈ្មោះវគ្គសិក្សា | ចំនួនថ្ងៃ | អ្នកចូលរួម | | រៀបចំដោយ |
|---|---|---|---|---|---|
| | | | សរុប | ស្រី | |
| ១ | វគ្គបណ្តុះបណ្តាលស្តីពីការរៀបចំបិទបញ្ជីថវិកាឃុំឆ្នាំ២០១៨ និងរៀបចំគម្រោងថវិកាឆ្នាំ២០១៩ | ១ថ្ងៃ | ៤៧ | ១៩ | រតនាគារខេត្ត |
| ២ | វគ្គបណ្តុះបណ្តាលស្តីពីតួនាទី ភារកិច្ចរបស់គកសក និងគកនក | ១ថ្ងៃ | ៤៥ | ១៦ | សាលាខេត្ត |
| ៣ | វគ្គបណ្តុំបណ្តាលស្តីពីជំរឿន | ៣ថ្ងៃ | ១២៩ | ៤៩ | មន្ទីរផែនការ |
| ៤ | វគ្គបណ្តុះបណ្តាលស្តីពីយេនឌ័រ និងសុខភាពភ្នែក | ៣ថ្ងៃ | ៦០ | ២២ | មន្ទីរកិច្ចការនារី |
| ៥ | វគ្គបណ្តុះបណ្តាលស្តីពីរៀបចំផែនការសកម្មភាពនិងថវិកាលើវិស័យសេវាសង្គម | ១ថ្ងៃ | ១៥ | ១៥ | សាលាខេត្ត+រតនាគារខេត្ត |
| ៦ | វគ្គបណ្តុះបណ្តាលស្តីពីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ | ២ថ្ងៃ | ៦០ | ១៥ | សាលាស្រុក |
| ៧ | វគ្គបណ្តុះបណ្តាលស្តីពីការបន្សាំទៅនិងការបម្រែបម្រួលអាកាសធាតុ | ១ថ្ងៃ | ៤៥ | ១៧ | សាលាខេត្ត |
| ៨ | វគ្គបណ្តុះបណ្តាលស្តីពីការរម្លឹកឡើង ស្តីពីរបៀបកត់ត្រាការងារអគ្រានុកូលដ្ឋាន | ២ថ្ងៃ | ៤៥ | ០៣ | សាលាខេត្ត |
| ៩ | វគ្គបណ្តុះបណ្តាលស្តីពីសៀវភៅណែនាំការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ | ១ថ្ងៃ | ៤៨ | ២២ | សាលាខេត្ត |
| ១០ | វគ្គបណ្តុះបណ្តាលស្តីពីការរម្លឹកឡើងវិញសៀវភៅណែនាំ ស្តីពីគម្រោងមូលនិធិឃុំសង្កាត់ | ១ថ្ងៃ | ៤៧ | ១៧ | សាលាខេត្ត |
| ១១ | វគ្គបណ្តុះបណ្តាលស្តីពីការពង្រឹងអំណាចផ្ទាល់ខ្លួន | ២ថ្ងៃ | ១៥ | ១ | សមាគមន៍ក្រុមប្រឹក្សា |
| ១២ | វគ្គបណ្តុះបណ្តាលស្តីពីស្តីពីដំណើរការប្រមូលទិន្នន័យភូមិ ឃុំ | ១ថ្ងៃ | ៧៣ | ៤ | សាលាស្រុក |

| ១៣ | វគ្គបណ្ដុះបណ្ដាលស្ដីពី សៀវភៅប្រតិបត្តិគោល និងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងពត៌មាន សម្រាប់កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះនិងកុមារអាយុក្រោម២ឆ្នាំ | ២ថ្ងៃ | ៧៥ | ៤៥ | មន្ទីរសង្គមកិច្ច+សាលាខេត្ត |
|---|---|---|---|---|---|
| ១៤ | វគ្គបណ្ដុះបណ្ដាលស្ដីពី បរិយាប័ន្ន និងសមធម៌សង្គម | ១ | ៣២ | ១២ | សាលាស្រុក |

២.១.៩.សកម្មភាពសេវាសង្គម:

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | មគ្គុទ្ទេសក៍សិក្សាសហគមន៍កំពុងដំណើរការដែលគាំទ្រពីឃុំ សង្កាត់ | 20=21ថ្នាក់ |
| ២ | គ្រួសារងាយរងគ្រោះគាំទ្រពីឃុំ សង្កាត់សម្រាប់កែលម្អអនាម័យការលាងដៃនឹងសាប៊ូ | 5 |
| ៣ | គ្រួសារងាយរងគ្រោះគាំទ្រពីឃុំ សង្កាត់ដើម្បីទទួលបានទឹកស្អាតប្រើប្រាស់ | 46 |
| ៤ | គ្រួសារងាយរងគ្រោះគាំទ្រពីឃុំ សង្កាត់ដើម្បីទទួលបានបង្គន់អនាម័យប្រើប្រាស់ | 52 |
| ៥ | គ្រួសារងាយរងគ្រោះដែលឃុំ សង្កាត់ចុះកំណត់អត្តសញ្ញាណ | 1786 |
| ៦ | ស្ត្រីរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារដែលទទួលការគាំទ្រពីឃុំ-សង្កាត់ | 0 |

២.១.១០.ការសម្រុះសម្រួលទំនាស់:

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | ករណីដែលបានសម្រុះសម្រួលបញ្ចប់ដោយឃុំ-សង្កាត់ | 158 |
| ២ | ករណីដែលបានបញ្ជូនទៅស្ថាប័នពាក់ព័ន្ធ | 12 |

២.១.១១.ការងារអត្រានុកូលដ្ឋាន:

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | សំបុត្រកំណើត | 1519 |
| ២ | សំបុត្របញ្ជាក់កំណើត | 907 |
| ៣ | សេចក្តីចម្លងសំបុត្រកំណើត | 860 |
| ៤ | សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត | 331 |
| ៥ | សំបុត្រអាពាហ៍ពិពាហ៍ | 349 |
| ៦ | សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ | 216 |
| ៧ | សំបុត្រមរណភាព | 357 |
| ៨ | សេចក្តីចម្លងសំបុត្រមរណភាព | 157 |

២.១.១២.ការចុះឈ្មោះ និងការពិនិត្យបញ្ជីឈ្មោះអ្នកបោះឆ្នោត:

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | ប្រជាពលរដ្ឋដែលបានចុះឈ្មោះថ្មី | 433 |
| ២ | ប្រជាពលរដ្ឋដែលត្រូវបានលុបឈ្មោះចេញពីបញ្ជីឈ្មោះអ្នកបោះឆ្នោត | 137 |
| ៣ | ប្រជាពលរដ្ឋសរុបដែលមានឈ្មោះបោះឆ្នោត (ចាស់និងថ្មី) | 49.845 |

២.២.បញ្ហាប្រឈមដែលរដ្ឋបាលឃុំ-សង្កាត់បានជួបប្រទះ:

| ល.រ | បញ្ហាប្រឈមសំខាន់ៗ | សំណើដំណោះស្រាយ |
|---|---|---|
| ១ | ផ្លូវក្នុងឃុំមិនទាន់បាលល្អប្រសើរ(ឃុំកោះរះ) | ជួសជុលផ្លូវដី ស ៣៨០០ម និងជួសជុលផ្លូវបេតុង៣ខ្សែ ៩១០ម |
| ២ | ស្ពានតូចចង្អៀត(កោះរះ) | សាងសង់ស្ពានថ្មី(៣០មX៨ម) |
| ៣ | ទឹកលិចផ្ទះប្រជាពលរដ្ឋពេលរដូវវស្សា(កោះរះ) | ដាក់លូរំដោះទឹក |

# ផ្នែកទី៣
# ការងាររបស់ការិយាល័យ អង្គភាពជំនាញ

## ៣.១. សេដ្ឋកិច្ច

### ៣.១.១.ការងារកសិកម្ម

*១)- ស្ថានភាពធម្មជាតិ:*

\+ ស្ថានភាពទឹកភ្លៀង:

ទឹកភ្លៀងក្នុងមួយឆ្នាំមានភ្លៀងធ្លាក់ចំនួន៣៥លើក ដែលមានកម្ពស់ ១២៩៦,៩ ម.ម។ ធៀបរយៈពេលដូចគ្នានិងឆ្នាំ២០១៨ ទាបជាង១៩៤,៤ម.ម។

*២)- ការងារបង្កបង្កើនផល*

ក-ដំណាំស្រូវ:

\+ ក្ដួររាស់សរុប= ៧៨៨៧ហ.ត

\+ស្រូវអនុវត្តបានចំនួន ៧៨៦៩ហ.ត ក្នុងនោះ ស្រូវប្រាំងអនុវត្តបានចំនួន ៧០១៤ ហ.ត ស្រូវវស្សាអនុវត្តបានចំនួន ៨៥៥ ហ.ត។

ខ-ដំណាំអនុផល:

\- ពោតក្រហម: អនុវត្តបាន ១៣៩៩ ហ.ត (ស្មើនឹង៩៨,៦៦%នៃផែនការ)សណ្តែក អនុវត្តបាន ២៦ ហ.ត បន្លែចំរុះ អនុវត្តបាន ១១៦ ហ.ត (ស្មើនឹង៨៧,៨៧%នៃផែនការ) .ម្ទេស: ៨ ហ.ត ស្លឹកគ្រៃ: ២៥០ ហ.ត .ចេក: ៤៥ ហ.ត ល្ហុង ៧៣ ហ.ត ឈូក ៧៦៨ ហ.ត (ស្មើនឹង១០០%នៃផែនការ) ដំណាំស្វាយកែវរមៀត ៧៧៤ហ.ត=១១១ ០២៤ដើម .ដូង: ២៣ ហ.ត ល្មុត០៤ហ.ត និងដំណាំរួមផ្សំផ្សេងៗ ២៣ ហ.ត ។

គ-ការប្រមូលផល

\- ការប្រមូលផលស្រូវលើផ្ទៃដីចំនួន ៧៨៦៩ ហ.ត បរិមាណផលសរុប ៣២,៦៧៩តោន

\- ពោតការប្រមូលផលលើផ្ទៃដីចំនួន ១៣៩៩ហ.ត មានបរិមាណផលសរុប ៥៥៩៦តោន។

*៣)-ការងារគម្រោងអភិវឌ្ឍន៍កសិកម្ម និងជំរុញកំណើនសេដ្ឋកិច្ច(PADEE)*

\- ធ្វើផែនការមុខរបរសមាជិកក្រុម ដើម្បីខ្ចីទុនប្រកបមុខរបរបន្ត

\- សមាជិកក្រុមកែលម្អទុនបង្វិលបានអនុវត្តបង់ការប្រាក់ដល់ក្រុមបានទៀងទាត់ប្រចាំខែ។

\- ក្រុមកែលម្អទុនបង្វិលទាំង២៤ក្រុមមានការកើនឡើង នៃសាច់ប្រាក់ក្នុងក្រុមតាមរយៈការប្រាក់ប្រចាំខែរបស់សមាជិកក្រុមដែលបានធ្វើការកម្ចីប្រកបមុខរបរកសិកម្ម ចន្លោះពី៦៨លានរៀលទៅ៧៨លានរៀលរបស់ក្រុមនីមួយ ដោយធៀបនឹងសាច់ប្រាក់ដើមមានចំនួនត្រឹមតែ៤៨លានរៀលក្នុងមួយក្រុមៗ (អត្រាកើន៧៧%ក្នុងរយៈពេល៥ឆ្នាំ)

*៤)-កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់នឹងការប្រែប្រួលអាកាសធាតុ (ASPIRE)*

- មន្ត្រីកសិកម្មស្រុកបានសហការជាមួយ មន្ត្រីការិយាល័យផ្សព្វផ្សាយកសិកម្មខេត្តនិងភ្នាក់ងារផ្សព្វផ្សាយឃុំរៀបចំជ្រើសរើសកសិករចងក្រងក្រុមបណ្តុំចំនួន១២ ក្នុងនោះមាននៅឃុំបឹងគ្រំ ៣បណ្តុំ ពោត២ ស្រូវ១ ឃុំកោះកែវមាន៣បណ្តុំបន្លែ ឃុំសំបួរ មាន១បណ្តុំស្រូវ ឃុំព្រែកឫស្សី១បណ្តុំស្រូវ ឃុំសារិកាកែវ២បណ្តុំចិញ្ចឹមមាន់ស្រែ ឃុំពាមឧកញ៉ាអុង២បណ្តុំមាន់ស្រែ ។

*៥)-ការងារបសុព្យាបាល:*

- មន្ត្រីផ្នែកបសុព្យាបាល បានអញ្ជើញភ្នាក់ងារផ្សព្វផ្សាយឃុំប្រជុំប្រចាំខែ លទ្ធផលគឺ៖

+ ចំនួនគោសរុបៈ ៣,៥៣៣ ក្បាល ក្នុងនោះ បាចំនួន ២៨ក្បាល .គោ៣ឆ្នាំឡើងឈ្មោលសរុប ៤១ក្បាល គោ៣ឆ្នាំឡើងញី សរុប ២,៣១៧ក្បាល គោ៣ឆ្នាំចុះឈ្មោល សរុប ៥០៧ក្បាល គោ៣ឆ្នាំចុះញី សរុប ៦៤០ក្បាល កម្លាំងអូសទាញ សរុប ៤១ក្បាល

+ ក្របីសរុបៈ ២៤៦ ក្បាល ក្នុងនោះ ក្របី៣ឆ្នាំឡើងឈ្មោលសរុប ៤០ក្បាល ក្របី៣ឆ្នាំឡើងញីសរុប ១០៨ក្បាល ក្របី៣ឆ្នាំចុះឈ្មោលសរុប ៤៥ក្បាល ក្របី៣ឆ្នាំចុះញីសរុប ៥៣ក្បាល កំលាំងអូសទាញ សរុបៈ ១៥៣ ក្បាល

+ សេះ សរុប ១៧ ក្បាល ញី ១០ ក្បាល
+ ជ្រូកសរុបៈ ៦៧៩ ក្បាល ក្នុងនោះមេ១២៤ក្បាល, សាច់៣១៨ ក្បាល, កូន២៣៧ក្បាល
+ ពពែសរុបៈ១,១១៣ ក្បាល
+ មាន់សរុបៈ ៥៦,៤៨២ ក្បាល
+ ទាសរុបៈ ៣០៤ ក្បាល ក្នុងនោះ ទាពង៦១ ក្បាល, ទាកាប៉ា ២៤៣ ក្បាល។
+ ក្ងាន ៣៥ ក្បាល។

➢ ការចាក់វ៉ាក់សាំងជ្រូកៈ

| ប្រភេទវ៉ាក់សាំង | ប៉េស្ត | សារទឹក | សាម៉ូ | អូហ្សេស្គី | រាគ | កញ្ជិល | ជាតិដែក | ផ្លូវដង្ហើម |
|---|---|---|---|---|---|---|---|---|
| ចំនួនសត្វ | ៦៩៥ | ៤១០ | ២៨៥ | ៦៩៥ | ៦៩៥ | ៦៩៦ | ៦៩៥ | ៤៧៩ |

➢ ការចាក់វ៉ាក់សាំងសត្វស្លាបៈ

| ប្រភេទវ៉ាក់សាំង | ញូកាស | អាសន្នរោគ | អុតបក្សី |
|---|---|---|---|
| ចំនួនសត្វ | ៣,១៧៥ | ២,៦២៥ | ២,៤៥០ |

➢ ការចាក់វ៉ាក់សាំងគោ-ក្របី៖

+ ផ្នែកពសុព្យាបាលបានសហការ ជាមួយភ្នាក់ងារសុខភាពសត្វភូមិចាក់វ៉ាក់សាំង គោ ក្របី ក្នុងនោះ៖

| ប្រភេទសត្វ | ប្រភេទវ៉ាក់សាំងសារទឹក | ប្រភេទវ៉ាក់សាំងអុចក្តាម |
|---|---|---|
| គោ | ០ ក្បាល | ០ ក្បាល |
| ក្របី | ០ ក្បាល | ០ ក្បាល |
| សរុប | ០ ក្បាល | ០ ក្បាល |

➢ សត្វឈឺនិងព្យាបាលសត្វ ក្នុងនោះមានៈ

+ គោ ១១៧ ក្បាល(ងាប់០១ក្បាល)
+ ក្របី ១២ ក្បាល(ងាប់០២ក្បាល)
+ ជ្រូក ២៤៦ ក្បាល(ងាប់១១២ក្បាល)

*៦)-សកម្មភាពផ្សេងៗ*

- ដឹកនាំកសិករ៤រូប និងភ្នាក់ងារផ្សព្វផ្សាយឃុំ១រូប ទៅធ្វើទស្សនៈកិច្ចសិក្សារយៈពេល១ថ្ងៃ ស្តីពីការចិញ្ចឹមមាន់ស្រុកនៅស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង។

**៣.១.២-ការងារផែនការ**

- បានទៅរៀនវគ្គបណ្តុះបណ្តាល គ្រូបង្គោល ២វគ្គ នៅមន្ទីរផែនការខេត្ត។
- ធ្វើសៀវភៅទិន្នន័យ ស្រុក និងប្រមូលសៀវភៅទិន្នន័យ ភូមិ ឃុំ ត្រួតពិនិត្យរួចបញ្ជូនទៅមន្ទីរផែនការខេត្ត។
- បានបើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីសម្ភាសន៍ និងមន្ត្រីត្រួតពិនិត្យ ជំរឿនប្រជាជនចំនួន២វគ្គ៖

វគ្គ១៖ចាប់ពីថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៩នៅសាលាបឋមសិក្សាពោធិមាស សរុបៈ ១១៧នាក់

វគ្គ២៖ចាប់ពីថ្ងៃទី១៨ដល់ថ្ងៃទី២១ខែកុម្ភៈ ឆ្នាំ២០១៩ នៅសាលាវិទ្យាល័យល្វាសរ សរុប១០៦នាក់

- ចាប់ពីថ្ងៃទី២៨ ខែកុម្ភៈ ដល់ថ្ងៃទី០២ ខែមិនា ឆ្នាំ២០១៩ ធ្វើបច្ចុប្បន្នភាពគូសផែនទី និងតារាង"ក"។
- ចាប់ពីថ្ងៃ០៣ ខែមិនា ធ្វើជំរឿនទូទៅ សម្ភាសន៍បំពេញតារាងខ រហូតដល់ថ្ងៃទី១៣ ខែមិនា ឆ្នាំ២០១៩ ត្រូវបញ្ចប់ការសម្ភាសន៍។
- ថ្ងៃទី១៤ ខែមិនា ប្រមូលឯកសារ ពីមន្ត្រីសម្ភាសន៍មកផ្ទៀងផ្ទាត់ រួចបំពេញទម្រង់បែបបទ រួចបញ្ជូនឯកសារទៅក្រសួង។
- បានប្រជុំនៅមន្ទីរផែនការខេត្ត រួចទទួលឯកសារព័ត៌មានស្ថានភាព ស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ២០១៩ របស់ស្រុក និងឃុំរួចបែងចែកអោយតាមបណ្តាលឃុំ។
- ជ្រើសរើសមន្ត្រីទទួលបន្ទុកឃុំ ៥នាក់ និងមន្ត្រីខេត្ត ០១នាក់ប្រចាំស្រុកត្រៀមធ្វើអត្តសញ្ញាណកម្ម គ្រួសារក្រីក្រអាណត្តិទី៤។
- បានទៅរៀនវគ្គបណ្តុះបណ្តាល អត្តសញ្ញាណកម្មគ្រួសារក្រីក្រចំនួន៣ថ្ងៃ នៅមន្ទីរផែនការខេត្ត
- បានស្រង់តារាងស្ថិតិ សហគមន៍ ទិន្នន័យឆ្នាំ២០១៩ មាន១៤សហគមន៍៖ សហគមន៍កសិកម្ម ៨ និងសហគមន៍នេសាទចំនួន៨។
- បើកវគ្គបណ្តុះបណ្តាល នីតិវិធីអត្តសញ្ញាណគ្រួសារក្រីក្រនៅថ្នាក់ស្រុករយពេល៣ថ្ងៃ សរុប១០៣នាក់ ស្រី១២នាក់ ចែកចេញជា២ថ្នាក់៖

  + ថ្នាក់ទី១៖ មានសមាជិក ៥៤នាក់, ស្រី០៧នាក់
  + ថ្នាក់ទី២៖ មានសមាជិក ៤៩នាក់, ស្រី០៥នាក់

- បើកវគ្គបំប៉នអត្តសញ្ញាណកម្មគ្រួសារក្រីក្រដល់ គ.ផ.ថ ចំនួន០១ថ្ងៃដែលមានសមាជិកចូលរួម ៤៥នាក់ ស្រី០៩នាក់។
- ចុះតាមដានជ្រើសរើសក្រុមតំណាងភូមិ
- ចុះតាមដានការបើកវគ្គបណ្តុះបណ្តាល ក្រុមតំណាងភូមិ តាមឃុំ
- បានចុះតាមដានការចេងក្រងបញ្ជីគ្រួសារក្នុងភូមិ សម្រាប់ធ្វើអត្តសញ្ញាណកម្មគ្រួសារក្រីក្រ
- បានចុះតាមដានការសម្ភាសន៍
- បានចុះតាមដានការបូកសរុបពិន្ទុ និងរៀបចំ បញ្ជីព្រាងចំណាត់ថ្នាក់គ្រួសារក្រីក្រ

– ចុះតាមដានប្រជុំពិគ្រោះយោបល់ក្នុងភូមិ ស្តីពីបញ្ជីព្រាងគ្រួសារក្រីក្រចុងក្រោយ

– ការងារអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ត្រូវបានបញ្ចប់នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលមានគ្រួសារសរុបៈ ១៧,៩៧៧គ្រួសារ ក្នុងនោះមនុស្សមានៈ ៧៥,៣៤០នាក់ស្រី៣៨,៨១២នាក់ បានជ្រើសរើសគ្រួសារត្រូវសម្ភាសន៍ចំនួន ៤,០៥២គ្រួសារ=២២,៥៣% បានទទួលលទ្ធផល ដាប់៖

+ ក្រ១ចំនួន ៣០៦គ្រួសារ = ១,៧០%

+ ក្រ២ចំនួន ៣០៦គ្រួសារ = ១,៧០%

➢ សរុបក្រ១ក្រ២ ១,៧៨៦គ្រួសារ ស្មើរនិង៩,៩៣% បើប្រៀបធៀបក្នុងឆ្នាំ២០១៦ អត្រាភាពក្រីក្រ ១៣,៥២% ឆ្នាំ២០១៩ ថយចុះ ៣,៥៩%។

– បានបើកវគ្គបណ្តុះបណ្តាលរំលឹកទិន្នន័យឡើងលវិញនៅសាលប្រជុំសាលាស្រុក មានសមាសភាពចូលរួម មេឃុំ មេភូមិ ស្មៀន សរុប ៧០នាក់ ស្រី០៦នាក់។

– បានបូករបាយការណ៍ ស្ថានភាពប្រែប្រួល ប្រជាជនប្រចាំខែក្នុងឆ្នាំ២០១៩ ទាំង១២ខែ។

**៣.១.៣-ការងារពន្ធដារៈ**

– បានចុះប្រមូលពន្ធបង់ចូលថវិកាជាតិរយៈពេល ១២ ខែបានទឹកប្រាក់ចំនួនៈ ៨៥,៨៦៣,១៦៧រៀល បើប្រៀបធៀបផែនការឆ្នាំស្មើ ៥៣,៥០ ភាគរយ នៃផែនការឆ្នាំ ២០១៩ ដែលមានទឹកប្រាក់ចំនួនៈ១៦០,៥០០,០០០រៀល។

**៣.១.៤.ការងារអភិវឌ្ឍន៍ជនបទៈ**

– បានចូលរួមសហការជាមួយមន្ទីរអភិវឌ្ឍន៍ជនបទខេត្តចុះសិក្សាផ្លូវបានចំនួន៣ឃុំ៖

+ ឃុំទឹកឃ្លាំងមានចំនួន ៣ខ្សែ

+ ឃុំបឹងគ្រំមានចំនួន ២ខ្សែ

+ ឃុំសំបួរមានចំនួន ៣ខ្សែ

➢ សរុប ០៨ខ្សែ ស្មើ ១២១០០ម៉ែត្រ

– បានចូលរួមសហការជាមួយគណៈកម្មការស្រុក ចុះសម្រួលបើកផ្លូវបេងវត្តសុវណ្ណសាគរ នៅឃុំអរិយក្សត្រ ក្រោមការដឹកនាំដោយលោក យី យ៉េន អភិបាលរងស្រុក។

– បានចូលរួមសហការណ៍ជាមួយការិយាល័យពាក់ព័ន្ធ ចុះសិក្សាអំពីបញ្ហាទំនប់ទឹកស្ថិតនៅ ភូមិ៣មស្តី ឃុំព្រែកឬស្សី ក្រោមការដឹកនាំដោយ លោក យី យ៉េន អភិបាលរងស្រុក។

– បានសហការណ៍ជាមួយក្រសួងមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ចុះសិក្សាគម្រោងផ្លូវបេតុង ០១ខ្សែមានប្រវែង១០Km ស្ថិតនៅក្នុង ឃុំភូមិធំ និងឃុំព្រែករៃ ដែលជាគម្រោងរបស់សាធារណៈរដ្ឋកូរ៉េ។

– បានសហការណ៍ជាមួយគណៈកម្មការស្រុក និងអាជ្ញាធរ ភូមិ-ឃុំ ចុះបើកផ្លូវ ០១ខ្សែប្រវែង ១៦០០ម៉ែត្រ និងទទឹង២០ម៉ែត្រ ស្ថិតនៅក្នុងឃុំកោះរះ និង៣មខកញ៉ាអុង ក្រោមការដឹកនាំដោយលោក កន សុខកាយ អភិបាលរងស្រុក។

– បានចូលរួមជាមួយគណៈកម្មការស្រុក ចុះសិក្សាផ្លូវ និងលូ ស្ថិតនៅក្នុងឃុំ៣មខកញ៉ាអុង ក្រោមការដឹកនាំដោយ លោក គីម ភីរ៉ា អភិបាលស្រុក និងមានកាចូលរួមដោយលោក កន សុខកាយ អភិបាលរងស្រុក និងការិយាល័យពាក់ព័ន្ធ។

- បានចុះពិនិត្យមើលបណ្តាញទឹក(អូរី) និងបានជម្រាបជូនប្រធានក្រុមហ៊ុនធ្វើយ៉ាងណាឲ្យសម្អាតធុងទឹកឲ្យបានស្អាត និងលក់ជូនប្រជាពលរដ្ឋឲ្យបានតម្លៃទាប នៅក្នុងឃុំទឹកឃ្លាំង និងឃុំបឹងគ្រុំ។

- បានសហការណ៍ជាមួយក្រសួងអភិវឌ្ឍន៍ជនបទ ចុះកំណត់ទីតាំងខ្នងផ្ទះគ្រួសារ ក្រ១-ក្រ២ ទាំងអស់ដែលគ្មានលទ្ធភាពតភ្ជាប់បណ្តាញទឹកស្អាតនៅក្នុងឃុំព្រៃកប្បាស លទ្ធផលសម្រេចបានៈ

  + គ្រួសារសរុប =១៧៣៥គ្រួសារ
  + ខ្នងផ្ទះ សរុប =១៣៣៧ ខ្នងផ្ទះ
  + គ្រួសារក្រ១ សរុប = ៩៧គ្រួសារ
  + គ្រួសារក្រ២ សរុប = ២២២គ្រួសារ

- បានចូលរួមសហការណ៍ជាមួយមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ចុះសិក្សាវាស់វែងកំណត់ផ្លូវ ០១ខ្សែ ប្រវែង 20Kmដែលជាគម្រោង(RID4CAM) ស្ថិតនៅក្នុងឃុំព្រៃកប្បាស សមាសភាពអញ្ជើញចូលរួមមានៈ លោក ជួន តារាពង្ស នាយករងរដ្ឋបាលសាលាស្រុក និងអាជ្ញាធរ ភូមិ-ឃុំ។

- បានចូលរួមសហការណ៍ជាមួយមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត និងម្ចាស់គម្រោងចុះសិក្សាកម្ពស់ទឹក (ណេវ៉ូទឹក) និងប្រជាពលរដ្ឋរស់នៅអបសងខាងផ្លូវនៅឃុំព្រៃកប្បាស ក្រោមការដឹកនាំដោយ លោក ហឿន ទ្រី អនុប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត។

- បានចូលរួមសហការណ៍ជាមួយលោកប្រធាន និងសមាជិកក្រុមប្រឹក្សាស្រុកចុះពិនិត្យស្ថានភាពផ្លូវ ស្ពាន បានចំនួន ០៣ឃុំ រួមមាន ឃុំល្វាសរ ឃុំព្រៃកប្បាស ឃុំសំបួរ ក្រោមការដឹកនាំដោយលោក សែម សោភ័ក្តិ ប្រធានក្រុមប្រឹក្សាស្រុក។

- បានចូលរួមវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពគណៈកម្មធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ) បានចំនួន៤វគ្គ ១០ឃុំ ស្មើ២៨ភូមិ អ្នកចូលរួមសរុប១៤០នាក់, ស្រី៥៦នាក់ ក្រោមការដឹកនាំដោយលោក សួស សុវណ្ណនី អនុប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត។

- បានចូលរួមសហការណ៍ជាមួយក្រសួង មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត និងម្ចាស់គម្រោងចុះសិក្សាផ្លូវ ០១ខ្សែប្រវែង 10Km ស្ថិតនៅក្នុងឃុំភូមិធំ និងឃុំព្រៃក្រៃ ក្រោមការដឹកនាំដោយ លោកស្រី ជី ថារី ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត និងអាជ្ញាធរ ភូមិ-ឃុំ។

- បានចូលរួមសហការណ៍ជាមួយគណៈកម្មការស្រុកចុះពិនិត្យគម្រោងពង្រីកស្ពាន ហនុមាន នៅឃុំអរិយក្សត្រ ក្រោមការដឹកនាំដោយ លោក គឹម គីរ៉ា អភិបាល នៃគណៈអភិបាលស្រុក ការិយាល័យពាក់ព័ន្ធ និងអាជ្ញាធរ ភូមិ-ឃុំ។

- បានចូលរួមសហការណ៍ជាមួយក្រសួងអភិវឌ្ឍន៍ជនបទ ចុះជំរុញគ្រួសារ ក្រ១-ក្រ២ ដើម្បីភ្ជាប់បណ្តាញទឹកស្អាត នៅក្នុងឃុំព្រៃកប្បាស។

**៣.១.៦.ការងារជលផល**

*១).ស្ថានភាពទឹកៈ*

- ទឹកនៅក្នុងស្រុកល្វាឯម ឆ្នាំ២០១៩ មានកំរិតកម្ពស់ទាបជាងឆ្នាំ២០១៨ ០,៥ម៉ែត្រ

- ហើយទឹកដងទន្លេមេគង្គក្រោមចាប់ឡើងចូលព្រែកនៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៩ រយៈពេល២៥ថ្ងៃតែប៉ុណ្ណោះ ចាប់ផ្តើមហូរចេញពីបឹងវិញ។

*២).ការងារវារីវប្បកម្មៈ*

- ការចិញ្ចឹមត្រីឆ្តោតាមស្រះ មានចំនួន ៤៩គ្រួសារ

- ការចិញ្ចឹមត្រីឆ្តោតាមបែរ មានចំនួន ២៣គ្រួសារបច្ចុប្បន្នកំពង់ដំណើរការ នៃការចិញ្ចឹម។

*៣).ការងារសហគមន៍នេសាទ:*

- សហគមន៍នេសាទនៅក្នុងស្រុក មានចំនួន០៧៖
  + សហគមន៍នេសាទ ឃុំសារិកាកែវ
  + សហគមន៍នេសាទ ឃុំពាមឧកញ៉ាអុង
  + សហគមន៍នេសាទ ឃុំព្រែកក្មេង
  + សហគមន៍នេសាទ ឃុំបារុង
  + សហគមន៍នេសាទ ឃុំបឹងគ្រំ
  + សហគមន៍នេសាទ ឃុំកោះកែវ(មានបញ្ជីការ)
  + សហគមន៍នេសាទ ឃុំសំបួរ

*៤).ស្ថិតិត្រីប្រចាំឆ្នាំ២០១៩*

- ប្រភេទត្រីលេខ 1 = 13,5តោន
- ប្រភេទត្រីលេខ 2 = 32,5តោន
- ប្រភេទត្រីលេខ 3= 171តោន
  - ➢ បើយើងប្រៀបធៀបឆ្នាំ២០១៨ ទៅនិងឆ្នាំ២០១៩(ឆ្នាំ២០១៩ ថយចុះ៣៥%)

+ ផលកែច្នៃ
  - ត្រីឆ្អើ = ២,៥តោន
  - ប្រហុក = ៦តោន
  - ប្រអក = ២តោន
  - ទឹកត្រី = ២ម៉ឺនលីត្រ សិប្បកម្មទឹកត្រីមានមួយកន្លែងនៅឃុំសារិកាកែវ

*៥).ការការពារប្រភពធនធានជលផល:*

+ បានសហការជាមួយគណៈបញ្ជាការឯកភាពស្រុកល្វាឯម សម្រេចបានលទ្ធផលរួមមាន
  - លូស្បៃមុង ចំនួន ៣២០មាត់លូ
  - ព្រួលស្បៃមុង ប្រវែង៨៥៣០ម៉ែត្រ
  - បង្គោលចំរុះចំនួន ៣៣៥៥ដើម
  - លែងត្រីចំរុះចំនួន ៤៩២Kg
    - ➢ សរុប= ១២ករណី
    - ➢ ១០ករណី ដុតបំផ្លាញចោល
    - ➢ ២ករណីបញ្ជូនមកតុលាការមាន៖
      + ទូកស្នាច់ ៤គ្រឿង
      + ម៉ាស៊ីន៤គ្រឿង
      + អាគុយ ៨គ្រឿង
      + អាំងវែទ័រ ៦គ្រឿង
      + ដងឆក់ ៦ គូរ

## ៣.២. សង្គមកិច្ច

### ៣.២.១-ការងារសង្គមកិច្ច និង អតីតយុទ្ធជន

១).*ការងារសង្គមកិច្ច:*

– បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីច្បាប់យុត្តិធម៌អនីតិជន រយៈពេល០២ថ្ងៃនៅមន្ទីរ សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តកែប។

– បានសហការណ៍ជាមួយអាជ្ញាធរឃុំ ព្រែកឬស្សី បញ្ជូនកុមារចំនួន២នាក់ (មូលហេតុ ម្តាយកុមារទាំងពីរមានជីវភាពក្រីក្រខ្លាំង) ទៅរស់នៅក្នុងមណ្ឌលថែទាំកុមារ ផ្ទះខ្លារ៉ា ដើម្បីទទួលបានការស្នាក់នៅសមរម្យនិងរៀនសូត្រ។

– បានធ្វើពិធីចែកអំណោយផ្តល់មកពីមន្ទីរសង្គមកិច្ចខេត្តជូនគ្រួសារក្រីក្រខ្វះខាតស្បៀងចំនួន ៣០ គ្រួសារក្រោមអធិបតីភាពលោកស្រី រ៉ែន កន្និកា អភិបាលរងស្រុក ដែលក្នុង១គ្រួសារទទួលបាន៖ អង្ករ ៣០ kg , មី១កេះ, ត្រីខ១យួ, ទឹកស៊ីអ៊ីវ១យួ និងថវិការ ៥០,០០០៛។

– បានចុះធ្វើអធិការកិច្ចនៅមណ្ឌលកុមារកំព្រាបេះដូងតូច ស្ថិតនៅភូមិ ទួលតាមាស ឃុំអរិយក្សត្រ ដែលសព្វថ្ងៃមណ្ឌលកំពុងទទួលកុមារឱ្យស្នាក់នៅចំនួន ៣៦នាក់, ស្រី១៧។ ជាលទ្ធផលកុមារទាំងអស់នោះបានទទួលការរៀនសូត្រ និងថែទាំយ៉ាងយកចិត្តទុកដាក់ពីមណ្ឌល។

– បានសហការណ៍ជាមួយអង្គការ និងមណ្ឌលកុមារកំព្រា (អង្គការមេត្រីអន្តរជាតិ បុរីទារក) បញ្ជូនកុមារចំនួន ០៣នាក់ឱ្យបានរៀនសូត្រ និងស្នាក់នៅសមរម្យ។

– បានធ្វើសមាហរណកម្មកុមារចំនួន ០២នាក់ ភេទស្រី ឲ្យមករស់នៅជួបជុំគ្រួសារវិញស្ថិតនៅ ភូមិតាស្គរ ឃុំសារិកាកែវ ស្រុកល្វាឯម បន្ទាប់ពីកុមារទាំងពីរ ទទួលការថែទាំ អប់រំរៀនសូត្រពីអង្គការរួចមក ។

២).*ការងារអតីតយុទ្ធជន:*

– បានស្រាវជ្រាវមុខសញ្ញាអតីតយុទ្ធជនដែលមានជីវភាពក្រីក្រ មានដី គ្មានផ្ទះ ចំនួន ៧គ្រួសារ ដើម្បីស្នើសុំផ្ទះជូនពួកគាត់។

– គណៈអភិបាលស្រុក និងក្រុមការងារគណៈកម្មាធិការសមាគមអតីតយុទ្ធជនបាននាំយកប្រាក់បេឡាមរណៈសង្គ្រោះសមាគមអតីតយុទ្ធជន ជូនដល់គ្រួសារសពជាសមាជិកសមាគមអតីតយុទ្ធជនចំនួន ៦ គ្រួសារ ដែលក្នុងមួយគ្រួសារទទួលបានថវិការចំនួន៤.០០០.០០០៛ និងថវិការពីគណៈអភិបាលចំនួន ២០០.០០០៛, អង្ករ៥០kg ១បាវ, មី១កេះ, ទឹកក្រូច១កេះ, ទឹកសុទ្ធ១កេះ និងលិខិតមរណៈទុក្ខ១សន្លឹក ។

– បានរៀបចំសំណុំឯកសារស្នើសុំប្រាក់មរណៈសង្គ្រោះចំនួន ៦ គ្រួសារ ។

– កសាងឯកសារស្នើសុំប្រាក់ជានារ៉ាប់រង និងបូជាសព ជូនគ្រួសារសពអតីតយុទ្ធជន១គ្រួសារ ។

– ក្រុមការងារគណៈកម្មាធិការសមាគមអតីតយុទ្ធជនកម្ពុជាបានសាងសង់ផ្ទះចំនួន ៥ ជូនដល់អតីតយុទ្ធជនក្នុងស្រុកល្វាឯម។

– បានសហការណ៍ជាមួយគណៈកម្មាធិការសមាគមអតីតយុទ្ធជនដឹកនាំអតីតយុទ្ធជនចំនួន ២០ នាក់ទៅចូលរួមខួបលើកទី១២ ទិវាអតីតយុទ្ធជនកម្ពុជា។

– តាមដាន និងត្រួតពិនិត្យសមាជិកសមាគមអតីតយុទ្ធជនមានចំនួនសរុប ១៨៧នាក់ ៖

+ ជនពិការចំនួន ៧៩នាក់
+ គ្រួសារជនមរណៈចំនួន ២នាក់
+ និវត្តជនចំនួន ២០នាក់ នាក់

+ គ្រួសារជនពលីចំនួន ៨៣ នាក់

+ ជនបាត់បង់សម្បទាវិជ្ជាជីវៈចំនួន ៤នាក់ ។

៣). *ការងារមនុស្សចាស់:*

– ប្រមូលរបាយការណ៍សមាគមមនុស្សចាស់ជាប្រចាំខែ។

– បានចុះពង្រឹងសមាគមនៅឃុំសារិកាកែវ, ពាមឧកញ៉ាអុង, កោះរះ, ថ្មគរ,ទឹកឃ្លាំង បឹងគ្រំ,ល្វាស , កោះកែវ, សំបួរ, ព្រែកឬស្សី, ព្រែករំរៃ និងបារុង។

– បានប្រជុំពិភាក្សាស្តីពីដំណើរការការងារសមាគមមនុស្សចាស់តាមបណ្តាឃុំនីមួយៗបញ្ហាប្រឈម និង ដំណោះស្រាយ ក្រោមអធិបតីភាពលោកអភិបាលស្រុក។

– បូកសរុបបញ្ជីចំណូល -ចំនាយរបស់សមាគមប្រចាំឆ្នាំ២០១៩មានដូចខាងក្រោមៈ

- សមាគមមាន ១៥ ឃុំ សមាជិកសរុប ៦,២០០ នាក់
- ប្រាក់ចំណូលសរុបចំនួន ៧៩,៦១៩,៥០០០៛
- ប្រាក់ចំនាយសរុបចំនួន ៥៧,១៨៨០០០៛ៈ

  ក-ចំនាយលើការងាររដ្ឋបាលចំនួន ១,៥០៨,០០០៛

  ខ-ចំនាយឧបត្ថម្ភអ្នកជំងឺចំនួន ៣០ នាក់ ទឹកប្រាក់ ២,៨០០,០០០៛

  គ-ចំនាយមរណៈសង្គ្រោះចំនួន ១២៣នាក់ ទឹកប្រាក់ ៥២,៨៨០,០០០៛

  ឃ- ប្រាក់នៅសល់សរុបក្នុងបេឡាសមាគមទូទាំងស្រុកមាន ១១៤,៤១២,៤០០៛

**៣.២.២-ការងារអប់រំ យុវជន និង កីឡា:**

-បានចែកប័ណ្ណ ប.ស.ស លោកគ្រូ អ្នកគ្រូ ចំនួន៤៦៨ប័ណ្ណ នៅខ្វះចំនួន ១២២ នាក់ មិនទាន់បានទទួល និងចេញលិខិតបញ្ជាក់កែទិន្នន័យចំនួន ២នាក់ ។

-បានទទួលថវិកាឧបត្ថម្ភកម្មវិធីកាកបាទក្រហម និងអឌ្ឍចន្ទក្រហម ពីសាលាទាំង ៣កម្រិតជូនមន្ទីរអប់រំខេត្តប្រចាំឆ្នាំ២០១៩ ចំនួន ៤,៧០០,០០០រៀល ។

-បានផ្ទៀតផ្ទាត់បញ្ជីបើកប្រាក់បៀវត្សន៍ ៤៨០ នាក់ ស្រី ២៣៤ នាក់ ។

-បានទទួលគ្រូចេញថ្មី បឋមចេញថ្មី ០៧ នាក់ ស្រី ០៤នាក់ ។

-បានទទួលប្រាក់អាហារូបករណ៍ពីក្រសួង ផ្តល់ជូនសិស្សក្រីក្ររៀនពូកែនៅសាលាចំណេះទូទៅបឋម និងមធ្យម ចំនួន ២៧០,២៤០.០០០រៀល ។

-បានបែងចែកសៀវភៅសិក្សាគោលដល់សាលាទូទាំងស្រុកចំនួនទាំង ៣លើកសរុបចំនួន ១៨៩២ ក្បាល ។

-បានជ្រើសរើសសិស្សពូកែថ្នាក់ទី ១២ ចំនួន ១១៣នាក់ ចូលរួមប្រឡងថ្នាក់ជាតិ ០១ នាក់ ថ្នាក់ខេត្ត ១៤នាក់ និងថ្នាក់ស្រុក ៩៨នាក់ ។

-បានចូលរួមសន្និបាទ ៣លើក, ថ្នាក់ខេត្ត ២លើក ក្រសួង ១លើក អ្នកចូលរួមចំនួន២៧នាក់ ស្រី៧នាក់ ។

-បានប្រជុំពង្រឹងការងារដល់នាយក ទាំង ៣កម្រិតបាន ១២លើក អ្នកចូលរួមសរុបចំនួន ៣៥៤ នាក់ ស្រី៨៩នាក់ ។

-បានចុះពិនិត្យតាមដានការងាររៀននិងបង្រៀនបានចំនួន៦៧លើកនៅសាលាបឋមនិងមត្តេយ្យសិក្សា ។

-បានបញ្ជូនយុវជនកាយរឹទ្ធិ កាកបាទក្រហមទៅចូលរួមបោះជុំរុំថ្នាក់ខេត្ត ៣លើក ថ្នាក់ជាតិ ១លើក អ្នកចូលរួមសរុបចំនួន ៤៧នាក់ ស្រី ១២នាក់ និងបានចូលរួមគោរពទង់ជាតិជាមួយរដ្ឋបាលស្រុក រៀងរាល់ថ្ងៃចន្ទ ចំនួន ១០នាក់ រាល់សប្តាហ៍ ។

-បានរៀបចំក្រុមប្រឹក្សាកុមារ និងយុវជន គ្រប់សាលាទូទាំងស្រុក ។

-បានទទួលម្ជុកសុវត្ថិភាពចំនួន ៣០០ ពី ស.ស.យ.ក ស្រុកចែកជូនដល់យុវជនទាំង ៣ វិទ្យាល័យក្នុងស្រុក ។

-បានប្រកួតកីឡាចំនួន ២លើក នៅថ្នាក់ស្រុក ១លើក និងថ្នាក់ខេត្ត ១លើក ៖

+ថ្នាក់ស្រុកលេខ១ ផ្នែកបាល់ទាត់ បានទៅវិ.ហស ពាមឧកញ៉ាអុង ។

+ថ្នាក់ខេត្ត ផ្នែកបាល់ទាត់បានចំណាត់ថ្នាក់លេខ២ វិ.ហស ពាមឧកញ៉ាអុង ។

-បានទទួលថវិកាពីឯកឧត្តម ផាន់ ផល្លា ឧបត្ថម្ភដល់អ្នកគ្រូឆ្លងទន្លេចំនួន ៣២នាក់ ក្នុងម្នាក់ ៥០ម៉ឺនរៀល,គ្រូឈឺចំនួន ២៥ នាក់ ក្នុងម្នាក់ ២០ ម៉ឺនរៀល និង ឧបត្ថម្ភលោក ព្រំ ពឿន ចំនួន ៤លានរៀល, គ្រូទទួល

មរណៈភាពចំនួន ០៣នាក់ ក្នុងម្នាក់ ៥០ម៉ឺនរៀល ។

-បានឧបត្ថម្ភកម្មវិធី ៨មីនា ជូនអ្នកគ្រូ ២៨៧នាក់ ក្នុងម្នាក់៥ម៉ឺនរៀល និងក្រណាត់ប៉ាក់ចំនួន ២៨៧ ដុំ។

-បានចូលរួមវគ្គបណ្តុះបណ្តាល, វគ្គសិក្ខាសាលា,វគ្គបំប៉នកុមារតូចនៅថ្នាក់ស្រុក ខេត្ត និងក្រសួង ចំនួន ៩លើក អ្នកចូលរួមសរុប ១៧៩នាក់ ស្រី ២៤នាក់ ។

*☆-លទ្ធផលប្រឡង*

១/ថ្នាក់ទី៣ មានបេក្ខជនប្រឡងសរុបចំនួន ១,៨៨២ នាក់ ស្រី ៨៤១ នាក់ ក្នុងនោះជាប់មធ្យមភាគសរុបចំនួន ១,៥៧៤ នាក់ គិតជាភាគរយស្មើនឹង ៨៣.៦៣% ស្រីជាប់សរុបចំនួន ៧២៣ នាក់ គិតជាភាគរយស្មើនឹង ៨៥.៩៧% ។

២/ថ្នាក់ទី៦ មានបេក្ខជនប្រឡងសរុបចំនួន ១,៧៥៩ នាក់ ស្រី ៨១៦ នាក់ ក្នុងនោះជាប់មធ្យមភាគសរុបចំនួន ១,៤៨៨ នាក់ គិតជាភាគរយស្មើនឹង ៨៤.៥៩% ស្រីជាប់សរុបចំនួន ៧១៧ នាក់ គិតជាភាគរយស្មើនឹង ៨៧.៨៧% ។

-បានប្រឡងឆមាសលើកទី២ បឋមសិក្សា និងមធ្យមសិក្សា ឆ្នាំសិក្សា ២០១៨-២០១៩ ៖

*☆-លទ្ធផលប្រឡង*

១/បឋមសិក្សា ថ្នាក់ទី ៥ និងថ្នាក់ទី៦ មានបេក្ខជនប្រឡងសរុបចំនួន ៣,១៥៥នាក់ ស្រី ១,៥៧១នាក់ ក្នុងនោះជាប់មធ្យមភាគសរុបចំនួន ២,៦២០ នាក់ គិតជាភាគរយស្មើនឹង ៨៣.០៤% ស្រីជាប់សរុបចំនួន ១,៣៦៨នាក់ គិតជាភាគរយស្មើនឹង ៨៧.០៧% ។

២/ប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ មានបេក្ខជនប្រឡងសរុបចំនួន ៧៦៨ នាក់ ស្រី ៤០៩ នាក់ ប្រឡងជាប់មធ្យមភាគសរុបចំនួន ៧៣៨ នាក់ គិតជាភាគរយស្មើនឹង ៩៦.០៩% ស្រីជាប់ចំនួន ៤០៤ នាក់ គិតជាភាគរយស្មើនឹង ៩៨.៧៧% ។

-បានប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សម័យប្រឡង ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ២០១៩

*☆-លទ្ធផលប្រឡង*

| ល.រ | ឈ្មោះសាលា | បេក្ខជន | | ប្រឡងជាប់ | | ប្រឡងធ្លាក់ | | និទ្ទេស | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | A | | B | | C | | D | | E | |
| | | ស.រ | ស | ស.រ | ស | ស.រ | ស | ស.រ | ស | ស.រ | ស | ស.រ | ស | ស.រ | ស | ស.រ | ស |
| 1 | វិ.ហស.ពាមខ្វកញ៉ាអុង | 127 | 70 | 119 | 64 | 8 | 6 | 0 | 0 | 4 | 1 | 11 | 6 | 39 | 24 | 65 | 33 |
| 2 | វិ.ហស.ទឹកឃ្លាំង | 138 | 72 | 102 | 58 | 36 | 14 | 0 | 0 | 3 | 1 | 6 | 3 | 19 | 11 | 74 | 43 |
| 3 | វិ.ហស.ល្វាស | 114 | 61 | 100 | 58 | 14 | 3 | 0 | 0 | 4 | 1 | 11 | 6 | 22 | 17 | 63 | 34 |
| **សរុប** | | **379** | **203** | **321** | **180** | **58** | **23** | **0** | **0** | **11** | **3** | **28** | **15** | **80** | **52** | **202** | **11(** |

ឞគិតជាភាគរយសិស្សប្រឡងជាប់សរុបស្មើនឹង ៨៤.៧០% ស្រី ៨៨.៦៦ % (ប្រៀបធៀបនឹងឆ្នាំសិក្សា ២០១៧-២០១៨ ថយ ១.៦៧ %)

-សិស្សប្រឡងជាប់សញ្ញាបត្រ មធ្យមសិក្សាទុតិយភូមិ បានទទួលអាហារូបករណ៍ របស់ឯកឧត្តមបណ្ឌិត

**អួន ព័ន្ធមុនីរ័ត្ន** ចំនួន ៤៨នាក់ ស្រី ២៧ នាក់ ។

-ធ្វើស្ថិតិសិស្ស ថ្នាក់ នៅសាលាបឋមសិក្សា សម្រាប់ឆ្នាំសិក្សា ២០១៩-២០២០ ក្នុងស្រុកមាន៖

+ថ្នាក់ទី១ សរុបចំនួន ៥៥ ថ្នាក់ សិស្សសរុប ១៨២១ នាក់ ស្រី ៨៥២ នាក់ ។

+ថ្នាក់ទី២ សរុបចំនួន ៥៣ ថ្នាក់ សិស្សសរុប ១៨០៣ នាក់ ស្រី ៨៧៨ នាក់ ។

+ថ្នាក់ទី៣ សរុបចំនួន ៥០ ថ្នាក់ សិស្សសរុប ១៦៧៧ នាក់ ស្រី ៧៧០ នាក់ ។

+ថ្នាក់ទី៤ សរុបចំនួន ៥៣ ថ្នាក់ សិស្សសរុប ១៨១៦ នាក់ ស្រី ៨០៩ នាក់ ។

+ថ្នាក់ទី៥ សរុបចំនួន ៥១ ថ្នាក់ សិស្សសរុប ១៧៥៨ នាក់ ស្រី ៨៥៦ នាក់ ។

+ថ្នាក់ទី៦ សរុបចំនួន ៤៧ ថ្នាក់ សិស្សសរុប ១៥៩៣ នាក់ ស្រី ៧៩៤ នាក់ ។

*សរុបរួម ៣០៩ ថ្នាក់ សិស្ស ១០,៤៦៨ នាក់ ស្រី ៤,៩៥៩ នាក់ ។

### ៣.២.៣.ការងារសុខាភិបាល៖

សកម្មភាពជារួមរបស់មន្ទីរពេទ្យ និង មណ្ឌលសុខភាពទាំង១១ ក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋ មានភាពសកម្ម មានការយកចិត្តទុកដាក់ បង្កើនការទទួលខុសត្រូវ ព្រមទាំងមានការចូលរួមចំណែក ក្នុងការបំរើសេវាជូនប្រជាពលរដ្ឋប្រកបដោយវិជ្ជាជីវៈ ។ ដែលក្នុងនោះលទ្ធផលសំរេចបានសំខាន់ៗ ជារួមមានដូចជា ៖

- សេវាបេឡាជាតិសន្តិសុខសង្គម( បសស) ចំនួន ៣១៨២នាក់
- ការប្រើប្រាស់សេវាមូលនិធីសមធម៌ក្រៅប្រព័ន្ធ ចំនួន ១២៩នាក់
- ប្រជាពលរដ្ឋប្រើប្រាស់សេវាមូលនិធីសមធម៌ ចំនួន ៩ ៨៥៥ នាក់
- ស្ត្រីពិនិត្យផ្ទៃពោះ សំរាលកូន ពិនិត្យក្រោយសំរាល និង កុមារអាយុក្រោម២ឆ្នាំ ប្រើប្រាស់ប័ណ្ណសមធម៌និងប័ណ្ណអទិភាពក្នុងរយះពេល៦ខែ (ចាប់ពីថ្ងៃទី០១ខែមិថុនា រហូតដល់ថ្ងៃទី៣០ខែវិច្ឆិកា មានចំនួន ៥៥៣ ករណី )
- ការពិនិត្យ និង ព្យាបាលជំងឺជូនប្រជាពលរដ្ឋ ចំនួន ៥៥ ៤៨២នាក់
- សេវាសំរាកពេទ្យ ចំនួន ៤ ៣៩៨នាក់
- ការពិនិត្យផ្ទៃពោះមុនសំរាល ចំនួន ៦ ៩២១ករណី

- ការពិនិត្យថែទាំក្រោយសំរាល ចំនួន ៣ ១៨២ករណី
- ការសំរាលកូន ចំនួន ១៤៩៧នាក់
- ការពិនិត្យនិងព្យាបាលជំងឺភ្នែក ចំនួន ៧៨៥នាក់ (កាត់វែនតា១៤២នាក់)
- ការពិនិត្យនិងព្យាបាលជំងឺធ្មេញ ចំនួន ៧៣៩ នាក់
- អ្នកកំពុងប្រើប្រាស់សេវាពន្យាកំណើត ចំនួន ២ ០៥៤ នាក់
- អ្នកកំពង់ប្រើប្រាស់សេវារបេង ដូតស៍ ចំនួន ៤៣ នាក់
- បានធ្វើការស្រាវជ្រាវសកម្មដើម្បីរកអ្នកផ្ទុករបេង ចំនួន១ ៥៨២ នាក់
- អ្នកកំពុងទទួលការថែទាំព្យាបាលជំងឺអេដស៍ ចំនួន ១៦៥ នាក់
- បានផ្តល់ថ្នាំបង្ការគ្រប់មុខដល់កុមារ ចំនួន ២៨ ៩៦១ចំណាក់
- កុមារបានទទួលថ្នាំបង្ការគ្រប់មុខ ចំនួន ១ ៨៧០នាក់
- បានផ្តល់ថ្នាំបង្ការតេតាណូសដល់ស្ត្រីមានផ្ទៃពោះ ចំនួន ២ ១៦៩នាក់
- បានផ្តល់ថ្នាំបង្ការតេតាណូសដល់ស្ត្រីអាយុ១៥ដល់៤៤ ចំនួន ១ ០៥៣នាក់
- ផ្តល់ថ្នាំជាតិដែកដល់ស្ត្រី និង កុមារ ចំនួន៥ ៤១៨នាក់
- ផ្តល់ថ្នាំជីវជាតិអា កុមារ ចំនួន ២២ ៥១១នាក់
- ផ្តល់ថ្នាំទំលាក់សត្វល្អិតដល់ស្ត្រី និង កុមារ ចំនួន ៦២ ៧៩១នាក់
- មណ្ឌលសុខភាពចុះធ្វើការអប់រំសុខភាពដល់សហគមន៍បានចំនួន៧៣ដង
- ស្រុកប្រតិបត្តិបានចុះអភិបាលការងារនៅតាមមណ្ឌលសុខភាពបានចំនួន៣១ដង
- មណ្ឌលសុខភាពបានចុះផ្តល់ថ្នាំបង្ការតេតាណូសដល់សិស្សតាមវិទ្យាល័យបានចំនួន២ដង / វិទ្យាល័យ (ទាំង៣វិទ្យាល័យ គឺ៦ដង) ។
- ប្រធានការិយាល័យបានចូលរួមក្នុងសកម្មភាពចែកអំណោយ របស់កាកបាទក្រហមកម្ពុជាសាខាស្រុកល្វាឯម ដែលដឹកនាំដោយ ឯកឧត្តម គង់ សោភ័ណ្ឌ ដល់ស្ត្រីសំរាលកូន១៤នាក់ និង អ្នកជំងឺសំរាកក្នុងមន្ទីរពេទ្យ២៦នាក់ ។
- មន្ទីរពេទ្យបង្អែកបានចូលរួមធ្វើបទបង្ហាញនៅសាលាភូមិន្ទរដ្ឋបាល អំពីសេវាសាធារណៈគំរូ វិស័យសុខាភិបាល ដល់គណកម្មការប្រឡងប្រណាំងថ្នាក់ជាតិ ។
- មន្ទីរពេទ្យបង្អែកបានដំណើការប្រជុំគណកម្មការនាយកហិរញ្ញប្បទានសុខាភិបាល ចំនួន៣ដង ដោយមានការចូលរួមពីលោក ភិម គីរ៉ា អភិបាល នៃគណអភិបាល និងលោក ចេង ឌីណា អភិបាលរង នៃគណអភិបាលស្រុកល្វាឯម ។
- ការិយាល័យ និង មន្ទីរពេទ្យបានផ្តល់យុទ្ធនាការណ៍ពិនិត្យនិងវះកាត់ភ្នែក ក្រោមកិច្ចសហការជាមួយមន្ទីរពេទ្យជ័យជំនះ និង កម្មវិធីជាតិសុខភាពភ្នែក ដែលជាលទ្ធផលគឺពិនិត្យបានចំនួន៤៧៧នាក់ និងវះកាត់បានចំនួន ១២៧នាក់ ។
- ក្រុមគ្រូពេទ្យអាមេរិក តាមរយៈ ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនរ័ត្ន ផ្តល់ការពិនិត្យនិងព្យាបាល ដល់កុមារអាយុក្រោម១០ឆ្នាំ បានចំនួន៥៦១នាក់ ។
- ក្រុមគ្រូពេទ្យអាមេរិក បានបណ្តុះបណ្តាលក្រុមឆ្មបនៅតាមមណ្ឌលសុខភាពបានចំនួន៣៦នាក់
- មណ្ឌលសុខភាពបានធ្វើយុទ្ធនាការណ៍ ផ្តល់ថ្នាំជីវជាតិអា និង ថ្នាំទំលាក់ព្រូន ដល់កុមារអាយុក្រោម៥ឆ្នាំ នៅទូទាំងស្រុក ចំនួន២លើក ។

– មន្ទីរពេទ្យបានទទួលការចុះពិនិត្យនិងវាយតំលៃ អង្គភាពគំរូសេវាសាធារណ ពីគណកម្មការជាតិអន្តរក្រសួង (៧ក្រសួង) ដើម្បីជ្រើសរើស និង ធ្វើចំណាត់ថ្នាក់ ។

– មន្ទីរពេទ្យបានចូលរួមការប្រកាសលទ្ធផលនៃអង្គភាពគំរូសេវាសាធារណ ពីគណកម្មការជាតិអន្តរក្រសួង ដើម្បីជ្រើសរើសនិងធ្វើចំណាត់ថ្នាក់ដែលក្នុងនោះមន្ទីរពេទ្យបង្អែកល្វាឯមទទួលបានចំណាត់ថ្នាក់លេខ ៨ ទូទាំងប្រទេស ។

– ស្រុកប្រតិបត្តិ និង មន្ទីរពេទ្យ បានទទួលគណប្រតិភូស្រុកកណ្តាលស្ទឹង សំរាប់ទស្សនកិច្ចសិក្សានៅមន្ទីរពេទ្យបង្អែកល្វាឯម

– ស្រុកប្រតិបត្តិនិងមន្ទីរពេទ្យបានទទួលគណប្រតិភូ អង្គការគ្រិស្តសាសនាអាមេរិកាំងក្នុងដំណើរទស្សនកិច្ច សិក្សាស្វែងយល់ពីតម្រូវការរបស់នៅមន្ទីរពេទ្យបង្អែក និង មណ្ឌលសុខភាព ក្នុងល្វាឯម ។

– មន្ទីរពេទ្យ និង មណ្ឌលសុខភាពបានចាប់ផ្តើមដំណើរការផ្តល់ថវិកាដល់ស្ត្រីដែលមានប័ណ្ណសមធម៌ឬមានប័ណ្ណអទិភាពសំរាប់ការពិនិត្យផ្ទៃពោះការសំរាលការថែទាំសុខភាពម្តាយក្រោយ

០ សំរាលនិងកុមារដែលមានអាយុក្រោម២ឆ្នាំ ។

– មណ្ឌលសុខភាព បានធ្វើយុទ្ធនាការណ៍ ផ្តល់ថ្នាំអាល់បេតសំលាប់ដង្កូវទឹក ដល់ប្រជាពលរដ្ឋចំនួន១៣ឃុំ

– ការិយាល័យ បានធ្វើយុទ្ធនាការណ៍ ផ្តល់ថ្នាំបង្ការបន្ថែម ដល់កុមារក្រោម១ឆ្នាំ ទូទាំងស្រុក

– មណ្ឌលសុខភាពចុះធ្វើការអប់រំសុខភាពភ្នែក ដោយសហការណ៍ជាមួយកិច្ចការនារីឃុំ (គកនក) ដល់សហគមន៍បានចំនួន១២ដង (ថវិកា Fredd Hollow)

– មណ្ឌលសុខភាពសំបួរកោះកែវបានចូលរួមក្នុងវគ្គបណ្តុះបណ្តាល អប់រំសុខភាពជំងឺភ្នែកដល់សហគមន៍បានចំនួន០១ដង (ថវិកា Fredd Hollow)

– ស្រុកប្រតិបត្តិបានចុះវាយតំលៃគុណភាពសេវាប្រចាំត្រីមាសទី២ នៅគ្រប់មណ្ឌលសុខភាពទាំងអស់ ចំនួន២២ ដង ( ម្តង/ត្រីមាស/មណ្ឌលសុខភាព )

– ស្រុកប្រតិបត្តិ និង មន្ទីរពេទ្យ បានទទួលការចុះវាយតំលៃគុណភាពសេវាប្រចាំត្រីមាសទី២ ពីក្រុមវាយតម្លៃរបស់មន្ទីរសុខាភិបាលខេត្ត ចំនួន២ដង ( ម្តង/ត្រីមាស)

– ប្រធានការិយាល័យបានទំនាក់ទំនងនិងបញ្ចប់គំពោងសាងសង់អគារសំរាកពេទ្យនៅមណ្ឌលសុខភាពទឹកឃ្លាំង ក្រោមគំពោងជំនួយរបស់ស្ថានទូតជប៉ុន

– ប្រធានការិយាល័យ និង ប្រធានមណ្ឌលសុខភាពទាំង១២ បានចូលរួមវេទិកាសាធារណៈ នៅគ្រប់ឃុំទាំង១៥

– ប្រធានការិយាល័យ និង ប្រធានមណ្ឌលសុខភាពទាំង១២ បានចូលរួមកម្មវិធី ហូបអំបុកខ្មែរ ថៃជាតិ សាសនា ព្រះមហាក្សត្រ នៅគ្រប់ឃុំទាំង១៥

– បុគ្គលិកបានចូលរួមប្រចាំការនៅក្នុងពិធីបុណ្យអុំទូកនៅក្រុងតាខ្មៅ និង ពិធីបុណ្យអុំទូក អកអំបុក បណ្តែតប្រទីប នៅមុខព្រះបរមរាជវាំង ។

– បុគ្គលិកបានចូលរួមប្រចាំការនៅក្នុងកម្មវិធីប្រជុំបណ្តាប្រទេស អាស៊ី អ៊ឺរ៉ុប នាសណ្ឋាគារសុខាភ្នំពេញ

**៣.២.៤-ការងារកិច្ចការនារី**

- ចុះឃុំពាមឧកញ៉ាអុង ឃុំព្រែកឫស្សី ឃុំបារុង ឃុំអរិយក្សត្រ ឃុំកោះរះ ព្រែកឫស្សី ភូមិធំ ព្រែករៃ ចូលរួមកិច្ចប្រជុំប្រចាំខែ គ.ក.ន.ក ឃុំ វត្តមានចូលរួមសរុប១១៩នាក់, ស្រី៧៤នាក់។

- ចូលរួមកិច្ចប្រជុំគណៈអភិបាល ក្រោមអធិបតីភាព លោក ភឹម ភីរ៉ា អភិបាលនៃគណៈអភិបាលស្រុកល្វាឯម។

- ចុះឃុំកោះកែវ ឃុំព្រែកឫស្សី សំបួរ ពិនិត្យមើលការរៀន និងបង្រៀនរបស់មត្តេយ្យសិក្សាសហគម ៩កន្លែង បាននាំយកសម្ភារៈ មានសៀវភៅ ខ្មៅដៃ អាហារសម្រន់ ជូនដល់សិស្ស អ្នកគ្រូសំពត់សឹង១, នាឡិកាព្យួរជញ្ជាំង១ សម្រាប់ដាក់ក្នុងសាលា ដែលឧបត្ថម្ភដោយលោកអភិបាលស្រុក ក្នុងនោះដែលក្រុមការងារបានឧបត្ថម្ភថវិកា ៧៥,០០០៛ សម្រាប់ទិញកៅអីចំនួន៥ ដល់សាលាមត្តេយ្យឃុំកោះកែវ។

- សួរសុខទុក្ខស្ត្រីទើបនិងសម្រាលកូន ៤នាក់ នៅឃុំកោះរះ ឃុំកោះកែវ និងឃុំអរិយក្សត្រ បាននាំយកថវិការបស់សមាគមនារីស្រុកទៅឧបត្ថម្ភ ក្នុង១នាក់ ១០០,០០០៛។

- បានប្រារព្ធពិធីមិទ្ទិញអបអរសាទរខួបលើកទី១០៨ ទិវាអន្តរជាតិនារី ៨មិនា ឆ្នាំ២០១៩ ក្រោមអធិបតីភាពដ៏របស់ **លោកជំទាវ កែវ ចរិយា** អនុប្រធានក្រុមការងារថ្នាក់ជាតិចុះជួយស្រុកល្វាឯម ទទួលចលនាស្ត្រី តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ប្រធានក្រុមការងារថ្នាក់ជាតិចុះជួយស្រុកខ្សាច់កណ្តាល ស្រុកល្វាឯម និងស្រុកកៀនស្វាយ សមាជិកចូលរួម៤១២នាក់ ឧបត្ថម្ភសមាជិកចូលរួមម្នាក់ថវិកា ១០,០០០៛ និងសារុង១ ក្រុមការងារស្ត្រីថ្នាក់ស្រុកសំពត់សឹងម្នាក់១ និងបំពង់ទឹកក្តៅ១។

- ចុះឃុំពាមឧកញ៉ាអុង សួរសុខទុក្ខក្មេងស្រីរងគ្រោះដោយករណីប៉ុនប៉ងចាប់រំលោភ និងបាននាំយកថវិការបស់លោកអភិបាល អភិបាលរងស្រុក លោកប្រធានការិយាល័យភូមិបាល លោកជំទប់ទី២ ឃុំថ្មគរ សរុបចំនួន ៨៦០,០០០រៀល ទៅឧបត្ថម្ភដល់ក្មេងស្រីរងគ្រោះ ដែលមានការអញ្ជើញចូលរួមពី លោកស្រី ងិន សុខា អនុប្រធានមន្ទីរកិច្ចការនារីខេត្ត។

- ចុះឃុំបារុង ចូលរួមកិច្ចប្រជុំប្រចាំខែ គកនក ឃុំ វត្តមានចូលរួមសរុប ២៤នាក់, ស្រី១៦នាក់ ក្រោមអធិបតីភាព **លោកជំទាវ នួន នារតី** សមាជិកក្រុមប្រឹក្សាខេត្ត និងជាប្រធាន គ.ក.ស.ក ខេត្ត និងសហការី និងមានការចូលរួមពីលោកស្រីប្រធាន អនុប្រធាន គ.ក.ស.ក ស្រុក។

- ចូលរួមវគ្គបណ្តុះបណ្តាលការងារយេនឌ័រនិងសុខភាពភ្នែក ដែលមានការអញ្ជើញចូលរួមពីលោកលោកស្រីមេឃុំ ឫជំទប់ទី១ឃុំ លោកស្រីទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សរុប៣១នាក់ ។

- ចុះឃុំកោះរះសួរសុខទុក្ខគ្រួសាររងគ្រោះដោយភ្លើងឆេះផ្ទះ១គ្រួសារ ដោយបាននាំយកសម្ភារៈទៅឧបត្ថម្ភរួមមាន សម្ភារៈផ្ទះបាយ១ឈុត, មុងភួយ និងថវិកាមួយចំនួន ដោយមានអញ្ជើញចូលរួមពីលោកស្រីប្រធាន អនុប្រធាន គ.ក.ស.ក ស្រុក លោកលោកស្រី ក្រុមប្រឹក្សាឃុំ។

- ចូលរួមវេទិកាផ្សព្វផ្សាយច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរ និងអំពើធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ និងច្បាប់ស្តីពីការទប់ស្កាត់អំពើហឹង្សាលើស្ត្រីនិងកុមារ និងកិច្ចការពារជនរងគ្រោះ ក្រោមអធិបតីភាព **លោកជំទាវ ហ៊ុន កុសនី** អភិបាលរងខេត្ត និងជាអនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួយដូរមនុស្សខេត្តកណ្តាល និងមានការចូលរួមពី **លោកជំទាវ នួន នារតី** ប្រធាន គ.ក.ស.ក ខេត្ត និងលោកស្រីឧត្តមសេនីយ៍ត្រី ឈឹម វណ្ណី ស្នងការរងខេត្តកណ្តាល លោក លោកស្រី អភិបាល អភិបាលរងស្រុក ប្រធានការិយាល័យជំនាញជុំវិញស្រុក កងកម្លាំងទាំងបី ប្រជាពលរដ្ឋឃុំសារិកាកែវ សរុប២៥០នាក់។

- បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការរៀបចំផែនការស្តិតិ ការត្រួតពិនិត្យ និងការវាយតំលៃឆ្លើយតបទៅនិងយេនឌ័រ នៅខេត្តកំពង់ធំ រយៈពេល៣ថ្ងៃ ក្រោមអធិបតីភាព **លោកជំទាវ ច័ន្ទ សិរី** អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី ។

- ចុះឃុំសំបួរបើកវេទិកាអប់រំសហគមន៍ដល់ក្រុមបុរស និងក្មេងប្រុស ស្តីពីយេនឌ័រនិងសុខភាពផ្លែក ក្រោមអធិបតីភាពលោកស្រី ឡេង មោនីភាព ប្រធាននាយកដ្ឋានស្ត្រី និងសុខភាព ដែលមានការអញ្ជើញចូលរួមពីលោកស្រីថ្នាក់ដឹកនាំខេត្ត ស្រុក ឃុំ ភូមិ ប្រជាពលរដ្ឋសរុប ៧០នាក់, ស្រី០៧នាក់។

- ចុះឃុំពាមឧកញ៉ាអុង ឃុំកោះរះ ចូលរួមជាមួយអនុសាខាកាកបាទក្រហមស្រុក នាំយកអំណោយចែកជូនដល់គ្រួសារក្រីក្រ ចាស់ជរាគ្មានទីពឹង ២គ្រួសារ។

- ចុះឃុំអរិយក្សត្រ, សារិកាកែវ, ពាមឧកញ៉ាអុង, កោះរះ, ទឹកឃ្លាំង, បឹងគ្រំ, កោះកែវ, សំបួរ, ទឹកឃ្លាំង, កោះកែវ, ព្រែករ៉ៃ, ព្រែកក្មេង និងឃុំបារុង ចូលរួមវេទិកាសាធារណៈ របស់ក្រុមការងារថ្នាក់ជាតិ។

- ចូលរួមពិធីហូបអំបុកខ្មែរ **ការពារជាតិ សាសនា ព្រះមហាក្សត្រ** ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ប្រធានក្រុមការងារថ្នាក់ជាតិចុះជួយខេត្តកណ្តាល។

**៣.២.៥-ការងារធម្មការ និង សាសនា**

- បានចូលរួមការប្រឡងយកវិញ្ញាបនបត្រធម្មវិន័យថ្នាក់ត្រីទោឯក នៅមណ្ឌលប្រឡងស្រុកកៀនស្វាយ ដែលមានសមណសិស្សពីស្រុកល្វាឯមចូលរួមប្រឡងចំនួន ១០៩អង្គ/នាក់។

- បានចូលរួមក្នុងពិធីអនុសំវច្ឆរមហាសន្និបាត មន្ត្រីសង្ឃទូទាំងខេត្តកណ្តាល លើកទី២៧ នៅវត្តក្រពើហា ក្រុងតាខ្មៅ ខេត្តកណ្តាល។

- បានចូលរួមក្នុងពិធីបញ្ចុះបឋមសិលាកសាងកុដិ នៅវត្តខ្មោការ ឃុំបារុង។

- បានចុះផ្សព្វផ្សាយ និងជម្រុញឲ្យតាមបណ្តាវត្តក្នុងស្រុក ធ្វើការរៀបចំអាចារ្យ និង គណៈកម្មវត្តឲ្យបានពេញសិទ្ធិ ដើម្បីធ្វើការចុះបញ្ជីដីគរុភ័ណ្ឌរបស់វត្ត។

- បានបើកកិច្ចប្រជុំនៅវត្តយសមន្ត្រី វត្តបន្ទាយម្លូ វត្តល្វាសរ វត្តជ្រៃបឹងគ្រំ និងវត្តពោធិវនារាម ស្តីពីការពិនិត្យរបាយការណ៍ចំណូលចំណាយពីឆ្នាំ ២០១៧ និង២០១៨ បានចំនួន ៥លើក។

- បានចូលរួមក្នុងពិធីបុណ្យសពលោកតា ពេជ ឌឹម អាចារ្យវត្តយសមន្ត្រី (ហៅវត្តព្រែកចារ្យ) និងលោកតា ហ៊ិន សុខ អាចារ្យវត្តពាមតាឯក បានចំនួន២ លើក។

- បានបើកកិច្ចប្រជុំនៅវត្តជ្រៃ(បឹងគ្រំ) និងវត្តពោធិវនារាម ស្តីពីការពិភាក្សា ដើម្បីរៀបចំសមាសភាពអាចារ្យ និងគណៈកម្មការវត្តឲ្យបានពេញសិទ្ធ បានចំនួន ២ លើក។

- បានចុះផ្សព្វផ្សាយសេចក្តីណែនាំរបស់ក្រសួងធម្មការ និងសាសនា ស្តីពីការរៀបចំពិធីបុណ្យមាឃបូជា បុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ វិសាខបូជា ពិធីបុណ្យកាន់បិណ្ឌ ភ្ជុំបិណ្ឌ និងកឋិនទាន បានចំនួន ៤ លើក។

- បានចូលរួមក្នុងពិធីបុណ្យឆ្លងសមិទ្ធិផលនានា និងកាត់ខ្សែបូរ ក្នុងវត្តជ្រៃបឹងគ្រំ អាស្រមពេជ្រ វត្តពាមតាឯក និងវត្តបន្ទាយម្លូ បានចំនួន ៤លើក។

- បានចូលរួមក្នុងពិធីស្រោចស្រពព្រះគន្ធវារី ប្រគេនព្រះរាជាគណៈពីរព្រះអង្គ នៅក្នុងវត្តពោធិ៍មាស ឃុំពាមឧកញ៉ាអុង។

- បានចុះត្រួតពិនិត្យ និងជំរុញឲ្យបន្តធ្វើច្បាប់នៅតាមព្រះវិហារគ្រីស្ទ បានចំនួន ៣ កន្លែងនៅក្នុងឃុំអរិយក្សត្រ។

- បានចូលរួមក្នុងពិធីប្រកាសតែងតាំងចៅអធិការស្តីទីប្រចាំវត្តយសមន្ត្រី វត្តមុនីឃោសារាម បានចំនួន ២លើក។

- បានចូលរួមក្នុងពិធីប្រកាសតែងតាំងអាចារ្យ និងគណៈការប្រចាំវត្តនិមុលសាគរ ភូមិព្រែកឬស្សី ឃុំព្រែកឬស្សី។

- បានចូលរួមក្នុងពិធីបោះឆ្នោតជ្រើសរើសអាចារ្យ និងគណៈកម្មការវត្តជ្រោយស្តី ឃុំព្រែកឬស្សី។

- បានចុះស្រង់ស្ថិតិព្រះសង្ឃ អាចារ្យ គណៈកម្មការវត្ត ចៅអធិការវត្ត និងស្រង់ស្ថិតិព្រះវិហារ ស្នាក់ការថ្វាយបង្គំ និងចំនួនសាសនិក(គ្រីស្តនិងមហាយាន) បានចំនួន៣លើក។

- បានចូលរួមដោះស្រាយ និងសម្របសម្រួលបញ្ហាដីគុរ៍ណ្ឌវត្ត នៅវត្តសារិកាកែវ និងវត្តថ្មគរ បានចំនួន២លើក។

- បានចុះផ្សព្វផ្សាយផែនការណែនាំ ស្តីពីការរៀបចំព្រះរាជពិធីគោរពវិញ្ញាណក្ខ័ន្ធ **ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សីហនុ** ព្រះមហាវីរក្សត្រ ព្រះវររាជបិតា ឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ ព្រះបរមរតនកោដ្ឋ គម្រប់ខួប ៧ឆ្នាំ ទៅតាមបណ្តាវត្តក្នុងស្រុកល្វាឯម។

- បានចុះត្រួតពិនិត្យទីតាំងបង្កើតស្នាក់ការសមាគមទ្រទ្រង់ព្រះពុទ្ធសាសនាតាមសណ្តាប់ពីបុរាណកាល នៅឃុំអរិយក្សត្រ បានចំនួន ១លើក។

- បានចុះជំរុញដល់សមណសិស្ស នៅតាមសាលាពុទ្ធិកបឋមសិក្សាក្នុងស្រុកល្វាឯម ដើម្បីដាក់ពាក្យប្រឡងយកវិញ្ញាបនបត្រធម្មវិន័យថ្នាក់ត្រី ទោ ឯក ក្នុងឆ្នាំសិក្សា២០១៩-២០២០ ដែលមានសមណសិស្សដាក់ពាក្យប្រឡងចំនួន១០៩អង្គ។

- បានចុះស្រង់របាយការណ៍ ស្តីពីប្រាក់ចំណូលបិណ្ឌភ្ជុំ និងកឋិនទាន នៅតាមបណ្តាវត្តក្នុងស្រុកល្វាឯម បានចំនួន ២លើក។

- បានចូលរួមក្នុងពិធីចែកអំណោយចំនួន១១៩គ្រួសារ នៅវត្តជ្រៃបឹងគ្រំ ឃុំបឹងគ្រំ ដោយមានការឧបត្ថម្ភពីសំណាក់ព្រះគ្រូចៅអធិការវត្តជ្រៃបឹងគ្រំ។

- បានចូលរួមក្នុងពិធីផ្សព្វផ្សាយសភាពការណ៍ថ្មីៗនៅកម្ពុជា នៅសាលាគណខេត្ត កណ្តាល និងនៅវត្តកោះកែវមុនីរ័ត្ន បានចំនួន២លើក។

**៣.២.៦-ការងារវប្បធម៌**

*១).ការងារអាជីវកម្ម:*

- បានចុះផ្សព្វផ្សាយនិង ជំរុញអោយអាជីវករធ្វើច្បាប់ប្រកបអាជីវកម្មបានចំនួន ៧៥កន្លែង រួមមាន៖
  - + អ៊ុតសក់ កាត់សក់បុរស-នារី ២០កន្លែង
  - + ធុងបាស មេក្រូ+ ១៥ កន្លែង
  - + ផ្លាកឃីហោ ៣០ កន្លែង
  - + សំអាងការ ០៨ កន្លែង
  - + ចម្លាក់ពុម្ពស៊ីម៉ង់ត៍ ០២ កន្លែង

➢ លទ្ធផលសម្រេចបានរៀបចំឯកសាររបស់អាជីវករធ្វើច្បាប់អាជីវកម្មទៅមន្ទីរចំនួន ០២ច្បាប់។

+ បានចេញច្បាប់អាជីវកម្មអកកាដុង ០១ច្បាប់

+ បានចេញច្បាប់អាជីវកម្មមេក្រុ ០១ច្បាប់

*២).ការងារប្រែកចេញ-ចូលតែមួយ:*

- បានចេញច្បាប់ប្រកបអាជីវកម្មគ្រឿងបំពងសម្លេង ចំនួន ០១កន្លែង
- បានចេញច្បាប់ប្រកបអាជីវកម្មផ្ទាំងឃីហោ ចំនួន ០៧ផ្ទាំង
- បានចេញច្បាប់ប្រកបអាជីវកម្មសម្អាងការ ចំនួន ០១ កន្លែង
- បានចេញច្បាប់ប្រកបអាជីវកម្មអ៊ុតសក់ និងធ្វើក្រចក ចំនួន ០១ កន្លែង
- បានចេញលិខិតអនុញ្ញាតឲ្យសម្តែងសិល្បៈ ទស្សនីយភាពល្ខោនបាសាក់ ចំនួន ០៥លើក៖
  + នៅវត្តសុវណ្ណសាគរ ភូមិអរិយក្សត្រ ឃុំអរិយក្សត្រ ចំនួន ០១លើក
  + នៅវត្តបុទមចេតី ភូមិកោះរះលើ ឃុំកោះរះ ចំនួន ០១លើក
  + នៅវត្តសំពោង ភូមិផ្លូវត្រី ឃុំថ្មគរ ចំនួន ០១លើក
  + នៅវត្តវិហារខ្ពស់ ភូមិព្រែកក្រូច ឃុំភូមិធំ ចំនួន ០១លើក
  + នៅវត្តវាលអណ្តែត ភូមិកោះរះក្រោម ឃុំកោះរះ ចំនួន ០១លើក

*៣).ការងារសិប្បកម្ម និងសូនរូប*

- នៅថ្ងៃទី២៧ខែកុម្ភៈ ឆ្នាំ២០១៩ ការិយាល័យជំនាញរបស់មន្ទីរបានសហការជាមួយការិយាល័យវប្បធម៌ស្រុក និងអាជ្ញាធរភូមិឃុំ ចុះត្រួតពិនិត្យ និងវាយតម្លៃសិប្បកម្មក្រម៉ាសូត្រ របស់លោកស្រី សុខ សុវណ្ណ ស្ថិតនៅភូមិព្រែកជ្រៃ ឃុំព្រែកឬស្សី ស្រុកល្វាឯម ដើម្បីដាក់ចូលជាមរតកមនុស្សរស់។

*៤).ការងារបេតិកភ័ណ្ឌ:*

- នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៩ បានសហការជាមួយការិយាល័យជំនាញរបស់មន្ទីរចុះត្រួតពិនិត្យព្រះវិហារបុរាណនៅវត្តពេជ្រម្កុដ ស្ថិតនៅក្នុងឃុំអរិយក្សត្រ។
- នៅថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ២០១៩ ក្រុមការងាររបស់មូលនិធិ GOOD FUN ដឹកនាំដោយលោកស្រី ម៉ារីក្លួត ម៉ាក្បេ ជាប្រធានមូលនិធិ រួមនឹងក្រុមការងារទូរទស្សន៍ TV5 របស់បារាំងសរុបចំនួន ០៦នាក់ ស្រី ០២នាក់ បានចុះមកយកពត៌មានស្តីពីកិច្ចដំណើរការរបស់ក្រុមល្ខោនខោលវត្តស្វាយអណ្តែត។
- នៅថ្ងៃទី២១-២៤ ខែកុម្ភៈ ឆ្នាំ២០១៩ ក្រុមល្ខោនខោលវត្តស្វាយអណ្តែត ឃុំសារិកាកែវបានចូលរួមសម្តែងនៅក្នុងពិធីមហោស្រពគីហ្សូណា នៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន (CJCC) ក្រោមអធិបតីភាព **ឯកឧត្តម ហង់ ជួនណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងឯកឧត្តមឯកអគ្គរាជទូតជប៉ុន។
- នៅថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៩ ក្រុមល្ខោនខោលវត្តស្វាយអណ្តែត បានចូលរួមសម្តែងក្នុងទិវាវប្បធម៌ជាតិ ៣មីនា នៅសាលមហោស្រពកោះពេជ្រ ក្រោមអធិបតីភាព **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា **និងសម្តេចគតិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន។**
- នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៩ ក្រុមល្ខោនខោលវត្តស្វាយអណ្តែត បានចូលរួមសម្តែងអបអរសាទរក្នុងទិវាវប្បធម៌ជាតិ ៣មីនា លើកទី២១ ឆ្នាំ២០១៩ នៅសាលាគរុកសល្យភូមិភាគ។
- សនៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៩ ក្រុមល្ខោនខោលវត្តស្វាយអណ្តែត បានចូលរួមសម្តែងក្នុងកម្មវិធីសង្ក្រាន្តឆ្នាំថ្មី នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា។

- នៅថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៩ ក្រុមល្ខោនខោលវត្តស្វាយអណ្ដែត បានចូលរួមសម្ដែងក្នុងកម្មវិធីបុណ្យភូមិនៅវត្តព្រះធាតុ ខណ្ឌដង្កោរ រាជធានីភ្នំពេញ។
- នៅថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៩ ក្រុមល្ខោនខោលវត្តស្វាយអណ្ដែតបានចូលរួមសម្ដែងនៅវិទ្យាល័យហ៊ុន សែនពាមឧកញ៉ាអុង។
- នៅថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៩ ក្រុមល្ខោនខោលវត្តស្វាយអណ្ដែត បានចូលរួមសម្ដែងនៅក្រសួងអប់រំ យុវជន និងកីឡាក្នុងកម្មវិធីសង្ក្រាន្តឆ្នាំថ្មី។
- នៅថ្ងៃទី១៥ ខែមេសា ឆ្នាំ២០១៩ ក្រុមល្ខោនខោលវត្តស្វាយអណ្ដែត បានចូលរួមសម្ដែងក្នុងកម្មវិធីល្ងាចមសង្ក្រាន្តនៅទីលានបាល់ទាត់មុខវិទ្យាល័យហ៊ុន សែនទឹកឃ្លាំង ។
- នៅថ្ងៃទី១៤-១៥-១៦ ខែមេសា ឆ្នាំ២០១៩ ក្រុមល្ខោនខោលវត្តស្វាយអណ្ដែត បានសម្ដែងជូនទស្សនាក្នុងថ្ងៃចូលឆ្នាំប្រពៃណីជាតិខ្មែរ នៅសង្ក្រាន្តវត្តស្វាយអណ្ដែត។
- នៅថ្ងៃទី២០-២១-២២ ខែមេសា ឆ្នាំ២០១៩ ក្រុមល្ខោនខោលវត្តស្វាយអណ្ដែតបានធ្វើពីធីសំពះគ្រូប្រចាំឆ្នាំ និងសម្ដែងជូនប្រជាពលរដ្ឋទស្សនា។
- នៅថ្ងៃទី១៨ ខែឧសភាឆ្នាំ២០១៩ក្រុមល្ខោនខោលបានសម្ដែងជូនទស្សនានៅវត្តស្វាយអណ្ដែតក្នុងកម្មវិធីបុណ្យវិសាខបូជា។
- នៅថ្ងៃទី ០៨ ខែសីហា ឆ្នាំ២០២៩ ក្រុមល្ខោនខោលវត្តស្វាយអណ្ដែត បានចូលរួមសម្ដែងក្នុងកម្មវិធីបុណ្យបំបួសកុលបុត្រ ស្ថិតនៅសង្កាត់ព្រែកលាប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។
- បានសហការជាមួយអាជ្ញាធរភូមិ ឃុំសារិកាកែវ ចុះស្រង់និយាមការអាស្រម និងទូលបុរាណបានចំនួន ០៤កន្លែង រួមមាន៖

១.ទូលលោកយាយស នៅភូមិតាជោ

២.ទូលលោកតាឯក នៅភូមិតាជោ

៣.ទូលលោកតាគគីរធំ នៅភូមិក្ដីកណ្ដាល

៤.អាស្រមលោកតាប្រាំខេត្ត នៅភូមិក្ដីកណ្ដាល

- នៅថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ២០២៩ ក្រុមល្ខោនខោលវត្តស្វាយអណ្ដែត បានសម្ដែងជូនដល់ប្រជាពលរដ្ឋ ទស្សនាក្នុងកម្មវិធីបុណ្យភ្ជុំបិណ្ឌនៅរោងល្ខោនខោលវត្តស្វាយអណ្ដែត។
- នៅថ្ងៃទី១២-១៣ ខែតុលា ឆ្នាំ២០១៩ បានដឹកនាំទូក ង ចំនួន ០៦ទូក ទៅចូលរួមប្រណាំងនៅមាត់ទន្លេក្រុងតាខ្មៅ ដែលមានទូកចូលរួមសរុប ៦៣ទូក នឹងបានទទួលជ័យលាភីដូចខាងក្រោម ៖

+ ទូកអុំប្រពៃណីមានចំនួន ០៤ទូក
  - រតនៈកុមារតេជោសែនជ័យ ចំណាត់ថ្នាក់លេខ៤
  - បារមីពោធិ៍មាសតេជោសែនជ័យ ចំណាត់ថ្នាក់លេខ ៥
  - នាគសមានជ័យបារមីលោកតាឯក ចំណាត់ថ្នាក់លេខ ៧
  - តារាអណ្ដែតស៊ាសែនជ័យ ចំណាត់ថ្នាក់លេខ ១៧
+ ទូកអុំខ្នាតអន្តរជាតិមានចំនួន ០២ទូក
  - យុវជនសម័យតេជោសែនជ័យបារមីមហានគរ ចំណាត់ថ្នាក់លេខ ៣
  - ស.ស.យ.ក ក្រុងនគរសែនជ័យ ចំណាត់ថ្នាក់លេខ ១០

– បានចុះស្រង់ស្ថិតិទូក "ង" ទៅចូលរួមប្រណាំងនៅមុខព្រះបរមរាជវាំង នៅថ្ងៃទី ១០-១១-១២ ខែវិច្ឆិកា ឆ្នាំ២០១៩ មានចំនួន ១៩ទូក ក្នុងនោះទូកអុំប្រពៃណីមានចំនន ១៥ទូក និងទូកខ្នាតអន្តរជាតិមានចំនួន ០៤ទូក។

– នៅថ្ងៃទី១០-១១-១២ ខែវិច្ឆិកា ឆ្នាំ២០១៩ បានសហការជាមួយគណៈអភិបាលស្រុកដឹកនាំទូក ង ចំនួន ១៩ទូក ទៅចូលរួមប្រណាំងនៅមុខព្រះបរមរាជវាំង ដែលបានទទួលជ័យលាភីដូចខាងក្រោម ៖

+ ផែនលេខ ១ចំនួន ០៥ទូក

- តេនៈកុមារតេជោសែនជ័យ ស្ថិតនៅឃុំព្រែកក្មេង
- តារាអណ្ដែតស៊ាសែនជ័យ ស្ថិតនៅឃុំសំបួរ
- ជម្ពូពេជ្រ ស្ថិតនៅឃុំកោះរះ
- មហិទ្ធិឫទ្ធីកំហែងជ័យបារមីវត្តស្វាយអណ្ដែត ស្ថិតនៅឃុំសារិកាកែវ
- សង្គមខេមរាសែនជ័យបារមីល្វាសរ ស្ថិតនៅឃុំល្វាសរ

+ ផែនលេខ ២ចំនួន ១០ទូក

- បារមីកូនការវិបុលសែនជ័យ ស្ថិតនៅឃុំបារុង
- អន្ទង់ស មានជ័យបារមីវត្តពាមតាឯក ស្ថិតនៅឃុំពាមឧកញ៉ាអុង
- បារមីស្រីស្រស់ចំប៉ាមហាឆ្លាមសែនជ័យ ស្ថិតនៅឃុំព្រែកឫស្សី
- នាងតាវត្តីសែនមានជ័យ ស្ថិតនៅឃុំថ្មគរ
- ពេជ្រមុនីរត្ន័ពិជ័យបារមីវត្តវាលអណ្ដែត ស្ថិតនៅឃុំកោះរះ
- សំបូរសែនជ័យបារមីស្រីម៉ៅ ស្ថិតនៅឃុំសំបួរ
- សុវណ្ណកុមារល្វាឯមមានជ័យ ស្ថិតនៅឃុំព្រែករៃ
- ក្រុងនគរសែនជ័យ ស្ថិតនៅឃុំសារិកាកែវ
- យុវជនសម័យតេជោសែនជ័យ ស្ថិតនៅឃុំព្រែកឫស្សី
- តារារះពាមឧកញ៉ាអុងសម័យតេជោ ស្ថិតនៅឃុំពាមឧកញ៉ាអុង

+ ផែនលេខ ៣ចំនួន ០៣ទូក

- ជ្រៃសែនមានជ័យ
- យុវជនសម័យតេជោសែនជ័យបារមីមហានគរ ស្ថិតនៅឃុំពាមឧកញ៉ាអុង
- បារមីហនុមានពោធិ៍មាសតេជោសែនជ័យ ស្ថិតនៅឃុំពាមឧកញ៉ាអុង

+ អវត្តមានចំនួន ០១ទូក

- បារមីពោធិ៍មាសតេជោសែនជ័យ ស្ថិតនៅឃុំពាមឧកញ៉ាអុង

– នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៩ ក្រុមល្ខោនខោលវត្តស្វាយអណ្ដែត បានប្រារព្ធពិធីអបអរសាទរគម្រប់ខួប១ឆ្នាំនៃការដាក់បញ្ចូលល្ខោនខោលវត្តស្វាយអណ្ដែតទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក និងជាសម្បត្តិមនុស្សជាតិ ។

*៥).ការងារសិល្បៈភាពយន្ត:*

- នៅថ្ងៃទី ០៥ ខែមីនា ឆ្នាំ២០១៩ ការិយាល័យជំនាញរបស់មន្ទីរបានសហការជាមួយការិយាល័យវប្បធម៌ស្រុក និងអាជ្ញាធរភូមិ-ឃុំ ចុះត្រួតពិនិត្យអាជីវកម្មលក់ ដួលផលិតផលស្នាដៃភាពយន្តវីដេអូ ស្ថិតនៅភូមិកោះរះលើ ឃុំកោះរះ ស្រុកល្វាឯម ។

៦).ការងារផ្សេងៗ

- បានចុះត្រួតពិនិត្យ និងតាមដានការរីកហាត់របស់ក្រុមល្ខោនខោលនៅវត្តស្វាយអណ្តែតរៀលរាល់មួយសប្តាហ៍ម្តង។

- នៅថ្ងៃទី១៤-១៥-១៦ ខែមេសា ឆ្នាំ២០១៩ បានចូលរួមជាមួយក្រុមការងាររដ្ឋបាលស្រុករៀបចំសង្ក្រាន្តទទួលទេវតាឆ្នាំថ្មី។

- បានស្រង់ស្ថិតិតាមបណ្តាវត្ត និងតាមភូមិ ឃុំដែលបានរៀបចំធ្វើសង្ក្រាន្ត លេងល្បែងប្រជាប្រិយ ចាក់ផុងបាស់ អកកាដុង និងតន្ត្រីសម័យក្នុងស្រុកល្វាឯម ក្នុងនោះមានដូចជា៖

+ ការរៀបចំធ្វើសង្ក្រាន្ត ២២កន្លែង
+ លេងល្បែងប្រជាប្រិយ ២២កន្លែង
+ ចាក់ផុងបាស់ ២៦កន្លែង
+ តន្ត្រីសម័យ ០២កន្លែង
+ អកកាដុង ០៣កន្លែង
+ បញ្ចាំងភាពយន្ត ០១កន្លែង

➢ នៅក្នុងឱកាសបុណ្យចូលឆ្នាំថ្មីនេះប្រជាពលរដ្ឋទូទាំងស្រុកល្វាឯម បានចូលរួមអបអរសាទរទទួលទេវតាឆ្នាំថ្មី លេងល្បែងប្រជាប្រិយ រាំលេងកម្សាន្តតាមភូមិ វត្តអារាម និងតាមគេហដ្ឋាន យ៉ាងច្រើនកោះក និងសប្បាយរីករាយ។

៣.២.៧.ការងារកាកបាទក្រហមកម្ពុជា:

១. ការគ្រប់គ្រងគ្រោះមហន្តរាយ:

-បានធ្វើការអប់រំណែនាំដល់ក្រុមការងារកាកបាទក្រហមគ្រប់ឃុំ ត្រៀមលក្ខណៈបង្ការគ្រោះមហន្តរាយផ្សេងៗ ដែលនឹងកើតឡើង ដូចជាទឹកជំនន់ ខ្យល់ព្យុះ ភ្លៀងផ្គររន្ទះ...។ល។ ជំរុញឲ្យមាន ការជួសជុលឡើងវិញ ទីទួលសុវត្ថិភាព ត្រៀមមធ្យោបាយដឹកជញ្ជូន ទូក កាណូត ក្នុងពេលមានគ្រោះអាសន្ន រួមទាំងកំលាំងអន្តរាគមន៍របស់ក្រុមការងារស្រុក ឃុំនិងអ្នកស្ម័គ្រចិត្តកាកបាទក្រហមភូមិ។

-ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ នៅគ្រប់បណ្តាមូលដ្ឋាន ពិសេសគោលដៅដែលងាយរងគ្រោះ ដោយទឹកជំនន់ជន់លិចជ្រៅ និងមានរយៈពេលយូរ ឲ្យត្រៀមស្បៀង ថវិកា សំភារៈ និងមធ្យោបាយទុកជាដើម។

– ស្រុកបានជួបបញ្ហាគ្រោះមហន្តរាយបង្កឡើងដោយធម្មជាតិ រួមមានដូចខាងក្រោម៖

ក).ខ្យល់កន្ត្រាក់៖ កើតតមានចំនួន០៣លើក បណ្តាលឲ្យខូចខាតផ្ទះចំនួន២៩ គ្រួសារ។

ឃ).ការបាក់ច្រាំង៖ កើតមានចំនួន០៣លើក ប៉ះពាល់ប្រជាពលរដ្ឋសរុបចំនួន១៣គ្រួសារ រស់នៅឃុំចំនួន០៣ មានឃុំសារិកាកែវ, ឃុំពាមឧកញ៉ាអុង និងឃុំល្វាសរ។

ង).គ្រោះដោយទឹកជំនន់៖

+ ករណីផ្ទះលិចទឹក៖ ប៉ះពាល់ប្រជាពលរដ្ឋចំនួន៣៤០គ្រួសារ/ខ្នងផ្ទះ ជម្លៀសចេញពីលំនៅដ្ឋានចំនួន២៧គ្រួសារ។

+ ករណីលិចផ្លូវ៖ ប៉ះពាល់ផ្លូវចំនួន១៩ខ្សែ ស្មើ ៩,៨១០ម៉ែត្រ ក្នុងឃុំចំនួន៦។
+ លិចសាលារៀន៖ (គ្មាន)
+ លិចដំណាំ៖ (គ្មាន)

– អនុសាខាកាកបាទក្រហមកម្ពុជាស្រុកល្វាឯម មានរៀបចំពិធីទទួលសម្ភារៈ និងថវិកាពីព្រះអនុគណស្រុក និងព្រះមន្ត្រីសង្ឃស្រុក ព្រះគ្រូចៅអធិការវត្ត សម្រាប់ជួយដល់អនុសាខាកាកបាទក្រហមស្រុកល្វាឯម សម្ភារៈមានដូចជា

១- អង្ករ ១៥០ kg និងគ្រឿងបរិភោគ

៤-សម្ភារៈផ្ទះបាយ ៥ ឈុត

ថវិកាសរុបចំនួន ៣.៨៧០.០០០ រៀល

– ថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩ អនុសាខាកាកបាតក្រហមស្រុកល្វាឯម ប្រគល់ឱសថ(ថ្នាំពេទ្យ) ដែលមានដូចជា៖ Para ចំនួន២កេះ + 3ប្រអប់ = ៣៥ប្រអប់ និងMulti : ២កេះ + 1 ប្រអប់ =៣៣ ប្រអប់ បានជូនដល់ការិយាល័យសុខាភិបាលស្រុកល្វាឯម ដើម្បីយកទៅបែងចែកជូនមណ្ឌលសុខភាពទាំង១១ របស់ស្រុកនៅស្នាក់ការអនុសាខាកាកបាទស្រុកល្វាឯម ខេត្តកណ្តាល។

– ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៩ លោកគឹម គីរ៉ា អភិបាលស្រុក និងលោក សែម សោត្ថិ ប្រធានក្រុមប្រឹក្សាស្រុកល្វាឯម បានអញ្ជើញចូលរួមក្នុងខួបលើកទី១៥៦ នៃទិវាពិភពលោកកាកបាទក្រហម អឌ្ឍចន្ទក្រហម ខេត្តកណ្តាល ៨ឧសភា ឆ្នាំ២០១៩ ក្រោមអធិបតីភាព **លោកជំទាវ ឃួន សុដារី** អនុប្រធានកាកបាទក្រហមកម្ពុជា និង**ឯកឧត្តមបណ្ឌិត ម៉ៅ ភិរុណ** អភិបាល នៃគណៈអភិបាលខេត្តនិងជាប្រធានសាខាកាកបាទក្រហមកម្ពុជាខេត្តកណ្តាល នៅស្នាក់កណ្តាល កាកបាទក្រហមកម្ពុជាខេត្តកណ្តាល ក្រុងតាខ្មៅ។

២.សកម្មភាពមនុស្សធម៌ឆ្លើយតបគ្រោះមហន្តរាយ

រដ្ឋបាលស្រុក បានសហការណ៍ជាមួយអនុសាខាកាកបាទក្រហមកម្ពុជាស្រុក និងឯកឧត្តមប្រធានក្រុមការងារថ្នាក់ជាតិចុះជួយមូលដ្ឋានស្រុក ឃុំ និងបានគៀគរសប្បុរសជន ក្នុងការចុះជួយប្រជាពលរដ្ឋដែល រងគ្រោះដោយគ្រោះ មហន្តរាយមានដូចខាងក្រោម ៖

២.១. អំណោយរបស់អនុសាខាកាកបាទក្រហមកម្ពុជាស្រុក

– ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៨ អនុសាខាកាកបាទក្រហមកម្ពុជាស្រុក បាននាំយកអំណោយទៅជូនដល់ប្រជាពលរដ្ឋក្រីក្រ ស្ត្រីមេម៉ាយ និងជនគ្មានលំនៅដ្ឋាន ចំនួន៥គ្រួសារ ដែលស្ថិតនៅឃុំបឹងគ្រំ ក្នុងនោះមួយគ្រួសារទទួលបានអង្ករ២០គីឡូ, មី១៥កញ្ចប់, ទឹកត្រី៣ដប, ទឹកស៊ីអ៊ីវ៣ដប, ត្រីខ៥កំប៉ុង និងថវិកា២០០០០រៀល។ ក្នុងនោះលោកស្រីពុទ្ធ សុខានី បានឧបត្ថម្ភបន្ថែមថវិកាចំនួន១គ្រួសារដែលលំបាកខ្លាំង ចំនួន២ម៉ឺន លោក បេ សារ៉ុម ៣ម៉ឺន និងលោក ឆាយ លាងឈាង ៤ម៉ឺនរៀល សរុបថវិកាចំនួន ១១ម៉ឺនរៀល

– ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ២០១៩ អនុសាខាស្រុកបាននាំយកអំណោយឧបត្ថម្ភប្រជាជនក្រីក្រចំនួន ១គ្រួសារ នៅ ភូមិកោះរះក្រោម ឃុំកោះរះ ថវិកា ៥០.០០០ រៀល សម្ភារៈរួមមានអង្ករ ២០គក្រ ទឹកត្រី១យួ ទឹកស៊ីអ៊ីវ ១យួ ត្រីខ ១យួ និងសម្ភារៈដំណេក និងផ្ទះបាយចំនួន១៤ មុខ។

– នៅព្រឹកថ្ងៃសុក្រ ទី៣១ ខែឧសភា ឆ្នាំ២០១៩ លោក គឹម គីរ៉ា អភិបាល នៃគណៈអភិបាលស្រុក និងជាប្រធានអនុសាខាកាកបាទក្រហមកម្ពុជាស្រុកល្វាឯម ដោយមានការចូលរួមលោក ចេង ឌីណា អភិបាល

រងស្រុក ក្រុមការងារយុវជនស.ស.យ.កស្រុក-ឃុំ និងសមាជិកអនុសាខាកាកបាទក្រហមស្រុក អាជ្ញាធរឃុំ-ភូមិ ព្រមទាំងបានការនិមន្តចូលរួមពីព្រះតេជគុណ ជា ប៊ុនធឿន ព្រះគ្រូចៅអធិការវត្តស្វាយអណ្តែត បានអញ្ជើញចុះសួរសុខទុក្ខ និងបាននាំយកអំណោយរបស់អនុសាខាកាកបាទក្រហមស្រុក រួមមាន៖ អង្ករ៥០គីឡូ, មី១កេះ, ទឹកត្រី១យួរ, ទឹកស៊ីអ៊ីវ១យួរ, មុងភួយ និងសំភារៈផ្ទះបាយមួយឈុត និងថវិកា១០ម៉ឺនរៀល ឧបត្ថម្ភជូនដល់គ្រួសារចំនួន៣ ស្ថិតនៅភូមិតាស្គរ ឃុំសារិកាកែវ ដែលរងគ្រោះដោយសារខ្យល់កន្ត្រាក់ កាលពីល្ងាចថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៩ គ្រួសារទី១ឈ្មោះ គ្រួសារលោកតា អ៊ុក សំអុល របើកដំបូល, ទី២គ្រួសារលោក ភឿន យាន របើកដំបូលនិងទី៣គ្រួសារ រិន សុគា រលំផ្ទះ ក្នុងនោះព្រះតេជគុណ ជា ប៊ុនធឿន ព្រះគ្រូចៅអធិការវត្តស្វាយអណ្តែត បានចូលរួមនូវស័ង្កសីមួយគ្រួសារ១០សន្លឹក បីគ្រួសារសរុប៣០សន្លឹក។

+ អនុសាខាកាកបាទក្រហមកម្ពុជាស្រុក រួមជាមួយក្រុមការងារកាកបាទក្រហមឃុំ យុវជនសហសភាពសហព័ន្ធយុវជនកម្ពុជា ស្រុក ឃុំ និងយុវជនកាកបាទក្រហមបានចុះសួរសុខទុក្ខ និងនាំយកអំណោយមនុស្សធម៌អនុសាខាកាកបាទក្រហមស្រុក ផ្តល់ជូនគ្រួសារដែលបានរលំផ្ទះដោយសារខ្យល់កន្ត្រាក់ចំនួន ០៣ គ្រួសារ នៅភូមិព្រែកក្មេង ឃុំព្រែកក្មេង និងភូមិតាជោ ឃុំសារិកាកែវ ០២គ្រួសារ។

➢ សរុបអ្នកទទួលផល៖ គ្រួសារត្រូវខ្យល់កន្ត្រាក់ ០៣គ្រួសារ សមាជិក ០៩នាក់

– សរុបអំណោយ៖ អង្ករ៣០គីឡូ, គ្រឿងឧបភោគបរិភោគ សម្ភារៈផ្ទះបាយ និងសម្ភារៈគេងអស់ ៨៤០,០០០រៀល និងថវិកាចំនួណ៦៦០,០០០រៀល។

២.២. អំណោយរបស់សាខាកាកបាទក្រហមកម្ពុជាខេត្ត

– ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៩ សាខាកាកបទក្រហមកម្ពុជា ដែលដឹកនាំដោយ ឯកឧត្តម គង់ សោភ័ណ្ឌ អភិបាលរងខេត្ត និងជាប្រធានសាខាកាកបាទក្រហមកម្ពុជាខេត្តកណ្តាល បានចុះសួរសុខទុក្ខអ្នកជម្ងឺនៅមន្ទីរពេទ្យបង្អែកស្រុកល្វាឯមសរុបចំនួន ៤១នាក់ ក្នុងនោះស្រ្តីសម្រាលកូន១៥នាក់ មកពីឃុំសារិកាកែវ, ឃុំពាមឧកញ៉ាអុង និងឃុំកោះរះ អ្នកជម្ងឺទូទៅ ២៦ នាក់ មកពីឃុំពាមឧកញ៉ាអុង ក្នុងឱកាសនោះដែលឯកឧត្តមបាននាំយកអំណោយរបស់ សម្តេចកិតិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន និងឯកឧត្តមបណ្ឌិត ម៉ៅ ភិរុណ អភិបាល នៃគណៈអភិបាលខេត្តកណ្តាល ចែកជូនដល់ស្រ្តីសម្រាលកូន១៥នាក់ម្នាក់ៗទទួលបានឃិត១កញ្ចប់ មុងទារក១ និងថវិកា២០,០០០៛ អ្នកជម្ងឺទូទៅ២៦នាក់ម្នាក់ៗថវិកា៥០,០០០៛ ឧបត្ថម្ភលោកគ្រូអ្នកគ្រូពេទ្យ១,០០០,០០០៛ ចំណាយផ្សេងៗ៥០០,០០០៛។

២.៣.អំណោយរបស់ឯកឧត្តមក្រុមការងារថ្នាក់ជាតិចុះជួយមូលដ្ឋានឃុំ និងសប្បុរសជន

–ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៩ **ឯកឧត្តម គង់ ពិសិដ្ឋ** និង**លោកជំទាវ ឡូ ចាន់នី** និងក្រុមការងារបាននាំយកអំណោយចែកជូនដល់ប្រជាពលរដ្ឋ នៅក្នុងភូមិថ្មគរ ឃុំថ្មគរ ចំនួន ២៨៥ ខ្នងផ្ទះ ដែលជាអំណោយរបស់ អំណោយរួមមាន(អង្ករ២០kg,មី២កេះ,ទឹកត្រី,ទឹកស៊ីអ៊ីវនិងថវិការ២ម៉ឺនរៀល) ទីតាំងវត្តថ្មគរ ភូមិថ្មគរ ឃុំថ្មគរ ស្រុកល្វាឯម ខេត្តកណ្តាល។

+ អនុសាខាកាកបាទក្រហមកម្ពុជាស្រុក បានសហការជាមួយក្រុមកាកបាទក្រហមឃុំ បានចុះសួរសុខទុក្ខ និងនាំយកអំណោយមនុស្សធម៌របស់អនុសាខាកាកបាទក្រហមកម្ពុជាស្រុក ចែកជូនដល់ចាស់ជា

រគ្មានទីពឹងចំនួន ០៤គ្រួសារ៖ នៅឃុំកោះកែវ ០១គ្រួសារ, ឃុំថ្មគរ ០១គ្រួសារ, ឃុំកោះរះ ០១គ្រួសារ និងឃុំពាមឧកញ៉ាអុង ០១គ្រួសារ។សរុបអ្នកទទួលផល ៖ ០៤គ្រួសារ សមាជិក ០៧នាក់ សរុបអំណោយ

- អង្ករ ចំនួន៧៥គីឡូក្រាម
- គ្រឿងឧបភោគបរិភោគ សម្ភារៈផ្ទះបាយ និងសម្ភារៈគេងគិតជារៀល =៦០០,០០០៛
- អំណោយជាថវិកា២០០,០០០៛

\+ បានចុះសួរសួខទុក្ខ និងចែកអំណោយដល់ប្រជាពលរដ្ឋរងគ្រោះ និងងាយរងគ្រោះ សរុបចំនួន ០៧គ្រួសារ សមាជិក ១៦នាក់ ក្នុងនោះ គ្រួសារត្រូវខ្យល់កន្ត្រាក់០៣គ្រួសារ គ្រួសារចាស់ជរា ទីទាល់ក្រ ០៤គ្រួសារ សរុបអំណោយ អង្ករ១០៥គីឡូក្រាម, គ្រឿងឧបភោគបរិភោគ សម្ភារៈផ្ទះបាយ និងសម្ភារៈគេងគិតជារៀល=១,៤៤០,០០០រៀល

\+ អនុសាខាកាកបាទក្រហមកម្ពុជាស្រុក រួមជាមួយក្រុមកាកបាទក្រហមកម្ពុជាឃុំបានចុះសួរសុខទុក្ខ និងនាំយកអំណោយមនុស្សធម៌របស់អនុសាខាកាកបាទក្រហមកម្ពុជាស្រុក ទៅចែកជូនដល់ចាស់ជរាក្រីក្រគ្មានទីពឹងចំនួន៥គ្រួសារ៖ នៅឃុំល្វាសរ២គ្រួសារ ឃុំបឹងគ្រំ ១គ្រួសារ ឃុំភូមិធំ ២គ្រួសារ ដោយក្នុង១គ្រួសារទទួលបាន អង្ករ២៥គីឡូក្រាម ទឹកត្រី១យួរ ទឹកស៊ីអ៊ីវ១យួរ ត្រីខ១យួរ ក្រៅពីនេះមានសម្ភារៈផ្ទះបាយ និងថវិកា៥០.០០០រៀល។

\+ បានសហការណ៍ជាមួយក្រុមការងារកាកបាទក្រហមឃុំ រួមមាន នាំយកអំណោយកាកកបាទក្រហមជូនគ្រួសាររងគ្រោះដោយ អគ្គិភ័យនៅភូមិទឹកឃ្លាំង ឈ្មោះ ទឹម កល្យាណនិងប្រពន្ធឈ្មោះ យឹម សុផល ដែលរងគ្រោះដោយអគ្គីភ័យឆ្លងចរន្តអគ្គិសនីកាលពីព្រឹកថ្ងៃទី១៣ខែធ្នូឆ្នាំ២០១៩វេលាម៉ោង៩,១០ព្រឹកម៉ិអំណោយជាសម្ភារៈមាន៖ សម្ភារៈផ្ទះបាយ១កំប្លេ, ថវិកាសាលាស្រុក៥០,០០០រៀល, ថវិកាឃុំទឹកឃ្លាំង ២០ម៉ឺនរៀល និងថវិកាសប្បុរសជន១៦ម៉ឺនរៀល សរុបថវិកា ៤១០,០០០រៀល។

## ៣.៣. ការគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ

### ៣.៣.១-ការងាររៀបចំដែនដីនគររូបនីយកម្ម សំណង់និងភូមិបាលៈ

*១).ការងារសុរិយោដី និងភូមិសាស្ត្រៈ*

*ក).ការងារចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ៖*

\+ ចេញប័ណ្ណបានចំនួន ១៦៨៩ នៅភូមិអរិយក្សត្រ (ក្នុងនោះ ៣១០ ប័ណ្ណ ចែកជូនប្រជាពលរដ្ឋដោយផ្ទាល់ និង ១៣៧៩ ប័ណ្ណ តម្រូវឲ្យទៅដកនៅមន្ទីរ ដនសស ខេត្តកណ្តាល )

\+ កំពុងចុះបញ្ជីនៅភូមិទួលមាស ឃុំអរិយក្សត្រ

- ➢ លទ្ធផលទទួលបាន ៤៩៦១ក្បាលដី

*ខ).ការងារចុះបញ្ជីដាច់ដោយដុំ៖*

\+ បានធ្វើប័ណ្ណថ្មី (២៤៨ប័ណ្ណ)៖ ក្នុងនោះរួមមានៈ ឃុំអរិយក្សត្រ ២២០ប័ណ្ណ, ឃុំសារិកាកែវ ០៥ប័ណ្ណ, ឃុំកោះរះ ០៣ប័ណ្ណ, ឃុំពាមឧកញ៉ាអុង ០៩ប័ណ្ណ, ឃុំព្រែកក្មេង ០១ប័ណ្ណ, ឃុំទឹកឃ្លាំង ០២ប័ណ្ណ , ឃុំល្វាសរ ០៤ប័ណ្ណ,ឃុំបឹងគ្រំ០១ប័ណ្ណ,ឃុំថ្មគរ០១ប័ណ្ណ,ឃុំភូមិធំ០៣ប័ណ្ណ(បញ្ជូនទៅមន្ទីរ ដ.ន.ស.ស)។

+ លក់ផ្តាច់ចំនួន(៧៥)ប័ណ្ណរួមមានៈ ឃុំអរិយក្សត្រ ៤៤ប័ណ្ណ, ឃុំសារិកាកែវ ១៦ប័ណ្ណ, ឃុំកោះរះ ០៧ប័ណ្ណ, ឃុំថ្មគរ ០២ប័ណ្ណ, ឃុំពាមឧកញ៉ាអុង០៣ប័ណ្ណ,ឃុំព្រែករៃ០១ប័ណ្ណ,ឃុំព្រែកក្មេង០១ប័ណ្ណ និងឃុំបឹងគ្រំចំនួន ០១ប័ណ្ណ (បញ្ជូនទៅមន្ទីរ ដ.ន.ស.ស)។

+ លំហូរមរតកចំនួន(០៨)ប័ណ្ណរួមមានៈ ឃុំបឹងគ្រំ ០១ ប័ណ្ណ ,ឃុំអរិយក្សត្រ ០១ ប័ណ្ណ ,ឃុំសារិកាកែវ ០២ប័ណ្ណ ,ឃុំពាមឧកញ៉ាអុង ០២ ប័ណ្ណ, ឃុំកោះរះ ០២ ប័ណ្ណ (បញ្ជូនទៅមន្ទីរ ដ.ន.ស.ស)។

+ ទុតិយតាចំនួន(០៩)ប័ណ្ណរួមមាន៖ ឃុំពាមឧញ៉ាអុង ០៤ប័ណ្ណ, ឃុំសារិកាកែវ ០៥ប័ណ្ណ (ញ្ជូនទៅមន្ទីរ ដ.ន.ស.ស)។

+ អំណោយផ្តាច់ចំនួន(០២) ប័ណ្ណរួមមានៈ នៅឃុំអរិយក្សត្រ ០១ប័ណ្ណ, ឃុំសារិកាកែវ ០១ ប័ណ្ណ (បញ្ជូនទៅមន្ទីរ ដ.ន.ស.ស)។

+ លក់បំបែកក្បាលដីចំនួណ(៤២៧) ប័ណ្ណរួមមានៈ នៅឃុំអរិយក្សត្រ ៤២២ប័ណ្ណ, ឃុំសារិកាកែវ ០១ប័ណ្ណ, ឃុំពាមឧកញ៉ាអុង ០២ប័ណ្ណ, ឃុំព្រែករៃ ០១ប័ណ្ណ, ឃុំព្រែកក្មេង ០១ប័ណ្ណ (បញ្ជូនទៅមន្ទីរ ដ.ន.ស.ស)។

+ ប្តូររូបភាពដីចំនួន(១៣) ក្បាលដីរួមមានៈ ឃុំទឹកឃ្លាំង ០៣ប័ណ្ណ, ឃុំព្រែករៃ ០២ប័ណ្ណ, ឃុំព្រែកក្មេង០៣ប័ណ្ណ, ឃុំបឹងគ្រំ ០១ប័ណ្ណ, ឃុំភូមិធំ ០៣ប័ណ្ណ, ឃុំពាមឧកញ៉ាអុង ០១ប័ណ្ណ (បញ្ជូនទៅមន្ទីរ ដ.ន.ស.ស)។

+ បង្រួមក្បាលដី(០១) ក្បាលដីៈ នៅឃុំពាមឧកញ៉ាអុង (បញ្ជូនទៅមន្ទីរ ដ.ន.ស.ស)។

*២).ការដោះវិវាទដីធ្លី*

*ក).វិវាទក្នុងគណៈកម្មការសុរិយោដី(គ្មាន)*

*ខ).វិវាទក្រៅគណៈកម្មការសុរិយោដី៖*

- ដើមបណ្តឹងឈ្មោះ សៀន សយ ជាព្រះចៅអធិការវត្តមាត់ក្រសាស់ ប្តឹងពីឈ្មោះ អាត ចន្ថា និងឈ្មោះឃឹម រិទ្ធី រឿងរំលោភយកដីវត្ត ស្ថិតនៅភូមិក្តីកណ្តាល ឃុំសារិកាកែវ ជាលទ្ធផលបានបញ្ចប់សំណុំរឿង
- ដើមបណ្តឹងឈ្មោះ ចាប បូ ប្តឹងពីឈ្មោះ សុំ សឹង និង ង៉ុយ ពៅ រឿងរំលោភយកដី ស្ថិតនៅភូមិបារុង ឃុំបារុង ជាលទ្ធផលបានបញ្ចប់សំណុំរឿង។
- ដើមបណ្តឹងឈ្មោះ ចាន់ អេង ប្តឹងពីឈ្មោះ ស្រី ចាន់ថន រឿងជាន់ព្រំដី ស្ថិតនៅភូមិបារុង ឃុំបារុង ស្រុកល្វាឯម ខេត្តកណ្តាល ជាលទ្ធផលបានបញ្ចប់សំណុំរឿង។
- ដើមបណ្តឹងឈ្មោះ បាន ខឿន ប្តឹងពីឈ្មោះ ស្តើង ចង្រិត រឿងធ្វើរបងព្រំ ស្ថិតនៅភូមិជ្រោយជ្រៃ ឃុំសំបួរ ជាលទ្ធផលបានបញ្ចប់សំណុំរឿង។
- ដើមបណ្តឹងឈ្មោះ អ៊ុន ចាន់ និង សៅ ហៀម គណៈកម្មការវត្ត និងជាតំណាងចៅអធិការវត្ត ប្តឹងពីគ្រូបង្រៀនបឋមសិក្សាពោធិ៍ធំចំនួន ០៥នាក់ រឿងរំលោភយកដីវត្ត ស្ថិតនៅភូមិពោធិ៍ធំ ឃុំអរិយក្សត្រ ជាលទ្ធផលដើមបណ្តឹងឯកភាពដកពាក្យបណ្តឹងដើម្បីបញ្ចប់រឿង។
- ដើមបណ្តឹងឈ្មោះ ផាត់ សារ៉ាន់ ប្តឹងពីឈ្មោះ រឿន នៅ រឿងរំលោភយកដី ស្ថិតនៅភូមិល្វាសរ ឃុំល្វាសរ កំពុងបន្តដោះស្រាយ។ (ទទួលពីខាងអន្តរវិស័យស្រុក)

– ដើមបណ្ដឹងឈ្មោះ អ៊ួន ណារី ប្ដឹងពីឈ្មោះ ឆាយ គឹម រឿងដណ្ដើមដីគ្នាជាម្ចាស់កម្មសិទ្ធិ ស្ថិតនៅ ភូមិពោធិ៍ធំ ឃុំអរិយក្សត្រ កំពុងបន្តដោះស្រាយ។ (ទទួលពីខាងអន្តរវិស័យស្រុក)

– ដើមបណ្ដឹងឈ្មោះ សួន ហ៊ុនឡា ប្ដឹងពីឈ្មោះ ស៊ឹម ប៊ុរី រឿងសង់ឃ្លាំងចូលព្រំដី ស្ថិតនៅភូមិទួលមាស ឃុំអរិយក្សត្រ កំពុងបន្តដោះស្រាយ។ (ទទួលពីខាងអន្តរវិស័យស្រុក)

– ដើមបណ្ដឹងឈ្មោះ ជា សេងណារី ប្ដឹងពីឈ្មោះ ដៃ សុខុន រឿងធ្វើរបងចូលព្រំដី ស្ថិតនៅភូមិព្រែកក្រូច ឃុំភូមិធំ កំពុងបន្តដោះស្រាយ។ (ទទួលពីខាងអន្តរវិស័យស្រុក)

– ដើមបណ្ដឹងឈ្មោះ ស្រី ចាន់ថន ប្ដឹងពីឈ្មោះ ស៊ុន សូត្រ រឿងជាន់ព្រំដីគ្នា ស្ថិតនៅក្នុងភូមិពាមតាឯក ឃុំពាមឧកញ៉ាអុង កំពុងបន្តដោះស្រាយ។ (ទទួលពីខាងអន្តរវិស័យស្រុក)

– ដើមបណ្ដឹងឈ្មោះ ផែង សៀប ប្ដឹងពីឈ្មោះ ជុំ សុឃន រឿងរំលោភយកដីទៅលក់ ស្ថិតនៅភូមិព្រែកក្រូច ឃុំភូមិធំ កំពុងបន្តដោះស្រាយ។ (ទទួលពីខាងអន្តរវិស័យស្រុក)

– ដើមបណ្ដឹងឈ្មោះ លឹម អាយ ប្ដឹងពីឈ្មោះ លឹម មួយ រឿងដណ្ដើមដីគ្នាជាម្ចាស់កម្មសិទ្ធិ ស្ថិតនៅ ភូមិព្រែកតាប្រាំង ឃុំភូមិធំ កំពុងបន្តដោះស្រាយ។ (ទទួលពីខាងអន្តរវិស័យស្រុក)

– ដើមបណ្ដឹងឈ្មោះ សំ សារ៉ែន ប្ដឹងពីឈ្មោះ ធុច សាមាន រឿងដណ្ដើមដីគ្នាជាម្ចាស់កម្មសិទ្ធិ ស្ថិតនៅ ភូមិព្រែកជ្រៃ ឃុំព្រែកឫស្សី កំពុងបន្តដោះស្រាយ។ (ទទួលពីខាងអន្តរវិស័យស្រុក)

– ដើមបណ្ដឹងឈ្មោះឈ្មោះ ឃួន សុគន្ធី ប្ដឹងពីឈ្មោះ ផ្លុង សុខុន រឿងជាន់ព្រំគ្នា ស្ថិតនៅភូមិអរិយក្សត្រ ឃុំអរិយក្សត្រ ស្រុកល្វាឯម ខេត្តកណ្ដាល ទើបទទួលពាក្យបណ្ដឹងពីខាងអន្តរវិស័យស្រុក។

– ដើមបណ្ដឹងឈ្មោះ ឃួន សុគន្ធី ប្ដឹងពីឈ្មោះ កង គឹមយន រឿងជាន់ព្រំគ្នា ស្ថិតនៅក្នុងភូមិអរិយក្សត្រ ឃុំអរិយក្សត្រ ស្រុកល្វាឯម ខេត្តកណ្ដាល ទើបទទួលពាក្យបណ្ដឹងពីខាងអន្តរវិស័យស្រុក ។

៣).ការងារដើរផ្លូវ:

+ បានចុះបញ្ជី ០០ក្បាលដី

+ កំពុងស្នើសុំចុះបញ្ជីបានចំនួន ០៣ក្បាលដី

+ បានចុះពិនិត្យវាស់វែងដីបឹង និងទំនប់អាងទឹក

- បឹងក្រពើ ស្ថិតនៅឃុំទឹកឃ្លាំង និងឃុំថ្មគរ
- ទំនប់អាងទឹកយុទ្ធសាស្ត្រទី២ ស្ថិតនៅឃុំភូមិធំ
- បឹងអន្លង់ក្រសាំង ស្ថិតនៅឃុំកោះរះ និងឃុំព្រែកក្មេង
- បឹងកន្លែងត្រាវ ស្ថិតនៅឃុំភូមិធំ
- បឹងស្ពើងល្ពៅ ស្ថិតនៅឃុំទឹកឃ្លាំង
- បឹងបូកវែង ស្ថិតនៅឃុំទឹកឃ្លាំង
- បឹងប្រកែ ស្ថិតនៅឃុំទឹកឃ្លាំង
- ទំនប់អាងទឹកយុទ្ធសាស្ត្រទី១ ស្ថិតនៅឃុំភូមិព្រែករ៉ៃ
- ទំនប់អាងទឹកសហករណ៍ ស្ថិតនៅឃុំភូមិធំ

៤).ការងារវាស់វែង:

+ បានចុះវាស់ដី ( ប្លង់ទន់ ) បានចំនួន ៨៧៥ ក្បាលដី

+ បានចុះវាស់វែងដីតាមការស្នើសុំរបស់តុលាកាបានចំនួន០២ក្បាលដីចំនួនពីឃុំគឺៈ ឃុំព្រែកវៃ ឃុំពាមឧកញ៉ាអុង

+ បានចុះវាស់វែងស្វែងរកព្រំបានចំនួន ០០ ក្បាលដី

*៥).ការងាររៀបចំដែនដី នគរូបនីយកម្ម និងសំណង់:*

+ បានចុះយកឃាមការហេដ្ឋារចនាសម្ព័ន្ធប្លង់គោលក្នុងស្រុកល្វាឯម។

+ បានពិនិត្យសំណើសុំអនុញ្ញាតសាងសង់បានចំនួន(០៥)ច្បាប់

+ បានចុះពិនិត្យការដ្ឋានសាងសង់បាន ១០ កន្លែង

+ សំណង់ចូលតាមរយៈច្រកស្រុកល្វាឯមបានចំនួន ០២ ច្បាប់

*៦).ការងារទំនាស់ ៖ទទួលពាក្យបណ្តឹង (គ្មាន)*

*៧).សកម្មភាពផ្សេងៗ*

+ ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៨ ប្រជុំការងារផ្ទេរប្លង់ទន់ដឹកនាំដោយលោក គឹម គីរ៉ា អភិបាលស្រុកល្វាឯម។

+ ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៨ ពេលល្ងាចប្រជុំដោះស្រាយការចុះបញ្ជីដីបម្រុងរបស់ស្រុក ។

+ ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៨ ប្រជុំជាមួយប្រជាពលរដ្ឋរឿងដីដុះមាត់ទន្លេក្រោមអធិបតីភាព **ឯកឧត្តម ប៉ាត់ សុខ** ទីប្រឹក្សាក្រសួង ដ.ន.ស។

+ ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០៩ ប្រជុំសម្របសម្រួលវិវាទដីផ្លូវជាមួយប្រជាពលរដ្ឋ និងក្រុមហ៊ុន 7NG។

+ ថ្ងៃទី ០៤ ខែកុម្ភៈ ឆ្នាំ២០១៩ ប្រជុំគណៈកម្មការដើរដ្ឋថ្នាក់ស្រុក។

+ ថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ២០១៩ រៀបចំបិទផ្សាយដីអូរនៅភូមិខ្សាច់ និងភូមិអរិយក្សត្រ ។

+ ថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ២០១៩ ប្រជុំនៅសាលាខេត្តស្តីពីការស្នើសុំវាស់វែងហ៊ុំព័ទ្ធព្រំដីរបស់ក្រុមហ៊ុន ING។

+ ថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ២០១៩ គណៈកម្មការដើរដ្ឋថ្នាក់ស្រុកចុះពិនិត្យ និងវាយតម្លៃដីនៅឃុំព្រែកក្មេង , ឃុំកោះរះ របស់ក្រុមហ៊ុន៧NG ទៅ ណុប ដារ៉ា។

+ ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៩ គណៈកម្មការដើរដ្ឋថ្នាក់ស្រុកចុះពិនិត្យ និងវាយតម្លៃដីនៅឃុំភូមិធំ, ឃុំព្រែកវៃ និងឃុំទឹកឃ្លាំងប្រមាណ ៩៨ហ.ត។

+ ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៩ ប្រជុំដោះស្រាយដីជាន់នៅលើដីរបស់ឈ្មោះស៊ុន សូត្រ ដែលក្រុមហ៊ុន7NG ធ្វើប័ណ្ណរួច។

+ ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៩ ប្រជុំការងារពាក់ព័ន្ធប្លង់ទន់នៅសាលាស្រុកល្វាឯម។

+ ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៩ ពេលព្រឹកប្រជុំគណៈកម្មការសុរិយោដីថ្នាក់ខេត្តនៅសាលាខេត្តកណ្តាល ពេលល្ងាចប្រជុំប្រចាំខែនៅមន្ទីរ ដ.ន.ស.ស ខេត្តកណ្តាល។

+ ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៩ ប្រជុំគណៈកម្មការដើរដ្ឋថ្នាក់ស្រុកនៅសាលាស្រុកល្វាឯម។

+ ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៩ បិទផ្សាយបញ្ចប់ និងទទួលពាក្យបណ្តឹងពីប្រជាពលរដ្ឋនៅឃុំអរិយក្សត្រ។

+ ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩ ប្រជុំណែនាំរបស់អគ្គនាយកដ្ឋានសុរិយោដីនៅមន្ទីរ ដនសស។

+ ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៩ ប្រជុំពិសេសនៅមន្ទីរ ដ.ន.ស.ស ខេត្តកណ្ដាល។

+ ថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៩ ប្រជុំក្រុមវាលនៅឃុំអរិយក្សត្រ។

+ ថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៩ ប្រជុំដោះស្រាយវិវាទដីធ្លីនៅឃុំថ្មគរ។

+ ថ្ងៃទី ១៤ ខែមីនា ឆ្នាំ២០១៩ ប្រជុំដោះស្រាយវិវាទដីធ្លីនៅឃុំអរិយក្សត្រ។

+ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០១៩ ប្រជុំការងារពិសេសនៅមន្ទីដនសសកណ្ដាល។

+ ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៩ ប្រជុំការងារវាស់វែងប្លង់ទន់នៅសាលាស្រុក។

+ ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៩ កិច្ចប្រជុំវឌ្ឍនភាពនៃការចុះបញ្ជីដីធ្លីលក្ខណៈប្រព័ន្ធនៅក្រសួង ដ.ន.ស.ស។

+ ថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៩ ប្រកាសតំបន់វិនិច្ឆ័យភូមិទួលមាស និងភូមិពោធិ៍ធំ ឃុំអរិក្សត្រ។

+ ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៩ ប្រជុំគណៈកម្មការសុរិយោដី និងគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្តនៅសាលាខេត្តកណ្ដាល។

+ ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៩ ពេលព្រឹកប្រជុំសំរបសំរួលវិវាទដីជាន់គ្នារវាងលោក ថេង ពុទ្ធិតា និងលោកស្រី ផុង សុខដាណេ ស្ថិតនៅឃុំភូមិធំ និងពេលល្ងាចប្រជុំសម្របសម្រួលដី អាន អ៊ាញ ជាន់ជាមួយដីក្រុមហ៊ុន7NG ដីក្រុមហ៊ុន ប៉េង ហួត ស្ថិតនៅឃុំពាមឧកញ៉ាអុង មានទំហំប្រមាណជាង២ហ.ត។

+ ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៩ ពេលព្រឹកប្រជុំសំរបសំរួលវិវាទដីរំលោភលើកិច្ចសន្យារវាងឈ្មោះ អួន ចិន្ដានិងឈ្មោះ អួន ស្រីមុំ បងប្អូនបង្កើត ស្ថិតនៅឃុំភូមិបារុង ពេលល្ងាចប្រជុំសំរបសំរួលដីជាន់គ្នានៅឃុំល្វាសរ។

+ ថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩ ប្រជុំដោះស្រាយវិវាទដីធ្លីចំនួន ០២ករណី ស្ថិតនៅឃុំភូមិធំ និងឃុំព្រែកឫស្សី។

+ ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៩ ប្រជុំដោះស្រាយវិវាទដីធ្លីរវាងក្រុមហ៊ុន ៧NGនិងប្រជាពលរដ្ឋនៅឃុំបារុង ជាលទ្ធផលភាគីទាំងសងខាងព្រមព្រៀងគ្នាបញ្ចប់រឿង។

+ ថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៩ សិក្ខាសាលាស្ដីពីពីការគិតមូលដ្ឋានពន្ធប្រថាប់ត្រាចំពោះការផ្ទេរកម្មសិទ្ធិឫផ្ទេរអចលនវត្ថុនៅសាលាខេត្តកណ្ដាល។

+ ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៩ ចូលរួមដោះស្រាយទំនាស់ដីផ្លូវ ស្ថិតនៅភូមិវាលធំ ឃុំពាមឧកញ៉ាអុង ដឹកនាំដោយលោក ភឹម ភីរ៉ា អភិបាលស្រុក និងចូលរួមដោយលោក កន សុខកាយ អភិបាលរងស្រុក។

+ ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៩ ប្រជុំការចុះបញ្ជីដីរដ្ឋនៅសាលាខេត្តកណ្ដាល។

+ ថ្ងៃទី ២៩ ខែឧសភា ឆ្នាំ២០១៩ ប្រជុំការសាងសង់រោងចក្រផលិតវារីអគ្គិសនីកំលាំង ៤០០ $MH_z$ នៅសាលាខេត្តកណ្ដាល។

+ ថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០១៩ វាស់វែងដីបឹងឈូងគស្ថិតនៅភូមិផ្លូវត្រី និងភូមិទឹកឃ្លាំង។

+ ថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០១៩ ប្រជុំសាកសួរពីបញ្ហាប្រជាពលរដ្ឋចូលកាន់កាប់ដីខុសច្បាប់ស្ថិតនៅ ភូមិព្រែកក្រូច ឃុំភូមិធំ លើផ្ទៃដីទំនាស់មានប្រមាណ ៧០ហិកតា ។

+ ថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ២០១៩ ប្រជុំវឌ្ឍនភាពការងារចុះបញ្ជីដីធ្លីនៅក្រសួង ដនសស។

+ ថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ២០១៩ ប្រជុំនៅមន្ទីរ ដ.ន.ស.ស ខេត្តកណ្ដាល ធ្វើផែនការ។

+ ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៩ ប្រជុំនៅមន្ទីរ ដ.ន.ស.ស ខេត្តកណ្ដាល បន្តធ្វើផែនការ។

+ ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៩ កិច្ចប្រជុំអំពីកាផ្ដល់សេវាសាធារណៈជូនប្រជាពលរដ្ឋក្នុងស្រុកល្វាឯម ដឹកនាំដោយលោក ភឹម ភីរ៉ា អភិបាលស្រុកល្វាឯម។

+ ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ កិច្ចប្រជុំការងារធ្វើរបាយការណ៍ និងការគ្រប់គ្រងបុគ្គលិក ដឹកនាំដោយលោក សៀ មុយខួច អនុប្រធានមន្ទីរ ដ.ន.ស.ស ខេត្តកណ្ដាល។

+ ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៩ កិច្ចប្រជុំគណៈកម្មការសុរិយោដីខេត្ត និងគណៈកម្មធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិត ម៉ៅ ភិរុណ** អភិបាលខេត្តកណ្ដាល។

+ ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៩ ពេលព្រឹកប្រជុំក្រុមប្រឹក្សាស្រុក និងពេលល្ងាចចុះពិនិត្យដីនៅឃុំពាមឧកញ៉ាអុង។

+ ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៩ កិច្ចប្រជុំការងារចុះបញ្ជីដីជាប្រព័ន្ធនៅមន្ទីរ ដ.ន.ស.ស។

+ ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៩ កិច្ចប្រជុំអំពីការផ្ដល់សេវាសាធារណៈជូនប្រជាពលរដ្ឋក្នុងស្រុកល្វាឯម ដឹកនាំដោយលោក ភឹម ភីរ៉ា អភិបាលស្រុកល្វាឯម។

+ ថ្ងៃទី១-៣ ខែកក្កដា ឆ្នាំ២០១៩ បានចូលរួមសិក្ខាសាលានៅខេត្តកំពត។

+ ថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៩ ប្រជុំសម្របសម្រួលទិញដីអគ្គិសនី ៤០០MW ក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិត ម៉ៅ ភិរុណ** អភិបាលខេត្តកណ្ដាល។

+ ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៩ បានចូលរួមកិច្ចប្រជុំគណៈកម្មការសុរិយោដីថ្នាក់ខេត្ត និងគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិត ម៉ៅ ភិរុណ** អភិបាលខេត្តកណ្ដាល។

+ ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៩ : កិច្ចប្រជុំគណៈកម្មការសុរិយោដីថ្នាក់ខេត្ត និងគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិត ម៉ៅ ភិរុណ** អភិបាលខេត្តកណ្ដាល។

+ ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៩ បានចូលរួមកិច្ចប្រជុំការងារចំពោះកិច្ច ដើម្បីសិក្សា អង្កេតស្រាវជ្រាវ ករណីអនុញ្ញាតជាគោលការណ៍ស្ពានស្ទឹង ព្រែកធម្មជាតិ របស់ក្រុមហ៊ុន អាយអិនជី ហូលឌីង ទំហំ ១៨០០ហ.ត ស្ថិតនៅឃុំបារុង ស្រុកល្វាឯម និងឃុំវិហារសួគ៌, ឃុំព្រែកអំពិល និងឃុំព្រែកតាមាក់ ស្រុកខ្សាច់កណ្ដាល ក្រោមអធិបតីភាព **ឯកឧត្តម គង់ សោភ័ណ្ឌ** អភិបាលរងខេត្តកណ្ដាល។

+ ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៩ បានចូលរួមកិច្ចប្រជុំពិនិត្យនិងកែសម្រួលផែនការហេដ្ឋារចនាសម្ព័ន្ធ និងប្លង់គោលប្រើប្រាស់ដីរវាងមន្ទីរ ពាក់ព័ន្ធ និងរដ្ឋបាលស្រុកល្វាឯម។

+ ថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៩ បានចូលរួមកិច្ចប្រជុំត្រួតពិនិត្យ ពិភាក្សាស្ដីពីប្លង់គោល និងពន្ធដារ ក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិត ម៉ៅ ភិរុណ** អភិបាលខេត្តកណ្ដាល។

+ ថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៩ បានចូលរួមចុះសម្របសម្រួលជាមួយប្រជាពលរដ្ឋពីការតវ៉ាផលប៉ះពាល់ប្លង់ហេដ្ឋារចនាលើក្បាលដីក្នុងពេលបិទផ្សាយជាសាធារណៈ នូវឯកសារនៃការវិនិច្ឆ័យ នៅឃុំអរិយក្សត្រ ដឹកនាំដោយលោក លឹម ចាន់សូភី ប្រធានមន្ទីរ ដ.ន.ស.ស ខេត្តកណ្ដាល។

+ ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៩ កិច្ចប្រជុំពិភាក្សាករណីប្រជាពលរដ្ឋ ១០គ្រួសារ ស្នើសុំផ្ទេរសិទ្ធិដីទំហំ១៧ហ.ត ស្ថិតនៅអាងទឹកកំពីងពួយ ភូមិព្រែកជ្រៃ ឃុំព្រែកឫស្សី ស្រុកល្វាឯម ខេត្តកណ្ដាល ក្រោមអធិបតីភាព **ឯកឧត្តម គីម រិទ្ធី** អភិបាលរងខេត្តកណ្ដាល។

+ ថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៩ បានសហការជាមួយព្រះរាជអាជ្ញាខេត្តចុះអនុវត្តសាលក្រម នៅភូមិពាមតាឯក ឃុំពាមឧកញ៉ាអុង ដឹកនាំដោយលោក កន សុខកាយ អភិបាលរងស្រុកល្វាឯម និងពេលល្ងាចចូលរួមកិច្ចប្រជុំផ្សព្វផ្សាយលិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងការងាររ៉ែ និងថាមពល, ការងារសាធារណៈ និងដឹកជញ្ជូន។

+ ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៩ កិច្ចប្រជុំគណៈកម្មការសុរិយោដីថ្នាក់ស្រុក ដឹកនាំដោយលោក ភឹម គីរ៉ា អភិបាលស្រុកល្វាឯម។

+ ថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៩ ចុះត្រួតពិនិត្យសំណង់ដែលបានបាក់ស្រុតចូលក្នុងព្រែក(ចុះឃាត់ពីរដងបានធ្វើរបាយការណ៍ជូនសាលាស្រុក និងមន្ទីររួចហើយ) ដឹកនាំដោយលោក កន សុខកាយ អភិបាលស្រុរងល្វាឯម។

+ ថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៩ កិច្ចប្រជុំគណៈកម្មការសុរិយោដី និងគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋ ថ្នាក់ខេត្ត ក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិត ម៉ៅ ភិរុណ** អភិបាលខេត្តកណ្ដាល។

+ ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៩ បានចូលរួមកិច្ចប្រជុំជាមួយប្រតិភូអគ្គាធិការ នៃអគ្គាការដ្ឋានក្រសួង ដ.ន.ស.ស។

+ ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៩ : កិច្ចប្រជុំគណៈកម្មការសុរិយោដី និងគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋ ថ្នាក់ខេត្ត ក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិត ម៉ៅ ភិរុណ** អភិបាលខេត្តកណ្ដាល។

**៣.៣.២-ការងារបរិស្ថាន**

*១).ការងារត្រួតពិនិត្យការបំពុលៈ*

- បានចុះពិនិត្យផ្ទាល់ដល់ទីតាំងសិប្បកម្មអប់រំណែនាំ និងផ្សព្វផ្សាយ អោយពួកគាត់ចេះគ្រប់គ្រងសំណល់រឹង រាវនៅតាមបណ្ដាទីតាំងមានដូចខាងក្រោមៈ
  + សិប្បកម្មផលិតទឹកកក បានចំនួន ០៤លើក ស្មើ ០៦មូលដ្ឋានឃុំ
  + សិប្បកម្មផលិតទឹកត្រីបានចំនួន ០៣លើក ស្មើ០១មូលដ្ឋានឃុំ
  + អាជីវកម្មកាប់ជ្រូកបានចំនួន ០៤លើកស្មើ ០៤មូលដ្ឋានឃុំ
  + ចុះពិនិត្យផ្សារបានចំនួន ០៦លើក ស្មើនិង ០៤មូលដ្ឋាន ឃុំ
  + ចុះពិនិត្យអាជីវកម្ម ទិញ-លក់ អេតចាយបានចំនួន ០៤លើក ស្មើ០១មូលដ្ឋាននៅឃុំអរិយក្សត្រ។

*២).ការងារបណ្ដុះបណ្ដាលៈ* ចូលរួមរៀនវគ្គបណ្ដុះបណ្ដាល ០១លើក ស្ដីពីការពង្រឹងសមត្ថភាពជំនាញបច្ចេកទេសដល់មន្ត្រីរាជការ តាមការិយាល័យបរិស្ថានក្រុង-ស្រុក នៃមន្ទីររាជធានី-ខេត្ត រយៈពេល០៥ថ្ងៃ វគ្គ៣ នៅខេត្តកែប។

*៣).ការងារត្រួតពិនិត្យសំណល់សំរាមៈ*

- បានចុះត្រួតពិនិត្យរណ្ដៅសម្រាមផ្នែកទីផ្សារបានចំនួន២០លើក ស្មើនិង០៤មូលដ្ឋានឃុំរួមមានៈ ឃុំអរិយក្សត្រ, សារិកាកែវ, ពាមឧកញ៉ាអុង និងឃុំកោះរះ។
- ចុះពិនិត្យមើលចំណុចទីតាំងដែលធ្លាប់បង្កើតសំណល់សម្រាមបានចំនួន ៤៨លើក ស្មើនិង ០៧ មូលដ្ឋានឃុំរួមមានៈ ឃុំអរិយក្សត្រ, សារិកាកែវ, ពាមឧកញ៉ាអុង, កោះរះ, ថ្មគរ, ទឹកឃ្លាំង និងឃុំព្រែករៃ។
  ➢ បញ្ហាសំណល់សម្រាមទាំង០៧ ឃុំខាងលើមាន០៥ឃុំសំណល់សម្រាមច្រើនជាងគេក្នុងនោះរួមមានឃុំៈ ឃុំអរិយក្សត្រ, សារិកាកែវ, ពាមឧកញ៉ាអុង, កោះរះ និងឃុំព្រែករៃ។

❖ ប៉ុន្តែចាប់ពីពាក់កណ្តាលខែកុម្ភៈ មកដល់បច្ចុប្បន្ននេះសំណល់សម្រាមតាមបណ្តាលចំណុចបង្កើតមានសភាពទ្រើង ដោយសារបានការគិតគូរ របស់លោកអភិបាលស្រុក ធ្វើឡសម្រាប់ដុតសម្រាមចែកជូនតាមបណ្តាឃុំទាំង១៥ ចំនួន៥០ឡ សម្រាប់ដុតនៅតាមចំណុចទីតាំងដែលមានសម្រាម។

*៤).ការងារអនុវត្តលើកិច្ចសន្យា:* មានចំនួន១មូលដ្ឋានមន្ត្រីយើងបានសហការជាមួយក្រុមការងារថ្នាក់ស្រុក-ឃុំ ដែលដឹកនាំដោយលោក យី យ៉េន អភិបាលរងស្រុក ចុះពិនិត្យទីតាំងចិញ្ចឹមជ្រូករបស់ឈ្មោះ យ៉ា យ៉ុន នៅភូមិក្តីកណ្តាល ឃុំសារិកាកែវ (ប៉ះពាល់ក្លិនដល់អ្នកជិតខាង ប្រជាពលរដ្ឋជិតខាងប្តឹង)។

*៥).ការងារផ្សព្វផ្សាយ:*

– បានចូលរួមរៀនវគ្គផ្សព្វផ្សាយ លិខិតបទដ្ឋាននានាស្តីពីការបង្កើតយន្តការច្រកចេញ-ចូលតែមួយ ០១លើក។

– ចូលរួមវគ្គផ្សព្វផ្សាយស្តីពីការគ្រប់គ្រងសម្រាមសំណល់រឹងនៅតាមទីផ្សា រោងចក្រ ក្នុងភូមិសាស្ត្រខេត្តកណ្តាល ០១លើក។

– ចូលរួមវគ្គអប់រំផ្សព្វផ្សាយ ចំណេះដឹងបរិស្ថាន និងច្បាប់បរិស្ថានជាមួយក្រុមការងារការិយាល័យចំណេះដឹងព័ត៌មានបរិស្ថានខេត្តកណ្តាលបានចំនួន ០២លើក ស្មើ០២មូលដ្ឋានឃុំ៖ ឃុំព្រែករៃ និងឃុំល្វាសរ។

➢ *ការផ្សព្វផ្សាយមាន:*

– អនុក្រឹត្យលេខ:១១៣ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ស្តីពីការគ្រប់គ្រងសម្រាម សំណល់រឹងទីប្រជុំជន។

– ប្រកាសសអន្តរក្រសួងលេខ:១៩៥ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការកំណត់កម្រៃអតិបរិមានៃសេវាគ្រប់គ្រងសម្រាម សំណល់រឹងទីប្រជុំជន។

– ប្រកាសអន្តរក្រសួងលេខ:៨៦៨២ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៩ ស្តីពីការគ្រប់គ្រង និងការប្រើប្រាស់ចំណូល ពីការផាកពិន័យអន្តរការណ៍ចំពោះអំពើល្មើស និងអនុក្រឹត្យលេខ: ១១៣ស្តីពីការគ្រប់គ្រងសម្រាម សំណល់រឹងទីប្រជុំជន។

**៣.៣.៣-ការងារសាធារណការ:**

*ក).ការងារជួសជុលផ្លូវដីស គ្រួសក្រហម ផ្លូវបេតុង*

– តាមការត្រួតពិនិត្យរាល់សកម្មភាពការជួសជុល សាងសង់គ្រប់ប្រភេទផ្លូវខាងលើទទួលលទ្ធផលដូចខាងក្រោម៖

១.ឃុំអរិយក្សត្រ

\+ ភូមិខ្សាច់ ឃុំអរិយក្សត្រ: ជួសជុលផ្លូវដីសបានប្រវែង ៥០០ម៉ែត្រ, ទទឹងខ្នងលើ៨ម៉ែត្រ ពីចំណុចវត្តឧទម្ពរ ដល់មាត់ទន្លេ ឧបត្ថម្ភដោយឧកញ៉ា **យុន សៀអ៊ិចផត។**

\+ ភូមិអរិយក្សត្រ ឃុំអរិយក្សត្រ: ក្រាលបេតុងបានប្រវែង ៥០០ម៉ែត្រ, ទទឹង៥ម៉ែត្រ ឧបត្ថម្ភដោយសប្បុរសជន។

២.ឃុំពាមឧកញ៉ាអុង

\+ ក្នុងភូមិពាមតាឯក ឃុំពាមឧកញ៉ាអុង: ជួសជុលផ្លូវដីសបានប្រវែង ៥៥៣ម៉ែត្រ, ទទឹង៧ម៉ែត្រ កម្ពស់០,៣ម៉ែត្រទៅដល់០,៥ម៉ែត្រ កិច្ចសហការរវាងឃុំ និងក្រុមហ៊ុនរថយន្តដឹកដី។

+ នៅភូមិព្រៃកតាអុងទី២ ឃុំពាមឧកញ៉ាអុងៈ ក្រាលផ្លូវបេតុងបានប្រវែង ២៦៣ម៉ែត្រ, ទទឹង៤ ម៉ែត្រ ចំណាយអស់ថវិកា ១១០,០០០,០០០រៀល ថវិកាមូលនិធិឃុំ ឆ្នាំ២០១៩។

៣.ឃុំកោះរះ

+ នាយកដ្ឋានជួសជុលថែទាំផ្លូវថ្នល់របស់ក្រសួងសាធារណៈការ បានពង្រីកផ្លូវ3KD3 និងលើកកម្ពស់ដីសផុតទឹករួចក្រាលគ្រួសក្រហមបានប្រវែង ៣២០០ម៉ែត្រ, ទទឹង៧,៦ម៉ែត្រ ចំណុចចាប់ផ្តើមពីភូមិព្រៃក្មេង ឃុំកោះរះ ដល់ឃុំកោះរះ។

+ ភូមិកោះរះក្រោម ឃុំកោះរះៈ បានពង្រីកផ្លូវចាស់ រួចជួសជុលដីស ហើយក្រាលថ្មចំរុះបានប្រវែង ២៦០ម៉ែត្រ, ទទឹង៦ម៉ែត្រ ឧបត្ថម្ភដោយលោកស្រី មាស សុវណ្ណ។

+ បានចូលរួមបើកផ្លូវជាមួយរដ្ឋបាលសាលាស្រុក ពីឃុំកោះរះភ្ជាប់ពីផ្លូវ3KD3 ត្រង់ចំណុច PK0 +890 ហូតដល់ព្រៃកពោធិ៍ ឃុំពាមឧកញ៉ាអុង មានប្រវែង ១៨០០ម៉ែត្រ, ជើងក្រោម២០ម៉ែត្រ។

+ ភូមិកោះរះក្រោម ឃុំកោះរះ ក្រាលផ្លូវបេតុងបានប្រវែង ២១២ម៉ែត្រ, ទទឹងខ្នងលើ ៤ម៉ែត្រ ចំណាយអស់ថវិកា ៨៨,៥៦៨,០០០រៀល មូលនិធិឃុំឆ្នាំ២០១៩។

៤.ឃុំថ្មគរ

+ ភូមិថ្មគរ ឃុំថ្មគរៈ ជួសជុលផ្លូវដីសបានប្រវែង ៣៧០ម៉ែត្រ, ទទឹងខ្នងលើ៦ម៉ែត្រ ចំណាយអស់ថវិកា ៧០,៤១១,០០០រៀល ថវិកាមូលនិធិឃុំឆ្នាំ២០១៨។

+ ក្នុងឃុំថ្មគរ ក្រាលបេតុ បានប្រវែង ១.០០០ម៉ែត្រ, ទទឹង៥ម៉ែត្រ ចាប់ពីភូមិផ្លូវត្រី មកដល់ភូមិថ្មគរ ដែលបានឧបត្ថម្ភដោយក្រុមការងារថ្នាក់កណ្តាលចុះជួយឃុំថ្មគរ និងកំពុងសាងសង់បន្តទៀត។

៥.ឃុំទឹកឃ្លាំង

+ ជួយជុលផ្លូវដីសផ្លូវជាតិ 70B ហើយក្រាលគ្រួសក្រហមរួចរាល់១០០% ចាប់ពីវត្តសំរោង ភូមិទឹកឃ្លាំង ទៅភូមិសំរោងមានប្រវែង ២១៥០ម៉ែត្រ, ទទឹងខ្នងលើ ១០,៦ម៉ែត្រ កម្ពស់ពី១ម៉ែត្រ ទៅ១,៥០ម៉ែត្រ អនុវត្តដោយនាយកដ្ឋានជួសជុលថែទាំក្រសួងសាធារណការ។

៦.ឃុំបឹងគ្រំ

+ ជួសជុលផ្លូវដីសរួចក្រាលគ្រួសក្រហមបានប្រវែង ៨៤៤ម៉ែត្រ, ទទឹង៤ម៉ែត្រ កម្ពស់ចាក់ដីស ០,៤ម៉ែត្រ ទៅ០,៥ម៉ែត្រ ថវិកាមូលនិធិឃុំឆ្នាំ២០១៨ ចំណាយអស់ថវិកា ១៨,០០០,០០០រៀល។

៧.ឃុំល្វាសរ

+ ភូមិល្វាសរកណ្តាលៈ ជួសជុលផ្លូវដីសបានប្រវែង ១០២២មែត្រ, ទទឹង១០ម៉ែត្រ ថវិកាមូលនិធិឆ្នាំ២០១៧ ចំណាយអស់ទឹកប្រាក់ ១២៣,៦៤៨,៤៨២រៀល។

+ ភូមិល្វាសរកណ្តាលៈ ជួសជុលផ្លូវដីសបានប្រវែង ៤៨៥ម៉ែត្រ, ទទឹង១០ម៉ែត្រ ថវិកាមូលនិធិឃុំឆ្នាំ២០១៨ ចំណាយអស់ថវិកា ៣២,១០០,០០០រៀល។

+ ភូមិល្វាសរកណ្តាល និងល្វាសរក្រោមៈ ជួសជុលផ្លូវដីសបានប្រវែង ៧៨៣ម៉ែត្រ, ទទឹង ៦ ម៉ែត្រ ថវិកាមូលនិធិឃុំឆ្នាំ២០១៩ ចំណាយអស់ថវិកា ១៣៩,៣៤៤,៥៥៤រៀល។

៨.ឃុំភូមិធំ

+ ភូមិព្រៃក្រូច ឃុំភូមិធំៈ ជួសជុលផ្លូវដីសបានប្រវែង ១៣៥០ម៉ែត្រ, ខ្នងលើ១១ម៉ែត្រ កម្ពស់២ម៉ែត្រទៅ ២,៥ម៉ែត្រ អនុវត្តកងវិស្វកម្មមហាផ្ទៃ។

៩.ឃុំព្រៃករ

+ ភូមិព្រែកកោះ បានក្រាលផ្លូវបេតុងបានប្រវែង ១៨១ម៉ែត្រx៥ម៉ែត្រ ថវិកាមូលនិធិឃុំឆ្នាំ ២០១៩ ចំណាយថវិកាអស់ ៩៩,៥៥០,០០០រៀល។

+ ជួសជុលផ្លូវដីស ៣៨២ កងវិស្វកម្មក្រុម (ខ) បានជួសជុលផ្លូវខូចកាលទឹកជំនន់ឡើងឆ្នាំ២០១៨ និងក្រាលគ្រួសក្រហមចាប់ពីឃុំព្រែករៃ មកដល់ឃុំទឹកឃ្លាំង។

+ នាយកដ្ឋានជួសជុលថែទាំផ្លូវថ្នល់(សក)បានឈូសឆាយសំអាត ពីឃុំបាក់ដាវ មកដល់ឃុំព្រែកក្មេង បានប្រវែង ៤៣០០ម៉ែត្រ។

+ កងវិស្វកម្មក្រុម(ខ)បានជួសជុលផ្លូវកៅស៊ូ70B ដែលបានខូចខាតកាលទឹកជំនន់ឡើងឆ្នាំ២០១៨ ក្នុងឃុំពាមឧកញ៉ាអុង និងឃុំកោះរះ។

១០.<u>ឃុំព្រែកក្មេង</u>

+ ភូមិព្រែកក្មេង ឃុំព្រែកក្មេង៖ ក្រាលផ្លូវបេតុងបានប្រវែង ៦១៥ម៉ែត្រX6ម៉ែត្រ ថវិកាសាលាខេត្តកណ្ដាល។

+ ភូមិទួលទ្រា ឃុំព្រែកក្មេង ក្រាលបេតុងបានប្រវែង ១៦៥៥ម៉ែត្រ x ៥ម៉ែត្រ ថវិកាខេត្តកណ្ដាល

*<u>ខ).ការងារកសាងស្ពាន-លូ</u>*

- ស្ពានសាលាធទាន ឃុំថ្មគរ ប្រវែង ២៥ម៉ែត្រ x ៨ អនុវត្តបាន១០០% អនុវត្តដោយ (សក)
- ស្ពានកណ្ដាលជ្រោយពិសីប្រវែង ២៤ម៉ែត្រ x ៨ អនុវត្តបាន១០០%ស្ថាបនាដោយ (សក)
- ការដ្ឋានស្ពានបឹងគ្រំទី២ មានបណ្ដោយ ២០ម៉ែត្រx ៨ម៉ែត្រ សាងសង់បាន៤០%
- ការដ្ឋានស្ពានបឹងគ្រំទី៣ មានបណ្ដោយ ២០ម៉ែត្រ x ៨ម៉ែត្រ សាងសង់បាន៤៥%
- ការដ្ឋានស្ពានបឹងគ្រំទី៤ មានបណ្ដោយ ២០ម៉ែត្រ x ៨ម៉ែត្រ សាងសង់បាន១០០%
- ការដ្ឋានស្ពានកោះកែវ មានបណ្ដោយ ១៨ម៉ែត្រ x ៨ម៉ែត្រ សាងសង់បាន៤៥%
- ការដ្ឋានស្ពានព្រះអង្គខ្មៅ ឃុំសំបួរ មានបណ្ដោយ ៤៥ម៉ែត្រ x ៨ម៉ែត្រ សាងសង់បាន៧៥%

*<u>គ).ការថែទាំផ្លូវកៅស៊ូរបស់មន្ទីរសាធារណការខេត្តកណ្ដាល:</u>*

- ជួសជុលផ្លូវសំបុកមាន់ នៅភូមិទួលមាស ឃុំអរិយក្សត្រ PK 21+200
- ជួសជុលផ្លូវសំបុកមាន់ នៅភូមិក្ដីកណ្ដាល ឃុំសារិកាកែវ PK 27+700
- ជួសជុលចិញ្ចើមផ្លូវ គល់ស្ពានព្រែកជូនគឹម ឃុំសារិកាកែវ PK 27+440
- ជួសជុលផ្លូវផត នៅភូមិទួលមាស ឃុំអរិយក្សត្រ PK 21+200
- ជួសជុលផ្លូវបែកគ្រលុក សំបុកមាន់ ផ្លូវស្រុតផផត ចំនួន៥កន្លែង នៅភូមិតាដោ ឃុំសារិកាកែវនុងមានជួសជុលច្រើនកន្លែងទៀត

*<u>ឃ).សកម្មភាពផ្សេងៗ</u>*

- បានចូលរួមពង្រីកផ្លូវ និងតម្រង់ផ្លូវកោងទទឹងក្នុងភូមិអរិយក្សត្រ ឃុំអរិយក្សត្រ តភ្ជាប់ពីផ្លូវ380Aមកដល់ផ្លូវ70Bដើម្បីសាងសង់ផ្លូវបេតុង។
- បានចូលរួមជាមួយមន្ត្រីសាលាស្រុក លោកមេឃុំ ដើម្បីទប់ស្កាត់នូវការសាងសង់សំណង់លើចំណីផ្លូវនៅភូមិផ្លូវត្រី ឃុំថ្មគរ។
- បានចុះណែនាំប្រជាពលរដ្ឋកាត់បេតុងចាក់រំលោភលើចិញ្ចើមផ្លូវចំនួន ៤ឃុំ គឺឃុំអរិយក្សត្រ សារិកាកែវ ពាមឧកញ៉ាអុង និងឃុំកោះរះ។
- បានចុះបិទស្ទិកឃ័រចំណាំផ្លាកលើផ្លូវបេតុងក្នុងភូមិអរិយក្សត្រ ឃុំអរិយក្សត្រ

– បានចូលបើកផ្លូវក្នុងឃុំកោះរះភ្ជាប់ពីផ្លូវ3KD3 ទៅព្រៃកពោធិ៍ ឃុំពាមឧកញ៉ាអុងប្រវែង១៨០០ ម៉ែត្រ, បាតក្រោម ២០ម៉ែត្រ។

– បានចូលរួមវាស់វែងផ្លូវដើមាត់បឹងឈូកគរ ក្នុងឃុំថ្នល និងឃុំទឹកឃ្លាំង ជាមួយគណកម្មការដើរដួ ថ្នាក់ស្រុក ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៩។

– បានចូលរួមបើកមុខទឹកប្រវែង៣៥ម៉ែត្រ និងកំណត់ចំណីផ្លូវនៅស្ពានអន្លង់ក្រសាំង ក្នុងឃុំកោះរះ ជាមួយមន្ត្រីសាលាស្រុក និងមន្ត្រីសាលាឃុំ និងសកម្មភាពផ្សេងៗច្រើនតទៅទៀត

**៣.៣.៤-ការងារធនធានទឹកៈ**

*១).<u>ស្ថានភាពទឹកភ្លៀងៈ</u>*

– នៅក្នុងឆ្នាំ២០១៩នេះ បរិមាណទឹកភ្លៀងធ្លាក់ក្នុងស្រុកសរុបចំនួន ៨៨លើក បរិមាណទឹកសរុប ១២៣៤,៩ម.ម បើប្រៀបធៀបឆ្នាំ២០១៨ រយៈពេលដូចគ្នានៅក្នុងឆ្នាំ២០១៩ នេះបរិមាណទឹកភ្លៀងធ្លាក់តិច ជាងចំនួន២៤,៥ ម.ម។

*២).<u>បាតុភូតធម្មជាតិៈ</u>*

– ស្ថានភាពទឹកជំនន់ទន្លេមេគង្គ ចាប់ផ្តើមកំហុកពីដើមខែកញ្ញា រហូតដល់ពាក់កណ្តាល ខែកញ្ញា ដែលបណ្តាលឲ្យប៉ះពាល់ និងខូចខាតដល់ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធធារាសាស្ត្រ តាមបណ្តាលឃុំមួយចំនួនរួម មានដូចខាងក្រោមៈ

- ទំនប់អាងទឹកទទឹងថ្ងៃនៅភូមិបឹងគ្រំក្រោម ឃុំបឹងគ្រំប្រវែង ១៣៦ម៉ែត្រ
- ទំនប់អាងទឹកយុទ្ធសាស្ត្រទី២នៅភូមិព្រៃកតាប្រាំង ឃុំភូមិធំប្រវែង ៣៥០ម៉ែត្រ
- ទំនប់អាងទឹកចាស់ ភូមិព្រៃករំ ឃុំព្រៃករំប្រវែង៩០ម៉ែត្រ

*៣).<u>ការងារសិក្សាគម្រោងៈ</u>*

– ក្រសួងធនធានទឹក និងឧតុនិយម បានចុះសិក្សាគម្រោងស្តារប្រឡាយមេព្រៃកតាក្រូច ស្ថិននៅភូមិ អន្លង់ទ្រា ឃុំព្រៃកឬស្សី មានប្រវែង ៥៧០០ម៉ែត្រ អនុវត្តបាន១០០%។

– មន្ទីរធនធានទឹកខេត្ត បានចុះសិក្សាគម្រោងស្តារប្រឡាយមេព្រៃកថ្មី មានប្រវែង ១,១០០ម នៅភូមិ បឹងគ្រំលើ ឃុំបឹងគ្រំ។

*៤).<u>ការងារស្តារប្រឡាយៈ</u>*

– ក្រសួងធនធានទឹក និងឧតុនិយមបានចុះស្តារប្រឡាយមេព្រៃកតាក្រូច នៅភូមិអន្លង់ទ្រា ឃុំព្រៃក ឬស្សីមានប្រវែង ៥,៧០០ម អនុវត្តបាន១០០%។

– មន្ទីរធនធានទឹកខេត្តបានចុះស្តារប្រឡាយមេព្រៃកថ្មី នៅភូមិបឹងគ្រំលើ ឃុំបឹងគ្រំ មានប្រវែង ១,១០០ម អនុវត្តបាន១០០%។

*៥).<u>ការងារចូលរួមសហការៈ</u>*

– ការិយាល័យ បានធ្វើរបាយការណ៍ស្ថានភាពទឹកជំនន់ទន្លេមេគង្គឡើងកំហុកបណ្តាលឲ្យប៉ះពាល់ និងខូចខាតប្រព័ន្ធធារាសាស្ត្រជូនបមន្ទីរ និងធ្វើសំណើសុំសំបកបាវសម្រាមត្រៀមទប់ទំនប់អាងទឹកដែលខូច ខាតនៅពេលទឹកស្រក់ខាងមុខដើម្បីរក្សាទឹកទុកសម្រាប់ការងារបង្កបង្កើនផលស្រូវប្រាំង។

– ថ្ងៃទី១១.១២.១៣ ខែកក្កដា ឆ្នាំ២០១៩ៈ បានចូលរួមបោះបង្គោលព្រំដីអនុក្រឹត្យលេខ ២៥ ជាមួយថ្នាក់ខេត្តដឹកនាំដោយឯកឧត្តម នូវ ប៉េងច័ន្ទតារា អភិបាលរងខេត្ត ចុះនៅចំណុចភូមិក្តីកណ្តាល ឃុំ សារិកាកែវ ប៉ុន្តែប្រជាពលរដ្ឋមានការតវ៉ាមិនយល់ព្រមឲ្យក្រុមការងារចូលទៅបោះបង្គោលឡើយ។

- ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៩៖ បានចូលរួមបោះបង្គោលនៅចំណុចព្រំប្រទល់ឃុំសាវិកាកែវ និងឃុំពាមឧកញ៉ាអុង លេខ: ៧៨.៧៩.៧៥.៧៦.៧៤ បានបោះបង្គោលរួចហើយ។
- ថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៩៖ លោក កន សុខកាយ អភិបាលរងស្រុកបានដឹកនាំសហការណ៍ជាមួយអាជ្ញាធរភូមិចុះ ពិនិត្យតាមព្រែក និងកំណត់ទីតាំងទប់ទំនប់តាមព្រែកមួយ ព្រែកផ្លូត្រី ព្រែកការ ដើម្បីការពារទឹកទន្លេ មេគង្គឡើយហូរចូលបឹងលិចទីតាំងសាងសង់ចក្រអគ្គីសនី និងផលដំណាំប្រជាជន។
- ថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៩៖ បានចូលរួមជាមួយគណៈកម្មការដីរដ្ឋថ្នាក់ស្រុកដឹកនាំដោយលោក ចេង ឌីណា អភិបាលរងស្រុកចុះវាស់វែងដីបឹង និងទំនប់អាងទឹកជាដីរដ្ឋនៅតាមបណ្តាលឃុំក្នុងស្រុក។
- ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៩៖ បានចូលរួមជាមួយគណៈកម្មការដីរដ្ឋថ្នាក់ស្រុក ដឹកនាំដោយលោក យី យ៉េន អភិបាលរងស្រុកចុះវាស់វែងដី ១៨០០ហ.ត របស់ក្រុមហ៊ុន ING នៅចំណុចឃុំសាវិកាកែវ , ពាមឧកញ៉ាអុង, កោះរះ, ព្រែកក្មេង និងឃុំបារុង។
- បានចុះពិនិត្យស្ថានភាពការទប់ព្រែកផ្លាញ នៅភូមិពាមស្តី ឃុំព្រែកឬស្សី ដែលការដឹកនាំដោយលោក **យី យ៉េន** អភិបាលរងស្រុករួមដំណើរមានលោកប្រធានការិយាល័យ កសិកម្ម លោកប្រធានការិយាល័យសាធារណៈការ លោកប្រធានការិយាល័យអភិវឌ្ឍន៍ជនបទ និងក្រុមប្រឹក្សាឃុំលោកមេភូមិ នៅចំណុចព្រែកផ្លាញកំពស់ទឹកទន្លេតូចទាបជាងទឹកព្រែកប្រហែរ ៥០ស.ម លោក យី យ៉េន អភិបាលរងស្រុកស្នើសុំឲ្យកងវិស្វកម្មកាយទំនប់ដាក់លូ នៅពេលទឹកទន្លេតូចឡើងហូរចូលវិញដើម្បីឲ្យប្រជាកសិករបានទឹកបូមស្រោចស្រពស្រូវប្រាំងវិញ។
- បានចូលរួមសហការជាមួយគណៈកម្មការដីរដ្ឋ ដឹកនាំដោយ លោក កន សុខកាយ អភិបាលរងស្រុកចុះទប់ស្កាត់ការចោក់ដីតាមមាត់ព្រែក នៅលំនៅដ្ឋាននៅចំណុចព្រែកនាមសារ ភូមិទួលទ្រា ឃុំព្រែកក្មេង ចំនួន៣កន្លែង។
- បានសហការណ៍ជាមួយអាជ្ញាធរភូមិ-ឃុំ ណែនាំឲ្យប្រជាកសិកម្មចូលរួមការងារទប់ទំនប់ទឹកតម្កល់ទឹកទុកសម្រាប់ស្រោចស្រពស្រូវប្រាំង។
- បានសហការណ៍ជាមួយអាជ្ញាធរឃុំ-ភូមិ តាមដានស្ថានភាពទឹកនៅតាមប្រព័ន្ធធារាសាស្ត្រ នៅតាមបណ្តាឃុំ។

## ៣.៤. រដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

*១-ការអនុវត្តគោលនយោបាយភូមិ-ឃុំ មានសុវត្ថិភាព*

ការអនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថិភាពលក្ខណៈសម្បត្តិទាំង០៩យ៉ាងទទួលបានលទ្ធផល ដូចខាងក្រោម ៖

ក-គ្មានសកម្មភាពលួច ឆក់ ប្លន់ គ្រប់ប្រភេទ:

- កើតហេតុនៅថ្ងៃទី ២០-០១-២០១៩ នៅចំនុចភូមិព្រែក្មេង ឃុំព្រែកក្មេង ជនសង្ស័យគេចខ្លួន
- កើតហេតុនៅថ្ងៃទី ២៥-១០-២០១៩ នៅចំណុចភូមិវាលធំ ឃុំពាមឧកញ៉ាអុង ឃាត់ខ្លួនជនសង្ស័យ០១នាក់
- កើតហេតុនៅថ្ងៃទី ០៧-១២-២០១៩ នៅចំណុចភូមិបឹងគ្រំ ឃុំបឹងគ្រំ ឃាត់ខ្លួនជនសង្ស័យ០១នាក់

ខ-គ្មានការផលិត ការចែកចាយ និង ប្រើប្រាស់គ្រឿងញៀនខុសច្បាប់: ឃាត់មនុស្សចំនួន ៣៤ នាក់ ថ្នាំញៀន ៦១ កញ្ចប់

- ឃុំអរិយក្សត្រះឃាត់ខ្លួនមនុស្ស១៤នាក់ វត្ថុតាងរួមមានៈថ្នាំញៀន២៤កញ្ចប់ ,ម៉ូតូ០២គ្រឿង។
- ឃុំសារិកាកែវះឃាត់ខ្លួនមនុស្ស០២នាក់ វត្ថុតាងរួមមានៈថ្នាំញៀន០២កញ្ចប់ ,ម៉ូតូ០១គ្រឿង។
- ឃុំពាមឧកញ៉ាអុងះឃាត់ខ្លួនមនុស្ស០១នាក់ វត្ថុតាងរួមមានៈថ្នាំញៀន០៣កញ្ចប់។
- ឃុំកោះរះ ះឃាត់ខ្លួនមនុស្ស០៣នាក់ វត្ថុតាងរួមមានៈថ្នាំញៀន០១កញ្ចប់ ។
- ឃុំទឹកឃ្លាំងះឃាត់ខ្លួនមនុស្ស៦នាក់ វត្ថុតាងរួមមានៈថ្នាំញៀន១០កញ្ចប់,ម៉ូតូ០១គ្រឿង។
- ឃុំបឹងគ្រំ ះឃាត់ខ្លួនមនុស្ស៥នាក់ វត្ថុតាងរួមមានៈថ្នាំញៀន០៩កញ្ចប់។
- ឃុំកោះកែវះ ឃាត់ខ្លួនមនុស្ស១នាក់វត្ថុតាងរួមមានៈ ថ្នាំញៀន ០៤កញ្ចប់ ។
- ឃុំព្រែករៃ ះ ឃាត់ខ្លួនមនុស្ស២នាក់ វត្ថុតាងរួមមានៈ ថ្នាំញៀន ០៨កញ្ចប់ ។

➢ វិធានការអប់រំះ បានបញ្ជូនមនុស្សទៅអប់រំព្យាបាលស្ថានីតិសម្បទា និងសមាហរណកម្មចំនួន០៧ នាក់ ក្នុងនោះស្ថិត នៅឃុំសារិកាកែវ ៣ នាក់ និងឃុំអរិយក្សត្រ២នាក់ ទឹកឃ្លាំង១នាក់ និងឃុំព្រែករៃ១នាក់ ។

+ ចុះធ្វើការអប់រំផ្សព្វផ្សាយពីផលប៉ះពាល់និងច្បាប់ស្តីពីគ្រឿងញៀនដល់សិស្សានុសិស្សនៅតាមបណ្តា វិទ្យាល័យ ចូលរួមចំនួន ២២៧១នាក់ ,ស្រី១១៧៥នាក់។

គ-គ្មានអំពើអនាចារ ការជួញដូរស្ត្រី និង កុមារ និង អំពើហិង្សាក្នុងគ្រួសារៈ

ឃ-គ្មានក្មេងទំនើងៈ គ្មានសកម្មភាព

ង-គ្មានការលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ការប្រើប្រាស់អាវុធខុសច្បាប់ និង បទល្មើសគ្រប់ប្រភេទៈ

1) ករណីប៉ុនប៉ងរំលោភសេពសន្ថវៈ កើតមានចំនួន ១លើកកើតហេតុនៅថ្ងៃទី ១២-០៥-២០១៩ នៅចំនុចភូមិព្រៃតាអុងទី១ ឃុំពាមឧកញ៉ាអុង ឃាត់ខ្លួន ជនសង្ស័យ០១នាក់

2) ករណីហឹង្សាដោយចេតនា កើតមានចំនួន ៥លើក

- កើតហេតុនៅថ្ងៃទី ២៤-០៣-២០១៩ នៅចំនុចភូមិព្រៃក្មេង ឃុំព្រែកក្មេង ឃាត់ខ្លួនជនសង្ស័យ០២នាក់
- កើតហេតុនៅថ្ងៃទី២៤ ខែ០៣ ឆ្នាំ២០១៩ នៅចំនុចភូមិទួលមាស ឃុំអរិយក្សត្រ ជនសង្ស័យ គេចខ្លួន
- កើតហេតុនៅថ្ងៃទី ១០-០៩-២០១៩ នៅចំណុចភូមិអរិយក្សត្រ ឃុំអរិយក្សត្រ ឃាត់ខ្លួនជន សង្ស័យ០១នាក់
- កើតហេតុនៅថ្ងៃទី ៣០-០៩-២០១៩ នៅចំណុចភូមិបឹងគ្រំលើ ឃុំបឹងគ្រំ (គេចខ្លួន)
- កើតហេតុនៅថ្ងៃទី ១២-១២-២០១៩ នៅចំណុចភូមិទឹកឃ្លាំង ឃុំទឹកឃ្លាំង ឃាត់ខ្លួនជនសង្ស័យ០១នាក់

3) ករណីឃាតកម្ម កើតមានចំនួន ១លើក ស្លាប់០១នាក់ (ស្រី)

- កើតហេតុនៅថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៩ នៅចំនុចភូមិកោះរះលើ ឃុំកោះរះ ស្រុកល្វាឯម ឃាត់ខ្លួនជនសង្ស័យ០១នាក់

4) ករណីមនុស្សឃាតដោយអចេតនា កើតមានចំនួន ១លើក (បណ្តាលឲ្យស្លាប់០១នាក់)

▪ កើតហេតុនៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០១៩ នៅចំនុចភូមិខ្មោការ ឃុំបារុង ឃាត់ខ្លួនជនសង្ស័យ០១នាក់

5) ករណីបង្រ្កាបល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ៖ករណីបង្ក្រាបកន្លែងជល់មាន់

▪ កើតហេតុនៅថ្ងៃទី ០៦ខែ កុម្ភៈ ឆ្នាំ២០១៩ នៅចំណុចចំការស្វាយក្រោយផ្ទះប្រជាជន វៀតណាម នៅភូមិអរិយក្សត្រ ឃុំអរិយក្សត្រ ស្រុកល្វាឯម ខេត្តកណ្តាល ។ វត្ថុតាងរួមមានៈ មាន់ ចំនួន០៣ក្បាល,ស៊ុមក្រុង មាន់ចំនួន៥ ,បង់រុំជើងមាន់៣០ដុំ

▪ កើតហេតុនៅថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ ២០១៩ នៅចំណុចចំការស្វាយក្រោយផ្ទះប្រជាជន ស្ថិតនៅភូមិ កោះរះក្រោម ឃុំកោះរះ ស្រុកល្វាឯម ខេត្តកណ្ដាល ។ វត្ថុតាងរួមមានៈមាន់ ចំនួន០២ក្បាល(ងាប់)ជញ្ជីងថ្លឹងមាន់ ចំនួន០១គ្រឿង បង់រុំជើងមាន់២៣ដុំ,ស៊ុមក្រុង មាន់០២,ម៉ូតូ០៣គ្រឿង។

ឆ.គ្មានគ្រោះថ្នាក់ចរាចរណ៍៖

❖ ករណីគ្រោះថ្នាក់ចរាចរណ៍បញ្ជូនសុំណុំរឿងទៅខេត្តមាន១៧ករណី,របួសធ្ងន់២៤នាក់,ស្រាល២៣ នាក់,ខូចខាតម៉ូតូ២៧ គ្រឿង,រថយន្ត០២គ្រឿង,កង់បីចំនួន០៣គ្រឿង, កង់ ចំនួន០១គ្រឿងក្នុងរួមមាន៖

\+ ឃុំអរិយក្សត្រមាន០៨ករណី៖របួសធ្ងន់១២នាក់,ស្រាល១០នាក់,ខូចខាតម៉ូតូ១០គ្រឿង,កង់បី ចំនួន០៣គ្រឿង,រថយន្តចំនួន០១គ្រឿង

\+ ឃុំសារិកាកែវមាន០៤ករណី៖របួសធ្ងន់០៦នាក់,ស្រាល០៣នាក់,ខូចខាតម៉ូតូ០៩គ្រឿង,រថយន្ត ចំនួន០១គ្រឿង

\+ ឃុំពាមឧកញ៉ាអុងមាន០១ករណី៖របួសធ្ងន់០២នាក់,ស្រាល០១នាក់, ខូចខាតម៉ូតូ០២គ្រឿង

\+ ឃុំកោះរះមាន០១ករណី៖របួសធ្ងន់០១នាក់,ស្រាល០៣នាក់, ខូចខាតម៉ូតូ០២គ្រឿង

\+ ឃុំថ្មគរ មាន០១ករណី៖របួសធ្ងន់០១នាក់,ស្រាល០២នាក់, ខូចខាតម៉ូតូ០១គ្រឿង

\+ ឃុំកោះកែវ មាន០១ករណី៖របួសធ្ងន់០១នាក់,ស្រាល០១នាក់ ខូចខាតម៉ូតូ០១គ្រឿង, កង់ ចំនួន ០១គ្រឿង

\+ ឃុំព្រែកក្មេង មាន០១ករណី៖របួសធ្ងន់០១នាក់ ,ខូចខាតម៉ូតូ០១គ្រឿង។

❖ ករណីគ្រោះថ្នាក់ចរាចរណ៍ដោះស្រាយបញ្ចប់នៅប៉ុស្តិ៍និងនៅអធិការដ្ឋាន មាន០៧ករណី ,របួសធ្ងន់ ០៦នាក់,ស្រាល០៨នាក់,ខូចខាតម៉ូតូ០៨គ្រឿង,រថយន្ត០៤គ្រឿង,កង់ ចំនួន០១គ្រឿង ក្នុងរួមមាន៖

\+ ឃុំអរិយក្សត្រមាន០២ករណី៖របួសធ្ងន់០២នាក់,ស្រាល០៣នាក់,ខូចខាតម៉ូតូ០៣គ្រឿង, រថយន្ត ចំនួន០១គ្រឿង

\+ ឃុំសារិកាកែវមាន០១ករណី៖របួសធ្ងន់០១នាក់,ខូចខាតម៉ូតូ០១គ្រឿង

\+ ឃុំពាមឧកញ៉ាអុងមាន០១ករណី៖របួសធ្ងន់០១នាក់,ស្រាល០១នាក់,ខូចខាតម៉ូតូ០១គ្រឿង, កង់បី ០១ គ្រឿង

\+ ឃុំកោះរះមាន០១ករណី៖របួស០នាក់, រថយន្តចំនួន០២គ្រឿង

\+ ឃុំព្រែកក្មេង មាន០១ករណី៖របួសធ្ងន់០១នាក់,ស្រាល០២គ្រឿង ,ខូចខាតម៉ូតូ០១គ្រឿង។

\+ ឃុំល្វាសរ មាន០១ករណី៖របួសធ្ងន់០១នាក់ ,ស្រាល០២នាក់,ខូចខាតម៉ូតូ០២គ្រឿង។

❖ **ទិចឆានភារ៖** បានចុះធ្វើការផ្សព្វផ្សាយច្បាប់ចរាចរណ៍ផ្លូវគោកដល់សិស្សានុសិស្សនៅតាម បណ្តាសាលាសមាសភាព ចូលរួមសរុបចំនួន ២៥៥៥នាក់,ស្រី ១៣៤៣នាក់

- បានធ្វើការអប់រំអ្នកបើកបរនិងអ្នករួមដំណើរដែលមិនបានពាក់មួកសុវត្ថិភាពនិងពាក់មិនបានត្រឹមត្រូវបានចំនួន ០៧លើក សរុបបាន ៩៩១ នាក់ និងផ្តល់មួកសុវត្ថិភាពជូនពួកគាត់ចំនួន១១៥ មួក ចេញប័ណ្ណផាកពិន័យចំនួន៤៥ ប័ណ្ណ បានថវិកាចំនួន ៧០០,០០០រៀល ។

ជ.គ្មានគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌមិនទាន់ផ្ទុះ៖ បានប្រទះឃើញគ្រាប់មិនទាន់ផ្ទុះនៅតាមបណ្តាលឃុំរួមមាន៖

១.នៅឃុំសំបួរប្រទះឃើញគ្រាប់ចំនួន០២គ្រាប់រួមមាន៖គ្រាប់B40ចំនួន០១គ្រាប់,គ្រាប់A60ចំនួន ០១ គ្រាប់។

២.នៅឃុំសាវិកាកែវ ប្រទះឃើញគ្រាប់ចំនួន០៥គ្រាប់រួមមាន៖គ្រាប់ផ្លោង76 ចំនួន០១គ្រាប់ , គ្រាប់ផ្លោង105ចំនួន០១គ្រាប់,គ្រាប់ M79 ចំនួន០១គ្រាប់,គ្រាប់ត្បាល់ ចំនួន០២គ្រាប់។ក្រុមជំនាញ ស៊ីម៉ាក់បានចុះមកយករួចរាល់ហើយ។

៣.នៅឃុំថ្មគរ ប្រទះឃើញគ្រាប់ចំនួន០១គ្រាប់ ប្រភេទម៉ាកM79 (ក្រុមស៊ីម៉ាក់ចុះមកយករួចរាល់ហើយ)។

៤.នៅឃុំអរិយក្សត្រ ប្រទះឃើញគ្រាប់ចំនួន២២គ្រាប់ ប្រភេទ ម៉ាកM79ចំនួន២១គ្រាប់,គ្រាប់ផ្លោងចំនួន០១គ្រាប់។

៥.ឃុំព្រែកឬស្សី ប្រទះឃើញចំនួន០២គ្រាប់ប្រភេទ៖ម៉ាកMK82ចំនួន០១គ្រាប់,គ្រាប់រ៉ូកែតចំនួន ០១ គ្រាប់។

ឈ.មានវិធានការទប់ស្កាត់គ្រប់គ្រងនិងឆ្លើយតបចំពោះគ្រោះមហន្តរាយប្រកបដោយប្រសិទ្ធិភាព៖ កើតមាន

1..ករណីកម្ពស់ទឹកទន្លេតូចបានឡើងខុសពីធម្មតា ដែលបណ្តាលអោយស្រូវព្រោះ របស់ប្រជាពលរដ្ឋទាំង02ឃុំ រងផលប៉ះពាល់ ដូចខាងក្រោម ៖ឃុំព្រែកឬស្សី ៩៥ ហិចតា ស្មើនឹង៦៦ គ្រួសារ ,ឃុំសំបួរ ១៧៥ហិចតា ស្មើនឹង២៧៨ គ្រួសារ សរុបទាំង០២ ឃុំ ស្រូវដែលរងគ្រោះ មានចំនួន ២៧០ ហិចតា ស្មើនឹង ៣៤៤ គ្រួសារ។

2. ខ្យល់កន្ត្រាក់៖ កើតមានចំនួន០៤លើក បណ្តាលឲ្យខូចខាតផ្ទះចំនួន៣២ គ្រួសារ។

3. ការបាក់ច្រាំង៖ កើតមានចំនួន០៣លើក ប៉ះពាល់ប្រជាពលរដ្ឋសរុបចំនួន១៣គ្រួសាររស់នៅឃុំចំនួន០៣ មានឃុំសាវិកាកែវ, ឃុំពាមឧកញ៉ាអុង ឃុំល្វាសរ និងឃុំកោះកែវ។

4. គ្រោះដោយទឹកជំនន់៖ ប៉ះពាល់ប្រជាពលរដ្ឋចំនួន៣៤០គ្រួសារ/ខ្នងផ្ទះ ជម្លៀសចេញពីលំនៅដ្ឋានចំនួន២៧គ្រួសារ លិចផ្លូវចំនួន១៩ខ្សែ ស្មើ ៩,៨១០ម៉ែត្រ ក្នុងឃុំចំនួន៦។

ញ.គ្មានការត្រួតពិនិត្យខុលច្បាប់៖គ្មានសកម្មភាព

*២-គ្រោះថ្នាក់ផ្សេងៗ ៖*

១-ករណីឆក់ចរន្តអគ្គិសនី(ស្លាប់០៣នាក់) ឃុំព្រែកក្មេង១នាក់ បឹងគ្រំ១នាក់ ឃុំសាវិកាកែវ ១នាក់ និងឃុំព្រែករៃ ១នាក់ ។

២-ករណីលង់ទឹក(ស្លាប់០២នាក់) ឃុំទឹកឃ្លាំង១នាក់ និងឃុំព្រែករៃ ២នាក់ ។

៣-ករណីខ្យល់គ(ស្លាប់០៣នាក់) ឃុំថ្មគរ ១នាក់ និងឃុំពាមឧកញ៉ាអុង ២នាក់។

៤-ករណីឆក់កណ្តុល(ស្លាប់០១នាក់) ឃុំបារុង ។

៥-ករណីធ្វើអត្តឃាតបាញ់សម្លាប់ខ្លួនឯង(ស្លាប់០១នាក់) ឃុំអរិយក្សត្រ ។

៦-ករណីអត្តឃាតចងក (ស្លាប់០១នាក់) ឃុំថ្មគរ ។

៧-ករណីពុលពង គីង្គក់(ស្លាប់០១នាក់) ឃុំកោះកែវ។

៨. ធ្លាក់ពីលើកាំជណ្តើរ(ស្លាប់ ០១ នាក់ )ឃុំសារិកាកែវ ។

*៣-ការងារប្រជាការពារ*

- កម្លាំងប្រជាការពារតាមបណ្តាឃុំបានសហការជាមួយកងកម្លាំងប៉ុស្តិ៍រដ្ឋបាលរក្សាបានសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈជូនប្រជាពលរដ្ឋក្នុង ពិធីការ ពិធីបុណ្យផ្សេងៗ ជាពិសេសពិធីបុណ្យជាតិ អន្តរជាតិ បានល្អប្រសើរ ។

- បានការពារ និងរៀបចំសណ្តាប់ធ្នាប់ក្នុងពិធីអាពាហ៍ពិពាហ៍ ពិធីបុណ្យទាន និងកម្មវិធីផ្សេងៗបាន ចំនួន៤៣២ លើក ។

*៤- ការងារការពារថ្នាក់ដឹកនាំជាតិ និងអន្តរជាតិ ៖*

- ការពារសម្តេចនាយរដ្ឋមន្ត្រី ក្នុងថ្ងៃ០៧មករា នៅគោលដៅឃុំអរិយក្សត្រ ចំនួន០១ លើក កម្លាំង ៥០នាក់ ចាប់ពីថ្ងៃទី០៦ដល់០៧ ខែមករា ឆ្នាំ២០១៩។

- បានចូលរួមជាមួយគណៈកម្មាធិការស អ ក ខេត ចុះសិក្សា និងវាយតម្លៃ ដើម្បីសាងសង់ផ្ទះជូន គ្រួសារអតីតយុទ្ធជន ចំនួន០៥គ្រួសារនៅឃុំចំនួន០៤រួមមាន ឃុំព្រែករៃ ,សំបួរ,បារុង,និងឃុំកោះរះ។

- ថ្ងៃទី១១ ខែមេសា ឆ្នាំ ២០១៩ ប្រជុំផ្សព្វផ្សាយ,បែងចែកកម្លាំងការពារក្នុងឱកាសបុណ្យចូលឆ្នាំថ្មី ប្រពៃណីខ្មែររយៈពេល ០៣ថ្ងៃ គឺថ្ងៃទី ១៤-១៥-១៧ ខែមេសា ឆ្នាំ ២០១៩នៅគោលសង្រ្កាន្ត ចំនួន០៣ គោលដៅរួមមានៈគោលដៅកោះស្នេហ៍ ស្ថិតក្នុងឃុំទឹកឃ្លាំង, គោលដៅមុខវិទ្យាល័យ ហ ស ទឹកឃ្លាំង ស្ថិត ក្នុង ឃុំទឹកឃ្លាំង, វត្តស្វាយអណ្តែត ស្ថិតក្នុងឃុំសារិកាកែវ ។

- ថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៩ ការពារបុណ្យឯករាជ្យជាតិ នៅគោលដៅចំនុចខ្ពស់អរិយក្សត្រ ប្រើប្រាស់កម្លាំង៣០នាក់ និងការពារពិធីហូបអំបុកខ្មែរដើម្បីការពារជាតិ សាសនា និងព្រះមហាក្សត្រ ក្រោម អធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមអគ្គបណ្ឌិត សភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋ កិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមការងារថ្នាក់ជាតិចុះជួយខេត្តកណ្តាល និងបានការអញ្ជើញចូលរួមជាគ ណៈអធិបតី **ឯកឧត្តម គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាល អនុប្រធានក្រុមការងារជាតិចុះជួយស្រុកល្វាឯម។ បញ្ជាក់ៈ នៅក្នុងពិធីនោះក៏មានការអុំទូកថ្នាក់ស្រុកផងដែរ នៅមាត់ទន្លេ ឃុំពាមឧកញ៉ាអុង សរុបវត្តមានចូលរួម ប្រមាណ៣៨០០នាក់។

- ថ្ងៃទី១០.១១.១២ ខែតុលា ឆ្នាំ២០១៩ បានការពារព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប អកអំបុក និងសំពះព្រះខែ នៅចំណុចកំពុងដរអរិយក្សត្រ ឃុំអរិយក្សត្រ និងការពារក្រុមទូកង ទៅចូលរួម ប្រណាំងនៅ រាជធានីភ្នំពេញ ។

- បានការពារ និងរៀបចំសណ្តាប់ធ្នាប់ជូនថ្នាក់ដឹកនាំជាន់ខ្ពស់ ភ្ញៀវជាតិ អន្តរជាតិ ដែលឃាង និង អញ្ជើញឆ្លង កាត់បានចំនួន១២លើក ។

- ការពារឯកឧត្តមបណ្ឌិតអភិបាលខេត្ត កម្មវិធីបញ្ចុះបឋមសិលាសាងសង់អគាររដ្ឋបាលស្រុកល្វាឯម ចំនួន១លើក ប្រើប្រាស់កម្លាំង ២០ នាក់ ។

៥-សភាពការណ៍សហគមន៍ពលរដ្ឋ និងសាសនា

-នៅក្នុងស្រុកមានព្រះវិហារគ្រីស្ត មហាយាន និងស្នាក់ការថ្វាយបង្គំ(គ្រីស្ត) ៩ កន្លែង ព្រះវិហារគ្រីស្ត មាន ៧ កន្លែង ព្រះវិហារមហាយានមាន ១ កន្លែង និងស្នាក់ការថ្វាយបង្គំគ្រីស្តមាន ២ កន្លែង សាសនិកសរុប មានចំនួន ៨៨០ នាក់ ស្រី ៥២៥ នាក់។

-ការប្រារព្ធធ្វើពិធីបុណ្យសាសនារបស់ជនបរទេស

* ឃុំអរិយក្សត្រ ០១លើក មនុស្សចូលរួមចំនួន ៥២០ នាក់ ស្រីចំនួន ២៨០ នាក់

+ ខ្មែរ ចំនួន ១០ នាក់ ស្រីចំនួន ០៧ នាក់

+វៀតណាមចំនួន ៥០៦ នាក់ ស្រីចំនួន ២៧១នាក់

+អូទ្រីសចំនួន ០២ នាក់ ស្រីចំនួន ០២នាក់

+នីហ្សេរីយ៉ាចំនួន ០២នាក់

*ឃុំថ្មគរ ០១លើក មនុស្សចូលរួមចំនួន ១៥១៣ នាក់ ស្រីចំនួន ៩៦៧ នាក់

+ ខ្មែរ ចំនួន ០៧ នាក់ ស្រីចំនួន ០៧ នាក់

+វៀតណាមចំនួន ១៥០៦ នាក់ ស្រីចំនួន ៩៦០

**៦.ផែនការការងារសណ្តាប់ធ្នាប់៖** បានចុះសម្រួលចរាចរណ៍ជូនប្រជាពលរដ្ឋនៅចំណុចកំពុងចម្លងអរិយក្សត្រ បានចំនួន ៣៥លើក ។

**៧.ផែនការងារអត្តសញ្ញាណកម្ម**

៧.១.ការងារអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ៖ បានចំនួន១៣១២នាក់,ប្រុស៥៨៥នាក់ និងកំពុងបន្តធ្វើ វិលជុំតាម បណ្តាលឃុំនិងនៅអធិការដ្ឋានស្រុកល្វាឯម

៧.២.ការងារស្ថិតិប្រជាពលរដ្ឋ៖

- ការងារផ្តល់សៀវភៅក២: សៀវភៅស្នាក់នៅ (ក២) ផ្តល់ថ្មីចំនួន៩៧០ គ្រួសារ ទុតិយតា: ២១១ក្បាល ថែមសមាជិក ១៥០ក្បាល

- សៀវភៅគ្រួសារ(ក៤)ធ្វើជូនប្រជាពលរដ្ឋ បំបែកគ្រួសារថ្មីបានចំនួន៣៩៨គ្រួសារទុតិយតា ១០១ ថែមសមាជិក៩៩ គ្រួសារ។

៨.ការអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព៖ គណៈបញ្ជាការឯកភាពឃុំគ្រប់ឃុំ បានធ្វើការ ផ្សព្វផ្សាយ ពីគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព ទាំង៩ចំណុច និងគត្តាគ្រោះថ្នាក់នៃការប្រើប្រាស់គ្រឿង ញៀនជូនប្រជាពលរដ្ឋបាន ១១៥៧ លើក ប្រជាពលរដ្ឋ ចូលរួមចំនួន ២១៣៣១នាក់ ស្រី ១២៧៥៧ នាក់។

៩.ការងារអន្តោប្រវេសន៍

៩.១.ការងារគ្រប់គ្រងជនបរទេសមិនមែនអន្តោប្រវេសន៍ ៖ជនបរទេសបែបអន្តោប្រវេសន្ត (ជនជាតិវៀត ណាម) ក្នុងស្រុកល្វាឯម រួមមាន៖

-សរុបមានចំនួន ៤៨១ គ្រួសារ

-ចំនួនមនុស្សសរុប ១៩១២ នាក់ ស្រី ៩៦១ នាក់

-អាយុ១៨ឆ្នាំឡើងចំនួន ១២៣៥ នាក់ ស្រី ៦០០នាក់

-អាយុ១៨ឆ្នាំចុះចំនួន ៦៨០ នាក់ ស្រី ៣៦១ នាក់

❖ ការស្នាក់នៅបណ្តោះអាសន្នរបស់ជនបរទេសៈគិតចាប់ពីថ្ងៃទី០១ ខែមករា ដល់ ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៩ មាន១៦លើក មានជនបរទេសជំនួន ១៦៨ នាក់ ស្រី ៨២ នាក់ រួមមានៈ

- ឃុំពាមឧកញ៉ាអុង០៣លើក មនុស្សរួម ៣២ នាក់ ស្រី០៨នាក់ មាន០៣ សញ្ជាតិ គឺ
  - សញ្ជាតិបារាំង ចំនួន ០៤ នាក់ ស្រី ០២ នាក់
  - សញ្ជាតិចិន ០៦ នាក់ ស្រី ០០ នាក់
  - អូស្ត្រាលី ២២នាក់ ស្រី ០៦ នាក់
- ឃុំសារិកាកែវ ០៥លើក មាមនុស្សរួម ១៣៩ នាក់ ស្រី ៧២នាក់ មាន០៥សញ្ជាតិ ក្នុងនោះ
  - -សញ្ជាតិអូស្ត្រាលី ចំនួន ១២៧នាក់ ស្រី ៦៨នាក់
  - -សញ្ជាតិអាមេរិក ចំនួន ០២នាក់ ស្រី០០នាក់
  - -សញ្ជាតិអ៊ីតាលី ចំនួន ០២នាក់ ស្រី០០នាក់
  - -សញ្ជាតិបេហ្ស៊ិច ចំនួន ០២នាក់ ស្រី០១នាក់
  - -សញ្ជាតិអង់គ្លេស ចំនួន ០២នាក់ ស្រី០១នាក់
- ឃុំថ្មគរ ០១លើក មាមនុស្សរួម ០១ នាក់ ស្រី ០១នាក់ មាន០១ គឺសញ្ជាតិបារាំង
- ឃុំទឹកឃ្លាំងៈ មាន ០៣លើក មនុស្សរួម ០៨ នាក់ ស្រី០៤ នាក់ មាន០៣ សញ្ជាតិ
  - -សញ្ជាតិចិនជំនួន ០១នាក់ ស្រី ០០ នាក់
  - -សញ្ជាតិបេហ្ស៊ិច ០១នាក់ ស្រី ០០ នាក់
  - -សញ្ជាតិខ្មែរ អាមេរិក ០៦នាក់ ស្រី ០៤ នាក់
- ឃុំព្រែកក្មេង ០២លើក មនុស្សរួម ០៥ នាក់ ស្រី០២ នាក់ មាន០១សញ្ជាតិ គឺសញ្ជាតិចិន
- ឃុំកោះរះ ០១លើក មនុស្សរួម ០៤ នាក់ ស្រី០១ នាក់ មាន០២ សញ្ជាតិ
  - -សញ្ជាតិចិន ០៣នាក់ ស្រី ០០ នាក់
  - -សញ្ជាតិអាល្លឺម៉ង់ ០១នាក់ ស្រី ០០ នាក់

+ ដាក់ពាក្យប័ណ្ណស្នាក់នៅអចិន្ត្រៃ(បង់អាករ)ៈគ្មាន

+ដាក់ពាក្យសុំប្រកាសៈគ្មាន

+ ដកហូតឯកសារមិនប្រក្រតី ៈគ្មាន

+ជនបរទេសរៀបអាពាហ៍ពិពាហ៍ៈមាន ០៤លើក ស្មើនឹង ០៤គូ

- ▪ឃុំថ្មគរៈ០១លើក រវាងជនបរទេស សញ្ជាម៉ាឡេស៊ី និងពរដ្ឋខ្មែរ
- ▪ឃុំកោះរះ០១លើក រវាងជនបរទេស សញ្ជាតិអាមេរិក និងពរដ្ឋខ្មែរ
- ▪ឃុំអរិយក្សត្រៈ ០២លើក
  - - រវាង វៀតណាម និងវៀតណាម
  - -រវាង វៀតណាម និង ខ្មែរ

៩.២-កាដកហូតឯកសារមិនប្រក្រតីពីជនបរទេសៈគ្មាន

៩.៣-ជនបរទេសរងគ្រោះថ្នាក់ផ្សេងៗៈគ្មាន

៩.៤-ជនបរទេសរងគ្រោះថ្នាក់ដោយឧប្បទ្ទវហេតុផ្សេងៗៈគ្មាន

៩.៥-ជនបរទេសរងប្រព្រឹត្តបទល្មើសផ្សេងៗៈគ្មាន

១០.ការងារគ្រប់គ្រងព្រំដែន ( គ្មាន )

១១.ការងារប៉ុស្តិ៍អនាធិបតេយ្យ ( គ្មាន )

១២.ការងារជើកលើកអធ្វិជាតុកងទ័ពស្មក្រ័កិច្ចវៀតណាម ( គ្មាន )

## ផ្នែកទី៤

## បញ្ហាប្រឈម និងដំណោះស្រាយ

៣.១.រដ្ឋបាលស្រុក

| លរ. | បញ្ហាប្រឈមសំខាន់ៗ | សំណើដំណោះស្រាយ |
|---|---|---|
| ១ .(ការងាររដ្ឋបាល | | |
| ១ | រិយាល័យជំនាញមួយចំនួន នៅមានការយឺត យ៉ាវក្នុងការផ្តល់របាយការណ៍មិនគោរពតាមកាលកំណត់របស់) អង្គប្រជុំគណៈអភិបាល និងក្រុមប្រឹក្សាស្រុក ( | សុំការិយាល័យជំនាញមេត្តាផ្តល់របាយការណ៍ បានទាន់ពេលវេលា ឲ្យបានមុនថ្ងៃទី១៥ រៀងរាល់ខែ |
| ២ | មន្ត្រីនៅអង្គភាពយន្តការច្រកចេញចូលតែមួយ ពុំទាន់ចូលរួមវគ្គបណ្តុះបណ្តាលផ្នែកជំនាញរបស់ខ្លួន | ស្នើឲ្យមានវគ្គបណ្តុះបណ្តាល |
| ៣ | ប្រជាពលរដ្ឋពុំទាន់យល់ដឹកពីដំណើរការយន្តការច្រកចេញចូលតែមួយ | ស្នើដល់រដ្ឋបាលឃុំជួយផ្សព្វផ្សាយជូនប្រជាពលរដ្ឋឲ្យបានយល់ដឹង |
| ២ .(ការងារផែនការ និងការគាំទ្រឃុំ សង្កាត់ | | |
| ១ | មន្ត្រីនៅថ្នាក់ឃុំមួយចំនួន ផ្តល់របាយការណ៍ និងឯកសារមានការយឺតយ៉ាវមិនគោរពតាមកាលកំណត់របស់ ) (មប្រឹក្សាស្រុកអង្គប្រជុំក្រុ | ជំរុញការផ្តល់របាយការណ៍បានទាន់ពេលវេលា |
| ៣ .(ការគ្រប់គ្រងធនធានមនុស្ស | | |
| ១ | មន្ត្រីពុំទាន់មានឆន្ទះ និងការទទួលខុសត្រូវលើការងារ | ជំរុញដល់មន្ត្រីឲ្យគោរព និងអនុវត្តតាមលក្ខន្តិកៈរបស់ មន្ត្រីរាជការស៊ីវិល |
| ៤(.ការងារអន្តរវិស័យ | | |
| ១ | ប្រជាពលរដ្ឋមិនទាន់យល់អំពីច្បាប់សាងសង់ពិបាកដល់ការអនុវត្តច្បាប់។ | ស្នើសុំការិយាល័យជំនាញ និងអាជ្ញាធរភូមិឃុំពន្យល់ណែនាំ និងជម្រុញឲ្យប្រជាពលរដ្ឋមកសុំច្បាប់សាងសង់៥០០សំណង់ក្រោម) នៅយន្តការច្រក។ (ម៉ែត្រការ៉េ |
| ៥.(ការងារហិរញ្ញវត្ថុ | | |
| ១ | - មន្ត្រីជំនាញទទួលផ្នែកហិរញ្ញវត្ថុពុំទាន់យល់ពីកិច្ចការងារហិរញ្ញវត្ថុ | -ពង្រឹងសមត្ថភាពមន្ត្រីអនុវត្តការងារ និងខិតខំរៀនសូត្របន្ថែម ។ |
| ៦.(ការងារលទ្ធកម្ម | | |
| | អង្គភាពលទ្ធកម្ម ចំណេះដឹងនូវមានកម្រិត | សិក្សារៀនសូត្របន្ថែមទៀត |

៤.២.ការិយាល័យ អង្គភាពជំនាញ

| ល.រ | បញ្ហាប្រឈមសំខាន់ៗ | សំណើដំណោះស្រាយ |
|---|---|---|
| ១).ការងារពន្ធដារ | | |

| | | |
|---|---|---|
| ១ | អាជីវករនូវមិនទាន់បានយល់ច្បាស់អំពីកាតព្វកិច្ចបង់ពន្ធ ស្របតាមប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងប្រមូលពន្ធឆ្នាំ២០១៦នៅឡើយ ។ | ជំរុញការផ្សព្វផ្សាយច្បាប់ពន្ធតាមគ្រប់រូបភាពដូចជាតាមរយៈសិក្ខាសាលា តាមរយៈវិទ្យុ ទូរទស្សន៍ កាសែត...។-ល-។ |
| ២).ការងារអភិវឌ្ឍន៍ជនបទ | | |
| ១ | ផ្លូវមួយចំនួនរងការខូចខាតដោយគ្រោះទឹកជំនន់ | មន្ទីរ/ក្រសួងអភិវឌ្ឍន៍ជនបទជួយដោះស្រាយ |
| ២ | គ្រួសារក្រ១ក្រ២មានការយឺតយ៉ាវក្នុងការបង់ថ្លៃ បណ្តាញទឹកស្អាត | សូមឲ្យអាជ្ញាធរឃុំ ភូមិដាក់គោលដៅជួយជំរុញ |
| ៣).ការងារសាធារណៈការ: | | |
| ១ | ផ្លូវនៅមានការលំបាកក្នុងការធ្វើចរាចរណ៍ នៅរដូវភ្លៀងធ្លាក់ | សំណូមពរក្រសួងពាក់ព័ន្ធពន្លឿនក្នុងការជួសជុលផ្លូវឡើងវិញអោយបានឆាប់រួសរាន់ |
| ២ | ស្ពានតូចជាងផ្លូវពិបាកធ្វើដំណើរ | |
| ៣ | ផ្លូវកៅស៊ូនៅឃុំកោះរះ និងឃុំពាមឧកញ៉ាអុងមានការខូចខាតជាតំណំដោយសាររថយន្តដឹកទំនិញធ្ងន់លើសចំណុះ | |
| ៤).ការងារដែនសក | | |
| ១ | ពាក់ព័ន្ធការកាត់ចំណីដីបឹង , ព្រែក និងទន្លេ។ | សូមមន្ទីរជួយផ្តល់សម្ភារៈប្រើប្រាស់ក្នុងការិយាល័យ |
| ២ | ប្រជាពលរដ្ឋមានការលំបាកចំពោះការបង់ពន្ធប្រ ថាប់ត្រាលើលិខិតផ្ទេរសិទ្ធិកាន់កាប់ដី (ប្លង់ទន់ ប្លង់រឹង) ដោយធ្វើដំណើរឆ្ងាយហើយមានរយៈពេលយូរ២ ទៅ៣អាទិត្យ។ | |
| ៣ | នៅរដូវទឹកឡើងនៅខែ៩ ដល់១២ មិនអាចវាស់វែងបាន | |
| ៥).ការងារធម្មការ: | | |
| ១ | ការងារគ្រប់គ្រងខាងផ្នែករដ្ឋបាល មិនទាន់បានល្អប្រសើរនៅឡើយ នៅតាមបណ្តាវត្តមួយចំនួន។ | ចុះពង្រឹងបន្ថែម ស្តីពីការរៀបចំប្រព័ន្ធរដ្ឋបាលឲ្យកាន់តែល្អប្រសើរ នៅតាមបណ្តាវត្តក្នុងស្រុក ដោយសហការជាមួយព្រះអនុគណស្រុកល្វាឯម។ |
| ២ | ការសាមគ្គីភាពរវាងចៅអធិការ-អាចារ្យ និងគណៈកម្មការវត្ត នៅមិនទាន់មានការសហការគ្នាបានល្អនៅឡើយ។ | បន្តចុះផ្សព្វផ្សាយពីតួនាទី ចៅអធិការ អាចារ្យ និងគណៈកម្មការវត្ត ឲ្យបានយល់ពីតួនាទីរបស់ខ្លួន ក្នុងការគ្រប់គ្រងវត្តអារាម។ |
| ៦).ការងារវប្បធម៌ | | |
| ១ | អាជីវករមិនយល់ពីច្បាប់ប្រកបអាជីវកម្ម | ពន្យល់ និងផ្សព្វផ្សាយបន្ថែម |
| ៧).ការងារអប់រំ | | |
| ១ | សាលាមិនទាន់បានធ្វើការវាស់វែងធ្វើប្លង់កម្មសិទ្ធ(បញ្ជីជាតិដី) របស់សាលារៀនដែលដីរបស់សាលាផ្ទាល់ ។ | ស្នើសុំការិយាល័យជំនាញស្រុកចុះវាស់វែងធ្វើប្លង់កម្មសិទ្ធិ ។ |
| ២ | សាលាមិនទាន់បានជំរះបញ្ជីសម្ភារៈដែលខូច ឬបាត់នៅឡើយដោយសារនិតិវិធីមានភាពស្មុគស្មាញ ។ | ឱ្យសាលារៀនធ្វើការជំរះបញ្ជីសម្ភារៈឱ្យបានទាន់ពេលវេលាផ្ញើមកការិ អយក ស្រុក ដើម្បីធ្វើការជំរះបន្ត ។ |

| | | |
|---|---|---|
| ៨).ការងារសុខាភិបាលៈ | | |
| ១ | ខ្វះខាតបន្ទប់មន្ទីរពិសោធន៍ | - ស្នើការគាំទ្រពីអាជ្ញាធរមូលដ្ឋាន<br>- ស្នើការគាំទ្រពីសប្បុរសជននានា |
| ២ | ខ្វះខាតបន្ទប់ និង ម៉ាស៊ីនថតកាំរស្មីអ៊ិច | - ស្នើការគាំទ្រពីអាជ្ញាធរមូលដ្ឋាន<br>- ស្នើការគាំទ្រពីសប្បុរសជននានា |
| ៩).ការងារបរិស្ថានៈ | | |
| ១ | មាន០១ករណី នៅភូមិក្ដីកណ្ដាល ឃុំសារិកាកែវ បណ្ដាលមកពីការចិញ្ចឹមជ្រូក របស់ឈ្មោះ យ៉ា យ៉ុន ប៉ះពាល់ក្លិនដល់អ្នកជិតខាង (ប្រជាពលរដ្ឋជិតខាងប្ដឹង)។ | ករណីនេះគណៈកម្មការថ្នាក់ស្រុក-ឃុំ បានចុះពិនិត្យហើយ ដោយណែនាំរបស់ជំទប់ទី១ ឃុំ សារិកាកែវរួចហើយ។ ប៉ុន្ដែអ្នកជិតខាងនៅតែមិនសុខចិត្ត ចង់អោយបញ្ឈប់ការចិញ្ចឹម។ ករណីនេះរង់ចាំគណៈកម្មការថ្នាក់ស្រុក ឃុំ ពិនិត្យពិចារណា និង ចុះពិនិត្យម្ដងទៀត(ប៉ុន្ដែបច្ចុប្បន្ននេះមានតែមេជ្រូក ០១ក្បាលក្នុងទីតាំងនោះ)។ |
| ១០). ការងារជលផល | | |
| ១ | ខ្វះខាត់ប្រេងសាំងចុះអនុវត្តការងារ | ស្នើសុំប្រេងសាំងចុះអនុវត្តការងារ |

## ផ្នែកទី៥
## ទិសដៅការងារឆ្នាំបន្ទាប់

### ៥.១. រដ្ឋបាលស្រុក

| លរ. | សកម្មភាពអាទិភាព | ត្រីមាសទី | | | |
|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ |
| ១.ការងារក្រុមប្រឹក្សា និងគណៈកម្មាធិការ | | | | | |
| ១ | ចុះស្ដាប់សំណូមពរ & សេចក្ដីត្រូវការរបស់ប្រជាពលរដ្ឋ | √ | √ | √ | √ |
| ២ | ពិនិត្យ & អនុម័តរបាយការណ៍រីកចម្រើនប្រចាំឆ្នាំ | √ | √ | √ | √ |
| ៣ | តាមដាន & ត្រួតពិនិត្យវាយតម្លៃគ្រប់កិច្ចការដែលក្រុមប្រឹក្សាបានអនុម័ត | √ | √ | √ | √ |
| ៤ | ពិនិត្យ & ដោះស្រាយឲ្យបានសមស្របនូវសំណូមពររបស់ប្រជាពលរដ្ឋ | √ | | √ | |
| ៥ | ត្រៀមបញ្ជូនមន្ត្រី ដើម្បីចូលរួមវគ្គបណ្ដុះបណ្ដាលនានាដែលថ្នាក់លើដាក់ចុះ ដើម្បីលើកកម្ពស់សមត្ថភាពមន្ត្រី | √ | | √ | |
| ៦ | ត្រៀមរៀបចំ & ចូលរួមវេទិកាផ្សព្វផ្សាយ & ពិគ្រោះយោបល់របស់ក្រុមប្រឹក្សាខេត្ត | | √ | | |
| ៧ | ពិនិត្យ និងដោះស្រាយឲ្យបានសមស្របអំពីសំណូមពរ ឬការតវ៉ានានាពីសំណាក់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ច | √ | √ | √ | √ |
| ៨ | ត្រៀមបញ្ជូន និងចូលរៀនវគ្គបណ្ដុះបណ្ដាលនានាដែលថ្នាក់ជាតិដាក់ចុះដើម្បីពង្រឹងស្ថាប័ន និងកសាងសមត្ថភាពមន្ត្រី។ | √ | √ | √ | √ |
| ២ . ការងារគណៈអភិបាល | | | | | |

| | | | | | |
|---|---|---|---|---|---|
| ១ | -ធ្វើវេទិកាសាធារណៈ និងផ្សព្វផ្សាយការអនុវត្តសារាចរស្តីពី ភូមិ ឃុំមាន សុវត្ថិភាព ចំនួន ០៩ចំណុចថ្មី | √ | √ | √ | √ |
| ២ | -អនុវត្តគោលនយោបាយភូមិ-ឃុំ មាន សុវត្ថិភាព | √ | √ | √ | √ |
| ៣ | -ខិតខំយកចិត្តទុកដាក់ និងចាត់ចែងអនុវត្តន៍គ្រប់លិខិតបទដ្ឋាននានារបស់ថ្នាក់លើឲ្យកាន់តែមានប្រសិទ្ធិភាពទាន់ពេលវេលា ចំពោះមុខបន្ត ពង្រឹងនិរន្តរភាពរបៀបរបប ធ្វើការងារបានល្អតាមតួនាទីភារកិច្ច ។ | √ | √ | √ | √ |
| ៤ | -ជម្រុញការគ្រប់គ្រងស្ថិតិប្រជាពលរដ្ឋការធ្វើអត្តសញ្ញាណបណ្ណ័ និង ការចុះ បញ្ជីអត្រានុកូលដ្ឋាន គ្រប់ ប្រភេទជូនប្រជាពលរដ្ឋ ។ | √ | √ | √ | √ |
| ៥ | -ភ្ជាប់ស្ថិតិគ្រួសារ ដែលរងគ្រោះផ្សេង ៗគ្រួសារក្រីក្រ ចាស់ជរាពិការ កំពុងជួបការលំបាកខ្លាំងដើម្បីមានគោលការណ៍ឧបត្ថម្ភទាន់ពេលវេលា ។ | √ | √ | √ | √ |
| ៦ | - ចុះពិនិត្យលើការងារបង្កបង្កើនផល និង ជំរុញលើការដាំដុះនារដូវប្រាំង រដូវវស្សា នាពេល ខាងមុខ ។ | √ | √ | √ | √ |
| ៣.ការងារការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ | | | | | |
| ១ | បន្តនិរន្តរភាពការងារចុះបញ្ជី និងសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានគ្រប់ ប្រភេទជូន ជាពលរដ្ឋ ឱ្យស្របតាមសេចក្តីណែនាំលេខ០២៩របស់ក្រសួង មហាផ្ទៃស្តីពីការចុះបញ្ជីនិងសេចក្តីចំលងសំបុត្រ អត្រានុកូលដ្ឋាន និងប្រកាសអន្តរក្រសួង មហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលេខ១៤៣៤២ប្រក ស្តីពីការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។ | √ | √ | √ | √ |
| ២ | រៀបចំរបាយការណ៍ប្រចាំខែ និងប្រចាំឆ្នាំ ជូនក្រុមប្រឹក្សាស្រុកពិនិត្យ និងអនុម័ត | √ | √ | √ | √ |
| ៣ | ខិតខំយកចិត្តទុកដាក់និងចាត់ចែងអនុវត្តន៍លិខិតបទដ្ឋាននានារបស់ថ្នាក់លើឲ្យកាន់តែមានប្រសិទ្ធិភាព និងទាន់ពេលវេលា ។ | √ | √ | √ | √ |
| ៤ | រៀបចំប្រាក់បៀវត្សន៍ និងប្រាក់ឧបត្ថម្ភប្រចាំខែ ជូនបុគ្គលិក មន្ត្រីរាជការសាលាស្រុក ក្រុមប្រឹក្សាស្រុក និងធ្វើការទូទាត់ថវិកាប្រចាំឆ្នាំជូនខេត្ត | √ | √ | √ | √ |
| ៥ | បន្តចុះស្រង់ស្ថិតិ ផ្សព្វផ្សាយ និងចែកខិតបណ្ណ័ ពីដំណើរការយន្តការច្រកចេញចូលតែមួយដល់ម្ចាស់អាជីវកម្ម | | | | |
| ៦ | -ត្រៀមរៀបចំវគ្គបណ្តុះបណ្តាលអភិវឌ្ឍន៍សមត្ថភាពរួមមានៈ<br>1.វគ្គការអភិវឌ្ឍន៍សម្ថភាព និងភាពជាអ្នកដឹកនាំដល់មន្ត្រី និងថ្នាក់ដឹកនាំរដ្ឋបាលស្រុក<br>2.វគ្គរំលឹកឡើង ស្តីពីកិច្ចការរដ្ឋបាល( ជូនដល់មន្ត្រីស្រុក១៥នាក់,មេឃុំ១៥នាក់និងស្មៀនឃុំ១៥នាក់<br>.3.វគ្គលិខិតបទដ្ឋានគតិយុទ្ធនានាពាក់ព័ន្ធការគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិនាក់១៥ជូនដល់មន្ត្រីស្រុក),ការិយាល័យជុំវិញស្រុក១៥នាក់និងស្មៀនឃុំ,១៥(<br>4.វគ្គនិតិវិធីនៃការចុះបញ្ជីអត្រានុកូលដ្ឋាន( ជូនដល់មន្ត្រីស្រុក១០នាក់,មេឃុំ១៥,ស្ត្រីឃុំ១៥និងស្មៀនឃុំ១៥) | √ | √ | √ | √ |
| ៤)ការងារការិយាល័យផែនការ និង គាំទ្រឃុំសង្កាត់ | | | | | |
| ១ | - គាំទ្រក្នុងការរៀបចំថវិកាឃុំឆ្នាំ២០២០ និង បិទបញ្ជីថវិកាឃុំឆ្នាំ២០១៩ | √ | | | |

| | | | | | |
|---|---|---|---|---|---|
| ២ | - គាំទ្រក្នុងកសាងកម្មវិធីវិនិយោគប្រចាំឆ្នាំរបស់ឃុំឆ្នាំ២០២០ | √ | | | |
| ៣ | - គាំទ្រ និងសហការក្នុងការចុះសិក្សាគម្រោងមូលនិធិឃុំឆ្នាំ២០២០ | √ | √ | | |
| ៤ | - គាំទ្រ និងសហការក្នុងការចុះសិក្សាផលប៉ះពាល់ដីធ្លី និងបរិស្ថាន | √ | √ | | |
| ៥ | - គាំទ្រក្នុងការដេញថ្លៃ និងចុះកិច្ចសន្យាគម្រោង | √ | √ | | |
| ៦ | - សហការក្នុងពិនិត្យ និងវាយតំលៃការអនុវត្តគម្រោង | √ | √ | √ | √ |
| ៧ | - គាំទ្រកិច្ចប្រជុំប្រចាំខែរបស់ CC និងគនកន | √ | √ | √ | √ |
| ៨ | - ប្រមូលរបាយការណ៍និងបើកប្រអប់គណនេយ្យភាពមូលនិធិឃុំបញ្ជូនទៅខេត្ត | √ | √ | √ | √ |
| ៩ | - រៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ស្រុក | √ | √ | √ | √ |
| ១០ | - គាំទ្រក្នុងការប្រជុំជ្រើសរើសគម្រោងអាទិភាពរបស់ឃុំឆ្នាំ២០១៨ | √ | | | |
| ១១ | - គាំទ្រក្នុងការរៀបចំប្រតិទិននៃកិច្ចប្រជុំសាមញ្ញ និងគកនក | √ | | | |
| ១២ | - តាមដានកិច្ចប្រជុំសាមញ្ញរបស់ឃុំ ដើម្បីបញ្ជូនទៅខេត្ត | √ | √ | √ | √ |
| ៥)ការិយាល័យការិយាល័យអន្តរវិស័យ | | | | | |
| ១ | -ទទួលពាក្យបណ្ដឹង និងសម្របសម្រួលផ្សះផ្សាទំនាស់ផ្សេងៗក្នុងដែនសមត្ថកិច្ចរបស់ស្រុកស្របតាមនីតិវិធីច្បាប់ ។ | √ | √ | √ | √ |
| ២ | បន្តសម្របសម្រួលការងារតាមវិស័យ | √ | √ | √ | √ |
| ៣ | សហការជាមួយការិយាល័យ ដ ន ស កនិងអាជ្ញាធរមូលដ្ឋានតាមបណ្ដាលឃុំ នូវសំណង់មានច្បាប់ អត់ច្បាប់ដើម្បីសាងសង់ត្រូវមានច្បាប់អនុញ្ញាត និងស្រប តាមបទដ្ឋានបច្ចេកទេស។ | √ | √ | √ | √ |

### ៥.២.ការិយាល័យ និងអង្គភាពជំនាញ:

| ល.រ | សកម្មភាពអាទិភាព | ត្រីមាសទី | | | |
|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ |
| ១). ការិយាល័យកសិកម្ម | | | | | |
| ១ | ចុះតាមដានក្រុមបណ្ដុំទាំង១២បន្ត | √ | √ | √ | √ |
| ២ | ចុះតាមដានការអនុវត្តការងារដាំដុះរបស់កសិករនិងបញ្ហាប្រឈមផ្សេងៗ | √ | √ | √ | √ |
| ២). ការិយាល័យពន្ធដារ | | | | | |
| ១ | ចុះពិនិត្យសកម្មភាពអាជីវកម្មដើម្បីស្រង់ចូលរបបស្វ័យប្រកាសតូច និងណែនាំម្ចាស់សហគ្រាសឲ្យប្រកាសពន្ធ ឆ្នាំ ២០២០។ | √ | | | |
| ២ | ចុះប្រមូលពន្ធប្រចាំខែ និង ប្រចាំឆ្នាំ ២០២០។ | √ | | | |
| ៣ | បូកការងារប្រមូលពន្ធ និង បញ្ជូនលិខិតប្រកាសពន្ធ និងប្រាក់ពន្ធ ទៅខាសាពន្ធដារខេត្តកណ្ដាល។ | | √ | √ | |
| ៤ | ធ្វើបញ្ជីគណនេយ្យ និងរបាយការណ៍គ្រប់ប្រភេទ។ | | | | √ |
| ៣). ការងារអភិវឌ្ឍន៍ជនបទ | | | | | |
| ១ | បន្តបើកវគ្គបណ្ដុះបណ្ដាលគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ(ក.អ.ភ) | √ | √ | √ | √ |

| | | | | | |
|---|---|---|---|---|---|
| ២ | បន្តចុះផ្សព្វផ្សាយអំពីកាភ្ជាប់បណ្តាញទឹកស្អាតជូនគ្រួសារក្រ១ក្រ២ ស្ថិតនៅក្នុងឃុំកោះកែវ និងឃុំសំបួរ | √ | √ | √ | √ |
| ៤).ការិយាល័យធនធានទឹក: | | | | | |
| ១ | បន្តសហការជាមួយអាជ្ញាធរភូមិឃុំចុះពិនិត្យ និង តាមដានស្ថានភាពទឹកនៅតាមចំនុចប្រព័ន្ធធារាសាស្ត្រតាមបណ្តាឃុំក្នុងស្រុកដើម្បីជួយអន្តរាគមន៍។ | √ | √ | √ | √ |
| ២ | សហការជាមួយមន្ទីរ និងក្រសួងធនធានទឹកបន្តស្តារ និងសាងសង់សំណង់ធារាសាស្ត្រនៅចំណុចទំនប់ជោជន់ រាំងដាតាកេ ក្នុងឃុំល្វាសរ ។ប្រលាយមេព្យុង ឃុំពាមឧកញ៉ាអុង | √ | √ | √ | √ |
| ៣ | តាមដានស្ថានភាពទឹកទន្លេ និងទឹកបឹងនៅពេលរដូវទឹកទន្លេមេគង្គឡើង | √ | √ | √ | √ |
| ៥).ការិយាល័យស្ថិតិផែនការ | | | | | |
| ១ | បន្តធ្វើរបាយការណ៍ស្ថានភាពប្រែប្រួលប្រជាជនប្រចាំខែ | √ | √ | √ | √ |
| ២ | តាមដានការធ្វើទិន្នន័យតាមឃុំ | √ | √ | √ | √ |
| ៣ | ប្រមូលទិន្នន័យ ត្រួតពិនិត្យ និងបញ្ជូនទៅមន្ទីរផែនការខេត្ត | √ | √ | √ | √ |
| ៦).ការិយាល័យអប់រំ: | | | | | |
| ១ | រៀបចំធ្វើសៀវភៅ ផែនការប្រតិបត្តិប្រចាំឆ្នាំ ២០២០ (AOP) របស់ការិ.អយក ស្រុក និងសាលារៀន។ | √ | √ | √ | √ |
| ២ | ធ្វើរបាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំ ២០១៩ ជូនមន្ទីរ.អយក ខេត្ត ។ | | | | √ |
| ៣ | បន្តការប្រជុំធ្វើផែនការបង្រៀនខែធ្នូ និងផលិតសម្ភារៈ | √ | √ | √ | √ |
| ៤ | ចុះពិនិត្យតាមដាន និងវាយតម្លៃមត្តេយ្យសិក្សារដ្ឋ និងសហគមន៍ | | | | √ |
| ៧).ការិយាល័យសុខាភិបាល: | | | | | |
| ១ | បង្កើនការផ្តល់សេវាដល់ប្រជាពលរដ្ឋប្រកបដោយគុណភាព | √ | √ | √ | √ |
| ២ | កែលំអរសោភ័ណ្ឌភាពទាំងក្នុង និង ក្រៅមណ្ឌល | √ | √ | √ | √ |
| ៣ | បន្តបំពាក់នូវសំភារះបរិក្ខា និង គ្រឿងសង្ហារឹម | √ | √ | √ | √ |
| ៤ | ជំរុញការអនុវត្តន៍មូនិធិសមធម៌អោយកាន់តែមានប្រសិទ្ធិភាព | √ | √ | √ | √ |
| ៨).ការិយាល័យកិច្ចនារី | | | | | |
| ១ | បន្តរៀបចំកិច្ចប្រជុំប្រចាំខែ គ.ក.ស.ក ស្រុក | √ | √ | √ | √ |
| ២ | បន្តចុះគាំទ្រកិច្ចប្រជុំ គ.ក.ន.ក ថ្នាក់ឃុំ | √ | √ | √ | √ |
| ៣ | ពិនិត្យការរៀន និងបង្រៀនរបស់មត្តេយ្យសិក្សាសហគម ឃុំភូមិធំ ឃុំព្រែកឬស្សី | √ | √ | √ | √ |
| ៩).ការិយាល័យធម្មការ | | | | | |
| ១ | នឹងចូលរួមការប្រឡងយកវិញ្ញាបនបត្រថ្នាក់ត្រី ទោ ឯក នៅមណ្ឌលប្រឡងស្រុកកៀនស្វាយ | √ | √ | √ | √ |
| ២ | នឹងចុះតាមបណ្តាវត្តក្នុងស្រុកល្វាឯម ដើម្បីត្រួតពិនិត្យរបាយការណ៍ស្តីពីចំណូល ចំណាយរបស់វត្តនីមួយៗ។ | √ | √ | √ | √ |
| ១០).ការិយាល័យវប្បធម៌ | | | | | |
| ១ | ចុះត្រួតពិនិត្យ និងស្រាវជ្រាវរកទួលបុរាណ និងអាស្រមដែលមានក្នុងស្រុកល្វាឯម | √ | √ | √ | √ |
| ២ | ចុះផ្សព្វផ្សាយ ជំរុញអោយអាជីវករធ្វើច្បាប់ប្រកបអាជីវកម្មតាមយន្តការច្រកចេញចូលតែ | √ | √ | √ | √ |
| ៣ | បន្តចុះត្រួតពិនិត្យតាមដានការកែហាត់របស់ក្រុមល្ខោនខោលជារៀងរាល់សប្តាហ៍ | √ | √ | √ | √ |

| | | | | | |
|---|---|---|---|---|---|
| ៤ | ចុះស្រង់ស្ថិតិទូក"ង"ធ្វើសំណើសុំចូលរួមប្រលងប្រណាំងថ្នាក់ខេត្ត និងរាជធានីភ្នំពេញតាម | √ | √ | √ | √ |
| ១១).ការងារសង្គមកិច្ច | | | | | |
| ១ | ផ្សព្វផ្សាយ និងពង្រីកបន្ថែមសមាជិកសមាគមអតីតយុទ្ធជន | √ | √ | √ | √ |
| ២ | បន្តតាមដាន និងធ្វើសមាហរណកម្មកុមារជាមួយអង្គការនានា | √ | √ | √ | √ |
| ៣ | បន្តធ្វើសំណុំឯកសារផ្សេងៗជូនមុខសញ្ញាអតីតយុទ្ធជន | √ | √ | √ | √ |
| ១២).ការងារដ.ន.ស.ភ | | | | | |
| ១ | ពន្លឿនការចុះបញ្ជីដីធ្លី។ | √ | √ | √ | √ |
| ២ | បន្តពន្យល់ប្រជាជនចូលរួមការចុះបញ្ជីដីឲ្យបានច្រើន។ | √ | √ | √ | √ |
| ៣ | ណែនាំប្រជាជនអោយមានការយល់ដឹងពីការសុំច្បាប់សាងសង់សំណង់។ | √ | √ | √ | √ |
| ៤ | ផ្សព្វផ្សាយច្បាប់ភូមិបាលអោយប្រជាជនយល់ដឹងឲ្យបានកាន់តែច្បាស់។ | √ | √ | √ | √ |
| ១៣). ការិយាល័យជលផល | | | | | |
| ១ | បន្តអនុវត្ត អនុសាស្ត្ររបស់ថ្នាក់ដឹកនាំអោយប្រសិទ្ធិភាព | √ | √ | √ | √ |
| ២ | ពង្រឹងការទប់ស្កាត់បទល្មើសនេសាទគ្រប់ប្រភេទ និងជំរុញវារីវប្បកម្មឲ្យខ្លាំង | √ | √ | √ | √ |
| ៣ | ជំរុញការប្រមូលជុំធក់ និងលូ ស្បៃ មុង ពីពលរដ្ឋ | √ | √ | √ | √ |
| ៤ | ទំនាក់ទំនងជាមួយអាជ្ញាធរ មូលដ្ឋានឲ្យបានល្អ | √ | √ | √ | √ |
| ៥ | កំណត់ផែនទីរបស់បឹងសហគមន៍ឲ្យបានបន្ត | √ | √ | √ | √ |
| ៦ | រកតំបន់អភិរក្សបន្ថែម | √ | √ | √ | √ |
| ៧ | ពង្រឹងសហគមន៍នេសាទ | √ | √ | √ | √ |
| ៨ | ផ្សព្វផ្សាយច្បាប់ជលផល ដល់ប្រជាពលរដ្ឋឲ្យបានច្រើនផង | √ | √ | √ | √ |
| ៩ | ចុះធ្វើកិច្ចសន្យាកន្លែងផលិតជុំធក់ និងលូស្បៃមុង | √ | √ | √ | √ |
| ១០ | ខិតខំបង្ក្រាប បន្ត រាល់បទល្មើសជលផលដែលមាន | √ | √ | √ | √ |
| ១៣).ការិយាល័យបរិស្ថានៈ | | | | | |
| ១ | បន្តចុះពិនិត្យអប់រំ ណែនាំ តាមបណ្តាសិប្បកម្ម អាជីវកម្ម | √ | √ | √ | √ |
| ២ | បន្តចុះពិនិត្យឃ្លាំមើលនៅតាមបណ្តាចំណុចទីតាំងដែលធ្លាប់បង្កើតសំណល់សម្រាមឮ | √ | √ | √ | √ |
| ៣ | ចុះពិនិត្យមើលតាមចំណុចទីតាំងរណ្តៅសម្រាមរបស់អាជីវកម្មទីផ្សារ | √ | √ | √ | √ |
| ៤ | ត្រៀមសហការជាមួយគណៈកម្មការថ្នាក់ស្រុក រកដំណោះស្រាយបញ្ហាសម្រាម រណ្តៅ | √ | √ | √ | √ |
| ៥ | ដាក់សម្រាម ទីលានដាក់ឡដុតសម្រាម។ | √ | √ | √ | √ |
| ១៤).ការងារសាធារណៈការៈ | | | | | |
| ១ | បន្តតាមដានរាល់សកម្មភាពជួសជុលផ្លូវ ស្ពាន លូ ក្នុងខែបន្តបន្ទាប់។ | √ | √ | √ | √ |

## ផ្នែកទី៦

## សេចក្តីសន្និដ្ឋាន

-ក្នុងឆ្នាំនេះរដ្ឋបាលស្រុកបានបំពេញមុខងារភារកិច្ចកាន់តែមានប្រសិទ្ធិភាព លើការផ្តល់ សេវា ការដោះស្រាយសំណូមពរ និងបាតុភាពអសកម្មនានាក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

ដោយមានការជួយគាំទ្រពីក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានផង បានធ្វើឲ្យការអនុវត្តគោលនយោបាយយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ របស់រាជរដ្ឋាភិបាល ឆ្ពោះទៅមុខនិងកាន់តែមានប្រសិទ្ធិ

ភាពដោយ មានបើកវេទិកាសាធារណៈនៅតាមបណ្តាឃុំមួយចំនួន និងបានបកស្រាយបំភ្លឺដោះស្រាយសំណូមពរនានា របស់ប្រជាពលរដ្ឋ និងបានកាត់បន្ថយបាតុភាពអសកម្មមួយចំនួនបន្ថែមទៀត។ចំណែកការអនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថិភាពរបស់ក្រសួងមហាផ្ទៃដែលជាមូលដ្ឋានគ្រឹះក្នុងការថែរក្សា សន្តិសុខ សណ្តាប់ធ្នាប់ សាធារណៈនៅតាមមូលដ្ឋាន ។ ឧបាយកល ល្បិចកល បង្កចលាចល អស្ថេរភាពសង្គម ត្រូវបានទប់ស្កាត់ បទល្មើសព្រហ្មទណ្ឌ ត្រូវបានថយចុះគួរឲ្យកត់សំគាល់ ។

ការងារអភិវឌ្ឍន៍មូលដ្ឋាន មានការចូលរួមប្រឹងប្រែងយ៉ាងសកម្មទាំងការផ្តល់បច្ចេកទេស និងធនធានពី ឃុំនិងបណ្តាការិយាល័យអង្គភាពជំនាញជុំវិញស្រុកដែលបានជួយធ្វើឲ្យជីវភាពរស់នៅ របស់ប្រជាពលរដ្ឋមាន ភាពល្អប្រសើរតាមរយៈការបង្កើនទិន្នផល និងផលិតផលកសិកម្ម ការបង្កើន ការងារមុខរបរ ការកសាងហេដ្ឋា រចនាសម្ព័ន្ធ ពង្រឹងការចូលរួមរបស់ស្ត្រី និងការអភិវឌ្ឍសមត្ថភាព។

លទ្ធផលលេចធ្លោរបស់រដ្ឋបាលស្រុកក្នុងឆ្នាំនេះ គឺការធ្វើផ្តល់ជូនអត្តសញ្ញាបណ្ណ័សញ្ជាតិខ្មែរ សៀវភៅស្នាក់នៅ សៀវភៅគ្រួសារ ជាពិសេសការបំរើសេវាជូនប្រជាពលរដ្ឋបានឆាប់រហ័សមានភាពល្អប្រសើរជាងមុន ការផ្គត់ផ្គង់ទឹកស្អាត និងការស្នើសុំបើកផ្លូវរទេះនៅតាមបណ្តាឃុំមួយចំនួនបញ្ហាបរិស្ថាន ដែលជាបញ្ហារបស់ប្រជាពលរដ្ឋបានលើក ឡើងក្នុងវេទិកាផ្សព្វផ្សាយ និងពិគ្រោះ យោបល់របស់ក្រុមប្រឹក្សាស្រុក ។

**១.ការងារគ្រប់គ្រងសន្តិសុខសណ្តាប់ធ្នាប់សង្គមៈ**

-គណៈបញ្ជាការឯកភាពរដ្ឋបាលស្រុកឃុំត្រូវយកចិត្តទុកដាក់ពង្រឹងកិច្ចការពារភូមិសាស្ត្រ និង គោលដៅ សំខាន់ៗក្តាប់សភាពការណ៍សន្តិសុខសភាពការណ៍បទល្មើសក្តាប់ជាប់មុខសញ្ញាជានាបង្ក្រាបបានទាន់ពេលវេលា ពិសេសដូចជាការបង្ក្រាបការជួញដូរគ្រឿងញៀន .ល. ។

-រដ្ឋបាលស្រុក ជម្រុញឲ្យមានការគ្រប់គ្រងស្ថិតិប្រជាពលរដ្ឋការធ្វើអត្តសញ្ញាណបណ្ណ័ និង ការចុះបញ្ជីអត្រានុកូលដ្ឋានគ្រប់ប្រភេទជូនប្រជាពលរដ្ឋ ។ក្តាប់ស្ថិតិគ្រួសារប្រជាពលរដ្ឋដែលរងគ្រោះផ្សេងៗគ្រួសារក្រីក្រចាស់ជរាពិការកំពុងជួបការលំបាកខ្លាំងដើម្បីមានគោលការណ៍ឧបត្ថម្ភទាន់ពេលវេលា ។

**២.ការងារសេដ្ឋកិច្ចៈ**

-រដ្ឋបាលស្រុកបានបង្កើនផ្ទៃដីដាំដុះស្រូវប្រាំង និង ផ្ទៃដីស្រូវបង្កើនរដូវ ជំរុញផ្សព្វផ្សាយពូជស្រូវ និង បច្ចេកទេស កសិកម្ម ដល់កសិករ ដើម្បីទិន្នផល ជំរុញប្រជាកសិករឲ្យប្រើប្រាស់ជីធម្មជាតិ ថ្នាំផ្សំអំពីរុក្ខជាតិ និង បង្កើនវិធានការពារ ជម្ងឺសត្វពាហនៈ ទប់ស្កាត់រាល់ការរីករាលដាលជម្ងឺឆ្លងផ្សេងៗ

**៣.ការងារសង្គមកិច្ចៈ**

-ជំរុញការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈបន្ថែម និង ការអប់រំក្រៅប្រពន្ធ័

-យកចិត្តទុកដាក់លើកកំពស់សេវាសុខភាពជូនដល់ប្រជាពលរដ្ឋ ។

-ពង្រឹង និង ពង្រីកសមត្ថភាពអ្នកទទួលបន្ទុកកិច្ចការនារីឃុំ ពង្រឹងសមត្ថភាពការងារបញ្ជ្រាបយេនឌ័រ ដល់មន្ត្រីកិច្ចការនារីស្រុក ។

**៤.ការគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ**

-បានចុះទប់ស្កាត់ការសាងសង់សំណង់ដែលគ្មានច្បាប់ និង ណែនាំដល់ប្រជាពលរដ្ឋឲ្យធ្វើច្បាប់ត្រឹមត្រូវមុន និង ធ្វើការសាងសង់ និង បន្តយកចិត្តទុកដាក់ការងារចុះបញ្ជីដីធ្លី ។

-ជំរុញការគ្រប់គ្រងការអនុវត្ត ច្បាប់គ្រប់គ្រងសំណល់រឹង រាវ តាមសិប្បកម្ម និង អាជីវកម្មក្នុងស្រុក ។

បន្ទាប់ពីទទួលបានលទ្ធផលខាងលើ យើងក៏មានបញ្ហាមួយចំនួនទៀតរបស់រដ្ឋបាលស្រុករួមជា មួយការិយាល័យជំនាញ អង្គភាពជុំវិញ ស្រុក និងអាជ្ញាធរមូលដ្ឋានកំពុងរិះរកមធ្យោបាយ ដោះស្រាយដូចជាការបង្ក្រាបបទល្មើសនេសាទ ពុំទាន់មាន ប្រសិទ្ធិភាព សហគមន៍នេសាទពុំទាន់បានចូលរួមខ្លាំងក្លាដើម្បីការពារធនធានមច្ឆាជាតិ , សេវាសាធារណៈ ត្រូវកែលម្អនិងពង្រឹងគុណភាព ថែមទៀត គម្រោងហេដ្ឋារចនាសម្ព័ន្ធជាច្រើនត្រូវបានជួសជុល និង សាងសង់ និងវិស័យផ្សេងៗ ទៀត ក៏នៅមិនទាន់មានការចូលរួមពេញលេញពីប្រជាពលរដ្ឋផងដែរ ។

ជាមួយនិងលទ្ធផលគួរជាទីមោទនៈ និងបញ្ហាប្រឈមមួយចំនួនដែលបានរៀបរាប់ ខាងលើ រដ្ឋបាលស្រុក ចាំបាច់បន្តពុះពារអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលឈរលើគោលការណ៍អភិបាលកិច្ចល្អដោយៈ

-បង្កើនគុណភាពនៃការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ

-ពង្រឹងការបំពេញតួនាទីរបស់មន្ត្រីរដ្ឋបាលស្រុកឲ្យស្របតាមសេចក្តីប្រកាស៤២៧៤របស់ក្រសួងមហាផ្ទៃ

-តាមដាន ថែរក្សាសុវត្ថិភាព សន្តិសុខសង្គម ឲ្យបានល្អប្រសើរថែមទៀត

-បន្តយកចិត្តទុកដាក់លើការងារអភិវឌ្ឍន៍សេដ្ឋកិច្ចមូលដ្ឋាន ដើម្បីលើកស្ទួយជីវភាពរបស់ប្រជាពលរដ្ឋតាមរយៈពង្រឹងពង្រីកវិស័យកសិកម្ម សិប្បកម្ម ។ល។

-តាមដានការអនុវត្តវិធានការឆ្លើយតប និងបញ្ហា សំណូមពរ ដែលប្រជាពលរដ្ឋលើកឡើងក្នុងវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាស្រុក ។

សរុបមកយើងអាចនិយាយបានថា ការអនុវត្តការងាររបស់រដ្ឋបាលស្រុកល្វាឯម យើងសម្រេចលទ្ធផលជាវិជ្ជមាននិងអនុវត្តស្របតាមគោលនយោបាយកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ នៅថ្នាក់ក្រោមជាតិ ដែលបានចូលរួមចំណែក ជំរុញកំណើនសេដ្ឋកិច្ច ប្រកបដោយសមធម៌ និងធានាប្រសិទ្ធិភាពនៃស្ថាប័ន សាធារណៈ និងបានជួយលើកកម្ពស់អភិបាលកិច្ចល្អ មានតម្លាភាព គណនេយ្យភាព ប្រសិទ្ធិភាព និង ភាពស័ក្តិសិទ្ធិ ។

របាយការណ៍ប្រចាំឆ្នាំនេះ ត្រូវបានពិនិត្យ និងអនុម័តនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាស្រុក នាថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ២០១៩។

ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ២០១៩

អភិបាលស្រុកល្វាឯម

គីម ឬទ្ធី